ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

# របាយការណ៍
# បូកសរុបលទ្ធផលការងារពាណិជ្ជកម្មឆ្នាំ២០២៣
# និងទិសដៅការងារពាណិជ្ជកម្មឆ្នាំ២០២៤




ថ្ងៃព្រហស្បតិ៍ ៩កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៣

# មាតិកា

សេចក្តីផ្តើម ......................................................................................១

**ជំពូកទី ១**

**សកម្មភាព និងលទ្ធផលការងារពាណិជ្ជកម្មឆ្នាំ២០២៣**

**១. ការងារកំណែទម្រង់ ......................................................................................៤**

១.១. រដ្ឋបាលសាធារណៈ ......................................................................................៤

១.២. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ......................................................................................៦

១.៣. ការងារវិមជ្ឈការ និងវិសហមជ្ឈការ ......................................................................................៦

**២. ការងារផ្តល់សេវាពាណិជ្ជកម្ម ...................................................................................... ៧**

២.១. ការងារចុះបញ្ជីពាណិជ្ជកម្ម ...................................................................................... ៧

២.២. ការងារកម្មសិទ្ធិបញ្ញា ......................................................................................៩

២.៣. ការនាំចេញ-នាំចូល ...................................................................................... ១៩

**៣. ការងារពាណិជ្ជកម្មក្នុងប្រទេស ......................................................................................៣២**

៣.១. ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងការតម្កល់លិខិតជូនដំណឹង ...................................................................................... ៣២

៣.២. ការអភិវឌ្ឍវិស័យឯកជន ......................................................................................៣៦

៣.៣.ការងារផែនការ ស្ថិតិ និងផ្សព្វផ្សាយព័ត៌មានពាណិជ្ជកម្ម ......................................................................................៣៨

៣.៤. ការអនុវត្តគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច(AIMS) ......................................................................................៣៩

**៤. ការងារពាណិជ្ជកម្មអន្តរជាតិ និងសមាហរណកម្មសេដ្ឋកិច្ច ......................................................................................៤០**

៤.១. កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម ទ្វេភាគី អនុតំបន់ និងសមាហរណកម្ម ......................................................................................៤០

៤ .២. កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មជាមួយអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក ......................................................................................៤៧

៤.៣. កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មជាមួយទ្វីបអាម៉េរិក ...................................................................................... ៤៩

៤.៤. ការងារសមាហរណកម្មពាណិជ្ជកម្មពិភពលោក ......................................................................................៥១

៤.៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងជំនួយ ......................................................................................៥២

**៥. ការងារជំរុញពាណិជ្ជកម្ម ......................................................................................៥៥**

៥.១. ការរៀបចំ និងចូលរួមពិព័រណ៍ពាណិជ្ជកម្ម ......................................................................................៥៥

៥.២. ការងារអភិវឌ្ឍន៍ទីផ្សារ ......................................................................................៥៧

៥.៣. ការងារអភិវឌ្ឍគោលនយោបាយពាណិជ្ជកម្ម ...................................................................................... ៦០

**៦. កិច្ចការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ............ ៦២**
៦.១. កិច្ចការពារអ្នកប្រើប្រាស់............................................................................................ ៦២
៦.២. កិច្ចការប្រកួតប្រជែង ................................................................................................ ៦៣
៦.៣. កិច្ចការគ្រប់គ្រងផលិតផលហាឡាល.......................................................................... ៦៤
៦.៤. ការងារមន្ទីរពិសោធន៍.................................................................................................. ៦៤
៦.៥. ការងារស្រាវជ្រាវសេចក្តីជូនដំណឹង អំពីអនាម័យ និងភូតគាមអនាម័យ.......................... ៦៥
៦.៦. ការងារលើកកម្ពស់ការយល់ដឹងសាធារណៈ................................................................. ៦៥
៦.៧. ការបង្កើនប្រសិទ្ធភាពការងារមន្ត្រី................................................................................ ៦៥
៦.៨. កិច្ចសហប្រតិបត្តិការជាតិ តំបន់ និងអន្តរជាតិ ............................................................ ៦៦
**៧.ការងារគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ ................................................... ៦៦**
៧.១.ការគ្រប់គ្រងរដ្ឋបាលទូទៅ ......................................................................................... ៦៦
៧.២.ការងារហិរញ្ញវត្ថុ ...................................................................................................... ៦៧
៧.៣.ការងារបុគ្គលិក ........................................................................................................... ៦៨
៧.៤. ការងារបណ្តុះបណ្តាល ស្រាវជ្រាវ និងភាពជាដៃគូ ........................................................ ៧២
**៨.ការងារអាជីវកម្មស្រូវ-អង្ករ និងសន្និធិស្បៀងបម្រុងរដ្ឋ (ក្រុមហ៊ុនគ្រីនត្រេដ)......... ៧៥**
**៩. ការងារយេនឌ័រ ................................................................................................ ៧៨**
**១០. ការងារអគ្គាធិការដ្ឋាន ..................................................................................... ៨០**
**១១. ការងារសវនកម្មផ្ទៃក្នុង .................................................................................... ៨១**
**១២. សកម្មភាពការងារមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត..................................... ៨២**
**១៣. លទ្ធផលការងាររបស់គណៈកម្មាធិការជាតិពាក់ព័ន្ធវិស័យពាណិជ្ជកម្ម ............ ៨៤**

## ជំពូកទី ២
## ទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ២០២៤

**១. ទិសដៅការងារសេវាពាណិជ្ជកម្ម ........................................................... ៨៩**
១.១. ទិសដៅការងារចុះបញ្ជីពាណិជ្ជកម្ម............................................................................ ៨៩
១.២. ទិសដៅការងារកម្មសិទ្ធិបញ្ញា...................................................................................... ៨៩
១.៣. ទិសដៅការងារនាំចេញ-នាំចូល .................................................................................. ៩១
១.៤. ទិសដៅការងារតំណាងពាណិជ្ជកម្មប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស......................... ៩៣

**២.ទិសដៅការងារពាណិជ្ជកម្មក្នុងប្រទេស ........................................ ៩៣**

២.១. ទិសដៅការងារនីតិកម្ម ........................................................................................ ៩៣

២.២. ទិសដៅការងារអភិវឌ្ឍន៍វិស័យឯកជន ........................................................................ ៩៤

២.៣. ទិសដៅការងារផែនការ ស្ថិតិ និងព័ត៌មានវិទ្យា ........................................................... ៩៥

២.៤. ទិសដៅការងារអនុវត្តគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច ............................................ ៩៧

**៣.ទិសដៅការងារពាណិជ្ជកម្មអន្តរជាតិ ........................................ ៩៧**

៣.១.ទិសដៅសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មទ្វេភាគី អនុតំបន់ និងសមាហរណកម្មសេដ្ឋកិច្ច....... ៩៧

៣.២. ទិសដៅសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មជាមួយអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក .................. ៩៩

៣.៣. ទិសដៅកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មជាមួយទ្វីបអាម៉េរិក ................................................ ១០១

៣.៤. ទិសដៅការងារសមាហរណកម្មពាណិជ្ជកម្មពិភពលោក .................................................... ១០២

៣.៥. ទិសដៅកិច្ចសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងជំនួយ .................................................. ១០២

**៤. ទិសដៅការងារជំរុញពាណិជ្ជកម្ម ........................................ ១០៣**

៤.១. ទិសដៅការងារពិព័រណ៍ ........................................................................................ ១០៣

៤.២. ទិសដៅការអភិវឌ្ឍទីផ្សារ ..................................................................................... ១០៣

៤.៣. ទិសដៅការអភិវឌ្ឍគោលនយោបាយពាណិជ្ជកម្ម ............................................................ ១០៥

**៥.ទិសដៅកិច្ចការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ ......១០៦**

**៦. ទិសដៅការងាររដ្ឋបាល និងហិរញ្ញវត្ថុ ........................................១១០**

៦.១. ទិសដៅការងារគណនេយ្យ និងហិរញ្ញវត្ថុ ......................................................................... ១១០

៦.២. ទិសដៅការងារបុគ្គលិក ......................................................................................... ១១១

៦.៣.ទិសដៅការងាររដ្ឋបាល ........................................................................................... ១១២

៦.៤. ទិសដៅការងារវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ .......................................... ១១៣

**៧. ទិសដៅការងារអាជីវកម្មស្រូវ-អង្ករ និងសន្និធិស្បៀងបម្រុងរដ្ឋ (ក្រុមហ៊ុនគ្រីនត្រេដ) ....១១៤**

**៨. ទិសដៅការងារអគ្គាធិការដ្ឋាន ........................................១១៥**

**៩. ទិសដៅការងារសវនកម្មផ្ទៃក្នុង ........................................១១៥**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

# របាយការណ៍

## បូកសរុបលទ្ធផលការងារពាណិជ្ជកម្ម ឆ្នាំ២០២៣
## និងទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ២០២៤

សេចក្តីផ្តើម

នៅក្នុងយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៤ ដែលបានដាក់ចេញឱ្យអនុវត្តនៅក្នុងរាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា និងគោលដៅអាទិភាពទាំង៦ សម្រាប់ឆ្នាំ២០២៣ក្នុងការអនុវត្តយុទ្ធសាស្រ្តបញ្ចកោណដំណាក់កាលទី១ នៃរាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា វិស័យពាណិជ្ជកម្ម ជាពិសេសការធ្វើពិពិធកម្មទីផ្សារ ពិពិធកម្មផលិតផល សម្រាប់បម្រើការនាំចេញ និងការអនុវត្ត ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីឈានឆ្ពោះទៅរកសេដ្ឋកិច្ចឌីជីថល នៅតែជាកត្តាអាទិភាពក្នុងការរួមចំណែកយ៉ាងសំខាន់នៃការអភិវឌ្ឍវិស័យសេដ្ឋកិច្ច-សង្គមកម្ពុជា។ ក្រសួងពាណិជ្ជកម្មបានប្រឹងប្រែងអនុវត្តប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល នូវកិច្ចការរបស់ខ្លួនផ្អែកតាមទិសដៅ នៃយុទ្ធសាស្រ្តទាំងពីរខាងលើ ហើយបានដកស្រង់បទពិសោធន៍ និងវាយតម្លៃនូវបញ្ហាប្រឈម ព្រមទាំងលើកទិសដៅសម្រាប់ឆ្នាំបន្ទាប់ផ្អែកតាមកាលៈទេសៈជាក់ស្តែង និងបរិការណ៍សង្គមសេដ្ឋកិច្ចសកល ដែលបច្ចុប្បន្ននេះកំពុងទទួលរងនូវវិបាកអវិជ្ជមាន ដោយសារឥទ្ធិពលនៃជំងឺកូវីដ-១៩ សង្គ្រាម រុស្ស៊ី-អ៊ុយក្រែន វិបត្តិក្នុងតំបន់ដូចជា សង្គ្រាមហាម៉ាស់-អ៊ីស្រាអែល និងការប្រែប្រួលថ្លៃប្រេងឥន្ធនៈដែលផ្តល់ផលប៉ះពាល់ជារួមទៅលើទីផ្សារសេកល និងកម្លាំងទិញ នៅក្នុងទីផ្សារគោលដៅនានារបស់កម្ពុជា។

ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី និងសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ឆ្នាំ២០២៣កន្លងមកនេះក្នុងការអនុវត្តបិទបញ្ចប់ដោយជោគជ័យនូវយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល

ព្រមទាំងការចាប់ផ្តើមអនុវត្តគោលដៅអាទិភាពទាំង៦ នៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ក្រសួងពាណិជ្ជកម្មនៅតែអាចរក្សា និងបន្តបាននូវដំហរវឹងមាំនៃការពង្រឹងទីផ្សារចាស់ ពង្រីកទីផ្សារថ្មី និងជំរុញកិច្ចការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង ដើម្បីធានាការធ្វើពាណិជ្ជកម្មប្រកបដោយ សុចរិតភាព និងសមធម៌ ព្រមទាំងបានខិតខំប្រឹងប្រែងធ្វើពិពិធកម្មមុខទំនិញនាំចេញដោយរក្សា អាទិភាពចំពោះទំនិញនាំចេញដូចជា សម្លៀកបំពាក់ ស្បែកជើង កាបូប ទោចក្រយាន គ្រឿងបន្លាស់ គ្រឿងបង្គុំ ដែលជាទំនិញឯកទេសនីយកម្មផលិតរបស់កម្ពុជា និងបង្កើនការនាំចេញបន្ថែមទៀតនូវមុខ ទំនិញជាកសិផល-កសិផលកែច្នៃ ជលផល និងទំនិញឧស្សាហកម្មខ្នាតតូច និងមធ្យមមួយចំនួនទៀត ដោយធានាបាននូវការនាំចេញប្រកបដោយបរិយាប័ន្ន តាមរយៈការជួយសម្រួលដល់អ្នកនាំចេញជា សហគ្រាសធុនតូច និងមធ្យម ផលិតករ កសិករ និងវិនិយោគិន ដែលផលិតទំនិញនាំចេញ ក្នុងការបង្កើន ផលិតភាព ផលិតកម្ម និងរក្សាបាននូវខ្សែប្រវាក់ផ្គត់ផ្គង់ សម្រាប់បម្រើទីផ្សារនាំចេញប្រកបដោយនិរន្តភាព។

ក្នុងឆ្នាំកន្លងទៅ ក្រសួងពាណិជ្ជកម្ម បានបន្តការធ្វើកំណែទម្រង់ស៊ីជម្រៅ សំដៅពង្រឹងភាពប្រកួត ប្រជែងនៃទំនិញនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ការធ្វើ ធុរកិច្ច និងការវិនិយោគនៅកម្ពុជា តាមរយៈការដាក់ឱ្យប្រើប្រាស់ទាំងស្រុងនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា ទំនើប សម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម ការចុះបញ្ជីម៉ាក ការផ្តល់វិញ្ញាបនបត្រប្រភពដើមទំនិញ ដែលក្នុង នោះ ថ្លៃសេវា ពេលវេលា និងបែបបទមួយចំនួន ក៏ត្រូវបានកាត់បន្ថយជាអតិបរមា ដែលនេះជាជោគជ័យ ដ៏សំខាន់មួយទៀតរបស់ក្រសួងពាណិជ្ជកម្ម។

ក្នុងគោលដៅបង្កើនឧត្តមភាពប្រកួតប្រជែងទាំងក្នុងក្របខណ្ឌតំបន់ និងពិភពលោក ក្រសួង ពាណិជ្ជកម្ម បាននិងកំពុងខិតខំពង្រឹងសមត្ថភាព និងប្រសិទ្ធភាពការងាររបស់មន្ត្រីរាជការបន្ថែមទៀត តាមរយៈការបន្តកសាង អភិវឌ្ឍន៍ធនធានមនុស្ស ធ្វើកំណែទម្រង់រចនាសម្ព័ន្ធរដ្ឋបាល និងគ្រប់គ្រងអភិវឌ្ឍ ស្ថាប័ន រួមទាំងការកសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម ស្របតាមការវិវត្ត នៃបរិបទ សេដ្ឋកិច្ច-សង្គមនាពេលបច្ចុប្បន្ន។

សមិទ្ធផលសំខាន់ៗដែលសម្រេចបានក្នុងឆ្នាំ២០២៣ និងទិសដៅសកម្មភាពការងារសម្រាប់ឆ្នាំ ២០២៤ របស់ក្រសួងពាណិជ្ជកម្ម មានដូចខាងក្រោម៖

**តួលេខសមិទ្ធផលសំខាន់ៗគួរកត់សម្គាល់ក្នុង១១ខែ ឆ្នាំ២០២៣ ៖**

- ទំហំពាណិជ្ជកម្មអន្តរជាតិ ១១ខែដើមឆ្នាំ២០២៣ មានទំហំ ៤៣,៥១៥.៨៦លានដុល្លារ អាម៉េរិក ដែលក្នុងនោះការនាំចេញសរុបមាន ២១,៩៩២.៤០លានដុល្លារអាម៉េរិក កើន ឡើង ៤.០៨% បើប្រៀបធៀបនឹងការនាំចេញ រយៈពេល១១ខែ ឆ្នាំ២០២២
- ចំណូលប្រមូលបានក្នុងរយៈពេល១១ខែដើមឆ្នាំ២០២៣ នេះមានចំនួន ៥៣ ៥៧៨,១ លានរៀល (ស្មើនឹង ១០២,០៩% នៃច្បាប់ថវិកា)
- ចំណាយសរុបក្នុងរយៈពេល១១ខែដើមឆ្នាំ២០២៣ នេះមានចំនួន៖ ៩០ ៤៦៩,៨ លានរៀល (ស្មើនឹង ៨៧,៧២% នៃឥណទានថវិកាដែលបានផ្តល់)
- ការចុះបញ្ជីពាណិជ្ជកម្មមានចំនួនសរុប **១១ ៥០៦ ក្រុមហ៊ុន** និងការលុបចេញពីបញ្ជី មានចំនួនសរុប **៩៦៧ ក្រុមហ៊ុន**
- ការចុះបញ្ជីម៉ាកតាមប្រព័ន្ធជាតិមានចំនួនសរុប ៣ ៤៤៤ ម៉ាក
- ការចុះបញ្ជីម៉ាកតាមប្រព័ន្ធអន្តរជាតិមានចំនួនសរុប ១ ៨៨៤ម៉ាក

# ជំពូកទី ១

# សកម្មភាព និងលទ្ធផលការងារ ពាណិជ្ជកម្មឆ្នាំ២០២៣

## ១. ការងារគាំទ្រទូទៅ

### ១.១. រដ្ឋបាលសាធារណៈ

#### ក. ការអភិវឌ្ឍធនធានមនុស្ស

- ចាត់បញ្ជូនមន្ត្រីឱ្យចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា រយៈពេលវែង និងខ្លី ទាំងក្នុង និងក្រៅប្រទេស ដូចជា៖ មជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការកម្ពុជា-សិង្ហបុរី វិទ្យាស្ថានការទូត និងទំនាក់ទំនងអន្តរជាតិ វិទ្យាស្ថានអាហ្គា ប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន ឡាវ ថៃ វៀតណាម ជប៉ុន ចិន កូរ៉េ ស្វីស និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន
- រៀបចំធ្វើឱ្យប្រសើរឡើង និងកាន់តែមានប្រសិទ្ធភាពក្នុងការបំពេញការងារ ដោយកំណត់បែងចែកច្បាស់លាស់នូវមុខងារ និងភារៈកិច្ចតាមតួនាទី និងមុខតំណែងនីមួយៗ របស់ថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់រូបតាមអង្គភាពក្រោមឱវាទក្រសួង

#### ខ. ការគ្រប់គ្រងធនធានមនុស្ស និងប្រាក់បៀវត្ស

- រៀបចំធ្វើការកែទម្រង់ ការបើកផ្តល់ប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារ និងប្រាក់លើកទឹកចិត្តទៅតាមគុណវុឌ្ឍិរបស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា
- ធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការទាំងអស់ក្រោមឱវាទក្រសួងដើម្បីរៀបចំបោះពុម្ពអត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួនរបស់មន្ត្រីរាជការស៊ីវិលជាប្រភេទ «ស្មាតកាត» (Smart Card) ដែលអាចប្រើប្រាស់ដូចប័ណ្ណធនាគារ (Bank Card)
- ធ្វើតារាងទូទាត់ប្រាក់បៀវត្សមន្ត្រីរាជការ និងបញ្ចូលប្រាក់បៀវត្ស ប្រាក់បេសកកម្ម ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីមិនមែនក្របខណ្ឌមុខងារសាធារណៈតាមប្រព័ន្ធធនាគារ
- ធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការ និងធ្វើរបាយការណ៍ស្តីពីការផ្លាស់ប្តូរស្ថានភាពមន្ត្រីរាជការប្រចាំខែ
- ជ្រើសរើស និងចាត់បញ្ជូនមន្ត្រីរាជការ ឱ្យចូលរួមវគ្គវិក្រឹតការ ឬវគ្គបណ្តុះបណ្តាលរយៈពេលខ្លី វែង ក្នុង និងក្រៅប្រទេស តាមការផ្តល់ជូនរបស់ប្រទេស ឬទីភ្នាក់ងារនៃប្រទេសផ្តល់ជំនួយអាហារូបករណ៍។

#### គ. ការបង្កើនគុណភាពសេវាសាធារណៈ

ពង្រឹងកែលម្អគុណភាពសេវាសាធារណៈក្នុងវិស័យពាណិជ្ជកម្ម ដោយធ្វើឱ្យសេវានេះប្រកបដោយគុណភាព សាមញ្ញភាព ប្រសិទ្ធភាព ភាពជឿទុកចិត្ត និងឆ្លើយតបទាន់ពេលវេលាជូនអ្នកទទួលសេវា ឱ្យមានភាពងាយស្រួល និងមានការចូលរួមពេញលេញពីអ្នកប្រើសេវា តាមរយៈ៖

- ការដាក់ឱ្យប្រើប្រាស់នូវ ការស្នើសុំលិខិតអនុញ្ញាត និងអាជ្ញាបណ្ណការធ្វើអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកតាមរយៈប្រព័ន្ធស្វ័យប្រវត្តកម្ម
- ការបោះពុម្ពព្រឹត្តិបត្រផ្លូវការ សម្រាប់ផ្សព្វផ្សាយជាសាធារណៈតាមគេហទំព័រ www.cambodiaip.gov.kh និងចែកជូនភ្នាក់ងារតំណាងស្របច្បាប់ នៃម្ចាស់ម៉ាកតាមរយៈអ៊ីម៉ែល
- ការកែសម្រួលលិខិតផ្សេងៗ និងកែសម្រួលកម្រៃសេវាសាធារណៈពាក់ព័ន្ធកិច្ចការចុះបញ្ជីម៉ាក
- បានរៀបចំប្រព័ន្ធស្វ័យប្រវត្តិកម្មពេញលេញសម្រាប់កិច្ចការចុះបញ្ជីម៉ាក និងការបង់កម្រៃសេវាសាធារណៈតាមប្រព័ន្ធអនឡាញ និងបានធ្វើតេស្តសាកល្បង KHQR code ជាមួយក្រុមបច្ចេកទេសរបស់ធនាគារ Acleda
- រៀបចំប្រព័ន្ធជូនដំណឹងជាស្វ័យប្រវត្តិពីដំណើរការ និងស្ថានភាពការចុះបញ្ជីម៉ាកទៅអ្នកប្រើសេវា
- ដាក់ឱ្យប្រើប្រាស់ពេញលេញការចុះហត្ថលេខាតាមប្រព័ន្ធអេឡិចត្រូនិក (E-Signature) ក្នុងការចុះបញ្ជីម៉ាកអន្តរជាតិតាមប្រព័ន្ធម៉ាឌ្រីដ

- ធ្វើបច្ចុប្បន្នភាព ផ្សព្វផ្សាយព័ត៌មាន ចំណេះដឹងតាមរយៈ Facebook Page, Youtube និងគេហទំព័រកម្មសិទ្ធិបញ្ញា (IP Website) និងធ្វើបច្ចុប្បន្នភាពទិន្នន័យចុះបញ្ជីម៉ាក ទៅលើគេហទំព័រដៃគូមួយចំនួន ដូចជា ASEAN-TMview, TMview (EU), Global Brand Database (WIPO) ។ល។
- ការធ្វើប្រតិភូកម្មក្នុងការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ឌី(D)សម្រាប់ទំនិញកសិផលដល់គ្រប់មន្ទីរពាណិជ្ជកម្មខេត្តជាពិសេសមន្ទីរពាណិជ្ជកម្មខេត្តជាប់ព្រំដែន
- ការដាក់ឱ្យអនុវត្តប្រតិវេទន៍ស្វ័យបញ្ជាក់ដើមកំណើតទំនិញទូទាំងអាស៊ាន(ASEAN-WideSelf Certification AWSC) ដើម្បីសម្រួលដល់ការធ្វើពាណិជ្ជកម្មក្នុងតំបន់អាស៊ាន
- ការអនុវត្តគម្រោងចុះបញ្ជីអ្នកនាំចេញ (Registered Exporter System-REX) សម្រាប់ធ្វើការនាំចេញទៅកាន់សហភាពអឺរ៉ុប ប្រទេសស្វីស ណ័រវែស និងតួកគី
- ការណែនាំពីបែបបទស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញគ្រប់ទម្រង់ តាមប្រព័ន្ធស្វ័យប្រវត្តកម្ម
- ការចូលរួមអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ សម្រាប់ការចេញអាជ្ញាបណ្ណនាំចេញ-នាំចូល និងវិញ្ញាបនបត្រគីមប័លើប្រូសេស ក្រោមប្រព័ន្ធបញ្ជរតែមួយជាតិ (National Single Window-NSW) និងបានភ្ជាប់ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិច (E-payment) ជាមួយ ធនាគារវីង (ខេមបូឌា) ម.ក, ធនាគារកាណាឌីយ៉ា ក.អ, ធនាគារ ព្រីនស៍ ម.ក, ធនាគារវឌ្ឍនៈ, ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី
- ការតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តកម្មវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ (ATIGA e-Form D) ទៅក្នុងបញ្ជរតែមួយជាតិ និងភ្ជាប់ទៅបញ្ជរតែមួយអាស៊ាន
- ការបន្ថែមវិញ្ញាបនបត្រទម្រង់ផ្សេងៗទៀតស្របតាមវិធានប្រភពដើមទំនិញនៃប្រទេសនាំចូលទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម រួមមាន៖ Form ANNEX សម្រាប់នាំចេញទៅទីផ្សារជប៉ុន, Form Chile សម្រាប់នាំចេញទៅទីផ្សារស៊ីលី (Chile), Form AHK សម្រាប់នាំចេញទៅទីផ្សារហុងកុង នៃប្រទេសចិន, Form RCEP សម្រាប់នាំចេញទៅកាន់ទីផ្សារអាស៊ាន អូស្ត្រាលី ចិន ជប៉ុន សាធារណៈរដ្ឋកូរ៉េ និង នូវែលសេឡង់, Form CCFTA សម្រាប់នាំចេញទៅកាន់ទីផ្សារសាធារណរដ្ឋប្រជាមានិតចិន, និងForm CKFTA សម្រាប់នាំចេញទៅកាន់ទីផ្សារសាធារណរដ្ឋកូរ៉េ
- ការតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តកម្មវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញគ្រប់ទម្រង់ទៅតាមគ្រប់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស
- ការបង្កើតមជ្ឈមណ្ឌលទំនាក់ទំនងរវាងសាធារណៈជន និងមន្ត្រីផ្តល់សេវា (Call Center ១២៦៦) ដើម្បីដោះស្រាយសំណូមពរ និងចម្លល់នានាបានទាន់ពេលវេលា
- ការបន្តផ្សព្វផ្សាយគោលនយោបាយ ស្តីពីគុណភាពសេវាសាធារណៈក្នុងវិស័យពាណិជ្ជកម្ម ឱ្យបានជ្រួតជ្រាបដាក់ស្តែង និងទូលំទូលាយក្នុងចំណោមមហាជនទូទៅ ពិសេសវិស័យឯកជន
- ការបើកវគ្គបណ្តុះបណ្តាលសម្រាប់អ្នកផ្តល់សេវា អ្នកទទួលសេវា និងអន្តរការី ដូចជា៖ វគ្គបណ្តុះបណ្តាលអ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម, វគ្គបណ្តុះបណ្តាលអ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំឯកសារនាំចេញ-នាំចូល និងវិញ្ញាបនបត្រប្រភពដើមទំនិញ និងវគ្គបណ្តុះបណ្តាលភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា
- ការបង្កើតយន្តការព័ត៌មានត្រលប់វិញ (Feedback) និងបណ្តឹងតវ៉ារបស់អ្នកប្រើសេវា តាមរយៈប្រអប់សំបុត្រសាធារណៈសម្រាប់ព័ត៌មានត្រលប់ និងបណ្តឹងតវ៉ា
- ការអនុវត្តតាមយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨ ដោយបង្កើតយន្តការលើកទឹកចិត្ត សម្រាប់ការចុះបញ្ជីពាណិជ្ជកម្មដោយស្ម័គ្រចិត្ត របស់វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធដោយផ្តល់ការ

លើកលែងកាតព្វកិច្ចអនុលោមភាព និងលើកលែងការផាកពិន័យនានាសម្រាប់អាជីវកម្មដែលបានដំណើរការ ហើយមិនបានចុះបញ្ជី ។

## ១.២. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

### ក. ការរៀបចំផែនការ និងថវិកា

- រៀបចំផែនការថវិកាឆ្នាំ២០២៤ និងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៤-២០២៦
- រៀបចំរបាយការណ៍សមិទ្ធកម្មឆ្នាំ២០២២ របាយការណ៍សមិទ្ធកម្មពាក់កណ្ដាលឆ្នាំ២០២៣ និងការគ្រោងលទ្ធផលរំពឹងទុកសម្រាប់ឆ្នាំ២០២៣
- ដាក់បញ្ចូលថវិកាដៃគូ និងថវិកាបស់ក្រុមហ៊ុនហ្គ្រីនត្រេដ ទៅក្នុងឧបសម្ព័ន្ធនៃថវិកាប្រចាំឆ្នាំ
- រៀបចំកម្មវិធីចំណូល-ចំណាយ និងការព្យាករណ៍ចំណូល-ចំណាយប្រចាំត្រីមាស
- រៀបចំរបាយការណ៍ស្ថានភាពចំណូលប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- រៀបចំរបាយការណ៍ប្រៀបធៀបផែនការចំណាយតាមកម្មវិធីប្រចាំត្រីមាស និងការអនុវត្តជាក់ស្ដែងដោយឆ្លុះបញ្ចាំងនូវគោលដៅចំណាយមិនតិចជាង៩៧%
- រៀបចំរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តសកម្មភាពកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជូនអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំឱ្យមានការទទួលខុសត្រូវជាអង្គភាពថវិកា សម្រាប់អគ្គនាយកដ្ឋានក្រោមឱវាទក្រសួង។

### ខ. ការអនុវត្តប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS)

- ធ្វើរបាយការណ៍ ស្ដីពីការពិនិត្យលទ្ធភាពក្នុងការដាក់ឱ្យអនុវត្ត FMIS សម្រាប់ថវិកាដៃគូ និងថវិកាជំនួយ
- អនុវត្តពេញលេញប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈលើចំណូល និងចំណាយ
- អនុវត្តទាំងស្រុងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ដូចជាចំណូលកម្រៃសេវាសាធារណៈ ចំណូលកិច្ចសន្យា និងប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ(SARMIS)។

### គ. ការងារលទ្ធកម្ម

- បានអនុវត្តតាមនីតិវិធី និងវិធីសាស្ត្រលទ្ធកម្ម ដោយផ្អែកលើលិខិតបទដ្ឋានគតិយុត្តថ្មីៗ
- បានធ្វើការកែសម្រួលផែនការលទ្ធកម្មឆ្នាំ២០២៣ ឱ្យស្របតាមតម្រូវការជាក់ស្ដែងរបស់ក្រសួង

## ១.៣. ការងារវិមជ្ឈការ និងវិសហមជ្ឈការ

- សម្របសម្រួលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ពង្រឹងការអនុវត្តមុខងារវិស័យពាណិជ្ជកម្ម
- សហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប រៀបចំប្រកាសអន្តរក្រសួង ស្ដីពីការអនុវត្តមុខងារ វិស័យពាណិជ្ជកម្មដែលបានផ្ទេរទៅថ្នាក់ក្រោមជាតិ និងកែសម្រួលតម្លៃកម្រងសេវាសាធារណៈនៅថ្នាក់ក្រោមជាតិ
- ផ្សព្វផ្សាយអំពីព្រឹត្តការណ៍នានាស្ដីពីការងារកំណែទម្រង់ និងការលើកកម្ពស់សកម្មភាពយេនឌ័រ ក្នុងការអនុវត្តមុខងារដែលបានផ្ទេរទៅថ្នាក់ក្រោមជាតិ
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលអំពីគោលការណ៍ នីតិវិធី និងបែបបទនៃការអនុវត្តមុខងារវិស័យពាណិជ្ជកម្មទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ត្រួតពិនិត្យ តាមដាន និងគាំទ្រថ្នាក់ក្រោមជាតិក្នុងការអនុវត្តកិច្ចដំណើរការផ្ទេរមុខងារ។

## ២. ការងារផ្តល់សេវាពាណិជ្ជកម្ម [1]

### ២.១. ការងារចុះបញ្ជីពាណិជ្ជកម្ម

- បានបញ្ចប់ការអភិវឌ្ឍ ប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ការស្នើសុំលិខិតអនុញ្ញាត និងអាជ្ញាបណ្ណការធ្វើអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ការស្នើសុំលិខិតអនុញ្ញាត និងអាជ្ញាបណ្ណការធ្វើអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកជាមួយថ្នាលបច្ចេកវិទ្យា(CamDX)
- បានបញ្ចប់ការអភិវឌ្ឍ ប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ការចុះបញ្ជីកែប្រែ ដើម្បីប្រើប្រាស់ការចុះបញ្ជីកែប្រែជំនួសប្រព័ន្ធស្វ័យប្រវត្តកម្មដែលកំពុងប្រើប្រាស់បច្ចុប្បន្នរបស់ក្រុមហ៊ុន Foster moore
- បានបញ្ចប់ការជ្រើសរើសអ្នកតំណាងស្របច្បាប់ជំនាន់ទី៣
- បានបញ្ចប់កិច្ចការដំណើរការចុះ On-Site Visit របស់ក្រុមការងារត្រួតពិនិត្យរួម JG-APG (FATF)
- បានអនុវត្តការងារតាមការណែនាំរបស់អនុគណៈកម្មការចំពោះកិច្ចអនុវត្តផែនការសកម្មភាពការងាររបស់ក្រុមការងារត្រួតពិនិត្យរួមនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ (អ.អ.ផ.)។

**ក. ការងារកំពុងអនុវត្ត**

- ផ្ទេរ ទិន្នន័យចុះបញ្ជីពាណិជ្ជកម្ម ពីCLOUD ទៅមជ្ឈមណ្ឌលទិន្នន័យ (DATA CENTER)
- បន្តអនុវត្តការងារផែនការសកម្មភាពនៃយុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មឆ្នាំ២០១៩-២០២៣
- បន្តការបណ្តុះបណ្តាល និងផ្សព្វផ្សាយច្បាប់ក្នុងការចុះបញ្ជីពាណិជ្ជកម្ម និងការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- កំពុងធ្វើការសាកល្បងលើការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ការចុះបញ្ជីកែប្រែ។

**ស្ថិតិចុះបញ្ជីពាណិជ្ជកម្ម ក្នុងរយៈពេល ១១ខែ ឆ្នាំ២០២៣**

| ល.រ | យថាប្រភេទនៃការចុះបញ្ជីពាណិជ្ជកម្ម | ប្រៀបធៀបប្រចាំខែ | | |
|---|---|---|---|---|
| | | ១១ខែដើម ឆ្នាំ២០២២ | ១១ខែដើម ឆ្នាំ២០២៣ | កំណើន (%) |
| ក) ការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម (ថ្មី) | | | | |
| ១ | ក្រុមហ៊ុនមូលធន | ៤ ៤៦៥ | ៤ ៣៧៥ | -២,០១ |
| ២ | ក្រុមហ៊ុនពាណិជ្ជកម្មបរទេស | ៤១ | ៦៥ | ៥៨,៥៣ |
| ៣ | សហគ្រាសឯកបុគ្គល | ៥ ៥៤០ | ៧ ០៦៦ | ២៧,៥៤ |
| ៤ | ក្រុមហ៊ុនសហកម្មសិទ្ធ | 0 | 0 | 0 |
| **សរុបការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម** | | **១០ ០៤៦** | **១១ ៥០៦** | **១៤,៥៣** |
| ខ) ការស្នើសុំលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម | | | | |
| ១ | ក្រុមហ៊ុនមូលធន | ៧០៥ | ៨៣៦ | ១៨,៥៨ |
| ២ | ក្រុមហ៊ុនពាណិជ្ជកម្មបរទេស | ២៣ | ២៤ | ៤,៣៤ |
| ៣ | សហគ្រាសឯកបុគ្គល | ៦៦ | ១០៧ | ៦២,១២ |
| ៤ | ក្រុមហ៊ុនសហកម្មសិទ្ធ | 0 | 0 | 0 |
| **សរុបការស្នើសុំលុបឈ្មោះចេញពីបញ្ជាពាណិជ្ជកម្ម** | | **៧៩៤** | **៩៦៧** | **២១,៧៨** |

[1] ប្រភព៖ អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម

| | | | | |
|---|---|---|---|---|
| គ) ការស្នើសុំចុះបញ្ជីកែប្រែ | | | | |
| ១ | ការកែប្រែផ្លាស់ប្តូរភាគហ៊ុន បន្ថយដើមទុន បង្កើនដើមទុន | ២ ២៤៤ | ២ ១៨៩ | -២,៤៥ |
| ២ | ការកែប្រែផ្សេងៗ (អភិបាល កម្មវត្ថុអាជីវកម្ម នាមករណ៍...) | ៩ ៦៨០ | ១០,៣០៤ | ៦,៤៤ |
| ៣ | ការបង្កើតសាខាក្រុមហ៊ុនក្នុងស្រុក | ៦៨១ | ៧៨០ | ១៤,៥៣ |
| ៤ | ការកែប្រែសហគ្រាសឯកបុគ្គល | ៣៦៩ | ៤៩២ | ៣៣,៣៣ |
| ឃ) ការស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិក | | | | |
| ១ | លិខិតអនុញ្ញាតសម្រាប់រូបវន្តបុគ្គល | ៥ ៥៩៨ | ៧១ | -៩៨,៧៣ |
| ២ | លិខិតអនុញ្ញាតសម្រាប់សហគ្រាសឯកបុគ្គល | ១៧៧ | ១១ | -៩៣,៧៨ |
| ៣ | អាជ្ញាបណ្ណ | ៤៨៧ | ៣២ | -៩៣,៤២ |
| ង) ការបន្តសុពលភាពលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិក | | | | |
| ១ | លិខិតអនុញ្ញាតសម្រាប់រូបវន្តបុគ្គល | 0 | 0 | 0 |
| ២ | លិខិតអនុញ្ញាតសម្រាប់សហគ្រាសឯកបុគ្គល | 0 | 0 | 0 |
| ៣ | អាជ្ញាបណ្ណ | 0 | 0 | 0 |
| ច) ការកែប្រែលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិក | | | | |
| ១ | ការកែប្រែលិខិតអនុញ្ញាត | 0 | 0 | 0 |
| ២ | ការកែប្រែអាជ្ញាបណ្ណ | ២ | 0 | 0 |
| ឆ) ការផ្អាក ឬបិទអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក | | | | |
| ១ | លិខិតអនុញ្ញាតសម្រាប់រូបវន្តបុគ្គល | 0 | ៩ | |
| ២ | លិខិតអនុញ្ញាតសម្រាប់សហគ្រាសឯកបុគ្គល | 0 | 0 | 0 |
| ៣ | អាជ្ញាបណ្ណ | 0 | 0 | 0 |
| ជ) ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ | | ២១ ៣២២ | ២៤ ២៤៤ | ១៣.៧០ |
| ឈ) ការថតចម្លងឯកសារចុះបញ្ជីពាណិជ្ជកម្ម | | 0 | 0 | 0 |
| ញ) ការទទួលពាក្យស្នើសុំអនុវត្តនីតិវិធីការក្សាការពារ និងដោះស្រាយវិវាទ | | 0 | 0 | 0 |
| ដ) ការស្នើសុំបម្រុងទុកនាមករណ៍ | | | | |
| ១ | ការបម្រុងទុកនាមករណ៍ក្រុមហ៊ុនមូលធន | ៦ ០៨៤ | ៥ ៩១៧ | -២,៧៤ |
| ២ | ពន្យារការបម្រុងទុកនាមករណ៍ក្រុមហ៊ុនមូលធន | ២៣១ | ១៨៣ | -២០,៧៧ |
| ៣ | ការបម្រុងទុកនាមករណ៍សហគ្រាសឯកបុគ្គល | ៦ ២០៦ | ៧ ៩៤៥ | ២៨,០២ |
| ៤ | ពន្យារការបម្រុងទុកនាមករណ៍សហគ្រាសឯកបុគ្គល | ១៥២ | ១៧០ | ១១,៨៤ |
| ឋ) ការពិន័យ | | | | |
| ១ | ការមិនបានបំពេញបែបបទក្នុងការផ្លាស់ប្តូរកែប្រែផ្សេងៗ | ៧៧ | ៦៧ | -១២,៩៨ |

| | | | | |
|---|---|---|---|---|
| ២ | ការមិនតម្កល់ទុកប្រតិវេទន៍ប្រចាំឆ្នាំ | ៥៦០ | ៩៤០ | ៦៧,៨៥ |
| ៣ | ការផ្តល់ព័ត៌មានមិនពិត និងក្លែងបន្លំឯកសារតម្រូវសម្រាប់ចុះបញ្ជី | ០ | ០ | ០ |
| ៤ | ការធ្វើអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយគ្មានការអនុញ្ញាត | ១ | ១ | ០ |
| ៥ | ការផ្តល់ព័ត៌មានមិនពិត ឬឯកសារផ្សេងៗដែលត្រូវតម្កល់ទុក | ០ | ០ | ០ |
| ៦ | ការមិនបញ្ចូលច្បាប់ចម្លងរបាយការណ៍ហិរញ្ញវត្ថុ | ០ | ០ | ០ |

## ក្រាហ្វិកស្ថិតិចុះបញ្ជីពាណិជ្ជកម្មប្រៀបធៀបឆ្នាំ២០២២ និងឆ្នាំ២០២៣






## ២.២. ការងារកម្មសិទ្ធិបញ្ញា

### ក. ការងារកិច្ចសហប្រតិបត្តិការ និងគម្រោង

- បានចុះហត្ថលេខា លើអនុស្សរណៈកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាជាមួយនឹងអង្គការកម្មសិទ្ធិបញ្ញាហ្វីលីពីន ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ នៅទីខេត្តបូហូល ប្រទេសហ្វីលីពីន
- បានចុះអនុស្សរណៈយោគយល់គ្នា ស្តីពីគម្រោងសិក្សាស្រាវជ្រាវការកសាងកេរ្តិ៍ឈ្មោះម៉ាករវាងក្រសួងពាណិជ្ជកម្ម និងអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន និងវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចប្រចាំអាស៊ាន និងអាស៊ីបូព៌ា នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ នៅទីស្តីការក្រសួងពាណិជ្ជកម្ម
- បានបញ្ចប់គម្រោងសិក្សាស្រាវជ្រាវ លើការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញាតាមប្រព័ន្ធអេឡិចត្រូនិកជាមួយក្រុមហ៊ុនមេធាវី ROUSE តំណាងឱ្យអង្គភាពកម្មសិទ្ធិបញ្ញាចក្រភពអង់គ្លេស
- បានទទួលរបាយការណ៍ណែនាំរបស់លោក Demand Tan តំណាងឱ្យអង្គភាពកម្មសិទ្ធិបញ្ញាចក្រភពអង់គ្លេស ស្តីពី គម្រោងសិក្សាស្រាវជ្រាវលើការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញាតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា
- បានបញ្ចប់សេចក្តីព្រាងផែនការការងារជាមួយអង្គការកម្មសិទ្ធិបញ្ញាហ្វីលីពីន
- បានកំពុងអនុវត្តន៍គម្រោងសិក្សាស្រាវជ្រាវការកសាងកេរ្តិ៍ឈ្មោះម៉ាកជាមួយវិទ្យាស្ថានស្រាវជ្រាវ ERIA
- បានសហការរៀបចំធ្វើលិខិតសំណើសុំផ្តល់កិច្ចសម្ភាសន៍ ក្រោមគម្រោងស្រាវជ្រាវការកសាងកេរ្តិ៍ឈ្មោះម៉ាក ជាមួយវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាននិងអាស៊ីខាងកើត (ERIA) និងក្រុមហ៊ុនធី អឹម អាយ សូហ្វ អិលធីឌី (TMI)
- បានរៀបចំសំណើគម្រោងស្តីពី ការផ្តល់អំណាចដល់សហគ្រិនស្ត្រីតាមរយៈកិច្ចការពារ និងការប្រើប្រាស់កម្មសិទ្ធិបញ្ញា (Empowering Women Entrepreneurs Through Intellectual Property Protections and Utilizations)
- បានរៀបចំសំណើគម្រោង 2024 AISP ECWP Project under Regional Trade for Development (RT4D) conducted by AANZFTA-RCEP
- បានរៀបចំសំណើគម្រោងរបស់ KIOCA ស្តីពី "Advancing Cambodia's Business Infrastructure through Digital Transformation: Establishment of the National Trademark and Brand Management Center"
- បានធ្វើការបញ្ចប់បច្ចុប្បន្នភាពលើតារាងកម្មវិធីការងាររបស់រាជរដ្ឋាភិបាល ក្រោមក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក (WTO) Work Program បន្ទាប់ពីកម្ពុជាបានធ្វើការត្រួតពិនិត្យឡើងវិញ នូវគោលនយោបាយពាណិជ្ជកម្មកម្ពុជា (TPR) លើកទី១ និងទី២
- បានធ្វើការឆ្លើយតបលើ សំណើសុំផ្តល់មតិលើសេចក្តីព្រាងរបាយការណ៍ស្តីពី ការសិក្សាពិនិត្យឡើងវិញរួមគ្នានៃតំបន់ពាណិជ្ជកម្មសេរី អាស៊ាន-កូរ៉េ (Joint Review Study of the ASEAN-Korean Free Trade Area)
- បានធ្វើការសម្របសម្រួលជាមួយលេខាធិការដ្ឋានអាស៊ាន ក្រោមគម្រោង ARISE Plus IPR ដើម្បីឱ្យស្ត្រីនៃក្រុមហ៊ុនសិប្បករអង្គរ (Artisans Angkor) មានឱកាសបានចូលរួមធ្វើបទសម្ភាសន៍អំពីភាពជោគជ័យនៃការប្រើប្រាស់កម្មសិទ្ធិបញ្ញាក្នុងការប្រកបអាជីវកម្ម។

## ខ. ការងារគោលនយោបាយកម្មសិទ្ធិបញ្ញា

- បានធ្វើរបាយការណ៍លទ្ធផលការងារប្រចាំឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣ របស់គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា (គ.ក.ប) សម្រាប់កិច្ចប្រជុំលើកទី១២ គោរពជូន **សម្តេចតេជោ អគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** និងសមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា
- គោលនយោបាយកម្មសិទ្ធិបញ្ញាជាតិ ត្រូវបានរាជរដ្ឋាភិបាលអនុម័ត នៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៣
- បានបញ្ចប់ការរៀបចំសេចក្តីសម្រេចស្តីពី "ការតែងតាំងសមាសភាព តួនាទី និងភារកិច្ច របស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា"
- បានរៀបចំទិវាកម្មសិទ្ធិបញ្ញាពិភពលោក ឆ្នាំ២០២៣
- បានធ្វើលិខិតស្នើសុំចម្លើយលើកម្រងសំណួររបស់គណៈកម្មាធិការប្រឆាំងបទល្មើសក្លែងក្លាយអន្តរជាតិ (International Trademark Association-INTA) ទៅកាន់ក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ
- បានរៀបចំសេចក្តីជូនដំណឹងស្តីពីការរៀបចំបង្កើតការប្រកួតប្រជែងវីដេអូតាមបណ្តាញសង្គម Tiktok សម្រាប់យុវជន ក្រោមមូលបទកម្មសិទ្ធិបញ្ញា និងទេសចរណ៍៖ ការបង្ហាញពីភាពអស្ចារ្យរបស់មាតុភូមិខ្ញុំ« (IP and Tourism: My land is my ultimate flex) »។

## គ. ការលើកកម្ពស់ការយល់ដឹងសាធារណៈពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា

### គ.១. ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការចាត់បញ្ជូនមន្ត្រីទៅចូលរួមសិក្ខាសាលា

| | ឈ្មោះកម្មវិធីចូលរួម | លើក | ចំនួនអ្នកចូលរួម | មន្ត្រីមកពីស្ថាប័នពាក់ព័ន្ធ | ទីកន្លែង/ប្រទេស |
|---|---|---|---|---|---|
| ការរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា | | | | | |
| ១ | បានរៀបចំវគ្គបណ្តុះ បណ្តាល | ៦ | ៤៤៤ | | តាមបណ្តារាជធានី ខេត្ត |
| ២ | បានរៀបចំវគ្គបណ្តុះ បណ្តាលតាមអនឡាញ | ១ | ៩០ | | ក្រសួងពាណិជ្ជកម្ម (អនឡាញ) |
| ការចាត់បញ្ជូនមន្ត្រីចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល នៅក្នុងប្រទេស | | | | | |
| ១ | ចូលរួមសិក្ខាសាលា | ១ | ២ | | វិទ្យាស្ថាន ទីស្តីការក្រសួង |
| ២ | ចូលរួមវគ្គបណ្តុះបណ្តាល | ៧ | ១៦ | | វិទ្យាស្ថាន ទីស្តីការក្រសួង |

### វគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស

| | | | | | |
|---|---|---|---|---|---|
| ការចាត់បញ្ជូនមន្ត្រីចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ក្រៅប្រទេស | | | | | |
| ១ | ចូលរួមសិក្ខាសាលា | ៣ | ៥ | | ឡាវ, ថៃឡង់ដ៍, វៀតណាម |

| | | | | | |
|---|---|---|---|---|---|
| ២ | ចូលរួមវគ្គបណ្តុះបណ្តាល | ៦ | ៨ | | ជប៉ុន, ចិន,កូរ៉េ |
| ៣ | ចូលរួមសិក្ខាសាលាតាមអនឡាញ | ៣ | ២៨ | | អង្គការកម្មសិទ្ធិបញ្ញាពិភពលោក |
| ៤ | ចូលរួមវគ្គបណ្តុះបណ្តាលតាមអនឡាញ | ២ | ២៥ | | អង្គការកម្មសិទ្ធិបញ្ញាពិភពលោក |

## គ.២. ការចាត់បញ្ជូនមន្ត្រីទៅចូលរួមកិច្ចប្រជុំក្រៅប្រទេស

| ល.រ | ឈ្មោះកិច្ចប្រជុំ | ចំនួនអ្នកចូលរួម | ប្រទេស |
|---|---|---|---|
| ១ | សិក្ខាសាលាអនុតំបន់ KMOJ-WIPO ស្តីពីការអនុវត្តកម្មសិទ្ធិបញ្ញាសម្រាប់ព្រះរាជអាជ្ញា( KMOJ-WIPO Sub-regional seminar on Intellectual property enforcement for prosecutors ) | ២ (MoC) | សាធារណរដ្ឋកូរ៉េ |
| ២ | កិច្ចប្រជុំលើកទី៤៦នៃគណៈកម្មាធិការអន្តររដ្ឋាភិបាលស្តីពីកម្មសិទ្ធិបញ្ញា និងធនធានហ្សែន ចំណេះដឹងប្រពៃណីសម្រាប់ប្រជាជន (IGC) (Forty-Six Sission of the Intergovermenttal Committee on Intellectaul Property and Genetic Resource, Tranditional Knowledge for Folklore (IGC)) | ១ (MoC) | ស្វីស |
| ៣ | ទិដ្ឋភាពទាក់ទងនឹងពាណិជ្ជកម្មនៃសិទ្ធិកម្មសិទ្ធិបញ្ញា (Trade-Related Aspects of Intellectual Property Rights ) | ១ (MoC) | ស្វីស |
| ៤ | កិច្ចប្រជុំលើកទី៤ នៃម៉ាកសញ្ញាពាណិជ្ជកម្មអាស៊ាន និងបណ្តាញរួមគ្នានៃការរចនា (The Fourth Meeting of The ASEAN Trade Mark and Design Convergence Network) | ៤ (MoC,MISTI) | ថៃឡង់ដ៏ |
| ៥ | មន្ត្រីការិយាល័យកម្មសិទ្ធិបញ្ញាដែលទទួលខុសត្រូវចំពោះប្រព័ន្ធម៉ាឌ្រីដ( Intellectual Property Office Officials Responsible for the Madrid System) | ១ (MoC) | វៀតណាម |
| ៦ | កិច្ចប្រជុំលើកទី៤៣ នៃគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិពាក់ព័ន្ធ ( The Forty-Thrid Sesion of the Standing Committee on Copyright and Related Right (SCCR)) | ១ (MoC) | ស្វីស |
| ៧ | សមាគមពាណិជ្ជសញ្ញាអន្តរជាតិឆ្នាំ 2023 (International Trademark Association's 2023) | ១ (MoC) | សិង្ហបុរី |
| ៨ | កិច្ចប្រជុំលើកទី៦៩ របស់ក្រុមការងារអាស៊ានស្តីពីសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា (The ASEAN Working Group on Intellectual Property Cooperation $69^{th}$ ) | ៦ (MoC,MISTI, MoFA) | ហ្វីលីពីន |
| ៩ | កិច្ចប្រជុំថ្នាក់តំបន់ WIPO ស្តីពីការពង្រឹងបណ្តាញមជ្ឈមណ្ឌលគាំទ្របច្ចេកវិទ្យា និងនវានុវត្តន៍ក្នុងតំបន់ | ២ (MoC) | ឥណ្ឌូនេស៊ី |

| | | | |
|---|---|---|---|
| | អាស៊ាន (TISC) ( WIPO Regional Meeting on Strengthening the ASEAN Regional Technology and Innovation Support Center (TISC) Network) | | |
| ១០ | ការអនុវត្តច្បាប់ប្រឆាំងការក្លែងបន្លំចំណីអាហារ និងការជួញដូរទំនិញកសិកម្មក្លែងក្លាយ (Enforcement Against Food Fraud and Trade in Counterfeit Agricultural Goods) | ៦ (MoC,MoJ,MoH,CCF, CEC,MoT) | ថៃឡង់ដ៍ |
| ១១ | បណ្តាញអាស៊ាននៃអ្នកជំនាញអនុវត្ត IPR (ANIEE) និងការអនុវត្ត IP (ASEAN Network of IPR Enforcement Experts (ANIEE) and IP Enforcement) | ២ (MoC) | ហ្វីលីពីន |
| ១២ | សន្និសីទការទូតស្តីពីកម្មសិទ្ធិបញ្ញា ធនធានហ្សែន និងចំណេះដឹងប្រពៃណីដែលភ្ជាប់ជាមួយធនធានហ្សែន (Diplomatic Conference on Intellectual Property, Genetic Resources and Traditional Knowledge Associated with Genetic Resources) | ១ (MoC) | ឥណ្ឌូនេស៊ី |
| ១៣ | កិច្ចប្រជុំគណៈកម្មាធិការអន្តររដ្ឋាភិបាលលើកទី៤៧ ស្តីពីកម្មសិទ្ធិបញ្ញា និងធនធានហ្សែន ចំណេះដឹងប្រពៃណី និងប្រជាប្រិយ (The Forty-Seven Session Intergovernmental Committee on Intellectual Property and Genetic Resources, Traditional Knowledge and Folklore) | ១ (MoC) | ស្វីស |
| ១៤ | កិច្ចប្រជុំសភានៃរដ្ឋសមាជិក WIPOលើកទី៦៤ (The Sixty-Fourth Series of Meeting of the Assemblies of the Member States of WIPO) | ១ (MoC) | ស្វីស |
| ១៥ | សូចនាករភូមិសាស្ត្រជាតិ (National Geographical Indication (GIs) | ១ (MoC) | ហ្វីលីពីន |
| ១៦ | ការបង្ហាញលទ្ធផលគម្រោងទៅកាន់រដ្ឋសមាជិកអាស៊ាន - គម្រោងតំបន់អាស៊ាន WIPO ស្តីពីគោលនយោបាយកម្មសិទ្ធិបញ្ញារបស់ស្ថាប័នសម្រាប់វិទ្យាស្ថានសិក្សា និងការវាយតម្លៃ IP (Presenting the Outcomes of the Projects to the ASEAN Member States - WIPO ASEAN Regional Projects on Institutional IP Policies for Academic Institutions and IP Valuation) | ២ (MoC) | ឥណ្ឌូនេស៊ី |
| ១៧ | កម្មវិធីកសាងអាស៊ាន (The ASEAN BUILD Program) | ៣ (MoC, MISTI, TSC) | ហ្វីលីពីន |
| ១៨ | សិក្ខាសាលាថ្នាក់តំបន់ស្តីពីការអនុវត្តកម្មសិទ្ធិបញ្ញា និងបណ្តាញអាស៊ាននៃអ្នកជំនាញអនុវត្តកម្មសិទ្ធិបញ្ញា (Regional Workshop on IP Enforcement and ASEAN Network of IP Enforcement Experts (ANIEE) | ១ MISTI | ស្វីស |

| | | | |
|---|---|---|---|
| ១៩ | កិច្ចប្រជុំលើកទី ១៤ នៃប្រមុខការិយាល័យកម្មសិទ្ធិបញ្ញា ចិន-អាស៊ាន (The 14th Meeting of CHINA-ASEAN Heads of Intellectual Property offices) | ២ MoC | ចិន |
| ២០ | InterGI Europe 2023 'The Collective management of Quality for Geographical Indications" | ១ MoC | ស្វីស |
| ២១ | សិក្ខាសាលាថ្នាក់តំបន់ស្តីពីការអនុវត្តកម្មសិទ្ធិបញ្ញា និងបណ្តាញអាស៊ាននៃអ្នកជំនាញអនុវត្តកម្មសិទ្ធិបញ្ញា (ANIEE) និង សិក្ខាសាលាអាស៊ាន-USTPO ស្តីពីការអភិវឌ្ឍន៍ក្នុងការអនុវត្តច្បាប់សិទ្ធិអ្នកនិពន្ធ (Regional Workshop on IP Enforcement and ASEAN Network of IP Enforcement Experts (ANIEE) and ASEAN-USTPO Workshop on Developments in Copyright Law Enforcement' | ៣MCFA<br>៣ MOC | ថៃឡង់ដ៍ |
| ២២ | កិច្ចប្រជុំលើកទី១៧ និងកិច្ចប្រជុំពាក់ព័ន្ធនៃក្រុមការងារអាស៊ានស្តីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា (The 17th Meeting and Related Meetings of the ASEAN Working Group on Intellectual Property Cooperation) | ២ MOC | សិង្ហបុរី |
| ២៣ | សេដ្ឋកិច្ចច្នៃប្រឌិតសម្រាប់អាស៊ាន និងឥណ្ឌូប៉ាស៊ីហ្វិក (Creative Economy for ASEAN and the Indo-Pacific) | ១MOC | ឥណ្ឌូណេស៊ី |
| ២៤ | កិច្ចប្រជុំលើកទី១៦ នៃគណៈកម្មាធិការប្រឹក្សា WIPO ស្តីពីការអនុវត្ត នៃការសម្របសម្រួលការអនុវត្តកម្មសិទ្ធិបញ្ញា (16th Session of the WIPO Advisory Committee on Enforcement (ACE) of IP Enforcement Coordination) | ១MOC | ស្វីស |
| សរុបមាន ២៤ កម្មវិធី អ្នកចូលរួមមាន ចំនួន ៥០រូប | | | |

## ឃ. ការងារផ្តល់សេវាសាធារណៈ:

### តារាងចំណូលទទួលបានពីការផ្តល់សេវាសាធារណៈ:

| ល.រ | ប្រភេទមុខចំណូល | ចំណូលឆ្នាំ២០២២ | ចំណូល១១ខែ ឆ្នាំ២០២២ | ចំណូល១១ខែ ឆ្នាំ២០២៣ | ប្រៀបធៀបប្រចាំឆ្នាំ ២០២២ | ប្រៀបធៀប ១១ខែឆ្នាំ ២០២២ |
|---|---|---|---|---|---|---|
| ១ | ការទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកតាមប្រព័ន្ធជាតិ | ៤ ៥៤០ ៩៨០ ០០០ | ៤ ១៨៥ ២៨០ ០០០ | ៤ ៣៦៨ ២២០ ០០០ | -៣,៨%▼ | ៤,៤%▲ |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | ការទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកតាមប្រព័ន្ធអន្តរជាតិ និងការងារក្រោយចុះបញ្ជីម៉ាក | ៣ ៨៥១ ៤៨៦ ០០០ | ២ ៤៩៤ ១៧៤ ០០០ | ២ ៧៣៦ ៧៦១ ០០០ | -២៨,៩%▼ | ៩,៧%▲ |
| | **ចំណូលសរុប** | **៨ ៣៩២ ៤៦៦ ០០០** | **៦ ៦៧៩ ៤៥៤ ០០០** | **៧ ១០៤ ៩៨១ ០០០** | **-១៥,៣%▼** | **៦,៤%▲** |

### ខ. ការងារចុះបញ្ជីម៉ាក

- បានទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកសរុប(រួមទាំងការដាក់ពាក្យតាមប្រព័ន្ធជាតិ និងអន្តរជាតិ)គិតត្រឹមថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៣ មានចំនួន **១០ ៥៣៧** ចំណាត់ថ្នាក់ ថយចុះ **០,៧៩%** បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២២
- បានចុះបញ្ជីម៉ាកសរុប(រួមទាំងការដាក់ពាក្យតាមប្រព័ន្ធជាតិ និងអន្តរជាតិ) គិតត្រឹមថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៣ មានចំនួន **៨ ៥១៣** ចំណាត់ថ្នាក់ កើនឡើង **៣,៨៧%** បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២២
- ដោះស្រាយការរំលោភបំពានម៉ាកចំនួន **១៨ករណី** និងលុបម៉ាកបានចំនួន **៣០ករណី**។

## តារាងស្ថិតិចុះបញ្ជីម៉ាកពាណិជ្ជកម្ម

| សកម្មភាពការងារ | ឆ្នាំ២០២២ (១មករា - ២៥ វិច្ឆិកា) | ឆ្នាំ២០២៣ (១មករា -២៥ វិច្ឆិកា) | កំណើន(%) |
|---|---|---|---|
| ក. កិច្ចការចុះបញ្ជីម៉ាកពាណិជ្ជកម្ម | | | |
| **បានទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកពាណិជ្ជកម្ម**<br>- ក្នុងស្រុក<br>- ក្រៅស្រុក | ៣ ៩៦១ ម៉ាក<br>(៤.៦៣៧ ចំណាត់ថ្នាក់)<br>២ ០៥៨ ម៉ាក<br>១ ៩០៣ ម៉ាក | ៣ ៥១៥ ម៉ាក<br>(៤.២៤៧ ចំណាត់ថ្នាក់)<br>១ ៧៣៣ ម៉ាក<br>១ ៧៨២ ម៉ាក | ថយចុះ ៤៤៦<br>ស្មើនឹង<br>០,១១%▼ |
| **បានចុះបញ្ជីម៉ាកពាណិជ្ជកម្ម (តាមប្រព័ន្ធជាតិ)**<br>- ក្នុងស្រុក<br>- ក្រៅស្រុក | ២ ៨៧៨ ម៉ាក<br>(៣.៤៦៦ ចំណាត់ថ្នាក់)<br>១ ៧៦៦ ម៉ាក<br>១ ១១២ ម៉ាក | ៣ ៤៤៤ ម៉ាក<br>(៤.១៨៤ ចំណាត់ថ្នាក់)<br>១ ៧០០ ម៉ាក<br>១ ៧៤៤ ម៉ាក | កើនឡើង ៥៦៦<br>ស្មើនឹង ១៩%▲ |
| ការស្នើសុំពិនិត្យ និងវាយតម្លៃម៉ាក មុនការដាក់ពាក្យសុំចុះបញ្ជី | ២២៦ ម៉ាក | ១១១ ម៉ាក | ថយចុះ ១១៥<br>ស្មើនឹង ០,៤៩%▼ |
| ការបិទបញ្ចប់ការស្នើសុំចុះបញ្ជីម៉ាក ដោយចាត់ទុកថាអ្នកស្នើសុំបានបោះបង់ (TM Deemed Withdrawal) | ៩០៨ ម៉ាក | ៧២៨ ម៉ាក | ថយចុះ ១៨០<br>ស្មើនឹង ០,១៩%▼ |
| ការបដិសេធដាច់ណាត់ មិនចុះបញ្ជី (TM Absolute Refusal) | ១២ ម៉ាក | ៤៣ ម៉ាក | កើនឡើង៣១<br>ស្មើនឹង២៥%▲ |

## សារាចរកិច្ចការក្រោយចុះបញ្ជីម៉ាកពាណិជ្ជកម្ម

| សកម្មភាពការងារ | ឆ្នាំ២០២២ (១មករា - ២៥ វិច្ឆិកា) | ឆ្នាំ២០២៣ (១មករា - ២៥ វិច្ឆិកា) | កំណើន(%) |
|---|---|---|---|
| កិច្ចការក្រោយចុះបញ្ជីម៉ាកពាណិជ្ជកម្ម | | | |
| បញ្ជាក់អំពីការប្រើប្រាស់ ឬមិនប្រើប្រាស់ម៉ាក | ៣ ៨៩៦ | ៣ ៧១២ | ថយ ៥%▼ |
| ចុះបញ្ជីម៉ាកសាជាថ្មី | ៤ ២១៤ | ៣ ៨២៥ | ថយ ៩%▼ |
| កត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការនាំចូល | ៩៣ម៉ាក | ៨៣ម៉ាក | ថយ ១០%▼ |
| កត់ត្រាកិច្ចសន្យាអាជ្ញាបណ្ណ ឬកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម | ១៤២ម៉ាក | ៥០ម៉ាក | ថយ ៦៤%▼ |
| ការផ្លាស់ប្តូរផ្សេងៗ | ៣ ២៣៧ | ៣ ០៤០ | ថយ ៦%▼ |
| ការធ្វើទុតិយតាវិញ្ញាបនបត្រ | ៦៣៣ | ៧៩៣ | កើន ២៥%▲ |
| ផាកពិន័យចំពោះការស្នើសុំចុះបញ្ជីម៉ាកសាជាថ្មីយឺត | ២៤២ | ៤៣៤ | កើន ៧៩%▲ |

## សារាចរកិច្ចការចុះបញ្ជីម៉ាកអន្តរជាតិ

| សកម្មភាពការងារ | ឆ្នាំ២០២២ (១មករា - ២៥ វិច្ឆិកា) | ឆ្នាំ២០២៣ (១មករា - ២៥ វិច្ឆិកា) | កំណើន(%) |
|---|---|---|---|
| កិច្ចការចុះបញ្ជីតាមប្រព័ន្ធចុះបញ្ជីម៉ាកអន្តរជាតិ (Madrid System) | | | |
| ពាក្យស្នើសុំដែលបានដាក់នៅការិយាល័យដើមនៅកម្ពុជា (Office of Origin) ដើម្បីចុះបញ្ជីម៉ាកតាមប្រព័ន្ធអន្តរជាតិ | ០៤ | ០៩ | ១២៥%▲ |
| ទទួលពាក្យស្នើសុំតាមប្រព័ន្ធចុះបញ្ជីម៉ាកអន្តរជាតិ | ២ ៤៤២ (៥.៦៨៨ ចំណាត់ថ្នាក់) | ២ ៥២០ (៥.៥៥៦ ចំណាត់ថ្នាក់) | ៣%▲ |
| ចុះបញ្ជីម៉ាកតាមប្រព័ន្ធចុះបញ្ជីម៉ាកអន្តរជាតិ | ២ ២៣២ (៤.២២៨ ចំណាត់ថ្នាក់) | ១ ៨៨៤ (៤.១២១ ចំណាត់ថ្នាក់) | -១៥%▼ |
| ការផ្លាស់ប្តូរផ្សេង | ២ ៥៩២ | ២ ៩៨៦ | ១៥%▲ |
| ការចុះបញ្ជីសារឡើងវិញ | ១៣៦ | ២១១ | ៥៥%▲ |
| ការធ្វើប្រតិវេទ៍បញ្ជាក់អំពីការប្រើប្រាស់ឬមិនប្រើប្រាស់ | ១៧៦ | ៥៥២ | ២១៣%▲ |

## សារាចរកិច្ចការដោះស្រាយវិវាទ

| សកម្មភាពការងារ | ឆ្នាំ២០២២ (១មករា - ២៥ វិច្ឆិកា) | ឆ្នាំ២០២៣ (១មករា - ២៥ វិច្ឆិកា) | កំណើន(%) |
|---|---|---|---|
| កិច្ចការវិវាទម៉ាក | | | |
| ការទទួលពាក្យស្នើសុំទប់ស្កាត់ការបំពានម៉ាក វាយតម្លៃអំពីការរំលោភបំពានម៉ាក និងសម្រុះសម្រួលវិវាទ | ៩ | ១០ | ១១%▲ |
| ការទទួលពាក្យស្នើសុំលុបម៉ាក | ៤៦ | ៤៤ | -៤%▼ |

| | | | |
|---|---|---|---|
| លទ្ធផល នៃការស្នើសុំទប់ស្កាត់ការបំពានម៉ាក វាយតម្លៃអំពីការរំលោភបំពានម៉ាក និងសម្រុះសម្រួលវិវាទ | ៦ | ១៨ | ២០០%▲ |
| លទ្ធផល នៃការស្នើសុំលុបម៉ាក | ១៤ | ៣៧ | ១៦៤%▲ |

### ច. ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ, ម៉ាកសមូហភាព និងការងារពាក់ព័ន្ធ

| សកម្មភាពការងារ | លទ្ធផល |
|---|---|
| ***១) ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងស្រុក*** | បានចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញចំនួន ៣ម៉ាក គឺ៖ "**អំបិលកំពតកែប**" "**ទឹកត្រីកំពតកែប**" និង "**បង្កងតាកែវ** ព្រមទាំងបានរៀបចំពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការក្នុងទិវាកម្មសិទ្ធិបញ្ញាពិភពលោក នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ។ |
| ***២) ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអន្តរជាតិ*** | បានចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអន្តរជាតិម៉ាក "COGNAC" និងម៉ាកទទួលបានតាមរយៈការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអន្តរជាតិ (Geneva Act) ពីអង្គការកម្មសិទ្ធបញ្ញាពិភពលោក ចំនួន **២៣ ម៉ាក** |
| ***៣)ការចុះបញ្ជីម៉ាកសមូហភាព*** | បានចុះបញ្ជីម៉ាកសមូហភាពចំនួន ៣ម៉ាក គឺ៖ "**ដូងខ្ទិះបាត់ដំបង**" "**នំបញ្ចុកសៀមរាប**" និង "**ក្រូចថ្លុងកោះពីរ**" ព្រមទាំងបានរៀបចំពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការក្នុងទិវាកម្មសិទ្ធិបញ្ញាពិភពលោក នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ។ |
| ***៤) ការងារពាក់ព័ន្ធ***<br>- ចូលរួមមហាសន្និបាតប្រចាំឆ្នាំរបស់សមាគមលើកកម្ពស់ម្រេចកំពត នៅទីស្នាក់ការសមាគមខេត្តកំពត | - អនុម័តលើរបាយការណ៍ស្តីពី លទ្ធផលដែលសមាគមបានអនុវត្តកន្លងមករបស់សមាគម និងបានស្នើឱ្យសមាគមពិនិត្យលើចំណុចមួយចំនួន ដូចខាងក្រោម៖<br>• ពិនិត្យ និងពិចារណាចំពោះការបន្ថែមស្តង់ដាសរីរាង្គ (Organic) និងទិញឧបករណ៍តេស្តសារជាតុគីមីចល័ត សម្រាប់ប្រើប្រាស់ក្នុងការត្រួតពិនិត្យផ្ទៃក្នុង<br>• បន្តវិធានការពិនិត្យ និងសម្រេចចំពោះករណីឆ្លងសារជាតុគីមីលើដំណាំម្រេចកំពត<br>- រៀបចំនីតិវិធីប្តឹងជំទាស់ទៅសហភាពអឺរ៉ុប ចំពោះករណី**ម្រេចកំពត**ក្លែងក្លាយនាំចេញ និងលក់នៅសហភាពអឺរ៉ុប។ |
| - ពិគ្រោះយោបល់ស្តីពី នីតិវិធីនៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព និងចុះសិក្សាស្រាវជ្រាវ ប្រមូលព័ត៌មានពាក់ព័ន្ធនឹងផលិតផល"***សំបុកត្រចៀកកាំកម្ពុជា***" នៅកោះកុង និងព្រះសីហនុ | - ផ្សព្វផ្សាយស្តីពីទស្សនទាន និងអត្ថប្រយោជន៍ការកសាងកេរ្តិ៍ឈ្មោះម៉ាក ម៉ាកសមូហភាព ឬម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដល់សមាជិកសមាគមនាំចេញសំបុកត្រចៀកកាំកម្ពុជា និងគ្រោងចុះបញ្ជីម៉ាកសមូហភាព "សំបុកត្រចៀកកាំកម្ពុជា" សម្រាប់ខេត្តកោះកុង និងខេត្តព្រះសីហនុ<br>- សហការជាមួយសមាគម ដើម្បីព្រាងសៀវភៅបទបញ្ជារួមគ្រប់គ្រងការប្រើប្រាស់ម៉ាក និងរូបសញ្ញាម៉ាកសមូហភាព "***សំបុកត្រចៀកកាំកម្ពុជា***"។ |
| - ពិគ្រោះយោបល់ជាមួយសមាគមអភិរក្សឃ្មុំព្រៃខេត្តមណ្ឌលគិរី | សហការជាមួយទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (AFD) ក្នុងការ៖<br>• បណ្តុះបណ្តាលគណៈកម្មាធិការប្រតិបត្តិស្តីពីប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង សំបកវេចខ្ចប់ និងយុទ្ធសាស្ត្រទីផ្សារ<br>• កែសម្រួលខ្លឹមសារសៀវភៅបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ "ទឹកឃ្មុំព្រៃមណ្ឌលគិរី" ដើម្បីឱ្យមានភាពងាយស្រួលក្នុងការអនុវត្ត<br>• រៀបចំចុះបញ្ជី "ទឹកឃ្មុំព្រៃមណ្ឌលគិរី" នៅប្រទេសវៀតណាម តាមរយៈការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអន្តរជាតិ (Geneva Act) ។ |

| | |
|---|---|
| - បន្តសហការ និងជំរុញអង្គការ UNIDO ឱ្យបន្តកិច្ចគាំទ្រដល់សមាគមអ្នកផលិតទឹកត្រីកំពតកែប និងវាយតម្លៃលើផលិតផលសក្តានុពល **"ប្រហុកសៀមរាប"** ដើម្បីរៀបចំចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ | តំណាង UNIDO បានឯកភាព ផ្តល់ជំនាញការជាតិ និងអន្តរជាតិ រៀបចំឯកសារចុះបញ្ជី **"ប្រហុកសៀមរាប"** ជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងបន្តកិច្ចគាំទ្រដល់សមាគមអ្នកផលិតទឹកត្រីកំពតកែប ដើម្បីរៀបចំប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ស្តង់ដាអនាម័យ សំបកវេចខ្ចប់ និងការកែសម្រួលសៀវភៅបន្ទុកទឹកត្រីកំពតកែប ដើម្បីបង្កលក្ខណៈងាយស្រួលដល់សមាជិកពាក់ព័ន្ធ ព្រមទាំងរៀបចំដំណើរទស្សនកិច្ចសិក្សាទៅប្រទេសវៀតណាម និងប្រទេសថៃ |
| - ជំរុញអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) ឱ្យបន្តកិច្ចគាំទ្រការកសាងកេរ្តិ៍ឈ្មោះ **"ក្តាមថ្មកោះកុង"** ជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ | អង្គការ WIPO បានទទួលសំណើនេះ ហើយនឹងបន្តពិនិត្យលក្ខណៈបច្ចេកទេសជាក់ស្តែង ដើម្បីធ្វើការវាយតម្លៃផលិតផល «ក្តាមថ្មកោះកុង» ជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ |
| - សហការជាមួយអង្គការ FAO ស្តីពីការកសាងកេរ្តិ៍ឈ្មោះម៉ាក **"សូត្រខ្មែរប្រណិត" "អង្ករបាត់ដំបង ឬថ្មគោល" "ខ្លឹមចន្ទន៍" "ក្រវាញពោធិ៍សាត់" "ស្ពូនថ្នាំងដីកំពង់ឆ្នាំង"** និងផលិតផលម្ហូបអាហារ **"សម្លកកូរ"** និង **"អាម៉ុកខ្មែរ"** | - បានប្រជុំពិភាក្សាជាមួយតំណាងរបស់អង្គការស្បៀងអាហារ និងកសិកម្មពិភពលោក (FAO) និងបានឯកភាពគ្នាក្នុងការរៀបចំសកម្មភាពការងារដូចខាងក្រោម៖<br>• រៀបចំយុទ្ធសាស្ត្រជាតិសម្រាប់ពង្រឹងយន្តការចុះបញ្ជី និងអភិវឌ្ឍន៍ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដើម្បីជំរុញ និងលើកកម្ពស់ផលិតផលសក្តានុពលរបស់កម្ពុជាបន្ថែមទៀត។<br>• កំណត់យកផលិតផលសក្តានុពលចំនួន ៣៖ **"អង្ករកម្ពុជា" "ស្វាយចន្ទីកំពង់ធំ" និង "ទុរេនកំពត"** សិក្សាស្រាវជ្រាវ និងចុះបញ្ជីការពារជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ |
| - រៀបចំចែករំលែកចំណេះដឹងស្តីពីការកសាងកេរ្តិ៍ឈ្មោះម៉ាកសមូហភាព **"ក្រូចថ្លុងកោះពីរ"** និងការទប់ស្កាត់ការក្លែងបន្លំម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ **"ក្រូចថ្លុងកោះទ្រង់"** នៅខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ | - ជំរុញផ្សព្វផ្សាយឱ្យសមាជិកសមាគម និងភាគីពាក់ព័ន្ធអនុវត្តឱ្យបានត្រឹមត្រូវតាមសៀវភៅបទបញ្ញត្តិរួមគ្រប់គ្រងការប្រើប្រាស់ម៉ាកសមូហភាព **"ក្រូចថ្លុងកោះពីរ"** ដើម្បីរក្សាកេរ្តិ៍ឈ្មោះ និងគុណតម្លៃរបស់ផលិតផលនេះនៅលើទីផ្សារ។<br>- ជំរុញឱ្យរដ្ឋបាលខេត្តក្រចេះ និងមន្ទីរពាណិជ្ជកម្មខេត្តក្រចេះ សម្របសម្រួលផ្ទៃក្នុងរបស់គណៈកម្មការប្រតិបត្តិ រួបរួមគ្នាប្រើប្រាស់រូបសញ្ញាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ "ក្រូចថ្លុងកោះទ្រង់" លើសំបកវេចខ្ចប់ និងពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់សមាគម។ |
| - កិច្ចប្រជុំពិភាក្សាជាមួយសមាគមសហព័ន្ធចម្លាក់ប្រាក់ស្ពាន់កម្ពុជា និងមន្ទីរពាណិជ្ជកម្មខេត្តកណ្តាល ស្តីពីវឌ្ឍនភាពនៃការអនុវត្តគម្រោងចុះបញ្ជី **"ចម្លាក់ប្រាក់ស្ពាន់ខេត្តកណ្តាល"** ជាម៉ាកសមូហភាព | បានពិនិត្យ និងសម្រេចលើ ឈ្មោះសមាគមអ្នកផលិតចម្លាក់ប្រាក់-ស្ពាន់កម្ពុជាថ្មី សៀវភៅលក្ខន្តិកៈថ្មី និងសៀវភៅបទបញ្ញត្តិរួមគ្រប់គ្រងការប្រើប្រាស់ម៉ាកសមូហភាព "ចម្លាក់ប្រាក់ស្ពាន់ខេត្តកណ្តាល" និងកំពុងរៀបចំឯកសារចុះបញ្ជីសមាគមអ្នកផលិតចម្លាក់ប្រាក់ស្ពាន់កម្ពុជា នៅក្រសួងមហាផ្ទៃ។ |
| - ប្រជុំពិភាក្សាជាមួយ តំណាងទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) ស្តីពីវឌ្ឍនភាព និងទិសដៅការងារសម្រាប់អនុវត្តគម្រោងថ្នាក់តំបន់ | - អនុម័តរបាយការណ៍អនុវត្តគម្រោងថ្នាក់តំបន់របស់ AFD ដែលគម្រោងនេះបានបន្តគាំទ្រដល់សមាគមលើកកម្ពស់ម្រេចកំពត សមាគមលើកកម្ពស់ស្ករត្នោតកំពង់ស្ពឺ សមាគមអភិរក្សទឹកឃ្មុំព្រៃខេត្តមណ្ឌលគិរី និងអំបិលកំពតកែប។<br>- ជំរុញឱ្យអង្គការនេះសហការជាមួយអង្គការដៃគូ គាំទ្រដល់ការចុះបញ្ជី **"ស្វាយចន្ទីកំពង់ធំ" "អង្ករកម្ពុជា"** និង **"សូត្រភ្នំស្រុក"** ជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។ |
| - ចូលរួមកិច្ចប្រជុំថ្នាក់តំបន់ Asia and Pacific Group (APG) ស្តីពី Diplomatic Conference on Intellectual Property, Genetic | បានផ្តល់ធាតុចូលលើសេចក្តីព្រាងច្បាប់ស្តីពី Genetic Resources and Traditional Knowledge Associate with Genetic Resources ហើយគ្រោងនឹងរៀបចំកិច្ចប្រជុំជាបន្ត |

| | |
|---|---|
| Resources and Traditional Knowledge Associate with Genetic Resources នៅឥណ្ឌូនេស៊ី | បន្ទាប់ដើម្បីពិនិត្យសម្រេចសេចក្តីព្រាងច្បាប់នេះ មុននឹងដាក់អនុម័ត នៅក្នុងមហាសន្និបាតរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO)។ |
| - ចូលរួមសិក្ខាសាលាថ្នាក់តំបន់ឥណ្ឌូប៉ាស៊ីហ្វិកស្តីពីកិច្ចការពារប្រឆាំងនឹងការក្លែងបន្លំផលិតផលម្ហូបអាហារ និងការធ្វើពាណិជ្ជកម្មទំនិញកសិកម្មក្លែងក្លាយ (Enforcement Against Food fraud and Trade Counterfeit Agricultural Goods) នៅប្រទេសថៃ | ជាលទ្ធផលបានពិនិត្យ និងវាយតម្លៃជាក់ស្តែងលើ ៖<br>• ផលប៉ះពាល់នៃការក្លែងបន្លំម្ហូបអាហារក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក<br>• កំណត់លក្ខខណ្ឌក្នុងការទប់ស្កាត់ការក្លែងបន្លំគុណភាព ការដាក់ស្លាកមិនត្រឹមត្រូវ និងការបន្លំប្រភពម្ហូបអាហារ<br>• ការផ្សព្វផ្សាយពាណិជ្ជកម្មមិនពិត ធ្វើឱ្យការាន់ច្រឡំ និងការក្លែងបន្លំម្ហូបអាហារក្នុងតំបន់អាស៊ីអាគ្នេយ៍<br>• ឧបករណ៍កម្មសិទ្ធិបញ្ញាក្នុងការការពារផលិតផលម្ហូបអាហារ ស្រា និងផលិតផលកសិកម្ម (ម៉ាក ម៉ាកសមូហភាព និងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ)<br>• យុទ្ធសាស្ត្រនៃការទប់ស្កាត់ការក្លែងបន្លំ ស្តង់ដាអនាម័យ និងម្ហូបអាហារឆ្លាតវៃ |

## ២.៣. ការនាំចេញ-នាំចូល

### ក. ការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្ម ពាក់ព័ន្ធវិធានដើមកំណើតទំនិញ និងកិច្ចប្រជុំផ្សេងៗ

- ចូលរួមចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ទ្វេភាគី តំបន់ ពហុភាគី និងកិច្ចប្រជុំនានាដែលពាក់ព័ន្ធនឹងវិធានដើមកំណើតទំនិញ ក្នុងនោះរួមមាន៖ ការចរចាកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (អាសិប) ការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-ចិន ការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-កូរ៉េ ការចរចាបន្តសុពលភាពនៃកិច្ចសម្របសម្រួលជំរុញពាណិជ្ជកម្មទ្វេភាគីកម្ពុជា-វៀតណាម និងបន្តការចរចានិងតាមដានការអនុវត្តក្រោមក្របខណ្ឌអាស៊ាន និងដៃគូអាស៊ាន ជាដើម។ល។
- បន្តចូលរួមកិច្ចប្រជុំពាក់ព័ន្ធនឹងវិធានដើមកំណើតទំនិញក្រោមក្របខ័ណ្ឌអាស៊ាន ដៃគូអាស៊ាន និងអាសិបរួមមាន៖
  - កិច្ចប្រជុំអនុក្រុមការងារវិធានដើមកំណើតទំនិញ នៃកិច្ចព្រមព្រៀងអាសិប
  - កិច្ចប្រជុំអនុគណៈកម្មាធិការវិធានដើមកំណើតទំនិញនៃកិច្ចព្រមព្រៀងភាពជាដៃគូគ្រប់ជ្រុងជ្រោយអាស៊ាន និងជប៉ុន
  - កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន
  - កិច្ចប្រជុំអនុគណៈកម្មាធិការវិធានដើមកំណើតទំនិញ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន
  - កិច្ចប្រជុំអនុគណៈកម្មកាធិការវិធានដើមកំណើតទំនិញ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន អូស្ត្រាលី នូវែលហ្សេឡង់
- បន្តកិច្ចពិភាក្សាទ្វេភាគីរវាង កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងថៃ លើបញ្ហាកសិផល
- បានចូលរួមកិច្ចប្រជុំពាក់ព័ន្ធនឹងវិធានដើមកំណើតទំនិញក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន និងកាណាដា។

### ខ. ការចូលរួមកិច្ចប្រជុំ និងសកម្មភាពការងារផ្សេងៗ

- ពិធីសម្ពោធគម្រោងគាំទ្ររបស់ប្រទេសអូស្ត្រាលី ក្នុងការជំរុញការប្រើប្រាស់កិច្ចព្រមព្រៀងសេរី និងសៀវភៅព័ត៌មានពាណិជ្ជកម្ម
- កិច្ចប្រជុំលើកទី៣ គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ

- កិច្ចប្រជុំពិភាក្សាការងារ និងប្រកាសបញ្ចប់ការចរចាកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម
- កម្មវិធីចុះហត្ថលេខាលើ «កិច្ចសម្របសម្រួលជំរុញពាណិជ្ជកម្មទ្វេភាគីរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម សម្រាប់ឆ្នាំ២០២៣-២០២៤»
- កិច្ចជំនួបពិភាក្សាជាមួយគណៈប្រតិភូធនាគារពិភពលោកស្តីពី កម្មវិធីគាំទ្រកិច្ចសម្រួលពាណិជ្ជកម្មកម្ពុជា
- កិច្ចប្រជុំផ្ទៃក្នុងស្តីពីការធ្វើបច្ចុប្បន្នភាព នៃការអនុវត្តម៉ាទ្រីសសកម្មភាពរបស់យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ២០១៩-២០២៣
- កិច្ចប្រជុំគណៈកម្មការគ្រប់គ្រងកិច្ចសន្យាដួលផលិតបន្តក្នុងឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ វាយនភណ្ឌ និងស្បែកជើង
- កិច្ចប្រជុំជាមួយក្រុមបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) លើកម្មវិធី «Cambodia Trade and competitiveness Subprogram 2»
- កិច្ចប្រជុំស្តីពីការពិនិត្យ និងផ្តល់យោបល់លើតារាងសន្យាពាណិជ្ជកម្មទំនិញ និងសេវាកម្មបឋម (Initial Offers) និងតារាងបញ្ជីលើកលែង MFN (MFN Exception List)
- ជំនួបពិភាក្សាការងារជាមួយគណៈប្រតិភូក្រុមប្រឹក្សាធុរកិច្ចសហរដ្ឋអាមេរិក-អាស៊ាន (USABC)
- កិច្ចប្រជុំពិគ្រោះយោបល់ស្តីពី ការពង្រឹងស្ថានភាពសេដ្ឋកិច្ចស្ត្រី និងកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធិភាពនៅកន្លែងការងារ
- កិច្ចប្រជុំប្រឹក្សាយោបល់ស្តីពីការរៀបចំយុទ្ធសាស្ត្រចាកចេញ និងនិរន្តរភាពនៃគម្រោងអភិវឌ្ឍន៍ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- កិច្ចប្រជុំរវាងគណៈកម្មការ និងសមាគមសម្លៀកបំពាក់និងស្បែកជើងអាមេរិក (AAFA) និងក្រុមហ៊ុន VF Corporation
- កិច្ចប្រជុំពិភាក្សាលើការនាំចេញផលិតផលម្រេចពីកម្ពុជា
- កិច្ចប្រជុំអន្តរក្រសួងដើម្បីពិនិត្យលទ្ធភាពបញ្ចូលបន្ថែមមុខទំនិញដែលមានហានិភ័យខ្ពស់ និងកែសម្រួលប្រព្រឹត្តកម្មមួយចំនួន ក្នុងបញ្ជីឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៧ អនក្រ.បក
- កិច្ចប្រជុំពិនិត្យលើឯកសារសេវាកម្មនាំចូល នាំចេញ និងឆ្លងកាត់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីដាក់បញ្ចូលសេវាកម្មទាំងនោះចូលក្នុងប្រព័ន្ធបញ្ចរតែមួយជាតិ
- កិច្ចប្រជុំពិភាក្សាដើម្បីពិនិត្យ និងស្វែងរកដំណោះស្រាយលើផលប៉ះពាល់ពីការកើនឡើង នៃកាកសំណល់សារធាតុពុលគីមីក្នុងម្រេចកម្ពុជា
- កិច្ចប្រជុំអន្តរក្រសួងត្រៀមចូលរួមកិច្ចប្រជុំលើកទី១ នៃគណៈកម្មការរួមនៃកិច្ចព្រមព្រៀង CCFTA
- កិច្ចប្រជុំពិភាក្សារវាងគណៈកម្មការជំនាញ និងអភិវឌ្ឍន៍សូត្រកម្ពុជា និងក្រុមការងាររបស់សម្ព័ន្ធសូត្រអន្តរជាតិ
- កិច្ចប្រជុំអន្តរក្រសួងស្តីពីការលើកកម្ពស់ពាណិជ្ជកម្មឌីជីថលឆ្លងកាត់ព្រំដែនក្នុងបណ្តាប្រទេសសមាជិកអេកម៉ិក
- ជំនួបពិភាក្សាការងារជាមួយតំណាងស្ថានទូតអាមេរិក ប្រចាំព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធនឹងការគ្រប់គ្រងពាណិជ្ជកម្មជាយុទ្ធសាស្ត្រ (Strategic Trade Control)

### គ.ការខារផ្សព្វផ្សាយ និងបង្កើនសមត្ថភាព

- ពិធីសម្ពោធជាផ្លូវការនូវ UK's Developing Countries Trading Schemes In Cambodia
- ការផ្សព្វផ្សាយស្តីពី បទប្បញ្ញត្តិជាតិ និងអន្តរជាតិទាក់ទងនឹងការប្រើប្រាស់ពលកម្មដោយបង្ខំ
- ការផ្សព្វផ្សាយស្តីពីការប្រើប្រាស់ថ្នាលព័ត៌មាន និងទិន្នន័យពាក់ព័ន្ធនឹងពាណិជ្ជកម្ម
- វគ្គបណ្តុះបណ្តាលស្តីពីលក្ខខណ្ឌពាណិជ្ជកម្មអន្តរជាតិ ឯកសារបញ្ជូនទំនិញ និងការដឹកជញ្ជូនរួមបញ្ចូលគ្នា និងពហុមធ្យោបាយ។

## ឃ. ការងារពាណិជ្ជកម្មប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស

- ចុះត្រួតពិនិត្យនិងវាយតម្លៃអនុលោមភាព និងធ្វើការអង្កេតលើដើមកំណើតទំនិញ ដើម្បីទទួលបានភាពអនុគ្រោះពាណិជ្ជកម្មនិងណែនាំអំពីនីតិវិធី និងឯកសារពាក់ព័ន្ធក្នុងការស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញតាមប្រព័ន្ធស្វ័យប្រវត្តកម្ម
- ផ្សព្វផ្សាយពីវិធានដើមកំណើតទំនិញ ការប្រើប្រាស់ប្រព័ន្ធចុះបញ្ជីអ្នកនាំចេញ (Registered Exporter System-REX) និងណែនាំពីបែបបទស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញគ្រប់ទម្រង់ តាមប្រព័ន្ធស្វ័យប្រវត្តកម្ម
- សហការ និងចូលរួមជាមួយតំណាងការិយាល័យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងការិយាល័យតំណាង អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ធ្វើអធិការកិច្ចរោងចក្រ ត្រួតពិនិត្យការនាំចូលវត្ថុធាតុដើម និងពិនិត្យទំនិញមុននាំចេញ
- សហការជាមួយនឹងរោងចក្រ និងនាយកដ្ឋាននាំចេញ-នាំចូល ដើម្បីផ្តល់ឯកសារសេគ្គីកម្មនៅពេលដែលមានការស្នើសុំផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃវិធានដើមទំនិញពីប្រទេសនាំចូល
- សហការ និងចូលរួមជាមួយការិយាល័យតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តំណាងការិយាល័យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងការិយាល័យតំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាដោះស្រាយវិវាទកម្មករ និងម្ចាស់រោងចក្រ
- ចូលរួមកិច្ចប្រជុំប្រចាំខែ ដែលរៀបចំដោយការិយាល័យតំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាពាក់ព័ន្ធនឹងដំណើរការនៃរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ច្បាប់ នីតិវិធី បែបបទ និងបញ្ហាផ្សេងៗទៀត
- បានផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការនាំចេញទំនិញ
- ចូលរួមកិច្ចប្រជុំប្រចាំខែ និងសិក្ខាសាលាផ្សេងៗ ពាក់ព័ន្ធទៅនឹងវិធានដើមកំណើតទំនិញ
- បានចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ និងឯកសារឧបសម្ព័ន្ធជូនដល់អ្នកនាំចេញ។

## ឆ-ការងារផ្តល់សេវាសាធារណៈ:

### ពាណិជ្ជកម្មជាមួយដៃគូសំខាន់ៗ

(ឯកតា៖ លានដុល្លារអាមេរិក)

| ល.រ | ទិសដៅនាំចេញ | រយៈពេល ១១ខែ ឆ្នាំ២០២២ | | | រយៈពេល ១១ខែ ឆ្នាំ២០២៣ | | | បម្រែបម្រួល (%) | | |
|---|---|---|---|---|---|---|---|---|---|---|
| | | នាំចេញ | នាំចូល | ទំហំពាណិជ្ជកម្ម | នាំចេញ | នាំចូល | ទំហំពាណិជ្ជកម្ម | នាំចេញ | នាំចូល | ទំហំពាណិជ្ជកម្ម |
| 1 | **ពិភពលោក** | **២០.៤៤៨** | **២៧.៧៥៧** | **៤៨.២០៤** | **២១.២៩២** | **២២.២២៣** | **៤៣.៥១៦** | **៤.០៨%▲** | **-១៩.៩១%▼** | **-៩.៧៣%▼** |
| 2 | អាមេរិក | ៨.២១៨ | ២៩៣ | ៨.៥១០ | ៨.១៤៤ | ២២៣ | ៨.៣៦៧ | -០.៨៩%▼ | -២៣.៩៧%▼ | -១.៦៩%▼ |
| 3 | ជប៉ុន | ១.០៦៩ | ៧២០ | ១.៧៨៩ | ១.០៦៦ | ៥៧៣ | ១.៦៣៩ | -០.៣៣%▼ | -២០.៣៦%▼ | -៨.៣៩%▼ |
| 4 | ចិន | ១.១០៩ | ៩.៤៧០ | ១០.៥៧៩ | ១.៣១៥ | ៩.៧៦៣ | ១១.០៧៨ | ១៨.៥១%▲ | ៣.១០%▲ | ៤.៧២%▲ |
| 5 | **ចក្រភពអង់គ្លេស** | **៨២៣** | **៨០** | **៩០៣** | **៧២៧** | **៧៤** | **៨០១** | **-១១.៦២%▼** | **-៧.៧០%▼** | **-១១.២៨%▼** |
| 6 | កាណាដា | ១.០២៦ | ៣១ | ១.០៥៧ | ៧៧៤ | ៦១ | ៨៣៥ | -២៤.៥៦%▼ | ៩៦.៥២%▲ | -២០.៩៨%▼ |
| 7 | កូរ៉េ | ២០៧ | ៥០៤ | ៧១១ | ២៥៣ | ៤៣០ | ៦៨៣ | ២២.៣៥%▲ | -១៤.៦៩%▼ | -៣.៩០%▼ |
| 8 | អូស្ត្រាលី | ៣៤៦ | ១៣២ | ៤៧៨ | ៣២៥ | ១២៧ | ៤៥២ | -៦.០៥%▼ | -៤.២៣%▼ | -៥.៥៤%▼ |
| 9 | ឥណ្ឌា | ១៧១ | ២២៨ | ៣៩៩ | ២៦៥ | ១៧៩ | ៤៤៣ | ៥៥.១២%▲ | -២១.៧៨%▼ | ១១.០៨%▲ |
| 10 | នូវែលសេឡង់ | ១៩ | ២០ | ៣៨ | ១៦ | ២២ | ៣៨ | -១៥.៤៣%▼ | ១០.៦៨%▲ | -១.៩៩%▼ |
| 11 | **អាស៊ាន** | **២.៩២១** | **១១.៨៨៩** | **១៤.៨១០** | **៤.២៤៤** | **៨.៤៣៦** | **១២.៦៨០** | **៤៥.៣០%▲** | **-២៩.០៤%▼** | **-១៤.៣៨%▼** |
| | ថៃ | ៧៥៦ | ៣.៥៤២ | ៤.២៩៨ | ៧៩៧ | ២.៦៤៣ | ៣.៤៤០ | ៥.៤០%▲ | -២៥.៣៨%▼ | -១៩.៩៦%▼ |
| | វៀតណាម | ១.៨៩៥ | ៣.៦១៧ | ៥.៥១២ | ២.៦១១ | ៣.២៦៦ | ៥.៨៧៨ | ៣៧.៨២%▲ | -៩.៧០%▼ | ៦.៦៣%▲ |
| 12 | **សហភាពអឺរ៉ុប (EU)** | **៣.៧១៩** | **៧៥១** | **៤.៤៦៩** | **៣.៣៤៨** | **៨៩៨** | **៤.២៤៦** | **-៩.៩៧%▼** | **១៩.៦០%▲** | **-៥.០១%▼** |
| | បែលហ្ស៊ិក | ៥៩៦ | ៧៩ | ៦៧៥ | ៣៩៨ | ៥១ | ៤៤៩ | -៣៣.១៩%▼ | -៣៥.៤៩%▼ | -៣៣.៤៦%▼ |
| | បារាំង | ៣៨៩ | ១១១ | ៥០០ | ៣៣៣ | ១៤៧ | ៤៧៩ | -១៤.៥១%▼ | ៣១.៩៥%▲ | -៤.១៨%▼ |
| | អាល្លឺម៉ង់ | ១.០០១ | ១៥៣ | ១.១៥៤ | ៧៤២ | ១៨៥ | ៩២៧ | -២៥.៨៨%▼ | ២០.៩៥%▲ | -១៩.៦៦%▼ |
| | ហូឡង់ | ៥០៥ | ៣៨ | ៥៤៣ | ៥០៩ | ៤០ | ៥៤៩ | ០.៩៥%▲ | ២.៧៧%▲ | ១.០៧%▲ |
| 13 | **សហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី** | **១២** | **៤៤** | **៥៦** | **៤** | **២២** | **២៦** | **-៦៤.៣១%▼** | **-៥០.៧៣%▼** | **-៥៣.៦០%▼** |
| 14 | **អេមីរ៉ាត់អារ៉ាប់រួម (UAE)** | **៦៣** | **៣៥** | **៩៨** | **៦៥** | **១២** | **៧៨** | **៣.១១%▲** | **-៦៣.៩៦%▼** | **-២០.៥២%▼** |
| 15 | **ប្រទេសផ្សេងៗ** | **៧៥៦** | **៣.៥៥០** | **៤.៣០៧** | **៧៤៧** | **១.៤០៣** | **២.១៥០** | **-១.២៦%▼** | **-៦០.៤៧%▼** | **-៥០.០៧%▼** |


ស្ថិតិនាំចេញទំនិញទៅកាន់ទីផ្សារសំខាន់ៗ រយៈពេល ១១ខែ ឆ្នាំ២០២៣
ឯកតា៖ លានដុល្លារអាមេរិក
ចិន 1,315 6.17%
ចក្រភពអង់គ្លេស 727 3.41%
កាណាដា 774 3.63%
កូរ៉េ 253 1.19%
អូស្ត្រាលី 325 1.53%
ឥណ្ឌា 265 1.24%
នូវែលសេឡង់ 16 0.07%
ជប៉ុន 1,066 5.01%
អាស៊ាន 4,244 19.93%
អាមេរិក 8,144 38.25%
សហភាពអឺរ៉ុប ( EU )
3,348 15.72%
ប្រទេសផ្សេងៗ 747 3.51%
សហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី 4 0.02%
អេមីរ៉ាត់អារ៉ាប់រួម ( UAE ) 65 0.31%


ស្ថិតិនាំចូលទំនិញពីទីផ្សារសំខាន់ៗ រយៈពេល ១១ខែ ឆ្នាំ២០២៣
ឯកតា៖ លានដុល្លារអាមេរិក
កាណាដា 61 0.28%
កូរ៉េ 430 1.93%
អូស្ត្រាលី 127 0.57%
ចក្រភពអង់គ្លេស 74 0.33%
ឥណ្ឌា 179 0.80%
នូវែលសេឡង់ 22 0.10%
អាស៊ាន 8,436
37.96%
ចិន 9,763 43.93%
សហភាពអឺរ៉ុប ( EU ) 898 4.04%
សហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី 22 0.10%
ជប៉ុន 573 2.58%
អេមីរ៉ាត់អារ៉ាប់រួម ( UAE ) 12 0.06%
អាមេរិក 223 1.00%
ប្រទេសផ្សេងៗ 1,403 6.32%

## ស្ថិតិនាំចេញមុខទំនិញសំខាន់ៗ

*(ឯកតា៖ លានដុល្លារអាមេរិក)*

| ល.រ | មុខទំនិញ | ១១ខែ ឆ្នាំ២០២២ | ១១ខែ ឆ្នាំ២០២៣ | បម្រែបម្រួល | |
|---|---|---|---|---|---|
| | | ទឹកប្រាក់នាំចេញ | ទឹកប្រាក់នាំចេញ | ទឹកប្រាក់ | (%) |
| ១ | សម្លៀកបំពាក់ | ៨.៣៦៧ | ៧.១០៦ | -១.២៦១▼ | -១៥.០៧%▼ |
| ២ | វាយនភណ្ឌ | ១២១ | ១១៨ | -៣▼ | -២.៨៦%▼ |
| ៣ | ស្បែកជើង | ១.៥៧៣ | ១.២១៤ | -៣៥៩▼ | -២២.៨៤%▼ |
| ៤ | សម្ភារៈធ្វើដំណើរ | ១.៦៣៦ | ១.៤៧២ | -១៦៤▼ | -១០.០៣%▼ |
| ៥ | កង់ | ៨៤២ | ៣៩៩ | -៤៤៤▼ | -៥២.៦៧%▼ |
| ៦ | ម៉ាស៊ីនបរិធាន និងសម្ភារៈអគ្គិសនី | ១.៧០០ | ២.៩៤៤ | ១.២៤៤▲ | ៧៣.១៩%▲ |
| ៧ | ស្រូវ | ៦៥៨ | ១.០៩៣ | ៤៣៥▲ | ៦៦.១៣%▲ |
| ៨ | អង្ករ | ៣៦៣ | ៤២២ | ៥៩▲ | ១៦.៣០%▲ |
| ៩ | ចេក | ២០០ | ១៥៦ | -៤៣▼ | -២១.៧០%▼ |
| ១០ | ស្វាយចន្ទី | ២៥៨ | ៣៨១ | ១២៣▲ | ៤៧.៦៦%▲ |
| ១១ | ស្វាយ | ១០៥ | ១០២ | -៣▼ | -៣.១៩%▼ |
| ១២ | ដំឡូងមី | ៣៦០ | ៥៤៩ | ១៨៩▲ | ៥២.៦៣%▲ |
| ១៣ | ជ័រកៅស៊ូ | ៣៤៣ | ៤៥២ | ១០៩▲ | ៣១.៨៧%▲ |
| ១៤ | ផ្លែមៀន | ២ | ១៩ | ១៧▲ | ៩៥៦.៥៦%▲ |
| ១៥ | ម្រេច | ៤៦ | ១៤ | -៣២▼ | -៦៩.៦១%▼ |
| ១៦ | ស្ករអំពៅ | ៤២ | ១០៥ | ៦២▲ | ១៤៨.០០%▲ |
| ១៧ | ពោត | ០.៤៤ | ២៩ | ២៨▲ | ៦៤២៨.៣៣%▲ |
| ១៨ | មុខទំនិញផ្សេងទៀត | ៣.៨៤៣ | ៤.៧២១ | ៨៧៨▲ | ២២.៨៣%▲ |
| **សរុប៖** | | **២០.៤៥៨** | **២១.២៩២** | **៨៣៥▲** | **៤.០៨%▲** |

## ស្ថិតិនាំចូលមុខទំនិញសំខាន់ៗ

*(ឯកតា៖ លានដុល្លារអាមេរិក)*

| ល.រ | មុខទំនិញ | ១១ខែ ឆ្នាំ២០២២ | ១១ខែ ឆ្នាំ២០២៣ | បម្រែបម្រួល | |
|---|---|---|---|---|---|
| | | ទឹកប្រាក់នាំចូល | ទឹកប្រាក់នាំចូល | ទឹកប្រាក់ | (%) |
| ១ | វាយនភ័ណ្ឌ | ៥.០៤៦ | ៤.៦២០ | -៤២៥▼ | -៨.៤៣%▼ |
| ២ | សម្ភារៈសំណង់ | ១.១៩៩ | ១.២០៩ | ១០▲ | ០.៨០%▲ |
| ៣ | ដែក និងដែកថែប | ៤៣៣ | ៤៤៧ | ១៤▲ | ៣.១៩%▲ |
| ៤ | ស៊ីម៉ង់ត៍ | ២៣ | ១៨ | -៥▼ | -២១.១៣%▼ |
| ៥ | ទឹក | ២២២ | ២១៤ | -៨▼ | -៣.៤៥%▼ |
| ៦ | ស្រាបៀរ និងស្រាចំរុះ | ២៤ | ១៨ | -៥▼ | -២២.៥៦%▼ |
| ៧ | រថយន្ត | ១.៣៧៦ | ៨៤៧ | -៥២៩▼ | -៣៨.៤៥%▼ |
| ៨ | ផលិតផលឱសថ និងអាហារបំប៉ន | ៣៧០ | ៣២៣ | -៤៧▼ | -១២.៦៦%▼ |
| ៩ | ជីកសិកម្ម និងថ្នាំសម្លាប់សត្វល្អិតឬស្មៅ | ៤៣៥ | ៤៣៥ | ០.៣១▲ | ០.០៧%▲ |
| ១០ | គ្រឿងអេឡិចត្រូនិច និងសម្ភារៈអគ្គិសនី | ២.៥៨៩ | ២.៥៧១ | -១៨▼ | -០.៧១%▼ |
| ១១ | ប្រេងម៉ាស៊ូត ( D.O ) | ១.៤០៥ | ១.១៨៥ | -២២០▼ | -១៥.៦៥%▼ |
| ១២ | ប្រេងសាំង ( E.A ) | ៧៧៧ | ៧៧៤ | -៣▼ | -០.៤០%▼ |
| ១៣ | គ្រឿងសម្អាង ឬគ្រឿងសម្អាតកាយ | ១០៧ | ១០៦ | -១▼ | -១.៣៧%▼ |
| ១៤ | បន្លែ ផ្លែឈើ | ២៤ | ៤៦ | ២៣▲ | ៩៤.៩៧%▲ |
| ១៥ | គ្រឿងឧបភោគ បរិភោគ | ៤៥០ | ៥១៤ | ៦៤▲ | ១៤.១៤%▲ |
| ១៦ | មុខទំនិញផ្សេងទៀត | ១៣.២៦៦ | ៨.៨៩៤ | -៤.៣៧២▼ | -៣២.៩៦%▼ |
| **សរុប៖** | | **២៧.៧៤៧** | **២២.២២៣** | **-៥.៥២៤▼** | **-១៩.៩១%▼** |

**ស្ថិតិនាំចេញមុខទំនិញសំខាន់ៗ រយៈពេល ១១ខែ ឆ្នាំ២០២៣**




**ស្ថិតិនាំចូលមុខទំនិញសំខាន់ៗ រយៈពេល ១១ខែ ឆ្នាំ២០២៣**

ឯកតា៖ លានដុល្លារអាម៉េរិក



## ការចុះបញ្ជីសុំសិទ្ធិនាំចេញតាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម

| ល.រ | រោងចក្រ-ក្រុមហ៊ុន | ឆ្នាំ២០១៩ | | ឆ្នាំ២០២០ | | ឆ្នាំ២០២១ | | ឆ្នាំ២០២២ | | ១១ខែ ឆ្នាំ២០២៣ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួន | ចំនួនកម្មករ | ចំនួន | ចំនួនកម្មករ | ចំនួន | ចំនួនកម្មករ | ចំនួន | ចំនួនកម្មករ | ចំនួន | ចំនួនកម្មករ |
| ១ | រោងចក្រកាត់ដេរសម្លៀកបំពាក់ | ៥៣ | ២៦.៦១៩ | ៥០ | ១៤.១៤៥ | ៣៨ | ១៥.០៧៦ | ៦៦ | ៣១.៦១៦ | ៦០ | ២៣.៣២៣ |
| ២ | រោងចក្រកាត់ដេរស្បែកជើង | ៧ | ៣.៨០៦ | ៩ | ៩.០៥៧ | ១២ | ៦.៣៦៥ | ៣ | ៨៤១ | ១៣ | ១៨.០៧១ |
| ៣ | រោងចក្រផលិតកាបូប | ៣៣ | ៨.៥៩២ | ១៨ | ៣.៧៧១ | ១៥ | ៣.៧៨៤ | ១៤ | ៣.៦៥៣ | ៦ | ១.២១២ |
| ៤ | រោងចក្រផ្សេងៗ | ៥៩ | ៥.៧៥២ | ៨៣ | ៨.៨៩៤ | ៤៨ | ៦.៣៩៨ | ៣៩ | ៦.៩១៦ | ៦៥ | ៧.៨៣៥ |
| ៥ | ក្រុមហ៊ុនផ្សេងៗ | ១១៥ | | ៩៩ | | ៨១ | | ៩៣ | | ១០៤ | |
| **សរុប៖** | | **២៦៧** | **៤៤.៧៦៩** | **២៥៩** | **៣៥.៨៦៧** | **១៩៤** | **៣១.៦២៣** | **២១៥** | **៤៣.០២៦** | **២៤៨** | **៥០.៤៤១** |

## ចុះបញ្ជីស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញតាមប្រព័ន្ធអេឡិចត្រូនិក

| ល.រ | ប្រភេទ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ឆ្នាំ២០២២ | ១១ខែ ឆ្នាំ២០២៣ |
|---|---|---|---|---|---|---|
| ១ | ចុះបញ្ជីស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញតាមប្រព័ន្ធអេឡិចត្រូនិកថ្មី | ២៩៩ | ២៤០ | ១៤៩ | ១៩០ | ២៣៧ |
| ២ | ចុះបញ្ជីស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញតាមប្រព័ន្ធអេឡិចត្រូនិកសារឡើងវិញ | ៧៧៣ | ៩៦២ | ៦១១ | ១.១០០ | ១.០៥៥ |
| **សរុប៖** | | **១.០៧២** | **១.២០២** | **៧៦០** | **១.២៩០** | **១.២៩២** |

## ស្ថិតិនៃការផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមទំនិញ

*(ឯកតា៖ ចំនួនច្បាប់)*

| ល.រ | ទម្រង់ CO | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ឆ្នាំ២០២២ | ១១ខែ ឆ្នាំ២០២៣ |
|---|---|---|---|---|---|---|
| ១ | A | ១៦១.១៦៦ | ៤១.៣៧៧ | ៧៧.៥៧៨ | ៧៧.៨៦៨ | ៦១.១៥៤ |
| ២ | AB | ១២.៥៣៩ | ១០.៤០៥ | ១០.៦០៦ | ១២.៥៧៨ | ៩.៣៧៣ |
| ៣ | N | ៤៦.០២២ | ៤៨.២៨៣ | ៥៣.២៧៩ | ៥៧.០៤៧ | ៤៤.៤៩៤ |
| ៤ | AANZ | ៣.៣៤៤ | ៤.២៥៤ | ៧.០២២ | ៩.២៧៣ | ៦.៦៩៣ |
| ៥ | AI | ៥.៥៤១ | ៤.១៧៩ | ៣.៧១៥ | ៥.០០៩ | ៥.១៦៣ |
| ៦ | AJ | ៥.៧៦៨ | ២.៤៦២ | ២.៦៥៣ | ៣.៣២៩ | ២.៥៨៩ |

| | | | | | | |
|---|---|---|---|---|---|---|
| ៧ | AK | ៧.១៨៥ | ៦.០២៨ | ៦.៣០១ | ៧.៣៩៨ | ៦.២៣៦ |
| ៨ | CRF | ២០៣.៦០៩ | ៣១៩.២៣៨ | ២៩៨.៦៣៥ | ៣៣៧.៣២៥ | ២៨០.៧៥១ |
| ៩ | D | ៣៤.៧៦១ | ៣៣.៥២៨ | ៤៨.៩៨៣ | ៦៨.៦០៧ | ៥៦.៣០៩ |
| ១០ | DFTPILDC | ២៥២ | ២៣០ | ៤០១ | ៤៦៨ | ៤០២ |
| ១១ | E | ១៥.០៤២ | ១៩.៣៦១ | ២៨.៣៤៥ | ៣២.៤៧៧ | ៣៤.៤២៧ |
| ១២ | KLDC | ៨៣៤ | ៨៨៨ | ១.១៦៨ | ១.១៣៦ | ៥៥៣ |
| ១៣ | SPT | - | - | - | - | - |
| ១៤ | S | ១៣ | ៣៦៣ | ១៩៨ | ៣៥ | ៧ |
| ១៥ | CHILE | - | ៥៨ | ២៨៤ | ៤១៨ | ២៦៧ |
| ១៦ | AHK | - | - | - | ២ | - |
| ១៧ | RCEP | - | - | - | ៣៥៧ | ៦៤៣ |
| ១៨ | CCFTA | - | - | - | - | ១ |
| ១៩ | CKFTA | - | - | - | ៣៦ | ១០២៤ |
| ២០ | ANNEX | - | ២ | ២៩ | ១២ | ១៩ |
| **TOTAL:** | | **៤៩៦.០៧៦** | **៤៩០.៦៥៦** | **៥៣៩.១៩៧** | **៦១៣.៣៧៥** | **៥១០.១០៥** |

## ប្រភេទអាជ្ញាបណ្ណ និងលិខិតជូនដំណឹងសុំដឹកជញ្ជូនទំនិញឆ្លងកាត់

*(ឯកតា៖ លានដុល្លារអាមេរិក)*

| ល.រ | ប្រភេទ | ឆ្នាំ២០១៩ | | ឆ្នាំ២០២០ | | ឆ្នាំ២០២១ | | ឆ្នាំ២០២២ | | ១១ខែ ឆ្នាំ២០២៣ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួន | ទឹកប្រាក់ | ចំនួន | ទឹកប្រាក់ | ចំនួន | ទឹកប្រាក់ | ចំនួន | ទឹកប្រាក់ | ចំនួន | ទឹកប្រាក់ |
| ១ | អាជ្ញាប័ណ្ណនាំចេញ | ៣៤ | ៣ | ៥៦ | ៥ | ៥៥ | ៦ | ៣៦ | ៣ | ៣១ | ២ |
| ២ | ពន្យាអាជ្ញាប័ណ្ណនាំចេញ | ៩ | | ២៣ | | ២៣ | | ១៤ | | ៦ | |
| ៣ | អាជ្ញាប័ណ្ណនាំចូល | ៩ | ១ | ១០ | ១ | ១១ | ១ | ៨ | ០.៩៧ | ៦ | ០.៤៧ |
| ៤ | ពន្យាអាជ្ញាប័ណ្ណនាំចូល | ៤ | | ១ | | ៥ | | ២ | | ១ | |
| ៥ | លិខិតជូនដំណឹង | ១៧ | | ៣៤ | | ៣៣ | | ៦៨ | | ១៥ | |

## ការនាំចេញ-នាំចូល ត្បូងពេជ្រមិនទាន់កែច្នៃ និងសល់ពីការកែច្នៃ

*(ឯកតា៖ លានដុល្លារអាមេរិក)*

| ល.រ | លិខិតបញ្ជាក់ | ឆ្នាំ២០១៩ | | ឆ្នាំ២០២០ | | ឆ្នាំ២០២១ | | ឆ្នាំ២០២២ | | ១១ខែ ឆ្នាំ២០២៣ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួន | ទឹកប្រាក់ | ចំនួន | ទឹកប្រាក់ | ចំនួន | ទឹកប្រាក់ | ចំនួន | ទឹកប្រាក់ | ចំនួន | ទឹកប្រាក់ |
| ១ | នាំចូល | ៥៥ | ៤៩ | ២៣ | ២៤ | ១៦ | ១៨ | ២២ | ៤៩ | ២៣ | ៧៥ |
| ២ | នាំចេញ | ៣៩ | ៤៣ | ២២ | ២០ | ២៧ | ១១ | ៣៧ | ២៥ | ៤៩ | ៣៩ |

**ពិនិត្យ និងផ្ទៀងផ្ទាត់អនុលោមភាពវិធានដើមកំណើតទំនិញ**

| ប្រភេទ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ឆ្នាំ២០២២ | ១១ខែ ឆ្នាំ ២០២៣ |
|---|---|---|---|---|---|
| បានពិនិត្យ និងផ្ទៀងផ្ទាត់អនុលោមភាពវិធានដើមកំណើតទំនិញគ្រប់ទម្រង់ | ៣២ | ៧២ | ៤៩ | ៣៥ | ២២ |

## ៣. ការងារពាណិជ្ជកម្មក្នុងប្រទេស[2]

### ៣.១. ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងការតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការ ដែលមានកិច្ចធានា

### ក. ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

| ល.រ | ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ | លទ្ធផល |
|---|---|---|
| **ច្បាប់** | | |
| ១ | ច្បាប់ស្តីពីវិធានដើមកំណើតទំនិញ | បានឡាយព្រះហស្តលេខាដាក់ឱ្យប្រើប្រាស់ កាលពីថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣ |
| **អនុក្រឹត្យ** | | |
| ១ | អនុក្រឹត្យលេខ២៦០ អនក្រ.បក ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការរួមបញ្ចូលគ្នានៃធុរកិច្ច | បានទទួលការអនុម័ត និងដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី ៦ ខែមីនា ឆ្នាំ ២០២៣ |
| ២ | អនុក្រឹត្យលេខ១៣ អនក្រ.បក ស្តីពី លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអង្កេតដាននិងការដកហូតម្ហូបអាហារ | បានទទួលការអនុម័ត និងដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី ៦ខែមករា ឆ្នាំ ២០២៣ |
| ៣ | អនុក្រឹត្យលេខ ៣៣៧អនក្រ.បក ស្តីពីលក្ខណៈវិនិច្ឆ័យនៃមន្ទីរពិសោធន៍យោងនិងមន្ទីរពិសោធន៍ផ្លូវការ | បានទទួលការអនុម័ត និងដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ២០២៣ |
| **ប្រកាសអន្តរក្រសួង** | | |
| ១ | ប្រកាសអន្តរក្រសួងលេខ ៤១០ សហវ.ប្រក.អទច ស្តីពីការពិន័យអន្តរការណ៍ចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិ នៃច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ | បានចុះហត្ថលេខារួមគ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួចបានដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ |
| ២ | ប្រកាសអន្តរក្រសួងលេខ០៤២ កយ.ពណ.ប្រក/២៣ ស្តីពីនីតិវិធីនៃការពិន័យអន្តរការណ៍ លើអំពើល្មើសពាក់ព័ន្ធនឹងច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ | បានចុះហត្ថលេខារួមគ្នាជាមួយក្រសួងយុត្តិធម៌ រួចបានដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ |
| ៣ | ប្រកាសអន្តរក្រសួងលេខ១៦៧ សហវ.ប្រក.អទច ស្តីពីការផ្តល់លិខិតបញ្ជាក់អនុលោមភាព នៃការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិងសេវា | បានចុះហត្ថលេខារួមគ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួចបានដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ |

[2] ប្រភព៖ អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស

| | | |
|---|---|---|
| ៤ | ប្រកាសអន្តរក្រសួងលេខ១៦៩សហវ.ប្រក.អទច ស្តីពីការបែងចែកចំណូលពីការផ្តល់លិខិតបញ្ជាក់ អនុលោមភាពនៃការផ្សាយពាណិជ្ជកម្មលើ ផលិតផលទំនិញនិងសេវា និងការពិន័យចំពោះ បុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការ ប្រកួតប្រជែង | បានចុះហត្ថលេខារួមគ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួចបាន ដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ |
| ៥ | ប្រកាសអន្តរក្រសួងលេខ០៤១ កយ.ពណ.ប្រក/២៣ ស្តីពី**នីតិវិធី**នៃការផាកពិន័យជាប្រាក់លើអំពើល្មើស នឹងច្បាប់ស្តីពីការប្រកួតប្រជែង | បានចុះហត្ថលេខារួមគ្នាជាមួយក្រសួងយុត្តិធម៌ រួចបានដាក់ឱ្យប្រើ ប្រាស់នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ |
| ៦ | ប្រកាសអន្តរក្រសួងលេខ១៦៨ សហវ.ប្រក.អទច ស្តីពីការផាកពិន័យជាប្រាក់ចំពោះបុគ្គលប្រព្រឹត្ត ល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការប្រកួតប្រជែង | បានចុះហត្ថលេខារួមគ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួចបាន ដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ |
| ៧ | ប្រកាសអន្តរក្រសួងលេខ៤១១ សហវ.ប្រក.អទច ស្តីពីការ**ផ្តល់សេវាសាធារណៈ**លើការជូនដំណឹង ការចេញវិញ្ញាបនបត្រជាមុន និងការចុះបញ្ជីការរួម បញ្ចូលគ្នានៃធុរកិច្ច | បានចុះហត្ថលេខារួមគ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួចបាន ដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ |
| ៨ | ប្រកាសអន្តរក្រសួងលេខ៤១២ សហវ.ប្រក.អទច ស្តីពីការ**បែងចែកចំណូលពីសេវាសាធារណៈ**លើការ ជូនដំណឹង ការចេញវិញ្ញាបនបត្រជាមុន និងការចុះ បញ្ជីការរួមបញ្ចូលគ្នានៃធុរកិច្ច និងការពិន័យចំពោះ បុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពី សុវត្ថិភាពម្ហូបអាហារ | បានចុះហត្ថលេខារួមគ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួចបាន ដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ |
| ៩ | ប្រកាសអន្តរក្រសួងលេខ១០៩ សហវ.ប្រក.អទច ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម លើការគ្រប់គ្រងផលិតផលហាឡាល | បានចុះហត្ថលេខារួមគ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួចបាន ដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៣ |
| ១០ | ប្រកាសអន្តរក្រសួងលេខ១១០ សហវ.ប្រក.អទច ស្តីពីការបែងចែកចំណូលពីសេវាសាធារណៈលើការ គ្រប់គ្រងផលិតផលហាឡាល | បានចុះហត្ថលេខារួមគ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួចបាន ដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៣ |
| **ប្រកាស** | | |
| ១ | ប្រកាស ស្តីពី "ការអនុវត្តសិទ្ធិរបស់គូភាគីនៃ ប្រតិបត្តិការដែលកិច្ចធានា" | បានចុះហត្ថលេខារួចហើយដោយថ្នាក់ដឹកនាំ លើប្រកាសលេខ ៣១៩ ព.ណ.នគក.ប្រកចុះថ្ងៃទី២៣ តុលា ២០២៣ |
| ២ | ប្រកាសលេខ០៨០ ពណ.អ.កបប.ប្រក ស្តីពីទម្រង់ និងបែបបទនៃការដកហូតម្ហូបអាហារគ្មានសុវត្ថិភាព ឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស | បានចុះហត្ថលេខា និងដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ២០២៣ |
| ៣ | ប្រកាសលេខ១៤៧ ព.ណ.អ.កបប.ប្រក ស្តីពីការ ចាត់ចែងចំណែកប្រាក់រង្វាន់លើកទឹកចិត្តរបស់ ក្រសួងពាណិជ្ជកម្ម ដែលទទួលបានពីការផ្តល់ | បានចុះហត្ថលេខា និងដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០២៣ |

| | | |
|---|---|---|
| | លិខិតបញ្ជាក់អនុលោមភាពនៃការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិងសេវា និងការពិន័យចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការប្រកួតប្រជែង | |
| ៤ | ប្រកាសលេខ២០៧៩ ព.ណ.អ.កបប.ប្រក ស្តីពី ***បែបបទនិងនីតិវិធី***នៃការចេញវិធានការផ្អាកជាបណ្តោះអាសន្ននិង/ឬសេចក្តីសម្រេចរបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា | បានចុះហត្ថលេខា និងដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ |
| ៥ | ប្រកាសលេខ១៧៧ ព.ណអ.កបប.ប្រក ស្តីពី ***លក្ខខណ្ឌនិងនីតិវិធី***នៃការចុះបញ្ជីការរួមបញ្ចូលគ្នានៃធុរកិច្ចដែលត្រូវជូនដំណឹងជាមុន | បានចុះហត្ថលេខា និងដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ២០២៣ |
| ៦ | ប្រកាសលេខ១៧៨ ព.ណ.អ.កបប.ប្រក ស្តីពី ***នីតិវិធីនៃការជូនដំណឹងជាក្រោយ***នៃការរួមបញ្ចូលគ្នានៃធុរកិច្ច | បានចុះហត្ថលេខា និងដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ២០២៣ |
| ៧ | ប្រកាសលេខ២០៨៩ ព.ណ.គនព.អ.កបប.ប្រក ស្តីពីស្លាកសញ្ញាហាឡាលកម្ពុជា | បានចុះហត្ថលេខា និងដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០២៣ |
| ៨ | ប្រកាសលេខ២០៩០ ព.ណ.គនព.អ.កបប.ប្រក ស្តីពីលក្ខខណ្ឌតម្រូវហាឡាលកម្ពុជាសម្រាប់ផលិតផលម្ហូបអាហារ | បានចុះហត្ថលេខា និងដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០២៣ |
| ៩ | ប្រកាសលេខ២០៩១ ព.ណ.គនព.អ.កបប.ប្រក ស្តីពីលក្ខខណ្ឌតម្រូវហាឡាលកម្ពុជាសម្រាប់ផលិតផលគ្រឿងសម្អាង | បានចុះហត្ថលេខា និងដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០២៣ |
| ***សេចក្តីសម្រេច*** | | |
| ១ | សេចក្តីសម្រេចលេខ២០៨៤ ព.ណ.អ.កបប.សសរ ស្តីពី***បែបបទនិងនីតិវិធី នៃការគណនា***ប្រាក់ផាកពិន័យចំពោះបទល្មើសក្រោមច្បាប់ស្តីពីការប្រកួតប្រជែង | បានចុះហត្ថលេខា និងដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០២៣ |
| ២ | សេចក្តីសម្រេចលេខ២០៩៥ ព.ណ.អ.កបប.សសរ ស្តីពី***កម្រិតកំណត់នៃការជូនដំណឹងជាមុន***អំពីការរួមបញ្ចូលគ្នានៃធុរកិច្ច | បានចុះហត្ថលេខា និងដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ ២០២៣ |
| ៣ | សេចក្តីសម្រេចលេខ១៨០ ព.ណ.អ.កបប.សសរស្តីពីការធ្វើ***ប្រតិភូកម្មអំណាច***របស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា ក្នុងការអនុវត្តអនុក្រឹត្យស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការរួមបញ្ចូលគ្នានៃធុរកិច្ច | បានចុះហត្ថលេខា និងដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ២០២៣ |
| ***សេចក្តីព្រាងច្បាប់ អនុក្រឹត្យ និងអនុស្សរណៈ:*** | | |
| ១ | សេចក្តីព្រាងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម | កំពុងរៀបចំសេចក្តីព្រាងឡើងវិញ ហើយគ្រោងនឹងបញ្ចប់ត្រឹមឆមាសទី១ឆ្នាំ២០២៤ ដើម្បីបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី |

| | | |
|---|---|---|
| ២ | សេចក្តីព្រាងច្បាប់ស្តីពីភ្នាក់ងារពាណិជ្ជកម្ម | កំពុងរៀបចំសេចក្តីព្រាង ហើយគ្រោងនឹងបញ្ចប់នៅដំណាច់ឆ្នាំ ២០២៤ ដើម្បីបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី |
| ៣ | សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ( E-Commerce Code of Conducts ) | កំពុងបូកសរុបធាតុចូលពីអន្តរក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងវិស័យឯកជន ដើម្បីបញ្ចប់សេចក្តីព្រាងប្រកាសនេះ |
| ៤ | សេចក្តីព្រាងអនុស្សរណៈនៃការយោគយល់ដំណាក់កាលទី២ រវាងក្រសួងពាណិជ្ជកម្ម និង ADB ក្នុងការរៀបចំក្របខណ្ឌគតិយុត្តសម្រាប់វិញ្ញាបនបត្រសម្គាល់ទំនុកចិត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច ( E-Commerce Trustmark Regulatory Framework ) | បានបញ្ចប់សេចក្តីព្រាងអនុស្សរណៈ និងរង់ចាំហត្ថលេខាពីថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម |
| ៥ | សេចក្តីព្រាងអនុស្សរណៈនៃកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយក្រសួងយុត្តិធម៌ នៃតំបន់រដ្ឋបាលពិសេសហុងកុង» | បានធ្វើការពិនិត្យ ពិគ្រោះយោបល់ផ្ទៃក្នុង និងរង់ចាំការឯកភាពជាគោលការណ៍ពីថ្នាក់ដឹកនាំក្រសួង |
| ៦ | សេចក្តីព្រាងអនុក្រឹត្យស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីក្នុងការតម្កល់ព័ត៌មាន និងកិច្ចសន្យាតំណាងម្ចាស់ភាគហ៊ុន | បានបញ្ចប់កិច្ចការបច្ចេកទេសក្នុងក្រុមការងារក្រសួងរួចរាល់ រង់ចាំបញ្ជូនសេចក្តីព្រាងទៅទីស្តីការគណៈរដ្ឋមន្ត្រី |
| ៧ | សេចក្តីព្រាងច្បាប់ ស្តីពីការសម្ងាត់ពាណិជ្ជកម្ម និងព័ត៌មានមិនបង្ហាញ ( Trade Secret and Undisclosed Information ) | បានពិនិត្យឡើងវិញលើសេចក្តីព្រាងបឋមត្រឹមកម្រិតបច្ចេកទេស និងរៀបចំស្នើសុំជំនួយបច្ចេកទេសពីអង្គការកម្មសិទ្ធិបញ្ញាពិភពលោក |
| ៨ | សេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានរដ្ឋបាលនៃការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា | បានបញ្ចប់ការពិភាក្សាបច្ចេកទេសលើសេចក្តីព្រាងអនុក្រឹត្យស្តីពី "វិធានការរដ្ឋបាលសម្រាប់ការអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញា" ហើយបានដាក់ឆ្លងក្នុងកិច្ចប្រជុំលើកទី១២ របស់គ.ក.ប. ដោយទទួលបានធាតុចូលមួយចំនួនទៀតពីសមាជិកគណៈកម្មាធិការដើម្បីបំពេញបន្ថែម |
| ៩ | សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីឈ្មោះដែនជាតិដែលបម្រុងទុកនិងហាមឃាត់ យន្តការសម្រាប់សហការតភ្ជាប់ ការផ្លាស់ប្តូរ ព័ត៌មានទាក់ទងនឹងឈ្មោះដែនជាតិ និងម្ចាស់ឈ្មោះដែនជាតិ | កំពុងពិភាក្សាបន្តជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ត្រង់ចំនុចយន្តការ និងបច្ចេកទេស សម្រាប់ការតភ្ជាប់ និងការផ្លាស់ប្តូរព័ត៌មាន ដើម្បីផ្ទៀងផ្ទាត់ជាមួយទិន្នន័យម៉ាកដែលបានដាក់ពាក្យស្នើសុំចុះបញ្ជី និងចុះបញ្ជីរួច |
| ១០ | សេចក្តីព្រាងប្រកាស ស្តីពីការបង្កើតក្រុមការងារបច្ចេកទេស ចំពោះកិច្ចអន្តរក្រសួងស្ថាប័ន ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងស្រូវអង្ករ និងយន្តការនៃការនាំចេញឆ្លើយតបទៅនឹងលក្ខខណ្ឌនានារបស់សហភាពអ៊ឺរ៉ុប | រង់ចាំការផ្តល់ធាតុចូលពីសហព័ន្ធស្រូវអង្ករ និងអង្គភាពពាក់ព័ន្ធដើម្បីបង្កើតបានជាក្រុមការងារបច្ចេកទេស ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងស្រូវអង្ករ |
| ១១ | សេចក្តីព្រាងច្បាប់ ស្តីពី «ការទទួលខុសត្រូវលើផលិតផល» ( Products Liability ) | សេចក្តីព្រាងបឋមបានបញ្ចប់ កំពុងរង់ចាំការសម្រេចពីថ្នាក់ដឹកនាំដើម្បីបន្តនីតិវិធី |

| | | |
|---|---|---|
| ១២ | សេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីការកំណត់អាយុអប្បបរមាស្របច្បាប់សម្រាប់ការទិញភេសជ្ជៈគ្រឿងស្រវឹងក្នុងព្រះរាជាណាចក្រកម្ពុជា | សេចក្ដីព្រាងបឋមបានបញ្ចប់ កំពុងរង់ចាំការសម្រេចពីថ្នាក់ដឹកនាំដើម្បីបន្តនីតិវិធី |

**ខ. ការងារតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា**

- បានទទួលតម្កល់លិខិតជូនដំណឹង នៃប្រតិបត្តិការដែលមានកិច្ចធានាចំនួន ៧ ៨១៣ (ប្រាំពីរពាន់ប្រាំបីរយដប់បី) លិខិត (គិតត្រឹមថ្ងៃ២០ ខែវិច្ឆិកា ឆ្នាំ២០២៣)
- ក្រុមការងារនីតិកម្ម និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) បានរៀបចំនីតិវិធីដេញថ្លៃជាសាធារណៈដើម្បីកែលម្អប្រព័ន្ធតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានាឱ្យមានភាពងាយស្រួលប្រើប្រាស់ និងកាន់តែមានប្រសិទ្ធភាពថែមទៀត។

**គ. ការងារប្រឹក្សាយោបល់ផ្នែកច្បាប់**

- បានផ្ដល់សេវាកម្មពិគ្រោះយោបល់ផ្នែកច្បាប់និងដោះស្រាយវិវាទជូនអាជីវករ-ពាណិជ្ជករ ម្ចាស់ឬអ្នកតំណាងក្រុមហ៊ុនសហគ្រាស និងអ្នកប្រកបវិជ្ជាជីវៈផ្នែកច្បាប់ពាក់ព័ន្ធនឹងការអនុវត្តច្បាប់ពាណិជ្ជកម្មបានចំនួន ១៦ លើក ក្នុងនោះបានផ្ដល់យោបល់លើករណីវិវាទរបស់ក្រុមហ៊ុន Cambodia Banana Agriculture Co., Ltd. និងក្រុមហ៊ុន Green Island Agriculture Development (Cambodia) Limited ដែលជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Hainan Digyi Green Island Ecological Agriculture Co.,Ltd. របស់ប្រទេសចិន។

**៣.២. ការអភិវឌ្ឍវិស័យឯកជន**

**ក.ការងារឃ្លាំមើល និងតាមដានសកម្មភាពពាណិជ្ជកម្ម**

| បរិយាយការងារ | លទ្ធផល |
|---|---|
| • តាមដាន និងធ្វើរបាយការណ៍សន្ទស្សន៍ថ្លៃទំនិញយុទ្ធសាស្ត្រ ៣៦មុខ និងតាមដានថ្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយ និងដេប៉ូ ចំនួន ១០៣ជធានី-ខេត្ត | ៣៣លើក |
| • តាមដាន និងធ្វើរបាយការណ៍ទំនិញក្នុងស្រុកចាំបាច់សម្រាប់បម្រើជីវភាពប្រចាំថ្ងៃ ១១៩មុខ | ២២០លើក |
| • ចេញសេចក្ដីជូនដំណឹង ស្ដីពីថ្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយ | ៣៣លើក |
| • តាមដាន និងធ្វើរបាយការណ៍ស្ថានភាពសន្និធិប្រេង និងហ្គាសរបស់ក្រុមហ៊ុនប្រចាំខែ | ១១លើក |
| • តាមដាន និងធ្វើរបាយការណ៍ ស្ដីពីបញ្ហាទំនិញកសិផល និងស្ថានភាពទំនិញនាំចេញ-នាំចូលទូទៅ នៅតាមច្រកព្រំដែនកម្ពុជា-ថៃ និងកម្ពុជា-វៀតណាម | ៣៣លើក |
| • តាមដាន និងសុបរបាយការណ៍ ការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម ពាណិជ្ជកម្ម សេវាកម្ម និងលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ និងការបិទស្លាកថ្លៃលើមុខទំនិញ និងសេវាកម្មគ្រប់ប្រភេទរបស់មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត | ៩លើក |
| • ចុះអនុវត្តគោលការណ៍ណែនាំ និងពង្រឹងការងារគ្រប់គ្រងអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម អាជីវកម្ម លោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ និងការបិទស្លាកថ្លៃលើមុខទំនិញ និងសេវាកម្មគ្រប់ប្រភេទនៅតាមបណ្ដាមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្តទាំង២៥ | ៦លើក |
| • ចេញសេចក្ដីជូនដំណឹងលេខ ១០២០ ព.ណ.អវង ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣ ស្ដីពីការបិទស្លាកថ្លៃលើមុខទំនិញ និងសេវាកម្មគ្រប់ប្រភេទជាប្រាក់រៀល | ១លើក |

**ខ.ការងារអភិវឌ្ឍន៍ស្ថាប័នពាណិជ្ជកម្ម**

| បរិយាយការងារ | លទ្ធផល |
|---|---|
| • បោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំង សភាពាណិជ្ជកម្មកម្ពុជា និងរាជធានី-ខេត្ត សម្រាប់អាណត្តិបន្ត និងអាណត្តិថ្មី | ១៦ លើក |
| • បោះឆ្នោត និងរៀបចំសេចក្តីសម្រេចទទួលស្គាល់ប្រធាន សមាជិកការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជានៅក្រៅប្រទេស(ប្រទេសជប៉ុន ១ការិយាល័យ និងអូស្ត្រាលី ២ការិយាល័យ) | ៣លើក |
| • រៀបចំអនុក្រឹត្យទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្មរាជធានី-ខេត្ត និងសមាសភាពការិយាល័យប្រតិបត្តិសភាពាណិជ្ជកម្មកម្ពុជា អាណត្តិទី៥ | ១៥មណ្ឌល-ខេត្ត |
| • ចេញប្រកាស ទទួលស្គាល់ប្រធាន និងសមាជិកក្រុមប្រឹក្សាសហព័ន្ធស្រូវអង្ករ អាណត្តិទី៤ | ១លើក |
| • ចេញប្រកាស ស្តីពីការកែប្រែសម្រួលសមាសភាពគណៈកម្មការរៀបចំការបោះឆ្នោតការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជានៅទីក្រុងម៉ុងរ៉េអាល់ ខេត្តកេប៊ិច ប្រទេសកាណាដា | ១លើក |
| • ចេញប្រកាសទទួលស្គាល់សមាសភាព ការិយាល័យប្រតិបត្តិ និងសមាជិកទីប្រឹក្សាសភាពាណិជ្ជកម្មមណ្ឌលខេត្តកំពង់ធំ ព្រះវិហារ អាណត្តិទី២ លើកទី២ | ១លើក |
| • ចេញប្រកាសទទួលស្គាល់សមាសភាពការិយាល័យប្រតិបត្តិ និងសមាជិកទីប្រឹក្សាសភាពាណិជ្ជកម្មខេត្តតាកែវ អាណត្តិទី១ លើកទី១ | ១លើក |
| • ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត នៃការបង្កើតសមាគម តួនាទី ភារកិច្ច និងអត្ថប្រយោជន៍នៃការបង្កើតសមាគមអាជីវកម្មចំនួន ៥ខេត្ត | ៥លើក |
| • ផ្សព្វផ្សាយតួនាទី ភារកិច្ច បទបញ្ជាផ្ទៃក្នុង និងការគ្រប់គ្រងរដ្ឋបាល ដល់សភាពាណិជ្ជកម្មខេត្តពោធិ៍សាត់ និងសភាពាណិជ្ជកម្មមណ្ឌលខេត្តកំពត-កែប | ២លើក |

## គ.ការងារអភិវឌ្ឍន៍ផលិតផល

| បរិយាយការងារ | លទ្ធផល |
|---|---|
| • ចុះស្រាវជ្រាវ ប្រមូលទិន្នន័យអំពីផលិតផលសូត្រ ព្រមទាំងធ្វើបច្ចុប្បន្នភាពកីតម្បាញនៅខេត្តគោលដៅចំនួន ៦ | ៦លើក |
| • រៀបចំកិច្ចពិគ្រោះយោបល់រវាងផលិតករ អាជីវករ និងភាគីពាក់ព័ន្ធក្នុងវិស័យ សូត្រ ដើម្បីចែករំលែកពីស្ថានការណ៍បច្ចុប្បន្នភាពនៃអាជីវកម្ម និងផលិតកម្មសូត្រ (សៀមរាប និងបន្ទាយមានជ័យ) | ២លើក |
| • រៀបចំកិច្ចពិគ្រោះយោបល់ ស្តីពីការអភិវឌ្ឍន៍ខ្សែច្រវាក់តម្លៃដល់ភាគីពាក់ព័ន្ធ (បាត់ដំបង និងកំពត) | ២លើក |
| • ចុះស្រាវជ្រាវ និងប្រមូលទិន្នន័យកំណត់ទីតាំងភូមិសាស្ត្រផលិតផល ដែលមានសក្តានុពលនៅក្នុងខេត្តគោលដៅ ដើម្បីសិក្សាលទ្ធភាពនៃការអភិវឌ្ឍខ្សែច្រវាក់តម្លៃ (១២ខេត្តគោលដៅ) | ១២លើក |
| • រៀបចំការពិភាក្សារវាងគណៈកម្មការសូត្រកម្ពុជា (SDC) និងសម្ព័ន្ធសូត្រអន្តរជាតិ (ISU) នៃសាធារណរដ្ឋប្រជាមានិតចិន ព្រមទាំងចុះទស្សនកិច្ចនៅកន្លែងត្បាញសូត្រនៅកោះដាច់ | ១លើក |
| • រៀបចំសៀវភៅរាយឈ្មោះ លេខទំនាក់ទំនង និងព័ត៌មានអាជីវកម្មរបស់ឈ្មួញ អ្នកផ្តល់សេវាកម្ម អ្នកផ្គត់ផ្គង់ជាតុចូលនៅតាមខេត្តគោលដៅ (មិនទាន់បោះពុម្ព) | បញ្ចប់ |
| • បានចុះអនុស្សរណៈនៃការយោគយល់គ្នា រវាងក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា និងក្រសួងពាណិជ្ជកម្ម ស្តីពីកិច្ចសហការប្រមូលទិញ ពោតក្រហម ដំឡូងមី កន្ទក់ ចុងអង្ករ និងការត្រួតពិនិត្យសាច់ជ្រូកបង្កក (ចំនួន ៣ អនុស្សរណៈ) | បានបញ្ចប់ |

| | |
|---|---|
| • ចូលរួម និងរៀបចំរបាយការណ៍ស្តីពីកិច្ចប្រជុំអន្តរក្រសួង-ស្ថាប័ន កម្រិតបច្ចេកទេស ដើម្បីពិនិត្យ និងពិភាក្សាអំពីការរៀបចំក្រុមការងារ ផែនការសកម្មភាព និងនីតិវិធីនៃការអនុវត្ត (១)យន្តការសម្របសម្រួល និងកម្មវិធីហិរញ្ញប្បទានសំដៅលើកស្ទួយផលិតកម្មកេទីផ្សារ និងក្បាលនឹងថ្លៃកសិផលសំខាន់ៗ ក្នុងកម្រិតសមរម្យ និង (២)ការដាក់ពង្រាយអ្នកជំនាញកសិកម្មគ្រប់ឃុំសង្កាត់ទូទាំងប្រទេស | រៀបចំរបាយការណ៍រួចរាល់ |
| • បានចូលរួមប្រជុំអន្តរក្រសួង-ស្ថាប័នកម្រិតបច្ចេកទេស ដើម្បីពិនិត្យ និងពិភាក្សាអំពីការរៀបចំក្រុមការងារ ផែនការសកម្មភាព និងនីតិវិធីនៃការអនុវត្តកម្មវិធីនយោបាយអាទិភាពទី៥ និងទី៦ និងបន្តកិច្ចប្រជុំស្តីពីស្ថានភាពស្រូវអង្ករជាមួយសហព័ន្ធស្រូវអង្ករ ព្រមទាំងពិភាក្សាលើបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងវិស័យស្រូវ-អង្ករ និងស្វាយចន្ទី ដើម្បីរៀបចំដាវិធានការដោះស្រាយ និងជំរុញការនាំចេញ | រៀបចំរបាយការណ៍រួចរាល់ |
| • បានរៀបចំលិខិតទៅសមាគមអ្នកចិញ្ចឹមសត្វកម្ពុជាទាក់ទងនឹងការទប់ស្កាត់ការនាំចូលសាច់ជ្រូកបង្កកពីបរទេស | ១លើក |

## ៣.៣.ការងារផែនការ ស្ថិតិ និងផ្សព្វផ្សាយព័ត៌មានពាណិជ្ជកម្ម

| **សកម្មភាពការងារ** | **បរិយាយការងារ** | **លទ្ធផល** |
|---|---|---|
| ការងារផែនការ | • ចងក្រងជាតុចូលរបស់ក្រសួងពាណិជ្ជកម្ម ដើម្បីដាក់បញ្ចូលទៅក្នុង "របាយការណ៍ត្រួតពិនិត្យ ថ្នាក់ជាតិដោយស្ម័គ្រចិត្ត ឆ្នាំ២០២៣ (VNR 2023) របស់ក្រសួងផែនការ" | បានបញ្ចប់ |
| | • ធ្វើបច្ចុប្បន្នភាពគម្រោងដែលមានស្រាប់ និងរៀបចំ គម្រោងថ្មី របស់ក្រសួងពាណិជ្ជកម្ម ដើម្បីដាក់បញ្ចូល ក្នុង" កម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០២៤-២០២៦" | កំពុងដំណើរការតាមការគ្រោងទុក |
| | • រៀបចំបំពេញព័ត៌មានរបស់ក្រសួងពាណិជ្ជកម្មទៅក្នុងកម្រង" មេតាទិន្នន័យ "ស្ថិតិផ្លូវការ តាមការស្នើសុំរបស់ក្រសួងផែនការ | បានបញ្ចប់ |
| | • រៀបចំ ចងក្រង សំយោគ ផែនការរួមក្រសួងពាណិជ្ជកម្ម ផ្អែកលើផែនការសកម្មភាព និងផែនការថវិកាតាមកម្មវិធី ដើម្បីរំលេចជាផែនការការងាររួមរបស់ក្រសួងពាណិជ្ជកម្មស្របតាមយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្ម (CTIS) | កំពុងរៀបចំ |
| ការងារស្ថិតិពាណិជ្ជកម្ម | • ប្រមូលព័ត៌មានស្ថិតិពាណិជ្ជកម្មពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដើម្បីចងក្រងជាប្រព័ន្ធស្ថិតិរួម សម្រាប់ការវិភាគ និងប្រើប្រាស់រួមក្នុងក្រសួងពាណិជ្ជកម្ម | វឌ្ឍនភាពបន្តបន្ទាប់ជាប្រចាំ |
| | • ប្រមូលចងក្រងស្ថិតិពាណិជ្ជកម្មពីនាយកដ្ឋានពាក់ព័ន្ធ (ស្ថិតិចុះបញ្ជីពាណិជ្ជកម្ម ស្ថិតិកម្មសិទ្ធិបញ្ញា និងស្ថិតិនាំចេញ-នាំចូល) ដើម្បីត្រៀមបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យរៀបរយ | កំពុងរៀបចំ |
| | • ធ្វើបច្ចុប្បន្នភាពស្ថិតិពាណិជ្ជកម្ម ទៅក្នុងប្រព័ន្ធវិភាគស្ថិតិ (Statistics Analysis System "SAS") ដើម្បីងាយស្រួលក្នុងការទាញយកទិន្នន័យសម្រួលដល់ការប្រើប្រាស់របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងអន្តរក្រសួង | វឌ្ឍនភាពបន្តបន្ទាប់ជាប្រចាំ |
| | • ធ្វើបច្ចុប្បន្នភាពសន្ទស្សន៍ថ្លៃទំនិញ១១៩មុខដាក់បញ្ចូលទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មសន្ទស្សន៍ថ្លៃទំនិញ ងាយស្រួលតាមដាន និងវិភាគ | វឌ្ឍនភាពបន្តបន្ទាប់ជាប្រចាំ |
| ការងារព័ត៌មានវិទ្យា | • អភិវឌ្ឍន៍កម្មវិធី លក់ស្តង់ និងកក់ទុកស្តង់ពិព័រណ៍ ព្រមទាំងបច្ចេកទេសពាក់ព័ន្ធ ងាយស្រួលសម្រាប់ពាណិជ្ជករ អាចធ្វើការកក់ស្តង់ និងទូទាត់ដោយខ្លួនឯង | បានសម្រេច ៧០% |
| | • អភិវឌ្ឍន៍គម្រោងផ្សារជំរុញផលិតផលកសិកម្ម (PHSAR) សម្រាប់កសិករអាចដាក់លក់ផលិតផល និងបញ្ចូលថ្លៃទំនិញសម្រាប់ការតាមដានទូទៅ | បានសម្រេច ៥០% |
| | • រៀបចំការងារបច្ចេកទេស និងសម្របសម្រួលសម្រាប់កិច្ចប្រជុំតាមប្រព័ន្ធវីដេអូ ជាមួយអន្តរក្រសួង ថ្នាក់ជាតិ និងអន្តរជាតិ | បានចំនួន ១០៦ លើក |
| | • ថែទាំ ជួសជុល ធានាដំណើរការមជ្ឈមណ្ឌលទិន្នន័យ ក្រសួងពាណិជ្ជកម្ម | ថែទាំ Servers ចំនួន៦៩ ដើម្បី |

| សកម្មភាពការងារ | បរិយាយការងារ | លទ្ធផល |
|---|---|---|
| | | ជានាដំណើរការសេវាកម្មទាំង ២៥ សេវា |
| | • ផ្តល់សេវាជួសជុល ថែទាំកុំព្យូទ័រ ឧបករណ៍ព័ត៌មានវិទ្យានិងម៉ាស៊ីនភ្លើងមជ្ឈមណ្ឌលទិន្នន័យ សម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រី | កុំព្យូទ័រ ៥៩ គ្រឿង ម៉ាស៊ីនព្រីន ៧គ្រឿង |
| | • រៀបចំប្រព័ន្ធបណ្តាញហេដ្ឋារចនាសម្ព័ន្ធ(Network)ថ្មីសម្រាប់គាំទ្រកំណែទម្រង់រដ្ឋបាល និងសេវាសាធារណៈ | បានសម្រេច 90% |
| | • បានបញ្ចប់ការអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងឃ្លាំងឯកសារការងារកិច្ចព្រមព្រៀងសេរី សម្រាប់ការងារចរចារ ស្រាវជ្រាវ និងបណ្តុះបណ្តាល (FTA Knowledge Center) | បានសម្រេច 90% |
| ការងារបោះពុម្ពផ្សាយព្រឹត្តិបត្រពាណិជ្ជកម្ម | • បោះពុម្ពផ្សាយព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម ចំនួន ១៧លេខ សរុប ចំនួន៩៩០០ក្បាល | ចែកជូនទៅថ្នាក់ដឹកនាំ និងអន្តរក្រសួងពាក់ព័ន្ធ |
| | • ស្រាវជ្រាវប្រមូលព័ត៌មានជាតិ និងអន្តរជាតិទាក់ទងថ្លៃទំនិញសំខាន់ៗ ទីផ្សារដើម្បីចងក្រង និងផ្សព្វផ្សាយសម្រាប់ជាព័ត៌មានជូនថ្នាក់ដឹកនាំ ពាណិជ្ជករ និងសាធារណជនទូទៅ | បានបញ្ចូលក្នុងព្រឹត្តិបត្រព័ត៌មាន និងគេហទំព័ររបស់ក្រសួង |
| | • កែលម្អខ្លឹមសារ សោភណភាព និងមាតិកា របស់ព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្មដែលមានស្រាប់ស្របតាមយុទ្ធសាស្ត្រឌីជីថលនីយកម្ម ដើម្បីត្រៀមបោះពុម្ពជា Hard Copy និង E-bulletin សម្រាប់ទាក់ទាញអ្នកអាន ក្នុងគោលដៅពាណិជ្ជកម្ម | សម្រេចបាន ៩០% |

## ៣.៤. ការអនុវត្តគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច(AIMS)

| បរិយាយការងារ | លទ្ធផល |
|---|---|
| ចងក្រងទិន្នន័យកសិករខ្នាតតូចជាចង្កោម និងក្រុមកសិករផលិត ក្រោមគម្រោង AIMS ក្នុងនោះកសិករ ក្រ-កម្រិត១ មានចំនួន **៣ ៨៨០ គ្រួសារ**, កម្រិត២ មានចំនួន **៩ ៦៦៧ គ្រួសារ** កសិករកម្រិតងាយរងគ្រោះ មានចំនួន **៦០ ១៦៨ គ្រួសារ** និងកសិករជីវភាពកម្រិតបង្គួរ មានចំនួន **៤ ៥៦៦ គ្រួសារ** ដែលស្ថិតក្រោមការអន្តរាគមន៍ពីគម្រោង AIMS និងកំពុងអនុវត្តលើផលិតផលចំនួន ៥ មុខរួមមាន៖ **បន្លែ មាន់ស្រែ ស្រូវ ដំឡូងមី និងសូត្រធៅ** | បានចងក្រងជាចង្កោមអាជីវកម្មចំនួន **៧៩៨ ចង្កោម** ក្រុមកសិករផលិតមានចំនួន **១ ៩០៨ ក្រុម** ដែលមានសមាជិកសរុបចំនួន **៧៨ ២៧៦ គ្រួសារ** |
| រៀបចំប្រជុំក្រុមផលិតបានចំនួន **២ ២៩៦ លើក** | ជំរុញផលិតកម្មដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ និងរក្សានិរន្តភាពនៃការផ្គត់ផ្គង់របស់ក្រុមកសិករផលិត |
| រៀបចំវេទិកាពហុភាគីអ្នកពាក់ព័ន្ធចំនួន **២៤៧ វេទិកា** | ដោះស្រាយបញ្ហាទាក់ទងនឹងផលិតកម្មរបស់កសិករផលិតទាក់ទងនឹងភាគីពាក់ព័ន្ធ ផ្គូផ្គងអាជីវកម្ម និងព្រមព្រៀងការអនុវត្តកិច្ចសន្យាទិញ-លក់ផលិតផលជាក់ស្តែង |

| | |
|---|---|
| ផ្សព្វផ្សាយចំណេះដឹងអាជីវកម្ម លើប្រធានបទសំខាន់ៗចំនួន៣គឺ (i) **ការរៀបចំផែនការអាជីវកម្ម** (ii) **ការងារទីផ្សារ និង** (iii) **ការគ្រប់គ្រងហិរញ្ញវត្ថុ** ដល់ក្រុមកសិករផលិតចំនួន **១ ៩០៨ វគ្គ** បានគ្រប់ផែនការ | បង្កើនការយល់ដឹងផ្នែកអាជីវកម្ម ជាពិសេសការរៀបចំផែនការវិនិយោគបានត្រឹមត្រូវរបស់ក្រុមកិសកផលិត |
| ជំរុញបង្កើតកិច្ចសន្យាទិញ-លក់ផលិតផល ចំនួន៤ គឺ**បន្លែ មាន់ស្រែ ដំឡូងមី និងស្រូវ** សរុបទឹកប្រាក់ក្នុងកិច្ចសន្យាចំនួន **៥៤ ១៨៤ ៦៦៦ លានដុល្លារអាមេរិក** | **- បន្លែ៖ ៣៧៨ កិច្ចសន្យា** សរុប **២៦ ១៩៧តោន** ក្នុងទឹកប្រាក់ **១០.៣៣៨.៣៩៦ដុល្លាអាមេរិក**<br>**-មាន់ស្រែ៖ ៥៧៣ កិច្ចសន្យា** សរុប **១ ១៥០តោន** ក្នុងទឹកប្រាក់ **៤.៦៨៦.៤១២ដុល្លាអាមេរិក**<br>-ដំឡូងមី៖ **១៨១ កិច្ចសន្យា** សរុប **១៤៩,២២៥តោន** ក្នុងទឹកប្រាក់ **១៥.៦៧៨.៣៣៧ដុល្លាអាមេរិក**<br>-ស្រូវ៖ **៥១៥ កិច្ចសន្យា** សរុប **៩០,៤៥៦តោន** ក្នុងទឹកប្រាក់ ២៣.៤៨១.៥២១ដុល្លាអាមេរិក |
| ផ្តល់មូលនិធិអភិវឌ្ឍន៍តាមវិស័យ (SDF) ដើម្បីបង្កើនផលិតភាព ផលិតកម្មតាមរយៈហេដ្ឋារចនាសម្ព័ន្ធរូបវន្តចំនួន **៧ ប្រភេទ**ដល់ក្រុមកសិករផលិត<br><br>សរុបរួមហេដ្ឋារចនាសម្ព័ន្ធចំនួន ៨៩ បានផ្តល់/សាងសង់ជូនក្រុមកសិករផលិតទាំង ១៨ ខេត្តគោលដៅរបស់គម្រោង | **១. អណ្តូងប្រើម៉ូទ័រចំនួន ៣១ អណ្តូង**<br>**២. អណ្តូងស្រោចស្រពប្រើថាមពលព្រះអាទិត្យចំនួន ១៥ អណ្តូង**<br>**៣. បំពាក់ប្រព័ន្ធថាមពលព្រះអាទិត្យសម្រាប់បូមទឹកពីស្រះ ចំនួន១**<br>**៤. កន្លែងប្រមូលផ្តុំមាន់ចំនួន ១២ កន្លែង**<br>**៥. ទីសត្តឃាតមាន់ចំនួន ៦កន្លែង**<br>**៦. កន្លែងប្រមូលផ្តុំបន្លែចំនួន ៥ កន្លែង**<br>**៧. កន្លែងលាងសម្អាត និងវេចខ្ចប់បន្លែចំនួន ៤កន្លែង**<br>**៨. កន្លែងប្រមូលផ្តុំ ផលិតផលចម្រុះចំនួន ១៥កន្លែង** |
| សម្របសម្រួលភ្ជាប់ទំនាក់ទំនងអាជីវកម្ម រវាងក្រុមកសិករផលិត និងទីផ្សារលក់ដុំ-លក់រាយនៅភ្នំពេញ និងបណ្តាខេត្ត គឺ ផ្សារអាហារសុវត្ថិភាពរបស់ក្រុមហ៊ុនខេ.ស៊ី.ស៊ី.វី ផ្លេនថេសិន (KCCV), ក្រុមហ៊ុនម៉ាក្រូ (ខេមបូឌា) ឯ.ក(ផ្សារម៉ាក្រូ), ក្រុមហ៊ុន Yamato Green Co.,Ltd, LyLy, Agrion, CJ Agro Business, Mala, REMIC, NAV, KOC, Lala Garden, Samaritan Purse, Home Food | មានផ្សារចំនួន១៣ ទទួលលក់ផលិតផលរបស់ក្រុមកសិករផលិតក្រោមក្របខ័ណ្ឌគម្រោង AIMS |
| ផ្តល់មូលនិធិនវានុវត្តន៍ខ្សែច្រវាក់តម្លៃ (VCIF-Win-1)ដល់កសិករ | កសិករចំនួន**១ ៤៥០ គ្រួសារ** ទឹកប្រាក់សរុប **១ ៩៩៩ ៣១៩ ដុល្លារអាមេរិក** |
| ពិនិត្យវាយតម្លៃសំណើមូលនិធិនវានុវត្តន៍ខ្សែច្រវាក់តម្លៃ VCIF-Win-2 | ចំនួន **៦ សំណើ** ដែលប៉ាន់ប្រមាណជាទឹកប្រាក់ **៥៨ ២០០ ដុល្លារអាមេរិក** |
| ផ្តល់ឥណទានដល់តួអង្គខ្សែច្រវាក់តម្លៃ គ្រួសារកសិករខ្នាតតូច និងគ្រួសារកសិករក្រចំនួន **៧៧២ គ្រួសារ** | ទឹកប្រាក់ **៦ ៣៦០ ២៨៦ ដុល្លារអាមេរិក** |

## ៤. ការងារពាណិជ្ជកម្មអន្តរជាតិ និងសមាហរណកម្មសេដ្ឋកិច្ច[3]

## ៤.១. កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម ទ្វេភាគី អនុតំបន់ និងសមាហរណកម្ម

| បរិយាយការងារ | លទ្ធផល |
|---|---|
| **១. កិច្ចការអាស៊ាន និងដៃគូ** | |
| កិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន ចំនួន ៧លើក និងកិច្ចប្រជុំពាក់ព័ន្ធ | • ពិនិត្យ ពិភាក្សា និងសម្រេចលើសមិទ្ធផលអាទិភាពសេដ្ឋកិច្ច ក្រោមភាពជាប្រធានអាស៊ានឆ្នាំ២០២៣ របស់ឥណ្ឌូណេស៊ី ដើម្បីដាក់ជូនរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ពិនិត្យ កត់សម្គាល់ ឬសម្រេច។<br>• ពិនិត្យ និងឯកភាពលើរបាយការណ៍សិក្សាឯកសារក្របខណ្ឌសម្រាប់ការចរចា និងសេចក្តីថ្លែងការណ៍ថ្នាក់ដឹកនាំអាស៊ាន ពាក់ព័ន្ធនឹងការចរចាកិច្ចព្រមព្រៀងក្របខណ្ឌសេដ្ឋកិច្ចឌីជីថលអាស៊ាន និងបានដាក់ជូនរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានដើម្បីបន្តនីតិវិធី។<br>• បានពិភាក្សា និងពិគ្រោះយោបល់លើវឌ្ឍនភាពនៃទំនាក់ទំនងសេដ្ឋកិច្ចនិងពាណិជ្ជកម្មជាមួយនឹងដៃគូសន្ទនាអាស៊ានដូចជា៖ ចិន កូរ៉េ រុស្ស៊ី ជប៉ុន អាស៊ានបូកបី អង់គ្លេស កាណាដា អូស្ត្រាលី និងនូវែលសេឡង់ អាស៊ីបូព៌ា សហភាពអឺរ៉ុប ហុងកុង-ចិន សហរដ្ឋអាម៉េរិក និងឥណ្ឌា។ |
| កិច្ចប្រជុំក្រុមការងារជាន់ខ្ពស់ សមាហរណកម្មសេដ្ឋកិច្ចអាស៊ាន ២លើក | • ពិនិត្យ និងផ្តល់អនុសាសន៍លើវឌ្ឍនភាពនៃការអនុវត្តក្របខណ្ឌស្តារឡើងវិញគ្រប់ជ្រុងជ្រោយអាស៊ាន (ACRF) សម្រាប់ដាក់ជូនកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៥៥ និងរដ្ឋមន្ត្រីក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ានលើកទី២២ និង២៣<br>• បានបន្តពិនិត្យ ពិភាក្សា និងសម្របសម្រួលលើកិច្ចការចក្ខុវិស័យអាស៊ានក្រោយឆ្នាំ២០២៥ សម្រាប់សសរស្តម្ភសហគមន៍សេដ្ឋកិច្ចអាស៊ាន ដោយក្នុងនោះបានរៀបចំ និងឯកភាពលើធាតុផ្សំគោលរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន ដើម្បីដាក់ជាផ្នែកមួយនៃឯកសារចក្ខុវិស័យអាស៊ានក្រោយឆ្នាំ២០២៥ ព្រមទាំងបន្តពិភាក្សាលើឯកសារពាក់ព័ន្ធផ្សេងទៀតសម្រាប់កិច្ចការនេះ។<br>• បានពិនិត្យ ពិភាក្សា រៀបចំ និងឯកភាពលើឯកសារយុទ្ធសាស្ត្រអាស៊ានស្តីពីអញ្ញាក្រឹតកាបូន និងក្របខណ្ឌសេដ្ឋកិច្ចពណ៌ខៀវ និងបន្តនីតិវិធីដាក់ជូនកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងកិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ាន។<br>• បានបន្តពិនិត្យ និងពិភាក្សាលើកិច្ចការពាក់ព័ន្ធនឹងបញ្ហាថ្មីៗ ដែលកើតឡើងក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានជាមួយនឹងដៃគូ។ |
| កិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ចសម្រាប់ក្របខណ្ឌកម្ពុជា-ឡាវ-មីយ៉ាន់ម៉ា -វៀតណាម ចំនួន២លើក | • បានពិនិត្យ និងរៀបចំរបាយការណ៍វឌ្ឍនភាពស្តីពីក្របខណ្ឌសម្រាប់ការអភិវឌ្ឍប្រទេស CLMV សម្រាប់ដាក់ជូនកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ច ក្របខណ្ឌកម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-វៀតណាម<br>• បានពិភាក្សាលើផែនការអនុវត្តក្របខណ្ឌសម្រាប់ការអភិវឌ្ឍ CLMV ដោយក្នុងនោះរួមមានការត្រៀមរៀបចំសិក្ខាសាលាបញ្ជ្រាបការយល់ដឹងសម្រាប់មន្ត្រីរបស់ CLMV ដែលនឹងត្រូវចូលរួមអនុវត្តក្របខណ្ឌនេះ។ |

[3] ប្រភព៖ អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ

| | |
|---|---|
| កិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៥៥<br>និងកិច្ចប្រជុំពាក់ព័ន្ធ | • អនុម័តលើសមិទ្ធផលអាទិភាពសេដ្ឋកិច្ចក្រោមកាពជាប្រធានអាស៊ានឆ្នាំ២០២៣ របស់ឥណ្ឌូណេស៊ី។<br>• ផ្តល់អនុសាសន៍ណែនាំបន្ថែម សម្រាប់ការអនុវត្តអាទិភាពប្រចាំឆ្នាំ២០២៣ ក្រោមដែនសមត្ថកិច្ចរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន។<br>• អនុម័តលើរបាយការណ៍សិក្សា ឯកសារក្របខណ្ឌសម្រាប់ការចរចា និងសេចក្តីថ្លែងការណ៍ថ្នាក់ដឹកនាំអាស៊ាន ពាក់ព័ន្ធនឹងការចរចាកិច្ចព្រមព្រៀងក្របខណ្ឌសេដ្ឋកិច្ចឌីជីថលអាស៊ាន។<br>• ធ្វើជាសាក្សីលើការចុះហត្ថលេខាអនុស្សរណៈយោគយល់គ្នារវាងអាស៊ាន និងអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ក្នុងការពង្រីកកិច្ចសហប្រតិបត្តិការលើការគាំទ្រដល់សហគ្រាសធុនតូចនិងមធ្យម និងការចាប់ផ្តើមអាជីវកម្ម។<br>• ពិគ្រោះយោបល់លើវឌ្ឍនភាពនៃទំនាក់ទំនងសេដ្ឋកិច្ចនិងពាណិជ្ជកម្ម ជាមួយនឹងដៃគូសន្ទនាអាស៊ានដូចជា៖ ចិន កូរ៉េ រុស្ស៊ី ជប៉ុន អាស៊ានបូកបី អង់គ្លេស កាណាដា អូស្ត្រាលីនិងនូវែលសេឡង់ អាស៊ីបូព៌ា សហភាពអឺរ៉ុប ហុងកុងនៃប្រទេសចិន សហរដ្ឋអាម៉េរិក និងឥណ្ឌា។ |
| កិច្ចប្រជុំរដ្ឋមន្ត្រីក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ាន លើកទី២២ និង២៣ | • ផ្លាស់ប្តូរមតិយោបល់ និងកត់សម្គាល់លើរបាយការណ៍របស់លេខាធិការដ្ឋានអាស៊ានស្តីពីទិដ្ឋភាពសេដ្ឋកិច្ចតំបន់និងសាកល។ នៅក្នុងឆ្នាំ២០២៣ អាស៊ានរំពឹងថាសម្រេចបានកំណើនសេដ្ឋកិច្ចក្នុង ៤,៦% និង៤,៩% ក្នុងឆ្នាំ២០២៤។<br>• បានកត់សម្គាល់ និងផ្តល់អនុសាសន៍ពីដំណើរការរៀបចំចក្ខុវិស័យសហគមន៍អាស៊ានក្រោយឆ្នាំ២០២៥ ដល់ក្រុមការងារជាន់ខ្ពស់សម្រាប់សមាហរណកម្មសេដ្ឋកិច្ចអាស៊ាន (HLTF-EI) ដែលទទួលបន្ទុកលើកិច្ចការនេះសម្រាប់សសរស្តម្ភសហគមន៍សេដ្ឋកិច្ចអាស៊ាន។<br>• អនុម័តលើឯកសារសមិទ្ធផលអាទិភាពសេដ្ឋកិច្ច ក្រោមកាពជាប្រធានអាស៊ានឆ្នាំ២០២៣ របស់ឥណ្ឌូនេស៊ីដែលមាន១៦សមិទ្ធផលអាទិភាព។<br>• ពិនិត្យ តាមដាន វឌ្ឍនភាព ការអនុវត្តសកម្មភាពអាទិភាពប្រចាំឆ្នាំ២០២៣ របស់សសរស្តម្ភសហគមន៍សេដ្ឋកិចអាស៊ានដែលមានចំនួន ១០៣ សកម្មភាព។<br>• អនុម័ត យុទ្ធសាស្ត្រអាស៊ានស្តីពីអព្យាក្រឹតកាបូន ដែលមានបែងពីយុទ្ធសាស្ត្រគោលចំនួន៨ រួមមាន៖ (១)ពន្លឿនការធ្វើសមាហរណកម្មខ្សែច្រវាក់តម្លៃបៃតង (២)លើកកម្ពស់ខ្សែច្រវាក់ផ្គត់ផ្គង់សេដ្ឋកិច្ចចក្រាតំបន់ (៣)តភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធនិងផ្សារបៃតង (៤)អភិវឌ្ឍទីផ្សារកាបូន (៥)អភិវឌ្ឍស្តង់ដារួមនិងទំនុកចិត្តសម្រាប់ឥណទានកាបូន (៦)ទាក់ទាញនិងរៀបចំផែនការប្រើប្រាស់មូលធនបៃតង (៧)លើកកម្ពស់បន្ទាស់ទីនិងការអភិវឌ្ឍទេពកោសល្យបៃតង និង (៨)ចែករំលែកបទពិសោធន៍នៃឧត្តមានុវត្តបៃតង។ |
| កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលសេវាកម្មអាស៊ាន ចំនួន ៣លើក | • ពិភាក្សាការងារបន្ត និងលើកផែនការដើម្បីអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ាន (ATISA)<br>• បានពិភាក្សាអំពីកម្មវិធីការងារ សម្រាប់បន្ទាស់ទីរូបវន្តបុគ្គលអាស៊ាន ដោយពិនិត្យលើឯកសារទស្សនទាន ស្តីពីធាតុផ្សំសំខាន់ៗសម្រាប់ដាក់បញ្ចូលក្នុងឯកសារកិច្ចការតាមដំណាក់កាល (Milestone Paper) ដើម្បីទុកជាគោលការណ៍ណែនាំដល់ការបង្កើតកម្មវិធីការងារបន្ទាស់ទីរូបវន្តបុគ្គលឆ្នាំ២០២៥-២០២៧។ |

| | |
|---|---|
| | • រៀបចំសេចក្ដីជូនដំណឹងដល់អង្គការ WTO អំពីការអនុវត្តកញ្ចប់សន្យាវិស័យសេវាកម្ម ក្រោមកិច្ចព្រមព្រៀងក្របខណ្ឌអាស៊ានស្ដីពីសេវាកម្ម។ |
| កិច្ចប្រជុំពិសេស នៃគណៈកម្មាធិការសម្របសម្រួលសេវាកម្មអាស៊ាន ចំនួន ៤លើក | • ពិភាក្សា និងបញ្ចប់ការចរចា ក្របខណ្ឌកិច្ចសម្រួលពាណិជ្ជកម្មសេវាកម្មអាស៊ាន ដែលជាសមិទ្ធផលអាទិភាពសេដ្ឋកិច្ចរបស់ឥណ្ឌូណេស៊ី។<br>• បន្តសម្អាតវាក្យសព្ទបច្ចេកទេស នៅក្នុងអត្ថបទចុងក្រោយនៃក្របខណ្ឌនេះ។ |
| កិច្ចប្រជុំគណៈកម្មាចរចាដំឡើងកម្រិតកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន ៧លើក | ពិភាក្សាលើសេចក្តីព្រាងជំពូកស្ដីពីប្រព្រឹត្តកម្មជាតិនិងការបើកទីផ្សារទំនិញ រួមមាន៖(១) លទ្ធភាពនៃការផ្ដល់ភាពអនុគ្រោះពន្ធគយលើទំនិញរបស់ប្រទេសនាំចេញ ដែលនាំចូលវិញដោយប្រទេសនោះ (២) ទំនិញដែលផលិតឡើងវិញ(Remanufactured Goods) (៣) ប្រព្រឹត្តកម្មប្រជាជាតិដែលទទួលបានការអនុគ្រោះបំផុត (MFN)(៤) ការពិចារណាពិសេសសម្រាប់អង្ករ និងស្ករស (៥) ការផ្ទេរបញ្ជីកាត់បន្ថយពន្ធគយ (៦) ការកាត់បន្ថយ ឬលុបបំបាត់កាតព្វកិច្ចនាំចូល និងបញ្ហា ដែលអនុក្រុមការងារនានា បានស្នើមកកាន់កិច្ចប្រជុំគណៈកម្មាធិការចរចាពាណិជ្ជកម្មដំឡើងកម្រិតកិច្ចព្រមព្រៀងអាស៊ានស្ដីពីពាណិជ្ជកម្មទំនិញ។ |
| កិច្ចប្រជុំគណៈកម្មាធិការចម្រុះនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ លើកទី២០ | • បញ្ចប់ការចរចាដំឡើងកម្រិតកិច្ចព្រមព្រៀងនេះ នៅក្រោមពិធីសារទីពីរ ដែលមានចំនួនសរុប ២០ជំពូក។<br>• អនុម័តកម្មវិធីការងារកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច២០២៣ ដើម្បីគាំទ្រការអនុវត្តកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់។<br>• ឯកភាពលើនីតិវិធី ចុះហត្ថលេខាពិធីសារទី២ ដើម្បីធ្វើវិសោធនកម្ម កិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់។ |
| កិច្ចប្រជុំគណៈកម្មាធិការចរចាដំឡើងកម្រិតកិច្ចព្រមព្រៀងអាស៊ាន-ចិន និងកិច្ចប្រជុំពាក់ព័ន្ធ ចំនួន ៤លើក | • អនុម័តឯកសារ នីតិវិធីការងារ សម្រាប់គណៈកម្មាធិការរួមពិសេសសម្រាប់ការចរចាដំឡើងកម្រិតកិច្ចព្រមព្រៀងACFTA3.0 និង ក្រមសីលធម៌រួមសម្រាប់អ្នកចរចា។<br>• ឯកភាពបង្កើតក្រុមការងារចរចាពាក់ព័ន្ធចំនួន១២។<br>• ឯកភាពឱ្យក្រុមអ្នកជំនាញពាណិជ្ជកម្មសេវាកម្ម ចូលរួមកិច្ចប្រជុំបន្ទាប់របស់ក្រុមការងារវិនិយោគ និងក្រុមអ្នកជំនាញវិធានប្រភពដើម ចូលរួមកិច្ចប្រជុំបន្ទាប់របស់ក្រុមការងារកិច្ចសម្រួលពាណិជ្ជកម្ម។<br>• ឯកភាពបង្កើតក្រុមអ្នកជំនាញលើការតភ្ជាប់ខ្សែច្រវាក់ផ្គត់ផ្គង់ ដើម្បីពិភាក្សាជាមួយភាគីចិន ពាក់ព័ន្ធនឹងវិសាលភាពដែលភាគីចិនចង់បានសម្រាប់ការងារ តភ្ជាប់ខ្សែច្រវាក់ផ្គត់ផ្គង់។<br>• ធ្វើបច្ចុប្បន្នភាពផែនការការងារ ដើម្បីសម្រេចបញ្ចប់ការចរចាដំឡើងកម្រិតកិច្ចព្រមព្រៀងនេះនៅឆ្នាំ២០២៤។ |
| កិច្ចប្រជុំគណៈកម្មាធិការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កាណាដា និងកិច្ចប្រជុំក្រុមការងារពាក់ព័ន្ធ ចំនួន៦លើក | • អនុម័តឯកសារលក្ខខណ្ឌប្រតិបត្តិការងារ និងគោលការណ៍ណែនាំសម្រាប់ការចរចា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កាណាដា។<br>• ឯកភាពបង្កើតក្រុមការងារចរចាពាក់ព័ន្ធចំនួន១៧ ។ |

| | |
|---|---|
| | • ឯកភាពបង្កើតក្រុមអ្នកជំនាញដាច់ដោយឡែកចំនួន ៣ គឺក្រុមអ្នកជំនាញស្តីពីបរិស្ថាន ក្រុមអ្នកជំនាញស្តីពីពលកម្ម និងក្រុមអ្នកជំនាញស្តីពីបរិយាប័ន្នពាណិជ្ជកម្ម។<br>• ឯកភាពបង្កើតក្រុមការងារបន្ថែម រួមមានក្រុមការងារស្តីពីសហគ្រាសរដ្ឋ (SOE) និងក្រុមការងារស្តីពីការប្រតិបត្តិល្អលើបទដ្ឋានគតិយុត្តិ (GRP)។<br>• ធ្វើបច្ចុប្បន្នភាពផែនការការងារ ដើម្បីសម្រេចបញ្ចប់ការចរចានៅឆ្នាំ២០២៥។ |
| រៀបចំឯកសារពាក់ព័ន្ធ ទៅអន្តរក្រសួង/ស្ថាប័ន ដើម្បីប្រមូលធាតុចូល និងវឌ្ឍនភាពសម្រាប់ការងារក្រោមក្របខណ្ឌអាស៊ាន ដៃគូអាស៊ាន អនុតំបន់ និងទ្វេភាគី | បានប្រមូលធាតុចូល និងសំយោគធាតុចូលទាំងនេះសម្រាប់ប្រើប្រាស់ និងទុកជាឯកសារយោង |
| រៀបចំជំនួយស្មារតី និងចំណុចពិភាក្សា គោរពជូន **សម្តេចធិបតីនាយករដ្ឋមន្ត្រី** សម្រាប់ដំណើរទស្សនកិច្ចផ្លូវការទៅកាន់ប្រទេសចិន សម្រាប់កិច្ចប្រជុំកំពូលអាស៊ាន-ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ សម្រាប់កិច្ចប្រជុំកំពូលអាស៊ានលើកទី៤២ និង៤៣ កិច្ចប្រជុំកំពូលធុរកិច្ចអាស៊ាន ជំនួបទ្វេភាគីជាមួយនាយករដ្ឋមន្ត្រីថៃ វេទិកាខ្សែក្រវ៉ាត់និងផ្លូវលើកទី៣ និងសម្រាប់ជំនួបទ្វេភាគីផ្សេងៗទៀត | ឯកសារបានរៀបចំសព្វគ្រប់ និងបញ្ជូនទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងខុទ្ទកាល័យសម្តេចធិបតី។ |
| រៀបចំបំពេញនីតិវិធីក្នុងស្រុកដើម្បីស្នើសុំសច្ចាប័នពីអង្គនីតិប្បញ្ញត្តិលើសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ាន | សេចក្តីព្រាងច្បាប់នេះត្រូវបានអនុម័តរួចរាល់ និងជូនដំណឹងទៅលេខាធិការដ្ឋានអាស៊ានរួចហើយ |
| រៀបចំនីតិវិធីស្នើសុំសិទ្ធិប្រទានជូន **លោកជំទាវរដ្ឋមន្ត្រី** ចុះហត្ថលេខាលើពិធីសារទី២ ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ និងពិធីសារទី១ ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុងនៃប្រទេសចិន និងកិច្ចសម្រុះសម្រួលស្តីពីការទទួលស្គាល់គ្នាទៅវិញទៅមកក្នុងវិស័យមួយចំនួនក្រោមក្របខ័ណ្ឌអាស៊ាន | **សម្តេចធិបតី** បានផ្តល់សិទ្ធិប្រទានជូន **លោកជំទាវរដ្ឋមន្ត្រី** ដើម្បីចុះហត្ថលេខាលើពិធីសារទាំងពីរ និងកិច្ចសម្រុះសម្រួលស្តីពីការទទួលស្គាល់គ្នាទៅវិញទៅមកក្នុងវិស័យមួយចំនួនក្រោមក្របខណ្ឌអាស៊ាន។ |

| **២. កិច្ចការអនុតំបន់** | |
|---|---|
| **កម្ពុជា-ឡាវ-វៀតណាម** | |
| ពិនិត្យ ផ្តល់ធាតុចូល សេចក្តីព្រាងរបាយការណ៍ស្តីពី «វឌ្ឍនភាពនៃការអនុវត្តការតភ្ជាប់សេដ្ឋកិច្ចកម្ពុជា-ឡាវ-វៀតណាម រហូតដល់ឆ្នាំ២០៣០» | បានសម្របសម្រួលជាមួយក្រសួង/ស្ថាប័នពាក់ព័ន្ធ ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាង រួចបញ្ជូនទៅភាគីវៀតណាម ដែលជាអ្នករៀបចំរបាយការណ៍រួចរាល់ |
| បានរៀបចំលិខិតផ្លូវការស្នើសុំភាគីឡាវពិចារណាលើកកាលបរិច្ឆេទប្រជុំគណៈកម្មាធិការសម្របសម្រួលចម្រុះសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ត្រីកោណកម្ពុជា-ឡាវ-វៀតណាម លើកទី១៣ នៅប្រទេសឡាវ ទៅខែមករា ឆ្នាំ២០២៤ | បានបញ្ជូនលិខិតតាមក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងរង់ចាំចម្លើយពីភាគីឡាវ |

| | |
|---|---|
| រៀបចំឯកសារជំនួយស្មារតីនិងវឌ្ឍនភាព ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្រាប់ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់នយោបាយលើកទី៨ រវាងកម្ពុជា និងវៀតណាម | បានបញ្ជូនឯកសារពាក់ព័ន្ធទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិរួចរាល់ |
| រៀបចំឯកសារ និងចូលរួមកិច្ចប្រជុំកំពូលសភាកម្ពុជា-ឡាវ-វៀតណាម (CLV) លើកទី១ ស្តីពីការពង្រឹងតួនាទីសភាដើម្បីជំរុញកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយរវាងប្រទេសទាំងបី នៅប្រទេសឡាវ | - ពិភាក្សា និងផ្តល់យោបល់លើវឌ្ឍនភាពការងាររបស់គណៈកម្មការសម្របសម្រួលចម្រុះ (JCC) ដើម្បីរាយការណ៍ជូនកិច្ចប្រជុំកំពូលធ្វើការពិនិត្យពិចារណា<br>- រៀបចំរបាយការណ៍វឌ្ឍនភាពការអនុវត្តគម្រោងក្នុងតំបន់ CLV-DTA និងស្នើសុំការសម្របសម្រួលពីកិច្ចប្រជុំសម្រាប់ការអនុវត្តបន្តឱ្យមានប្រសិទ្ធភាព<br>- លើកសំណើគំនិតយោបល់បច្ចេកទេសជូនប្រតិភូអង្គនីតិបញ្ញត្តិ សម្រាប់ធ្វើការពិភាក្សាក្នុងកិច្ចប្រជុំកំពូល |
| រៀបចំរបាយការណ៍វឌ្ឍនភាពតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម (CLV-DTA) ជូនអគ្គលេខាធិការដ្ឋានរដ្ឋសភាសម្រាប់ពិនិត្យមើលការងារអភិវឌ្ឍន៍ជាក់ស្តែងនៅតាមបណ្តាខេត្តជាប់ព្រំដែននៃប្រទេសទាំងបី | បានបញ្ជូនឯកសារពាក់ព័ន្ធទៅអគ្គលេខាធិការដ្ឋានរដ្ឋសភារួចរាល់ |
| បញ្ជូនលិខិតទៅអន្តរក្រសួង/ស្ថាប័នពាក់ព័ន្ធដើម្បីធ្វើបច្ចុប្បន្នភាពសមាជិកអនុគណៈកម្មការជំនាញទាំងបួនក្រោមគណៈកម្មាធិការជាតិសម្របសម្រួលកិច្ចសហប្រតិបត្តិការតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម | បានទទួលសមាសភាពថ្មីពីអន្តរក្រសួង/ស្ថាប័នពាក់ព័ន្ធ ហើយកំពុងរៀបចំប្រកាសក្រុមការងារថ្មីនេះ |
| **សមាហរណកម្មអាស៊ាន** | |
| ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីវាយតម្លៃលទ្ធផលផែនការការងារសមាហរណកម្មអាស៊ានលើកទី៣ (IAI Work Plan III) តាមប្រព័ន្ធវីដេអូ | បានធ្វើបច្ចុប្បន្នភាពវឌ្ឍនភាពការអនុវត្តគម្រោង ផែនការសកម្មភាព ដើម្បីចូលរួមកាត់បន្ថយគម្លាតអភិវឌ្ឍន៍ក្នុងអាស៊ាន |
| ចូលរួមពិភាក្សាជាមួយលេខាធិការដ្ឋានអាស៊ានទទួលបន្ទុកកិច្ចការ IAI និងវិទ្យាស្ថានមេគង្គ តាមប្រព័ន្ធវីដេអូ ដើម្បីរៀបចំសិក្ខាសាលា ក្រោមក្របខណ្ឌអភិវឌ្ឍន៍កម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-វៀតណាម។ | ភាគីពាក់ព័ន្ធឯកភាពលើខ្លឹមសារ និងរបៀបវារៈសិក្ខាសាលា និងរង់ចាំភាគីគូរដែលជាម្ចាស់ជំនួយ ពិនិត្យ និងសម្រេច |
| **មេគង្គ-ឡានឆាង** | |
| បានចូលរួមកិច្ចពិគ្រោះយោបល់ស្តីពីអនាគតរបស់តំបន់មេគង្គលើប្រធានបទ «ការប្រមូលយកកិច្ចសហការក្នុងតំបន់សម្រាប់ផ្តល់កិច្ចសម្រួលពាណិជ្ជកម្មឆ្លងកាត់ព្រំដែន និងភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់» | ទទួលបានការចែករំលែកនូវបទពិសោធន៍ និងការអនុវត្តជាក់ស្តែងក្នុងការសម្របសម្រួលនៃបម្លាស់ទីទំនិញ និងសេវាកម្មពាក់ព័ន្ធនឹងនីតិវិធីគយនៅតាមព្រំដែន ដើម្បីជួយសម្រួលសកម្មភាពពាណិជ្ជកម្ម របស់ប្រទេសជាសមាជិក |
| ពិនិត្យ និងផ្តល់ធាតុចូលលើសេចក្តីព្រាងឯកសារពាក់ព័ន្ធសម្រាប់កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-ឡានឆាង លើកទី៨ | បានបញ្ជូនចម្លើយ និងធាតុចូលទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិរួចហើយ |
| **មហាអនុតំបន់មេគង្គ** (GMS) | |
| ចូលរួមកិច្ចប្រជុំលើកទី២ នៃក្រុមការងារស្តីពីពាណិជ្ជកម្ម និងវិនិយោគក្រោមក្របខណ្ឌGMS | ពិនិត្យឡើងវិញនូវវឌ្ឍនភាពការអនុវត្តផែនការសកម្មភាពដែលបានអនុម័ត និងពិនិត្យឯកសារទស្សនទានស្តីពីខ្សែច្រវាក់ផ្គត់ផ្គង់ឌីជីថល និងគំនិតផ្តួចផ្តើម ក្នុងGMS |

| | |
|---|---|
| រៀបចំជំនួយស្មារតី និងសុន្ទរកថា ជូនលោកជំទាវរដ្ឋមន្ត្រីសម្រាប់ថ្លែងសុន្ទរកថាគន្លឹះបើកក្នុងវេទិកាស្តីពី Connectivity & Growth in the Mekong Region within ASEAN | សុន្ទរកថាផ្តោតលើចំនុចសំខាន់ៗនៃការតភ្ជាប់ កំណើនសេដ្ឋកិច្ច ក្នុងតំបន់មេគង្គ |
| **អេកម៉ិក** (ACMECS) | |
| ចូលរួមកិច្ចប្រជុំគម្រោងថ្នាក់តំបន់ ACMECS-ROK ស្តីពី "ការសម្រួលពាណិជ្ជកម្មឆ្លងកាត់ព្រំដែន តាមរយៈការធ្វើសមកាលកម្មច្បាប់ និងបទប្បញ្ញត្តិក្នុងប្រទេសសមាជិកអេកម៉ិក" | គម្រោងត្រូវបានប្រកាសអោយអនុវត្តចាប់ពីដើមខែឧសភា ឆ្នាំ២០២៣ រហូតដល់ចុងខែមេសា ឆ្នាំ២០២៤ |
| ធ្វើទស្សនកិច្ចសិក្សា ស្តីពីការអនុវត្តពាណិជ្ជកម្មឌីជីថល នៅសាធារណរដ្ឋកូរ៉េ | បានស្វែងយល់ពីការអនុវត្តជាក់ស្តែងពាណិជ្ជកម្មឌីជីថល បញ្ហាប្រឈម និងឱកាសឈានទៅរកការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម ដែលជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មឌីជីថល |
| **អេម៉ិក** (AMEICC) | |
| បានសម្របសម្រួលជាមួយ AMEICC ជប៉ុន រៀបចំខ្លឹមសារចំណាប់អារម្មណ៍ភាគីកម្ពុជា ដើម្បីបោះផ្សាយក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ AMEICC | របាយការណ៍ប្រចាំឆ្នាំបានបោះផ្សាយរួចដោយបញ្ចូលខ្លឹមសារពេញលេញរបស់ភាគីកម្ពុជា |
| ចូលរួមកិច្ចប្រជុំក្រុមការងារច្រករបៀងសេដ្ឋកិច្ចបស្ចិមនិងបូព៌ា (West-East Corridor) | តាមដានវឌ្ឍនភាពការអនុវត្តគម្រោងក្រោមក្របខណ្ឌមេគង្គ-ជប៉ុន និងកំណត់ផែនការអនុវត្តបន្តសម្រាប់ ឆ្នាំ២០២៤ |

| | |
|---|---|
| **<u>៣. ពាណិជ្ជកម្មទ្វេភាគី</u>** | |
| រៀបចំរបាយការណ៍វឌ្ឍនភាព ជំនួយស្មារតី និងចំណុចពិភាក្សា ស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មកម្ពុជា-វៀតណាម ជូន **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** សម្រាប់ជំនួបជាមួយនាយករដ្ឋមន្ត្រីវៀតណាមក្នុងកំឡុងពេលទស្សនកិច្ចផ្លូវការនៅប្រទេសវៀតណាម | បានបញ្ជូនរបាយការណ៍វឌ្ឍនភាព ជំនួយស្មារតី និងចំណុចពិភាក្សាទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| បានចូលកិច្ចប្រជុំគណៈកម្មាធិការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន លើកទី១ | តាមដានវឌ្ឍនភាពការអនុវត្តកិច្ចព្រមព្រៀង CCFTAនិងដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការអនុវត្តកិច្ចព្រមព្រៀងនេះ |
| រៀបចំរបាយការណ៍វឌ្ឍនភាព ជំនួយស្មារតី និងចំណុចពិភាក្សា ស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មកម្ពុជា-ថៃ ជូន **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** សម្រាប់ជំនួបជាមួយនាយករដ្ឋមន្ត្រីថៃក្នុងកំឡុងពេលទស្សនកិច្ចផ្លូវការនៅកម្ពុជា | បានបញ្ជូនរបាយការណ៍វឌ្ឍនភាព ជំនួយស្មារតី និងចំណុចពិភាក្សាទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| ចូលរួមកិច្ចប្រជុំលើកទី១ នៃគណៈកម្មាធិការ ស្តីពីពាណិជ្ជកម្ម ការវិនិយោគ សហគ្រាស និងនវានុវត្តន៍ធុរកិច្ច នៅទីក្រុងបាងកក ប្រទេសថៃ | សម្រេចបាននូវអនុសាសន៍ចំនួន៦ចំណុចផ្តល់ជូនគណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់ESCAPសម្រាប់ពិចារណា លើសកម្មភាពអនាគត។ |
| រៀបចំរបាយការណ៍វឌ្ឍនភាព និងយោបល់ស្តីពីកិច្ចសហប្រតិបត្តិការកម្ពុជា-ចិន ដើម្បីរៀបចំសំណុំឯកសារគោរពជូន **សម្តេចតេជោ អតីតនាយករដ្ឋមន្ត្រី** សម្រាប់ដំណើរទស្សនកិច្ចផ្លូវការទៅកាន់ប្រទេសចិន | បានបញ្ជូនរបាយការណ៍វឌ្ឍនភាព និងយោបល់ស្តីពីកិច្ចសហប្រតិបត្តិការកម្ពុជា-ចិនទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |

| | |
|---|---|
| *ចូលរួមកិច្ចប្រជុំលើកទី២០ របស់គណៈកម្មការចម្រុះកម្ពុជា-វៀតណាម ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៅទីក្រុងហាណូយ ប្រទេសវៀតណាម* | *- ជំរុញអនុវត្ត ឱ្យមានប្រសិទ្ធភាពកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មព្រំដែនកម្ពុជា-វៀតណាម ឆ្នាំ២០២២ និងប្តេជ្ញាអនុវត្ត"អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការក្នុងការជំរុញពាណិជ្ជកម្ម"។ -ឯកភាពចុះហត្ថលេខាកិច្ចព្រមព្រៀងស្តីពីការលើកកម្ពស់ពាណិជ្ជកម្មទ្វេភាគីកម្ពុជា-វៀតណាមសម្រាប់ឆ្នាំ២០២៣-២០២៤* |
| *ចូលរួមកិច្ចប្រជុំលើកទី១២ ស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម នៅប្រទេសវៀតណាម* | *បានវាយតម្លៃខ្ពស់នូវលទ្ធផលជាវិជ្ជមាននៃកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសទាំងពីរ និងឯកភាពពន្លឿនការបញ្ចប់នីតិវិធីផ្ទៃក្នុងការផ្តល់សច្ចាប័នអនុម័តយល់ព្រមកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មតាមព្រំដែន រវាងប្រទេសទាំងពីរ។* |
| *ចូលរួមកិច្ចប្រជុំគណៈកម្មការចម្រុះកម្ពុជា-សាធារណៈរដ្ឋកូរ៉េ លើកទី៥ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ* | *បានរៀបចំឯកសារពាក់ព័ន្ធ និងស្នើបញ្ចូលធាតុចូលទាក់ទងនឹងវិស័យពាណិជ្ជកម្ម ដើម្បីជូនភាគីកូរ៉េពិចារណាក្នុងការនាំចូលកសិផលបន្ថែមពីកម្ពុជា និងស្នើក្រុមហ៊ុនវិនិយោគធំៗរបស់សាធារណៈរដ្ឋកូរ៉េ ចូលមកវិនិយោគកាន់តែច្រើនថែមទៀតនៅកម្ពុជា* |
| *រៀបចំបំពេញនីតិវិធីក្នុងស្រុកដើម្បីស្នើសុំសច្ចាប័នពីអង្គនីតិប្បញ្ញត្តិលើសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មតាមព្រំដែនរវាងកម្ពុជានិងវៀតណាម* | *កិច្ចព្រមព្រៀងបានទទួលសច្ចាប័នហើយបានចូលជាធរមាន នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣* |
| *បានពិនិត្យខ្លឹមសារ និងផ្តល់ធាតុចូលការសិក្សាសមិទ្ធផលស្តីពីលទ្ធភាពបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ឥណ្ឌា ដែលការសិក្សានេះធ្វើឡើងដោយវិទ្យាស្ថានសិក្សាស្រាវជ្រាវសេដ្ឋកិច្ចអាស៊ាន និងអាស៊ីបូព៌ា (ERIA)* | *វិទ្យាស្ថាន ERIA បានបញ្ចប់ការសិក្សានេះ ហើយត្រៀមបោះផ្សាយរបាយការណ៍ជាសាធារណៈ (Public Report) និងរៀបចំកម្មវិធីផ្សព្វផ្សាយស្នាដៃនេះនៅកម្ពុជា* |
| *រៀបចំជំនួយស្មារតី និងចំណុចពិភាក្សា សម្រាប់ជំនួបទ្វេភាគីជាមួយឯកអគ្គរាជទូតកូរ៉េប្រចាំកម្ពុជា* | *ភាគីទាំងពីរបានពិភាក្សាអំពីការបង្កើនកិច្ចសហប្រតិបត្តិការក្នុងការពង្រឹង និងពង្រីកការធ្វើពាណិជ្ជកម្ម រវាងប្រទេសទាំងពីរ ព្រមទាំងស្វែងរកកិច្ចគាំទ្រពីសាធារណៈរដ្ឋកូរ៉េសម្រាប់ការធ្វើជាម្ចាស់ផ្ទះពិព័រណ៍ពិភពលោកឆ្នាំ២០៣០* |
| *រៀបចំជំនួយស្មារតី និងចំណុចពិភាក្សា សម្រាប់ជំនួបទ្វេភាគីជាមួយនាយកវិទ្យាស្ថានសិក្សាស្រាវជ្រាវសេដ្ឋកិច្ចអាស៊ាន និងអាស៊ីបូព៌ា (ERIA) និងជំនួបជាមួយវិស័យឯកជន និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត* | *ភាគីទាំងពីរបានពិភាក្សាអំពីការពង្រឹងកិច្ចសហប្រតិបត្តិការ រវាងក្រសួងពាណិជ្ជកម្ម និងវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចអាស៊ាន និងអាស៊ីបូព៌ា ដោយផ្តោតសំខាន់លើការបណ្តុះបណ្តាលនិងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការសិក្សាស្រាវជ្រាវលើលទ្ធភាព ផលចំណេញ និងបញ្ហាប្រឈមក្នុងការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ជាមួយនឹងបណ្តាប្រទេសមួយចំនួន* |
| *រៀបចំជំនួយស្មារតី និងចំណុចពិភាក្សា សម្រាប់ជំនួបជាមួយឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា* | *ភាគីទាំងពីរ បានពិភាក្សាអំពីការបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តរបស់ឥណ្ឌាចំពោះកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម ជាមួយនឹងប្រទេសកម្ពុជា និងបានឯកភាពរៀបចំនូវកិច្ចប្រជុំលើកទី២នៃក្រុមការងារចម្រុះសម្រាប់ពាណិជ្ជកម្មនិងការវិនិយោគ នៅក្នុងចុងឆ្នាំ២០២៣ ដោយភាគីឥណ្ឌាបានយល់ព្រមធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំនេះ។* |
| *រៀបចំជំនួយស្មារតី និងចំណុចពិភាក្សា សម្រាប់ជំនួបជាមួយឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា* | *ភាគីទាំងពីរ បានពិភាក្សាអំពីសមិទ្ធផលពីមុន និងកិច្ចសហប្រតិបត្តិការបន្ថែមទៀតរវាងក្រសួងពាណិជ្ជកម្ម និងភាគី ជប៉ុន ដើម្បីពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ចជាមូលដ្ឋាន ដោយផ្តោតសំខាន់លើពាណិជ្ជកម្ម និងការវិនិយោគរវាង កម្ពុជា និងជប៉ុន។* |

| | |
|---|---|
| រៀបចំជំនួយស្មារតី និងចំណុចពិភាក្សា សម្រាប់ជំនួបជាមួយឯកអគ្គរាជទូតថៃប្រចាំកម្ពុជា | ភាគីទាំងពីរបានពិភាក្សាអំពីការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មទ្វេភាគី និងកិច្ចសម្រួលពាណិជ្ជកម្ម ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការធ្វើអាជីវកម្មតាមច្រកព្រំដែន ជាពិសេសគឺការនាំចេញនូវទំនិញកសិផលពីប្រទេសកម្ពុជាទៅកាន់ប្រទេសថៃ។ |

## ៤.២. កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មជាមួយអឺរ៉ុប មជ្ឈិមបូព៌ា និងអាហ្វ្រិក

| បរិយាយការងារ | | លទ្ធផល |
|---|---|---|
| សហភាពអឺរ៉ុប | ភាគីកម្ពុជា និងភាគីវៀតណាមបានដាក់សំណើរួមគ្នាទៅកាន់សហភាពអឺរ៉ុបនិងចក្រភពអង់គ្លេសស្តីពីការប្រើវិធានប្តូកបន្ថែមសម្រាប់ឧស្សាហកម្មគ្រឿងបង្គុំទោចក្រយាននៅកម្ពុជា | សហភាពអឺរ៉ុប និងចក្រភពអង់គ្លេស បានឆ្លើយតបឯកភាពចំពោះសំណើនេះ |
| ចក្រភពអង់គ្លេស | សហការជាមួយស្ថានទូតចក្រភពអង់គ្លេសនៅកម្ពុជា និងសភាពាណិជ្ជកម្មកម្ពុជា រៀបចំវេទិកាពាណិជ្ជកម្ម និងវិនិយោគរួមគ្នាលើកទី១ កម្ពុជា-ចក្រភពអង់គ្លេស ចូលរួមដោយតំណាងអន្តរក្រសួង វិស័យឯកជនកម្ពុជានិងវិស័យឯកជនចក្រភពអង់គ្លេស | វិស័យឯកជនបានយល់ច្បាស់ពីលក្ខខណ្ឌទីផ្សារ លក្ខខណ្ឌផលិត និងតម្រូវការផ្នែកច្បាប់មួយចំនួនទៀតទាក់ទងនឹងពាណិជ្ជកម្ម-វិនិយោគទ្វេភាគី |
| ហុងគ្រី | រៀបចំកិច្ចប្រជុំអន្តរក្រសួងពិនិត្យវឌ្ឍនភាពការងារ ក្រោយកិច្ចប្រជុំលើកទី១ គណៈកម្មការចម្រុះកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចកម្ពុជា-ហុងគ្រី | អន្តរក្រសួងឯកភាពពិនិត្យតាមដានការអនុវត្តបន្តកិច្ចព្រមព្រៀង/អនុស្សរណៈដែលបានចុះហត្ថលេខាដោយភាគីទាំងពីរ និងផ្តល់ធាតុចូលសម្រាប់កិច្ចប្រជុំលើកទី២ នៅហុងគ្រី |
| កាហ្សាក់ស្ថាន | រៀបចំកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាសេចក្តីព្រាងអនុស្សរណៈកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មនិងសេដ្ឋកិច្ចរវាងកម្ពុជានិងកាហ្សាក់ស្ថាន | កម្ពុជាបានផ្ញើសេចក្តីព្រាងឆ្លើយតបអនុស្សរណៈ នេះទៅភាគីកាហ្សាក់ស្ថាន តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| អាស៊ែបៃហ្សង់ | បានពិនិត្យនិងឯកភាពលើខ្លឹមសារសេចក្តីព្រាងតបដែលកែសម្រួលដោយអាស៊ែបៃហ្សង់លើអនុស្សរណៈកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងពាណិជ្ជកម្ម | ភាគីទាំងពីរនឹងកំណត់ពេលសមស្រប ដើម្បីចុះហត្ថលេខាលើអនុស្សរណៈនេះ បន្ទាប់ពីទទួលចម្លើយវិជ្ជមានពីអាស៊ែបៃហ្សង់ |
| អឺរ៉ុប | រៀបចំជំនួបពិភាក្សាការងារ និងសម្តែងការគួរសមទ្វេភាគីរវាងថ្នាក់ដឹកនាំក្រសួង និងបណ្តាប្រទេសនៅតំបន់អឺរ៉ុបរួមមាន៖ សហភាពអឺរ៉ុប, បារាំង, ស៊ុយអែត,ប៊ុលហ្គារី,ហុងគ្រី, អ៊ីតាលី,ឆែក និងចក្រភពអង់គ្លេស | ជំនួបបានលើកឡើងអំពីការលើកកម្ពស់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងវិនិយោគព្រមទាំង ឆ្លុះបញ្ចាំងពីទំនាក់ទំនងល្អកន្លងមករវាងភាគីទាំងពីរ |
| អង្គការ OECD | សហការជាមួយអង្គការសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច រៀបចំកម្មវិធីដាក់សម្ពោធព្រឹត្តិបត្រព្យាករណ៍សេដ្ឋកិច្ចសម្រាប់តំបន់អាស៊ីអាគ្នេយ៍ ចិន និងឥណ្ឌាឆ្នាំ ២០២២ តាមប្រព័ន្ធវីដេអូ | ព្រឹត្តិបត្រព្យាករណ៍សេដ្ឋកិច្ចសម្រាប់តំបន់អាស៊ីអាគ្នេយ៍ នឹងឆ្លុះបញ្ចាំងទិន្នន័យជាក់ស្តែងរបស់ទីផ្សារ និងការព្យាករណ៍សេដ្ឋកិច្ច ដែលផ្តល់អត្ថប្រយោជន៍ ដល់កម្ពុជាក្នុងការធ្វើពាណិជ្ជកម្មក្នុងតំបន់ |
| តួកគី | រៀបចំកិច្ចប្រជុំលើកទី៣គណៈកម្មការសេដ្ឋកិច្ចចម្រុះកម្ពុជា-តួកគី ដើម្បីបន្តពង្រឹង និងពង្រីកទំហំពាណិជ្ជកម្ម, វិនិយោគ, ការធ្វើធុរកិច្ច និងវិស័យសក្តានុពលមួយចំនួនទៀត ក្នុងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ | ភាគីទាំងពីរឯកភាពក្នុងការពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការ លើវិស័យសក្តានុពលដើម្បីបង្កើនទំហំពាណិជ្ជកម្ម វិនិយោគ នាពេលអនាគត |

| | | |
|---|---|---|
| កូរ៉េ | បានស្នើសុំគោលការណ៍ពីរាជរដ្ឋាភិបាល ដើម្បីចូលរួមកិច្ចប្រជុំលើកទី២ គណៈកម្មាធិការពាណិជ្ជកម្មចម្រុះកម្ពុជា-កូរ៉េ នៅរដ្ឋកូរ៉េ | កម្ពុជានឹងសហការជាមួយកូរ៉េ កំណត់ពេលសមស្របម្រាប់កិច្ចប្រជុំនេះ នៅដើមឆ្នាំ២០២៤ |
| អេមីរ៉ាតអារ៉ាប់រួម | បានរៀបចំពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម (CEPA) នៅភ្នំពេញ | បានចុះហត្ថលេខារួចរាល់ កាលពីថ្ងៃទី៨ មិថុនា ២០២៣ |
| | បានបំពេញនីតិវិធីផ្ទៃក្នុងដោយរៀបចំសេចក្តីថ្លែងហេតុ និងសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម បញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី | គណៈរដ្ឋមន្ត្រី បានយល់ព្រមលើខ្លឹមសារសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣ ហើយបានបញ្ជូនទៅស្ថាប័ននីតិប្បញ្ញត្តិដើម្បីពិនិត្យ និងផ្តល់សច្ចាប័ន |
| | រៀបចំវេទិកាធុរកិច្ចលើកទី២កម្ពុជា-អេមីរ៉ាតអារ៉ាប់រួម នៅភ្នំពេញ | ជារួមធុរជននៃប្រទេសទាំងពីរបានជួបប្រាស្រ័យ និងស្វែងយល់ទៅវិញទៅមកពីបរិយាកាសធុរកិច្ចវិនិយោគក្នុងវិស័យថាមពល កសិកម្ម និងវិស័យកសាងការកម្ម |
| កាតា | - ភាគីទាំងពីរបានឯកភាពសេចក្តីព្រាងចុងក្រោយ នៃកិច្ចព្រមព្រៀងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម និងបច្ចេកទេសរវាងកម្ពុជា កាតា<br>- បានរៀបចំស្នើសុំសិទ្ធប្រទានពីរាជរដ្ឋាភិបាលដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ | រាជរដ្ឋាភិបាលបានប្រគល់សិទ្ធប្រទានជូនរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មដើម្បីចុះហត្ថលេខា។ ភាគីទាំងពីរនឹងកំណត់ពេលវេលាសមស្របសម្រាប់ចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះនៅរដ្ឋកាតា |
| អារ៉ាប៊ីសាអូឌីត | បានបញ្ជូនសេចក្តីព្រាងនៃអនុស្សរណៈស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មរវាងកម្ពុជា-អារ៉ាប៊ីសាអូឌីត ទៅភាគីអារ៉ាប៊ីសាអូឌីត តាមរយៈ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ភាគីអារ៉ាប៊ីសាអូឌីត បានឆ្លើយតបជាខ្លឹមសារកែតម្រូវត្រលប់មកវិញ ហើយក្រសួងនឹងរៀបចំប្រជុំអន្តរក្រសួងដើម្បីពិនិត្យសេចក្តីព្រាងតបនេះ |
| | រៀបចំកិច្ចពិភាក្សាការងារ រវាងថ្នាក់ដឹកនាំក្រសួង និងបណ្តាប្រទេសនៅមជ្ឈឹមបូព៌ា៖ អេមីរ៉ាតអារ៉ាប់រួម,តួកគី, អារ៉ាប៊ីសាអូឌីត, កាតា និងកូវ៉ែត | ជំនួបទាំងនេះជំរុញឱ្យមានការបង្កើតលិខិតុបករណ៍ដើម្បីប្រើប្រាស់ជាក្របខណ្ឌ សម្រាប់លើកកម្ពស់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចទ្វេភាគី ជាមួយបណ្តាប្រទេសដៃគូនៅមជ្ឈឹមបូព៌ា |
| ម៉ូរ៉ុក | បានរៀបចំកិច្ចប្រជុំផ្ទៃក្នុង និងកិច្ចប្រជុំអន្តរក្រសួងកែសម្រួលសេចក្តីព្រាងកិច្ចព្រមព្រៀងក្របខណ្ឌស្តីពីសហប្រតិបត្តិការរវាងកម្ពុជានិងម៉ូរ៉ុក | អន្តរក្រសួងបានឯកភាពកែសម្រួលប្តូរទម្រង់កិច្ចព្រមព្រៀងក្របខណ្ឌនេះ ទៅជាអនុស្សរណៈវិញ ហើយបានបញ្ជូនសេចក្តីព្រាងតបទៅភាគីម៉ូរ៉ុក តាមទំនាក់ទំនងការទូត |
| | បានសម្របសម្រួលតាមសំណើរបស់ភាគីម៉ូរ៉ុកជំរុញឱ្យស្ថាប័នពាក់ព័ន្ធ៖ MISTI, MPTC និង MEF ឆ្លើយតបសេចក្តីព្រាងអនុស្សរណៈដាច់ដោយឡែកដែលស្នើដោយភាគីម៉ូរ៉ុកចំពោះស្ថាប័នទាំង៣ នេះ | ដោយស្ថាប័នទាំង៣ ពុំទាន់បានទទួលសេចក្តីព្រាងអនុស្សរណៈ ក្នុងនាមជាភាគីសម្របសម្រួល យើងបានស្នើទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដើម្បីធ្វើអន្តរាគមន៍ |
| ហ្គាបុង | រៀបចំកិច្ចប្រជុំផ្ទៃក្នុង និងកិច្ចប្រជុំអន្តរក្រសួងកែសម្រួលសេចក្តីព្រាងលិខិតបញ្ជាក់គោលបំណង (Letter of Intent) ក្នុងការធ្វើពាណិជ្ជកម្មរវាងកម្ពុជា-ហ្គាបុង | អង្គប្រជុំអន្តរក្រសួងបានឯកភាពលើខ្លឹមសារកែសម្រួល និងបានបញ្ជូនសេចក្តីព្រាងតបទៅភាគីហ្គាបុងវិញ តាមរយៈទំនាក់ទំនងការទូត |
| នីហ្សេរីយ៉ា | បានរៀបចំដំណើរទស្សនកិច្ច លោកជំទាវឯកអគ្គរដ្ឋទូតសហព័ន្ធនីហ្សេរីយ៉ា ទៅទស្សនកិច្ចនៅតំបន់សេដ្ឋកិច្ច | ភាគីនីហ្សេរីយ៉ាមានបំណងបន្តកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មរវាងប្រទេសទាំងពីរឱ្យកាន់តែជិតស្និទ្ធថែមទៀត |

| | | |
|---|---|---|
| | ពិសេសភ្នំពេញ(SEZ)ដើម្បីស្វែងយល់ពីសក្តានុពលនៃដំណើរការរោងចក្រក្នុងតំបន់សេដ្ឋកិច្ចពិសេសនេះ និងត្រៀមរៀបចំទទួលដំណើរទស្សនកិច្ចរបស់ធុរជនសហព័ន្ធនីហ្សេរីយ៉ាមកកម្ពុជា | តាមរយៈការរៀបចំជំនួប និងដំណើរទស្សនកិច្ច រវាងធុរជនរបស់ប្រទេសទាំងពីរ |

## ៤.៣. កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មជាមួយទ្វីបអាមេរិក

| បរិយាយការងារ | លទ្ធផល |
|---|---|
| បន្តតាមដាន និងបញ្ចុះបញ្ចូលភាគីអាមេរិកតាមរយៈអនុព័ន្ធពាណិជ្ជកម្មកម្ពុជានៅអាមេរិក ដើម្បីបន្តសុពលភាព ប្រព័ន្ធអនុគ្រោះពន្ធទូទៅ (GSP) ដែលផុតសុពលភាពកាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | ចុះហត្ថលេខាលើលិខិតរួមជាមួយបណ្តាប្រទេសទទួលអត្ថប្រយោជន៍ GSP ពីអាមេរិក ហើយបានបញ្ជូនលិខិតនេះដល់សភាតំណាងរបស់អាមេរិករួចហើយ |
| ធ្វើបច្ចុប្បន្នភាពព័ត៌មានស្តីពីពាណិជ្ជកម្មរវាងកម្ពុជា-ប្រេស៊ីលជាជំនួយស្មារតីសម្រាប់ថ្នាក់ដឹកនាំ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | បានធ្វើបច្ចុប្បន្នភាព ជាប្រចាំសម្រាប់កិច្ចប្រជុំបន្តបន្ទាប់ៗ |
| ធ្វើបច្ចុប្បន្នភាពព័ត៌មានស្តីពាណិជ្ជកម្មរវាងកម្ពុជា-គុយបា ជំនួយស្មារតីសម្រាប់ថ្នាក់ដឹកនាំ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | បានធ្វើបច្ចុប្បន្នភាព ជាប្រចាំសម្រាប់កិច្ចប្រជុំបន្តបន្ទាប់ៗ |
| រៀបចំធ្វើបច្ចុប្បន្នភាព ផ្សព្វផ្សាយអំពីផលិតផលសក្តានុពលរបស់កម្ពុជាសម្រាប់នាំចេញទៅកាន់ទីផ្សារកាណាដា និងបណ្តាប្រទេសនៅទ្វីបអាមេរិកអ្នកចូលរួម ១៦០នាក់ | ប្រជ្រាបព័ត៌មានជាក់ស្តែងពីទំនិញសក្តានុពល អត្រាពន្ធនាំចូល និងលក្ខខណ្ឌផ្សេងៗរបស់ទីផ្សារទាំងនោះ |
| បញ្ចប់សេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការបង្កើតគណៈកម្មការសេដ្ឋកិច្ចរួម ដើម្បីជំរុញទំនាក់ទំនងសេដ្ឋកិច្ច និងការផ្លាស់ប្តូរពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងអាហ្សង់ទីន | បានបញ្ជូនទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| បញ្ចប់ការបំពេញធាតុចូលរបស់ក្រសួងពាណិជ្ជកម្មទៅក្នុងសេចក្តីព្រាងឧបសម្ព័ន្ធផែនការសកម្មភាពអាស៊ាន-សហរដ្ឋអាមេរិកឆ្នាំ២០២១-២០២៥ | បានបញ្ជូនទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| រៀបចំឯកសារជំនួយស្មារតីនិងចំណុចពិភាក្សាសម្រាប់ជំនួបពិភាក្សារវាង **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ជាមួយក្រុមប្រឹក្សាធុរកិច្ចអាស៊ាន-អាមេរិក នៅទីក្រុងញូយ៉កសហរដ្ឋអាមេរិក | បានបញ្ជូនទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| រៀបចំឯកសារជំនួយស្មារតីនិងចំណុចពិភាក្សាសម្រាប់ជំនួបពិភាក្សារវាង **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ជាមួយឯកឧត្តមរដ្ឋមន្ត្រីការបរទេសប្រេស៊ីល | បានបញ្ជូនទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| រៀបចំឯកសារជំនួយស្មារតី និងចំណុចពិភាក្សា សម្រាប់ជំនួបគណៈប្រតិភូនៃសភាអាមេរិក ប្រធានគណៈកម្មាធិការសភាអាមេរិក | បានបញ្ចប់ |
| រៀបចំឯកសារពាក់ព័ន្ធ សម្រាប់ជំនួបពិភាក្សាជាមួយមន្ត្រីត្រួតពិនិត្យការនាំចេញប្រចាំតំបន់នៃការិយាល័យឧស្សាហកម្ម និងសន្តិសុខសហរដ្ឋអាមេរិក | បានបញ្ចប់ |
| រៀបចំឯកសារជំនួយស្មារតី និងចំណុចពិភាក្សា សម្រាប់ជំនួប ការងារជាមួយនាយកការិយាល័យតំណាងពាណិជ្ជកម្មសហរដ្ឋអាមេរិកប្រចាំអាស៊ីអាគ្នេយ៍ | បានបញ្ចប់ |
| រៀបចំឯកសារជំនួយស្មារតី និងចំណុចពិភាក្សា សម្រាប់ជំនួបការងារជាមួយអគ្គកុងស៊ុលកិត្តិយសកម្ពុជាប្រចាំ រដ្ឋកាលីហ្វ័រញ៉ា និងវិនិយោគិនអាមេរិក | បានបញ្ចប់ |
| រៀបចំឯកសារជំនួយស្មារតី និងចំណុចពិភាក្សា សម្រាប់ជំនួបជាមួយគណៈប្រតិភូក្រុមប្រឹក្សាធុរកិច្ចសហរដ្ឋអាមេរិក-អាស៊ាន(US-ABC) | បានបញ្ចប់ |

| | |
|---|---|
| រៀបចំឯកសារជំនួយស្មារតី និងចំណុចពិភាក្សា សម្រាប់ជំនួបសម្តែងការគួរសម របស់ឯកអគ្គរដ្ឋទូតតែងតាំងថ្មី ប្រទេសប៉េរូ | បានបញ្ចប់ |
| រៀបចំឯកសារជំនួយស្មារតី និងចំណុចពិភាក្សា សម្រាប់ជំនួបពិភាក្សាជាមួយ ឯកអគ្គរដ្ឋទូតសហរដ្ឋអាម៉េរិកប្រចាំកម្ពុជា | បានបញ្ចប់ |
| រៀបចំឯកសារជំនួយស្មារតី និងចំណុចពិភាក្សាសម្រាប់ជំនួបពិភាក្សាជាមួយ ក្រុមហ៊ុនWalmart និងក្រុមហ៊ុនVISA | បានបញ្ចប់ |
| ចូលរួមជួបពិភាក្សាជាមួយការិយាល័យស្ថានទូតកាណាដាប្រចាំកម្ពុជា | បានបញ្ចប់ |
| ស្រាវជ្រាវគោលនយោបាយទីផ្សារ និងផលិតផលសក្តានុពលរបស់កម្ពុជា និងរៀបចំចងក្រងបច្ចុប្បន្នភាពព័ត៌មានស្តីពីពាណិជ្ជកម្មរវាងកម្ពុជា និងបណ្តាប្រទេសនៅទ្វីបអាម៉េរិកសម្រាប់ប្រើប្រាស់ក្នុងឆ្នាំ២០២៣ | សេចក្តីព្រាងបឋមបានបញ្ចប់ កំពុងកែសម្រួលបន្ត |
| រៀបចំឯកសារជំនួយស្មារតី និងចំណុចពិភាក្សាសម្រាប់ជំនួបពិភាក្សាជាមួយ សភាពាណិជ្ជកម្មអាម៉េរិកប្រចាំកម្ពុជា | បានបញ្ចប់ |
| សហការជាមួយតំណាងអង្គការពលកម្មអន្តរជាតិ តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងតំណាងសមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជាចុះអង្កេត និងផ្ទៀងផ្ទាត់ដំណើរការអនុវត្តលក្ខខណ្ឌការងារនៅរោងចក្រចំនួន៦រួមមាន៖ SeilCambodia APSARA Garment CIK Cambodia D&Blue Cambodia Hyunwoocam និង Top Ningbo Fashion | បានរៀបចំរបាយការណ៍រួមសម្រាប់ការងារបន្តរបស់ថ្នាក់ដឹកនាំ |

## ៤.៤. ការងារសមាហរណកម្មពាណិជ្ជកម្មពិភពលោក

| **បរិយាយការងារ** | **លទ្ធផល** |
|---|---|
| ចូលរួមកិច្ចប្រជុំឧត្តមមន្ត្រីពាណិជ្ជកម្ម(ថ្នាក់រដ្ឋមន្ត្រីឬរដ្ឋលេខាធិការ)នៅថ្ងៃទី២៣-២៤ ខែតុលា ឆ្នាំ២០២៣ នាទីក្រុងហ្សឺណែវ ប្រទេសស្វីស ដើម្បីត្រៀមសម្រាប់សន្និសីទរដ្ឋមន្ត្រីលើកទី១៣ (MC13) របស់អង្គការ WTO ដែលនឹងប្រព្រឹត្តទៅនៅខែកុម្ភៈ ឆ្នាំ២០២៤ នៅប្រទេសអាប៊ូឌួប | ឯកភាពលើរបៀបវារៈចំនួន ៦ សម្រាប់សន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី១៣៖ ១)កំណែទម្រង់ប្រព័ន្ធដោះស្រាយវិវាទ ២)កសិកម្ម និងសន្តិសុខស្បៀង ៣)ពាណិជ្ជកម្ម និងការអភិវឌ្ឍ ៤) ការឧបត្ថម្ភធនលើវិស័យជលផល ៥)ពាណិជ្ជកម្ម និងនិរន្តរភាពបរិស្ថាន និង៦)ពាណិជ្ជកម្ម និងគោលនយោបាយឧស្សាហកម្ម |
| ធ្វើរបាយការណ៍បច្ចុប្បន្នភាពតារាងកម្មវិធីការងាររបស់រាជរដ្ឋាភិបាលកម្ពុជាក្រោមក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក (WTO) ដែលជាការអនុវត្តរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន ១៥ | សកម្មភាពសរុបមានចំនួន៨៥ ក្នុងនោះ សកម្មភាពបានអនុវត្តរួចរាល់ មានចំនួន ៥៤ និង សកម្មភាពកំពុងបន្តអនុវត្តចំនួន ៣១ |
| សហការជាមួយធនាគារអភិវឌ្ឍអាស៊ី (ADB) រៀបចំកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី គោលនយោបាយពាណិជ្ជកម្មនិងជំនួយពាណិជ្ជកម្មសម្រាប់គាំទ្រដល់កម្ពុជា បន្ទាប់ពីការចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច នៅភ្នំពេញ | ទទួលបានធាតុចូលពីជំនាញការជាតិ និងអន្តរជាតិ ដើម្បីតាក់តែងជាឯកសារគោលនយោបាយជំនួយពាណិជ្ជកម្មសម្រាប់គាំទ្រដល់កម្ពុជា បន្ទាប់ពីការចាកចេញពី LDCs |
| រៀបចំឯកសារ ជំនួយស្មារតី និងចំណុចពិភាក្សា សម្រាប់ចូលរួមកិច្ចប្រជុំ World Economic Furum (WEF) 2023 នៅក្រុងដាវ៉ូស-ក្លូស្ទ័រ ប្រទេសស្វីស និងបានរៀបចំរបាយការណ៍សង្ខេបជូន **សម្តេចតេជោ អតីតនាយករដ្ឋមន្ត្រី** | បានស្រង់លទ្ធផលសំខាន់ៗ និងគោលគំនិតជាធាតុចូលគន្លឹះមួយចំនួនសម្រាប់ការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងពិភពលោកប្រកបដោយប្រសិទ្ធភាព |

| | |
|---|---|
| ចូលរួមក្នុងកម្មវិធីពិភាក្សាក្រោមប្រធានបទស្តីពីការសន្សាបៃតងរបស់អាស៊ាន, អំណាចស្រូបទាញរបស់អាស៊ាន, ភាពជាអ្នកដឹកនាំពាណិជ្ជកម្ម និងវិនិយោគ, និងការទាញយកសក្តានុពលនៃកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (អាសិប) | អតីតឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបានថ្លែងសន្ទរកថាគន្លឹះពីជំហររបស់កម្ពុជាទាក់ទងនឹងប្រធានបទទាំងអស់នេះ ហើយបានជួបប្រាស័យជាមួយដៃគូពាណិជ្ជកម្មមួយចំនួនក្នុងតំបន់ |
| បានចរចាបញ្ចប់ជំពូកឧបាស្រ័យពាណិជ្ជកម្ម នៅក្រោមកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាង កម្ពុជា - អារ៉ាប់អេមីរ៉ាត់រួម (CAM-UAE CEPA) នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣។ | **ការចរចាជំពូកឧបាស្រ័យពាណិជ្ជកម្មបានបញ្ចប់។ ឯកសារកិច្ចព្រមព្រៀង**( CAM-UAE CEPA ) ទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីរួចហើយ |
| បញ្ចប់សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម និងបានរៀបចំលិខិតស្នើសុំទីស្តីការគណៈរដ្ឋមន្ត្រីពិនិត្យ និងបន្តនីតិវិធីផ្ទៃក្នុង។ | បានបញ្ជូនសេចក្តីព្រាងនេះទៅទីស្តីការគណៈរដ្ឋមន្ត្រីពិនិត្យ កែសម្រួល និងឆ្លងការអនុម័ត។ |
| រៀបចំបញ្ជូនបន្តសេចក្តីជូនដំណឹង( Notification) ពីបណ្តាប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងធ្វើការជូនដំណឹងពីកម្ពុជាទៅអង្គការ WTO | -**បានជូនដំណឹងអំពី៖**១ )ការរឹតបន្តឹងបរិមាណ ២ )ការឧបត្ថម្ភធន ៣ )នីតិវិធីអាជ្ញាបណ្ណនាំចេញ-នាំចូល ៤ )វិធានការពាណិជ្ជកម្មទាក់ទងនឹងកូវីដ-១៩។ល។<br>-**បានទទួលដំណឹងត្រលប់មកវិញអំពី៖** ១ )លទ្ធផលនៃការចរចារបស់គណៈកម្មការក្រោមWTO ២ )វិធានការអនាម័យ និង<br>ភូតគាមអនាម័យ ៣ )ឯកសារពាក់ព័ន្ធនឹងសេចក្តីសម្រេចនានារបស់អង្គការWTO |
| រៀបចំឯកសារ និងប្រមូលធាតុចូលពីស្ថាប័នពាក់ព័ន្ធដើម្បីត្រៀមការងារត្រួតពិនិត្យឡើងវិញគោលនយោបាយពាណិជ្ជកម្មកម្ពុជាក្រោមក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក លើកទី៣ ( Trade Policy Review) | បានការឯកភាពជាគោលការណ៍ក្នុងការទទួលជំនួយបច្ចេកទេស ពីដៃគូអភិវឌ្ឍន៍ក្នុងការសហការសរសេររបាយការណ៍នេះ |
| រៀបចំឯកសារពាក់ព័ន្ធសម្រាប់ថ្នាក់ដឹកនាំចូលរួមវេទិកាសេដ្ឋកិច្ចពិភពលោក លើកទី៥៤ ឆ្នាំ២០២៤ នៅប្រទេសស្វីស | បានរៀបចំឯកសារទិន្នន័យសេដ្ឋកិច្ច-សង្គមពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម ការវិវត្តថ្មីៗទាក់ទងនឹងពាណិជ្ជកម្មកម្ពុជាព្រមទាំងជំហរអនាគតរបស់កម្ពុជា<br>នៅក្នុងពាណិជ្ជកម្ម-ពិភពលោក |

## ៤.៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងជំនួយ

| បរិយាយការងារ | លទ្ធផល |
|---|---|
| **១. ការងារកៀរគរជំនួយសម្រាប់អភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម** | |
| ដើរតួនាទីជាចំណុចបង្គោលសម្រាប់ជំនួយហិរញ្ញវត្ថុ និងជំនួយបច្ចេកទេស ក្នុងវិស័យពាណិជ្ជកម្ម ដោយធ្វើការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិទាំងក្នុងនិងក្រៅប្រទេស | សម្របសម្រួលរៀបចំប្រកបដោយជោគជ័យក្នុងការបង្កើតយុទ្ធសាស្ត្រក្របខណ្ឌគោលនយោបាយពាណិជ្ជកម្ម និងការអនុវត្តគម្រោង រួមមាន ៖ ១ )យុទ្ធសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ២ )យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ៣ )គម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច ( AIMS ) ៤ )គម្រោងអភិវឌ្ឍន៍ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ( Go4eCAM ) និង៥ )គម្រោងហិរញ្ញប្បទានឥតសំណងនានា |

| | |
|---|---|
| កៀរគរជំនួយបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍធនធានមនុស្ស កសាងសមត្ថភាពស្ថាប័ន និងពង្រឹងកិច្ចសហប្រតិបត្តិការបច្ចេកទេសជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន | • ទទួលជំនួយហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសពីអង្គភាពពង្រឹងសមាហរណកម្មក្របខ័ណ្ឌ (EIF), ទីភ្នាក់ងារសហប្រតិបត្តិការអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (GIZ), សហភាពអឺរ៉ុប, ធនាគារអភិវឌ្ឍន៍អូស្ត្រាលី, និងទីភ្នាក់ងារសម្ព័ន្ធសាកលសម្រាប់កិច្ចសម្រួលពាណិជ្ជកម្ម។<br>• តាមដានការអនុវត្តជំនួយបច្ចេកទេសពីធនាគារ ADB ធ្វើឱ្យប្រសើរឡើងផ្នែកបច្ចេកទេសលើប្រតិបត្តិការដែលមានកិច្ចធានា, ឧបាស្រ័យពាណិជ្ជកម្ម និងវិធានប្រភពដើមទំនិញ ក្រោមកម្មវិធីពង្រឹងភាពប្រកួតប្រជែងពាណិជ្ជកម្ម (Trade Competitiveness Programme)<br>• បានទទួលគណៈប្រតិភូនៃប្រទេស Zambia មកទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍នៃការអនុវត្តគម្រោងក្រោមកម្មវិធី EIF។ |
| សហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីទទួលបានការចុះកិច្ចព្រមព្រៀងភាពជាដៃគូក្នុងការអនុវត្តគម្រោងបង្កើត FTA Portal ក្រោមជំនួយរបស់ CAP RED/DFAT Australia | បានចុះហត្ថលេខាកិច្ចព្រមព្រៀងភាពជាដៃគូ (Partnership Agreement) ជាមួយនឹងទីភ្នាក់ងារ COWATER Int' ក្រោមកម្មវិធីភាពជាដៃគូរវាងកម្ពុជា និងអូស្ត្រាលីសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (CAPRED) ដើម្បីបង្កើតផ្ទាំងស្វែងរកព័ត៌មានកិច្ចព្រមព្រៀងសេរីសម្រាប់វិស័យឯកជន |
| រៀបចំផែនការបង្កើតក្របខណ្ឌគោលនយោបាយពាណិជ្ជកម្មកម្ពុជា (Cambodia Trade Policy Framework – CTPF) ឱ្យស្របទៅនឹងយុទ្ធសាស្ត្រ បញ្ចកោណ និងការត្រៀមចាកចេញពីភាពជាប្រទេសអភិវឌ្ឍន៍តិចតួច | បញ្ចប់ការធ្វើផែនការ និងឯកសារទស្សនទាន (Concept Note) ដំណាក់កាលទី១ ដែលអាចយកទៅអនុវត្តបានស្របតាមផែនការ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ |
| **២) ការគ្រប់គ្រងជំនួយ និងការអនុវត្តគម្រោងអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម** | |
| គ្រប់គ្រងប្រតិបត្តិការគម្រោងដែលមានស្រាប់តាមគោលការណ៍របស់ដៃគូអភិវឌ្ឍន៍ និងនីតិវិធីរបស់រាជរដ្ឋាភិបាល | ធានាបានជោគជ័យនៃការអនុវត្តគម្រោងទាំងអស់ ស្របតាមគោលការណ៍របស់ដៃគូអភិវឌ្ឍន៍ និងនីតិវិធីរបស់រាជរដ្ឋាភិបាល ដោយគម្រោងទាំងនេះបានជួយកសាងស្ថាប័ន ពង្រឹងសមត្ថភាពវិស័យសាធារណៈ និងឯកជន ដើម្បីអាចធ្វើសមាហរណកម្មទៅក្នុងពាណិជ្ជកម្មតំបន់ និងពិភពលោក រួមទាំងការពង្រឹង និងពង្រីកការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ |
| ការអនុវត្តគម្រោងអភិវឌ្ឍន៍ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (Go4eCAM) | • បានដាក់សម្ពោធផ្សារខេមបូឌាត្រេដឱ្យប្រើប្រាស់ជាផ្លូវការដោយភ្ជាប់ជាមួយប្រព័ន្ធទូទាត់ និងប្រព័ន្ធដឹកជញ្ជូន ហើយផ្តល់ឱកាសឱ្យសហគ្រាសចំនួន ១៦៥ ដាក់លក់ផលិតផលជាង ១៥០០មុខ លើទីផ្សារនេះ។<br>• បានផ្សព្វផ្សាយចំណេះដឹងស្តីពីការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការត្រៀមខ្លួនសម្រាប់ការនាំចេញតាមផ្សារអេឡិចត្រូនិកដល់សហគ្រាសធុនតូចនិងមធ្យមចំនួន ៤៥០សហគ្រាស។<br>• បានដាក់បង្ហាញផ្សារខេមបូឌាត្រេដ និងផលិតផលខ្មែរមួយចំនួនក្នុងកម្មវិធីពិព័រណ៍នៅប្រទេសជប៉ុន ថៃ ម៉ុងហ្គោលី និងកូរ៉េ។<br>• បញ្ចប់ការរៀបចំយុទ្ធសាស្ត្រចាកចេញ និងនិរន្តរភាពរបស់គម្រោង Go4eCAM និងផ្សារខេមបូឌាត្រេដ ដោយបានផ្លាស់ប្តូរផ្សារនេះទៅជា Sourcing Platform សម្រាប់បន្តជួយជំរុញការលក់ផលិតផលខ្មែរទៅកាន់ទីផ្សារអន្តរជាតិតាមរយៈផ្ទាំងអេឡិចត្រូនិក។ |

| | |
|---|---|
| គ្រប់គ្រងប្រតិបត្តិការ និងសម្របសម្រួលការអនុវត្តគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូចAIMS | • សហការជាមួយអង្គភាពពាក់ព័ន្ធអនុវត្តគម្រោង AIMS ដោយទទួលបន្ទុក ការគ្រប់គ្រងហិរញ្ញវត្ថុ លទ្ធកម្ម ត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយលទ្ធផលគម្រោង<br>• សម្របសម្រួលជាមួយមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD) និងតួអង្គពាក់ព័ន្ធសំខាន់ៗក្នុងការអនុវត្តគម្រោង ដោយសហការជាមួយគម្រោងពាក់ព័ន្ធនានា ដូចជា SAAMBAT, កម្មវិធី ASPIRE និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ក្នុងការផ្លាស់ប្តូរបទពិសោធន៍នៃការអនុវត្តគម្រោង។ |
| ពិនិត្យតាមដាន និងអនុវត្តយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា (CTIS 2019-2023) | • បញ្ចប់ និងអនុម័តការវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តម៉ាទ្រីសសកម្មភាពរបស់អន្តរក្រសួងនិងស្ថាប័ន ក្នុងការអនុវត្តយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា (CTIS 2019-2023) ដោយសម្រេចបានលទ្ធផល ៨៩% នៃផែនការសកម្មភាព។<br>• រៀបចំរបាយការណ៍វាយតម្លៃ និងត្រួតពិនិត្យនៃការអនុវត្តម៉ាទ្រីសសកម្មភាពក្នុងយុទ្ធសាស្ត្រនេះ ដើម្បីផ្សព្វផ្សាយ ។ |
| អនុវត្តយុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក | បញ្ចប់ និងអនុម័តរបាយការណ៍វាយតម្លៃវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់អន្តរក្រសួងនិងស្ថាប័ន សម្រាប់ការអនុវត្តយុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ |
| សហការអនុវត្តគម្រោង ARISE PLUS Cambodia ជាមួយអង្គការ GIZ | • រៀបចំប្រកាសស្តីពីការបង្កើតចេនាសម្ព័ន្ធគ្រប់គ្រងគម្រោងស្តីពី ការពង្រឹងស្ថាប័នរបស់វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្មនិងស្រាវជ្រាវ ការអភិវឌ្ឍមជ្ឈមណ្ឌលព័ត៌មានសម្រាប់ពាណិជ្ជកម្មសេរី និងការបង្កើតលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិចរចាពាណិជ្ជកម្ម<br>• រៀបចំប្រជុំគណៈកម្មការតម្រង់ទិសគម្រោង ARISE Plus Cambodia លើកទី៥ ដោយបានពិនិត្យវឌ្ឍនភាព និងទិសដៅរបស់គម្រោងដែលគ្រោងនឹងបញ្ចប់នៅខែមីនា ឆ្នាំ២០២៤។<br>• ជួបពិភាក្សាការងារជាមួយ EU-Germany និង ARISE Plus Cambodia ដើម្បីពិនិត្យលទ្ធភាពបង្កើតគម្រោងថ្មីដែលគ្រោងនឹងអនុវត្តក្នុងឆ្នាំ២០២៤-២០២៨ ។ |
| សហការអនុវត្តគម្រោង Set4SME ជាមួយ Swisscontact | • ជំរុញឱ្យមានការចុះអនុស្សរណៈយោគយល់គ្នារវាងអគ្គនាយកដ្ឋានគយ និង<br>រដ្ឋាកកម្ពុជា និងប៉ុស្តិ៍កម្ពុជាក្នុងការតភ្ជាប់ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យជាមុនសម្រាប់ការបញ្ញើទំនិញកញ្ចប់តូច<br>• សហការសម្ពោធកម្មវិធីប្រកួតប្រជែងជើងឯកអ្នកនាំចេញកញ្ចប់ទំនិញខ្នាតតូចឆ្នាំ២០២៣ ជាមួយស្វីសខុនថាក សហគ្រិនខ្មែរ និងសភាអឺរ៉ុប នៅខេត្តសៀមរាប បាត់ដំបង កំពង់ចាម និងព្រះសីហនុ<br>• សហការជាមួយស្វីសខុនថាក់ តំណាងឱ្យ Global Alliance រៀបចំទស្សនកិច្ចសិក្សា នៅទីក្រុងមីឡាន ប្រទេសអ៊ីតាលី ដោយបញ្ជូនតំណាងសហគ្រាស ជើងឯក ០៥ក្រុមហ៊ុន និងតំណាងក្រសួងពាណិជ្ជកម្ម ប៉ុស្តិ៍កម្ពុជា និងសហគ្រិនខ្មែរ សរុបចំនួន ១២រូបទៅចូលរួមក្នុងវេទិកា The NETCOMM FORUM 2023 ។ |

| | |
|---|---|
| **៣)ការងារកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ** | |
| សហការជាមួយអង្គការ UNCTAD ក្នុងក្របខណ្ឌពាណិជ្ជកម្មឌីជីថល | បញ្ចប់កិច្ចពិគ្រោះយោបល់អន្តរក្រសួងពាក់ព័ន្ធ និងជំនាញការ UNCTAD ដើម្បីផ្ដល់ធាតុចូលក្នុងការរបាយការណ៍តាមដានការអនុវត្តអនុសាសន៍របស់ UNCTAD លើកទី៣ (3rd E-Trade Readiness Assessment) សម្រាប់ការត្រៀមខ្លួនរបស់កម្ពុជាក្នុងក្របខណ្ឌពាណិជ្ជកម្មឌីជីថល។ |
| សហការជាមួយអង្គការ CUTS International | បញ្ចប់ការរៀបចំយន្តការធ្វើគោលនយោបាយពាណិជ្ជកម្មប្រកបដោយភាពធន់ និងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយពីយន្តការនេះ។ |
| **៤)ការងារចរចារការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេស (ECOTEC)ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា** | |
| ចូលរួមចរចារកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស (ECOTEC)ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា | • ចូលរួមបញ្ចប់ចរចាលើជំពូកស្ដីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស នៃកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងកម្ពុជា និងអេមីរ៉ាតអារ៉ាប់រួម<br>• ចូលរួមកិច្ចប្រជុំតាមដានការអនុវត្តកម្មវិធីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស នៃគណៈកម្មការរួមនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី<br>កម្ពុជា-ចិន (CCFTA) នៅទីក្រុងប៉េកាំង ប្រទេសចិន<br>• ចូលរួមកិច្ចប្រជុំក្រុមការងារកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានចិន នៅទីក្រុងឃុនមីង ខេត្តយូណាន ប្រទេសចិន។ |

## ៥. ការងារជំរុញពាណិជ្ជកម្ម[4]

## ៥.១. ការរៀបចំ និងចូលរួមពិព័រណ៍ពាណិជ្ជកម្ម

| **បរិយាយការងារ** | **លទ្ធផល** |
|---|---|
| **ក) ពិព័រណ៍ពាណិជ្ជកម្មក្នុងប្រទេស** | |
| ពិព័រណ៍ផលិតផលខ្មែរ និងបន្លែផ្លែឈើលើកទី១៦ (ថ្ងៃទី២៤-២៧ ខែកុម្ភៈ ឆ្នាំ២០២៣) នៅខេត្តសៀមរាប | • ស្តង់សរុបចំនួន១១៨ ដោយមានការចូលរួមពីមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត និងក្រុមហ៊ុន/សហគ្រាសកម្ពុជាចំនួន១២<br>• មានអ្នកទស្សនាប្រមាណ១២ ០០០នាក់ |
| ពិព័រណ៍ផលិតផលខ្មែរ ក្នុងឱកាសនៃការរៀបចំពិធីបុណ្យទន្លេលើកទី៧ (ថ្ងៃទី៨-១០ ខែមីនា ឆ្នាំ២០២៣) នៅខេត្តកំពង់ធំ | • ស្តង់រួមក្រសួងពាណិជ្ជកម្មចំនួន១ស្តង់<br>• មានអ្នកទស្សនាប្រមាណ៩០០នាក់ |
| ពិព័រណ៍ពាណិជ្ជកម្មក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន្ត សហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជាវិស័យពាណិជ្ជកម្ម (ថ្ងៃទី១៤-១៦ ខែមេសា ឆ្នាំ២០២៣)នៅខេត្តសៀមរាប | • ស្តង់សរុបចំនួន ៨៤ស្តង់ ដោយមានការចូលរួមពីមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត និងក្រុមហ៊ុន/សហគ្រាសកម្ពុជាចំនួន៥៤<br>• មានចូលអ្នកទស្សនាប្រមាណ១៨ ០០០នាក់ |
| តាំងបង្ហាញផលិតផលសក្ដានុពលកម្ពុជា ក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល (ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៣)នៅខេត្តកំពង់ធំ | • ស្តង់រួមក្រសួងពាណិជ្ជកម្មចំនួន១ស្តង់<br>• មានអ្នកទស្សនាប្រមាណ៣០០នាក់ |

[4] ប្រភព៖ អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម

| | |
|---|---|
| ពិព័រណ៍ផ្សារណាត់មិត្តភាពកម្ពុជា-វៀតណាម (ថ្ងៃទី១-៥ ខែមិថុនា ឆ្នាំ២០២៣) នៅខេត្តត្បូងឃ្មុំ | • ស្តង់សរុបចំនួន ៦១ស្តង់ ក្នុងនោះស្តង់មកពីប្រទេសវៀតណាម មានចំនួន ២១ស្តង់<br>• មានអ្នកទស្សនាប្រមាណ១៥០០នាក់ |
| តាំងបង្ហាញផលិតផលសក្តានុពលកម្ពុជា ក្នុងទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈលើកទី៦ (ថ្ងៃទី១៥-១៦ ខែមិថុនា ឆ្នាំ២០២៣) នៅរាជធានីភ្នំពេញ | • មានស្តង់រួមក្រសួងពាណិជ្ជកម្មចំនួន១<br>• មានអ្នកទស្សនាប្រមាណ៥០០នាក់ |
| ពិព័រណ៍ផលិតផលខ្មែរ និងទំនិញនាំចេញ-នាំចូលកម្ពុជា លើកទី១៦ (ថ្ងៃទី១៥-១៨ ខែធ្នូ ឆ្នាំ២០២៣) នៅរាជធានីភ្នំពេញ | • មានស្តង់សរុបចំនួន២០០ស្តង់ ដោយមានការចូលរួមពីបណ្តាប្រទេសអាស៊ាន និងដៃគូព្រមទាំងមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត និងក្រុមហ៊ុន/សហគ្រាសកម្ពុជា<br>• មានអ្នកទស្សនាប្រមាណ១៥ ០០០នាក់ |
| ពិព័រណ៍ផលិតផលខ្មែរក្នុងឱកាសបុណ្យសមុទ្រលើកទី១០ ជុំទី៣ (ថ្ងៃទី១-៣ ខែធ្នូ ឆ្នាំ២០២៣) ខេត្តកែប | • ស្តង់រួមក្រសួងពាណិជ្ជកម្មចំនួន១ស្តង់ផលិតផលខ្មែរ VIP ចំនួន១០ស្តង់ ផលិតផលទូទៅចំនួន ១០០ស្តង់ និងក្រុមហ៊ុន/សហគ្រាសកម្ពុជាចំនួន ៧០ បានចូលរួម<br>• មានអ្នកទស្សនាប្រមាណ២០ ០០០នាក់ |
| ចេញលិខិតអនុញ្ញាតជូនក្រុមហ៊ុនឯកជនរៀបចំពិព័រណ៍ និងស្តង់ | បានចេញលិខិតអនុញ្ញាតច្បាប់ជូនក្រុមហ៊ុនឯកជនចំនួន២១ និង៨៦៩ស្តង់ |
| **ខ) ពិព័រណ៍ពាណិជ្ជកម្មក្រៅប្រទេស** | |
| សម្របសម្រួលជូនវិស័យឯកជនក្នុងការចូលរួមព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្មក្រៅប្រទេស នៅប្រទេសថៃ កូរ៉េ ជប៉ុន ប្រ៊ុយណេ ចិន ឥណ្ឌូនេស៊ី វៀតណាម និងប្រទេសទួកគី | បញ្ជូនមន្ត្រីបច្ចេកទេស ដើម្បីសម្របសម្រួលដល់អាជីវករ និងក្រុមហ៊ុន/សហគ្រាសកម្ពុជាចំនួន ៦៦ ចូលពិព័រណ៍ពាណិជ្ជកម្មក្រៅប្រទេសផ្សេងៗគ្នាសរុបចំនួន ១២លើក |
| រៀបចំ និងចូលរួមពិព័រណ៍ចិន-អាស៊ាន លើកទី២០ នៅទីក្រុងណាននីង ខេត្តក្វាងស៊ី ប្រទេសចិន | • ទទួលជោគជ័យដោយទទួលបានពានរង្វាន់ចំនួន៤ រួមមាន៖ ១)ពានរង្វាន់សមិទ្ធផលកិច្ចសហការលើវិស័យសេដ្ឋកិច្ច-ពាណិជ្ជកម្ម កម្ពុជា-ចិន ក្នុងការចូលរួម រៀបចំពិព័រណ៍ចិនអាស៊ានជាមួយគណៈកម្មការពិព័រណ៍ រយៈពេល២០ឆ្នាំជាប់គ្នា (Best Co-Organizer Award) ២)ពានរង្វាន់រៀបចំពន្លាជាតិបានស្រស់ឆើតឆាយ (Best of National Pavilion Award) ៣)ពានរង្វាន់កៀរគរក្រុមហ៊ុន សហគ្រាសកម្ពុជា ចូលរួមបានច្រើន (Best of Trade and Economic Outcome Award) ៤) ពានរង្វាន់សហការរៀបចំវេទិកាធុរកិច្ច វិនិយោគ និងទេសចរណ៍ ដោយមានអ្នកចូលរួមបានច្រើន (Best of Investment Promotion Award )<br>• ក្នុងព្រឹត្តិការណ៍នេះមានក្រុមហ៊ុនចំនួន ៥៥ មានស្តង់ចំនួន ៨៤ និងមានអ្នកចូលរួមសរុបប្រមាណជាង ៦០០ ០០០នាក់ |
| រៀបចំ និងចូលរួមពិព័រណ៍ពាណិជ្ជកម្មទំនិញនាំចូលអន្តរជាតិចិន លើកទី៦ នៅទីក្រុងសៀងហៃ ប្រទេសចិន | ក្នុងព្រឹត្តិការណ៍នេះមានក្រុមហ៊ុនចូលរួមចំនួន ៤ និងមានស្តង់ចំនួន ៤ |

| | |
|---|---|
| ចូលរួមកិច្ចប្រជុំបច្ចេកទេស IPM 2023 Autumn នៅទីក្រុងអូសាកា ប្រទេសជប៉ុន | បានបង្ហាញជូនប្រទេសអ្នកចូលរួមទាំងអស់ឱ្យបានដឹងពីទីតាំង និងនីតិវិធីសាងសង់ពន្លាជាតិកម្ពុជាក្នុងពិព័រណ៌ពិភពលោក ឆ្នាំ ២០២៥ |
| ចូលរួមសន្និបាតប្រចាំឆ្នាំលើកទី១៧៣ របស់ការិយាល័យពិព័រណ៌អន្តរជាតិ (BIE) នៅទីក្រុងប៉ារីស ប្រទេសបារាំង | កម្ពុជានឹងចូលរួមបោះឆ្នោតជ្រើសរើស បេក្ខភាពម្ចាស់ផ្ទះរៀបចំពិព័រណ៌ពិភពលោកឆ្នាំ២០៣០ |
| **គ) កិច្ចការទំនាក់ទំនងអន្តរជាតិទាក់ទងនឹងវិស័យពិព័រណ៌** | |
| • រៀបចំលិខិតស្នើសុំ ឯកអគ្គរាជទូតកម្ពុជា ប្រចាំទីក្រុងប៉ារីស ចូលរួមសន្និបាតប្រចាំឆ្នាំលើកទី១៧២ របស់ការិយាល័យពិព័រណ៌អន្តរជាតិ (BIE)<br>• រៀបចំលិខិតចាត់បញ្ជូនមន្ត្រីអនុព័ន្ធពាណិជ្ជកម្មអមស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំនៅប្រទេសជប៉ុន និងទីប្រឹក្សាបច្ចេកទេស ១រូប ទៅចូលរួមកិច្ចប្រជុំ «The International Planning Meeting 2023 (IPM 2023 Spring)» នៅប្រទេសជប៉ុន<br>• រៀបចំលិខិតគាំទ្របេក្ខភាពទីក្រុងប៊ូសាន សាធារណរដ្ឋកូរ៉េ ធ្វើជាម្ចាស់ផ្ទះរៀបចំពិព័រណ៌ពិភពលោកឆ្នាំ២០៣០ (World Expo 2030) ក្នុងករណីដែលទីក្រុងប៊ូសាន មិនត្រូវបានជ្រើសរើស កម្ពុជានិងគាំទ្របេក្ខភាពអ៊ីតាលី។ ករណីដែលបេក្ខភាពអ៊ីតាលី មិនត្រូវបានជ្រើសរើស កម្ពុជានិងគាំទ្រទីក្រុងរីយ៉ាដ ប្រទេសអារ៉ាប៊ីសាអ៊ូឌីត។<br>• រៀបចំលិខិតស្នើសុំគាំទ្របេក្ខភាពសែប៊ី អេស្ប៉ាញ អាហ្សង់ទីន និងសហរដ្ឋអាម៉េរិក ធ្វើជាម្ចាស់ផ្ទះរៀបចំពិព័រណ៌ Specialized World Exhibition "Expo 2027/2028" | លិខិតបានបញ្ជូនតាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រួចហើយ |
| រៀបចំលិខិតជូន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្នើសុំបង់ប្រាក់វិភាគទានសមាជិកភាពរបស់កម្ពុជា ក្នុងការិយាល័យពិព័រណ៌អន្តរជាតិ (BIE) សម្រាប់រយៈពេល ៣ឆ្នាំ (២០២១-២០២៣) | លិខិតបានបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួចរាល់។ ប្រាក់វិភាគទានបានបង់រួចហើយ។ |

## ៥.២. ការងារអភិវឌ្ឍន៍ទីផ្សារ

| **បរិយាយការងារ** | **លទ្ធផល** |
|---|---|
| **ក.ការងារផ្សព្វផ្សាយដៃគូពាណិជ្ជកម្ម** | |
| សហការជាមួយមជ្ឈមណ្ឌលអាស៊ាន-ជប៉ុន រៀបចំវេទិកាស្តីពី "ផលិតផលផ្លែឈើក្រៀម និងផលិតផលកសិកម្មកម្ពុជាសម្រាប់ទីផ្សារប្រទេសជប៉ុន" នៅរាជធានីភ្នំពេញ | -អ្នកចូលរួមចំនួន ១១៧នាក់<br>-បានផ្តល់ចំណេះដឹង និងបទពិសោធន៍ ពីអ្នកជំនាញជប៉ុន ដើម្បីកែច្នៃផលិតផលផ្លែឈើក្រៀមឱ្យស្របតាមស្តង់ដាររបស់ប្រទេសជប៉ុន សម្រាប់នាំចេញទៅកាន់ទីផ្សារប្រទេសជប៉ុន និងបង្កើតទំនាក់ទំនងរវាងក្រុមហ៊ុនកម្ពុជា-ជប៉ុន |
| **រៀបចំព្រឹត្តិការណ៍ក្នុងប្រទេស** | |
| វេទិកាជំរុញពាណិជ្ជកម្ម និងវិនិយោគ កម្ពុជា-ចិន (ខេត្តក្វាងស៊ី) នៅភ្នំពេញ | -ចំនួន ២លើក មានអ្នកចូលរួមចំនួន ៣២៣នាក់<br>-ពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការជំរុញពាណិជ្ជកម្ម និងវិនិយោគនៅកម្ពុជា ដោយមានការចុះMoU ចំនួន ៥<br>-ពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការជំរុញពាណិជ្ជកម្ម (កែច្នៃផលិតផលកសិកម្ម) និងវិនិយោគនៅកម្ពុជា ដោយមានការចុះMoU ចំនួន ១១ |

| | |
|---|---|
| វេទិកាជំរុញពាណិជ្ជកម្ម និងវិនិយោគ កម្ពុជា-ចិន (ខេត្តហៃណាន) នៅភ្នំពេញ | -អ្នកចូលរួមចំនួន ១៨៥នាក់<br>-ពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការជំរុញពាណិជ្ជកម្ម (ជំរុញកិច្ចសហប្រតិបត្តិការឧស្សាហកម្ម និងកិច្ចសហប្រតិបត្តិការលើការដាំដុះម្រេច) និងវិនិយោគនៅកម្ពុជា ដោយមានចុះ MoU ចំនួន ២ |
| កិច្ចប្រជុំកំពូលសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគសហគ្រិនកម្ពុជា-ចិន នៅរាជធានីភ្នំពេញ | -អ្នកចូលរួម ១៥៩នាក់<br>-ពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការជំរុញពាណិជ្ជកម្ម និងវិនិយោគនៅកម្ពុជា ដោយមានការចុះMoU ចំនួន ២ |
| វេទិកាអភិវឌ្ឍន៍សេដ្ឋកិច្ចពិភពលោក លើកទី៩ និងកិច្ចប្រជុំកំពូលថ្នាក់ដឹកនាំធុរកិច្ច កម្ពុជា-ចិន នៅរាជធានីភ្នំពេញ | -អ្នកចូលរួម ១០៥នាក់<br>-ពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការជំរុញពាណិជ្ជកម្ម និងវិនិយោគនៅកម្ពុជា |
| វេទិកាធុរកិច្ចសំបុកត្រចៀកកាំកម្ពុជា នៅរាជធានីភ្នំពេញ | -អ្នកចូលរួម ៣១៦នាក់<br>-ពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការជំរុញសំបុកត្រចៀកកាំកម្ពុជាទៅកាន់ប្រទេសចិន ម៉ាឡេស៊ី ថៃ និងវៀតណាម ដោយមានចុះMoU ចំនួន៦ |
| **រៀបចំព្រឹត្តិការណ៍ក្រៅប្រទេស** | |
| វេទិកាធុរកិច្ច និងវិនិយោគកម្ពុជា-កូរ៉េ នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ | -អ្នកចូលរួម ២០០នាក់<br>-ពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការជំរុញពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍ |
| វេទិកាធុរកិច្ច វិនិយោគ និងទេសចរណ៍ កម្ពុជា-ចិន នៅរដ្ឋធានីប៉េកាំង ប្រទេសចិន | -អ្នកចូលរួម ៣០០នាក់<br>-ពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការជំរុញពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍ |
| វេទិកាធុរកិច្ច ពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍ កម្ពុជា-ចិន នៅទីក្រុងណាននីង ប្រទេសចិន | -អ្នកចូលរួម ៤៦៩នាក់<br>-ពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការជំរុញពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍រវាងប្រទេសទាំងពីរ ដោយមានចុះMoU រវាងក្រុមហ៊ុនកម្ពុជា-ចិន ចំនួន៦ |
| **រៀបចំជំនួបពាណិជ្ជកម្ម** | |
| រវាងសមាគមអ្នកផលិត និងនាំចេញសំបុកត្រចៀកកាំកម្ពុជា នៅរាជធានីភ្នំពេញ | -ចំនួនអ្នកចូលរួម៩៨នាក់<br>-ចាប់ដៃគូរវាងអាជីវករ/ក្រុមហ៊ុនកម្ពុជា ជាមួយក្រុមហ៊ុនមកពីប្រទេសចិន ថៃ ម៉ាឡេស៊ី និងវៀតណាម ក្នុងការជំរុញសំបុកត្រចៀកកាំកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ |
| រវាងពាណិជ្ជករកម្ពុជា និងបរទេស នៅរាជធានីភ្នំពេញ | -ចំនួនអ្នកចូលរួម៨០នាក់ និងបានចាប់ដៃគូរវាងអ្នកលក់ និងអ្នកទិញ<br>-ត្រៀមចុះកិច្ចសន្យាទិញ-លក់ (ស្រូវ-អង្ករ ដំឡូងមី ម្រេច ចេកអំបូងលឿង និងមៀនប៉ៃលិន) |
| រវាងសមាគម Future of Peninsula the Development Association ប្រទេសកូរ៉េ នៅរាជធានីភ្នំពេញ | -ចំនួនអ្នកចូលរួម៤០នាក់<br>-ចាប់ដៃគូរវាងក្រុមហ៊ុនកម្ពុជា-កូរ៉េ ក្នុងការជំរុញការនាំចេញ-នាំចូលគ្រឿងសំណង់ឧបករណ៍ការពារអគ្គិសនី បរិក្ខាពេទ្យ រវាងប្រទេសទាំងពីរ |
| **រៀបចំនិងសម្របសម្រួលជំនួបសម្ដែងការគួរសម** | |
| ជាមួយ គណៈប្រតិភូពាណិជ្ជកម្មចិន ថៃ ម៉ាឡេស៊ី កូរ៉េ អង់គ្លេស និងជប៉ុន នៅរាជធានីភ្នំពេញ (ទីស្ដីការក្រសួង) | -ចំនួន ១២លើក<br>-គណៈប្រតិភូបរទេសបានសិក្សាស្វែងយល់អំពីសក្ដានុពលរបស់កម្ពុជាក្នុងការនាំចេញ-នាំចូល និងនីតិវិធីក្នុងការធ្វើពាណិជ្ជកម្មនៅកម្ពុជា |
| **ការងារមជ្ឈមណ្ឌលពាណិជ្ជកម្ម ឯកជនកម្ពុជានៅក្រៅប្រទេស** | -ចំនួន១១ទីតាំង(ចិន១០ និងជប៉ុន១)<br>-បង្ហាញផលិតផលខ្មែរដល់សាធារណជននៅក្រៅប្រទេស<br>-ទទួលបានការគាំទ្រផលិតផលខ្មែរកាន់តែច្រើនបន្ថែមទៀតនៅក្រៅប្រទេស |

| | |
|---|---|
| | ទាក់ទាញពាណិជ្ជករ វិនិយោគិន និងភ្ញៀវទេសចរបរទេស មកកាន់ប្រទេស កម្ពុជាបន្ថែមទៀត |
| រៀបចំលិខិតអនុញ្ញាតបណ្តោះអាសន្នសម្រាប់ការបើកដំណើរការមជ្ឈមណ្ឌលពាណិជ្ជកម្មកម្ពុជា | ចំនួន៩ទីតាំងដើម្បីអនុញ្ញាតឱ្យអ្នកស្នើសុំមានសិទ្ធិនាំយកទៅដំណើការតាមនីតិវិធីជាមួយភាគីម្ចាស់ផ្ទះ រួមមានៈ ប្រទេសចិន ៦ទីតាំង ( ទីក្រុងស៊ិនជិន ឆាងសា ប៉េកាំង ឈីងតាវ ហាំងចូវ និងសៀងហៃ ) អេមីរ៉ាតអារ៉ាប់រួម ២ទីតាំង ( ទីក្រុង Dubai និងAbu Dhabi ) និងប្រទេសសិង្ហបុរី ១ទីតាំង( ទីក្រុងសិង្ហបុរី) |
| ***ខ.ការងារយុទ្ធសាស្ត្រជំរុញទីផ្សារ និងផលិតផល*** | |
| *ការងារផ្សព្វផ្សាយផលិតផល* | |
| ការលើកកម្ពស់ផលិតផលខ្មែរ<br>នៅខេត្តកំពង់ស្ពឺ-ត្បូងឃ្មុំ | • បានចំនួន ២លើក មានកចូលរួម ១៧៨នាក់<br>• ផលិតផលខ្មែរត្រូវបានទទួលការគាំទ្រ និងទទួលស្គាល់កាន់តែទូលំទូលាយ និងអាចប្រកួតប្រជែងជាមួយផលិតផលនាំចូល<br>• ផ្តល់លទ្ធភាព និងការលើកទឹកចិត្តដល់សហគ្រាសធុនមីក្រូ ធុនតូច និងមធ្យមកម្ពុជា<br>• ផលិតផលខ្មែរមានការកែច្នៃ ការវេចខ្ចប់ប្រកបដោយសោភ័ណភាពកាន់តែល្អប្រសើរស្របតាមស្តង់ដា<br>• ផ្តល់ឱកាសការងារ កាត់បន្ថយចំណាកស្រុក និងទទួលបានទិន្នន័យ ក្រុមហ៊ុនសហគ្រាស សិប្បកម្មដែលអាចនាំចេញផលិតផលខ្មែរនៅនឹងកន្លែង។ |
| ការកំណត់អត្តសញ្ញាណ និងការផ្សព្វផ្សាយផលិតផលសក្តានុពលកម្ពុជា នៅរាជធានីភ្នំពេញ កំពត សៀមរាប កែប កំពង់ធំ កំពង់ចាម កោះកុង ព្រះសីហនុ ប៉ៃលិន និងបាត់ដំបង | • បានចំនួន ១០លើក មានចំនួនអ្នកចូលរួម ៧៥១នាក់<br>• ដើម្បីចងក្រងអត្តសញ្ញាណ និងទិន្នន័យផលិតផលសក្តានុពល<br>• និងផលិតផលប្រចាំតំបន់ដែលផលិតនៅតាមបណ្តារាជធានី-ខេត្ត ព្រមទាំងផ្សព្វផ្សាយឱ្យបានទូលំទូលាយ ហើយក៏ជាផ្នែកមួយក្នុងការជំរុញផលិតផលចូលទីផ្សារក្នុង និងក្រៅប្រទេស ព្រមទាំងទីផ្សារឌីជីថលដើម្បីរួមចំណែកការស្តារសេដ្ឋកិច្ចជាតិឡើងវិញក្រោយវិបត្តិកូវីដ-១៩ |
| ការអភិវឌ្ឍផលិតផល និងអាជីវកម្មស្របតាមបរិការណ៍ទីផ្សារ នៅរាជធានីភ្នំពេញ | • ចំនួនអ្នកចូលរួម១២០នាក់<br>• ទទួលបានចំណេះដឹង និងបទពិសោធ៍ ដូចជានិតិវិធីនៃចេញព័ត៌មានទីផ្សារ និងការកសាងម៉ាកយីហោ |
| ពង្រឹងសមត្ថភាពអ្នកផលិត និងកែច្នៃផលិតផល នៅខេត្តកោះកុង ព្រះសីហនុពោធិ៍សាត់ និងកំពង់ឆ្នាំង | • បានចំនួន៤លើក មានអ្នកចូលរួម៣០៣នាក់<br>• អ្នកផលិតកម្ពុជាមានសមត្ថភាពបន្ថែមក្នុងការកែច្នៃវេចខ្ចប់មានសោភណភាព និងស្តង់ដាត្រឹមត្រូវ<br>• បង្កើនបរិមាណផលិតផលរបស់ខ្លួន<br>• អ្នកប្រើប្រាស់មានទំនុកចិត្តលើម៉ាកសញ្ញាសម្គាល់ប្រេនផលិតផលខ្មែរ។ |
| ***ផ្តល់សេវាពិគ្រោះយោបល់ និងប្រឹក្សាកិច្ចការពាណិជ្ជកម្ម និងទីផ្សារជូនដល់ធុរជន*** | • បានចំនួន២៥លើក និងផ្តល់ប្រឹក្សាចំនួន៨៥នាក់<br>• វិស័យឯកជនទទួលបានព័ត៌មានបន្ថែមពីការចុះបញ្ជីពាណិជ្ជកម្ម ការស្នើសុំC/O ការចុះបញ្ជីម៉ាក កិច្ចការប្រកួតប្រជែងស្របច្បាប់ ការកែច្នៃ និងការវេចខ្ចប់ផលិតផល បញ្ហាអនាម័យ និងភូតគាមអនាម័យ បច្ចេកទេស ក្នុងការដាំដុះ និងយុទ្ធសាស្ត្រស្វែងរកទីផ្សារ ។ |
| ***របាយការណ៍វឌ្ឍនភាពផ្សារតំរូព្រំដែនកម្ពុជា (ផ្សារដារខេត្តត្បូងឃ្មុំ)*** | - ចំនួន ៣របាយការណ៍ ដោយមានបញ្ជាក់ពីបញ្ជាក់ពីសភាពការណ៍គ្រប់គ្រងដំណើរការទីផ្សារ បញ្ហាប្រឈម ដែលកើតមានក្នុងប្រតិបត្តិការទីផ្សារ |

| | |
|---|---|
| **រៀបចំគម្រោងស្តីពី "ការជំរុញផលិតផលសក្តានុពលកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិតាមប្រព័ន្ធឌីជីថល" ពីផលិតផលចំនួន៥មុខ(ស្រូវ-អង្ករ ដំឡូងមី ម្រេច ចេកអំបូងលឿង និងមៀនប៉ៃលិន)** | ជំរុញ និងបង្កើនការនាំចេញផលិតផលសក្តានុពលកម្ពុជា ចំនួន៥មុខ ដូចជា ស្រូវ-អង្ករ ដំឡូងមី ម្រេច ចេកអំបូងលឿង និងមៀនប៉ៃលិន ទៅកាន់ទីផ្សារប្រទេសចិន និងអន្តរជាតិ |
| សិក្សាស្រាវជ្រាវ ប្រមូល ចងក្រងទិន្នន័យ ផលិតផលសក្តានុពលដើម្បីដាក់បញ្ចូលក្នុងថ្នាលទីផ្សារឌីជីថល | បានប្រមូលចងក្រងផលិតផលចំនួន ២០៨មុខ ដែលមានសក្តានុពល អាចដាក់លក់លើទីផ្សារឌីជីថល |
| ផលិតវីដេអូផ្សព្វផ្សាយខ្លី នៅខេត្តបាត់ដំបង ប៉ៃលិន កែប និងកំពត សម្រាប់ដាក់ផ្សព្វផ្សាយក្នុងប្រព័ន្ធផ្សព្វផ្សាយសាធារណៈនានា | វីដេអូខ្លីដែលមានរយៈពេល ៤នាទី អំពី "ការជំរុញផលិតផលសក្តានុពលកម្ពុជា សម្រាប់នាំចេញទៅទីផ្សារអន្តរជាតិ" ត្រូវបានផលិតរួច និងដាក់ផ្សាយលើគេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម និងប្រព័ន្ធផ្សព្វផ្សាយសង្គមនានា។ |
| **តាំងបង្ហាញ និងលក់ផលិតផលខ្មែរ តាមបណ្តាស្ថានីយប្រេងឥន្ធនៈភីធីធី** | ចំនួន ៤លើក ក្នុង១ឆ្នាំ នៅ១១ រាជធានី-ខេត្ត ដែលមានអាជីវករសរុបចំនួនប្រហែល ២០៦នាក់ |
| **អនុស្សរណៈនៃការយោគយល់គ្នា** | |
| ស្តីពីកិច្ចសហប្រតិបត្តិការរួមគ្នាក្នុងការសាងសង់សួនឧស្សាហកម្មចិន-កម្ពុជា នៅរដ្ឋធានីប៉េកាំង | អនុស្សរណៈត្រូវបានចុះហត្ថលេខារវាងក្រសួងពាណិជ្ជកម្ម និងតំបន់ស្វយ័តក្វាងស៊ីយ៉ង ដើម្បីបង្កើតជាមជ្ឈមណ្ឌលផ្គត់ផ្គង់វត្ថុធាតុដើម សំដៅគាំទ្រដល់ការផលិត លក់ ចែកចាយទំនិញ |
| ***<u>គ.ការងារតំណាងពាណិជ្ជកម្មក្រៅប្រទេស</u>*** | |
| បូកសរុបសង្ខេបរបាយការណ៍ពីអនុព័ន្ធពាណិជ្ជកម្មកម្ពុជាប្រចាំ ១៩ស្ថានតំណាង នៅ១៦ប្រទេស ៖ ចិន(ប៉េកាំង សៀងហៃ ណាននីង ក្វាងចូវ)-អូស្ត្រាលី និងណូវែលហ្សេឡង់-ឥណ្ឌូនេស៊ី-អាម៉េរិក-ម៉ាឡេស៊ី-សិង្ហបុរី -កូរ៉េ-ស្វីស-ថៃ-ជប៉ុន-វៀតណាម-បែលហ្ស៊ិក-រុស្ស៊ី-តួកគី-ហ្វីលីពីន និងចក្រភពអង់គ្លេស | ទទួលបាន ២០៧របាយការណ៍ ដែលរាយការណ៍ពីសកម្មភាពការងារ និងព័ត៌មានពាណិជ្ជកម្មរវាងកម្ពុជា និងប្រទេសសាមីដែលមានអនុព័ន្ធពាណិជ្ជកម្មនៅប្រចាំការ។ |
| តាមដាន និងធ្វើរបាយការណ៍ស្តីពីថ្លៃប្រេងឥន្ធនៈរៀងរាល់សប្តាហ៍ ដែលទទួលព័ត៌មានបានពីតំណាងពាណិជ្ជកម្ម កម្ពុជា ប្រចាំនៅក្រៅប្រទេស | បានធ្វើការសិក្សាវិភាគពីស្ថានភាពថ្លៃប្រេងឥន្ធនៈ នៃប្រទេសជិតខាងក្នុងតំបន់បានចំនួន ៣០លើក ដើម្បីផ្តល់ជាធាតុចូល និងជំនួយស្មារតីជូនថ្នាក់ដឹកនាំក្នុងការងារថ្លៃប្រេងឥន្ធនៈ |
| រៀបចំបច្ចុប្បន្នភាពបញ្ជីឈ្មោះ និងអាណត្តិការងាររបស់តំណាងពាណិជ្ជកម្មកម្ពុជា ប្រចាំនៅក្រៅប្រទេស | បានចងក្រងទិន្នន័យបច្ចុប្បន្នភាពដើម្បីផ្លាស់ប្តូរសមាសភាពតំណាងពាណិជ្ជកម្មប្រចាំទីតាំងនីមួយៗ ចំនួន ១០នាក់ |

## ៥.៣. ការងារអនុវត្តគោលនយោបាយពាណិជ្ជកម្ម

| **ចំណុចការងារ** | **លទ្ធផល** |
|---|---|
| ***<u>ក. គោលនយោបាយជាតិស្តីពីជំនួញទី ២០២០-២០២៥</u>*** | |

| | |
|---|---|
| រៀបចំចងក្រងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីដំឡូងមី ២០២០-២០២៥ ដែលទទួលបានពីក្រសួងស្ថាប័នពាក់ព័ន្ធចំនួន២៦ | • របាយការណ៍បានរៀបចំរួចរាល់សម្រាប់សកម្មភាពអនុវត្តគិតចាប់តាំងពីឆ្នាំ២០២០ រហូតដល់១០ខែដើមឆ្នាំ២០២៣<br>• ក្នុង ១០ខែឆ្នាំ២០២៣ ការនាំចេញដំឡូងមីស្រស់មានចំនួន ១ ២១៥ ៣៥០តោន ចំណិតដំឡូងមីក្រៀមចំនួន ១ ០០៤ ០៨៩,០៤តោន និងម្សៅដំឡូងមីចំនួន ២៧ ៥១៦,៨តោន<br>• ការអនុវត្តគោលនយោបាយដំឡូងមីបានសម្រេចវឌ្ឍនភាពគួរជាទីកត់សម្គាល់តាមការគ្រោងទុកបើធៀបនឹងផែនការសកម្មភាព<br>• របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិកំពុងត្រូវបានរៀបចំ |
| ការផ្សព្វផ្សាយនិងជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីដំឡូងមី ២០២០-២០២៥ ចំនួន ៤ខេត្ត រួមមាន៖ខេត្តក្រចេះ ពោធិ៍សាត់ ប៉ៃលិន និងខេត្តបន្ទាយមានជ័យ | អ្នកចូលរួមមានចំនួន ២២៣នាក់ និងទទួលបានលទ្ធផល ៖<br>• បានផ្សព្វផ្សាយដល់វិស័យឯកជន និងផ្នែកសាធារណៈ អំពីអត្ថប្រយោជន៍នៃការអនុវត្តគោលនយោបាយ និងការចូលរួមរបស់ភាគីពាក់ព័ន្ធដើម្បីជំរុញការផលិត កែច្នៃ និងនាំចេញ<br>• ផ្សព្វផ្សាយពីបច្ចេកទេសថ្មីៗក្នុងការលើកកម្ពស់ផលិតកម្ម ការបង្កើតស្តង់ដា នៃចំណិតដំឡូងមី និងអត្ថប្រយោជន៍ក្នុងការចងក្រងជាបណ្តុំអ្នកកែច្នៃ ដែលជំរុញដល់ការនាំចេញ<br>• ប្រមូលចងក្រងព័ត៌មានវឌ្ឍនភាពថ្មីៗ មតិយោបល់ និងបញ្ហាប្រឈមនានាក្នុងវិស័យនេះ |
| ការពិគ្រោះយោបល់ស្តីពី "កាលានុវត្តភាពធុរកិច្ចប្រកបដោយចីរភាពលើផលិតផលដំឡូងមីកម្ពុជា" ចំនួន ៣ខេត្ត រួមមាន៖ ខេត្តព្រះវិហារ ពោធិ៍សាត់ និងខេត្តឧត្តរមានជ័យ | អ្នកចូលរួម ២១០នាក់ និងទទួលបានលទ្ធផល ៖<br>• ប្រមូលបានទិន្នន័យ ពិភាក្សា និងទទួលធាតុចូលថ្មីៗពីស្ថាប័នពាក់ព័ន្ធសម្រាប់រៀបចំសេចក្តីព្រាងឯកសារនេះ<br>• ធ្វើបច្ចុប្បន្នភាពព័ត៌មាន និងឯកសារគាំទ្រនានា ដើម្បីជាជំនួយដល់ការកសាងសេចក្តីព្រាងឯកសារ |
| រៀបចំកែសម្រួលសមាសភាពក្នុងប្រកាសលេខ ១៩៣ ព.ណ. គនព ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ ២០២១ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីការបង្កើតក្រុមការងារអន្តរស្ថាប័ន សម្រាប់ពិនិត្យតាមដាន វាយតម្លៃ ការអនុវត្តគោលនយោបាយជាតិស្តីពីដំឡូងមី២០២០-២០២៥ | បានធ្វើបច្ចុប្បន្នភាពសមាសភាពចំនួន១៤ ស្ថាប័នរួចហើយនូវរង់ចាំការឆ្លើយតបពីស្ថាប័នចំនួន ២ទៀត |
| ចងក្រងកម្រងព័ត៌មានពាណិជ្ជកម្មអំពីវិស័យដំឡូងមីនៅកម្ពុជា ដោយដកស្រង់ពីប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, របាយការណ៍របស់មន្ទីរពាណិជ្ជកម្មខេត្ត, FAO, FAOSTAT (FAO, ២០២១), ផែនទីពាណិជ្ជកម្មរបស់ ITC | កម្រងព័ត៌មានបានចងក្រងរួចរាល់ដើម្បីផ្សព្វផ្សាយជូនថ្នាក់ដឹកនាំ និងស្ថាប័នពាក់ព័ន្ធដែលក្នុងនោះរួមមាន៖<br>• បរិមាណទិន្នផលប្រចាំឆ្នាំ និងផ្ទៃដីដាំដុះ<br>• បរិមាណនាំចេញតាមប្រភេទទំនិញ (ម្សៅដំឡូង ចំណិតដំឡូងស្រស់ និងក្រៀម)<br>• ព័ត៌មានទីផ្សារអន្តរជាតិ និងបម្រែបម្រួលថ្លៃក្នុងស្រុក រួមទាំងតម្រូវការដាក់ស្តែងតាមទីផ្សារក្នុងតំបន់ |
| ***ខ. គោលនយោបាយជាតិស្តីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧*** | |
| បញ្ចប់ការរៀបចំគោលនយោបាយជាតិស្តីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧ | គោលនយោបាយនេះបានទទួលការអនុម័តនាសម័យកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ |

| | |
|---|---|
| ពិធីផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការ គោលនយោបាយជាតិស្តីពី ស្វាយចន្ទីឆ្នាំ ២០២២-២០២៧ នៅក្រសួងពាណិជ្ជកម្ម | មានអ្នកចូលរួមចំនួន ២៥០ នាក់ និងបានចែកចាយសៀវភៅគោលនយោបាយចំនួន ៥០០ក្បាល ដល់អ្នកចូលរួមសម្រាប់ចែកចាយបន្ត |
| ការផ្សព្វផ្សាយនិងជំរុញការអនុវត្តគោលនយោបាយជាតិ ស្តីពី ស្វាយចន្ទីឆ្នាំ ២០២២-២០២៧ចំនួន៣ខេត្ត រួមមាន៖ខេត្តកំពង់ធំ កំពង់ចាម និងខេត្តព្រះវិហារ | អ្នកចូលរួមសរុបចំនួន ២៥០នាក់ និងទទួលបានលទ្ធផល ៖<br>• បានផ្សព្វផ្សាយចំណេះដឹង ព័ត៌មាន និងបទពិសោធន៍ពីផលិតកម្ម និងទីផ្សារជាតិ និងអន្តរជាតិ<br>• ទទួលបានការចែករំលែកបទពិសោធន៍ល្អៗ ទាក់ទងនឹងឥណទាន ហិរញ្ញវត្ថុ ការប្រមូលទិញ ដឹកជញ្ជូន និងដំណោះស្រាយបញ្ហាប្រឈមនានា |
| រៀបចំកែសម្រួលសមាសភាពសេចក្តីសម្រេច ស្តីពីគណៈកម្មការតាមដាន និងវាយតម្លៃគោលនយោបាយស្វាយចន្ទី (គ.ត.គ.ស) និងប្រកាស ស្តីពីការបង្កើតលេខាធិការដ្ឋាន គ.ត.គ.ស | ធ្វើបច្ចុប្បន្នភាពសមាសភាពបានចំនួន១៥ ស្ថាប័នរួចហើយនៅរង់ចាំការឆ្លើយតបពីស្ថាប័នចំនួន ៤ទៀត |
| ចងក្រងកម្រងព័ត៌មានពាណិជ្ជកម្មអំពីវិស័យស្វាយចន្ទីកម្ពុជា ដោយដកស្រង់ពីប្រភព៖ ក្រសួង-ស្ថាប័នពាក់ព័ន្ធ ITC Trade Map និង សមាគម សហព័ន្ធស្វាយចន្ទីកម្ពុជា | កម្រងព័ត៌មានបានចងក្រងរួចរាល់ដើម្បីផ្សព្វផ្សាយជូនថ្នាក់ដឹកនាំ និង ស្ថាប័នពាក់ព័ន្ធដែលក្នុងនោះរួមមាន៖<br>• បរិមាណទិន្នផលប្រចាំឆ្នាំ និងផ្ទៃដីដាំដុះ<br>• បរិមាណនាំចេញតាមប្រភេទទំនិញគ្រាប់ចន្ទីមិនទាន់កែច្នៃ និងកែច្នៃរួច<br>• ព័ត៌មានទីផ្សារអន្តរជាតិ និងបម្រែបម្រួលថ្លៃក្នុងស្រុក រួមទាំងតម្រូវការជាក់ស្តែងតាមទីផ្សារក្នុងតំបន់ |
| រៀបចំវេទិកាស្វាយចន្ទី នៅខេត្តកំពង់ធំ | អ្នកចូលរួមប្រមាណ ៣០០នាក់ និងទទួលបានលទ្ធផល ៖<br>• ផ្សព្វផ្សាយពីផលិតផលស្វាយចន្ទីកម្ពុជាជូនធុរជនក្នុងនិងក្រៅប្រទេស<br>• ស្វែងរកអ្នកវិនិយោគមកវិនិយោគបន្ថែមលើការកែច្នៃគ្រាប់ស្វាយចន្ទី<br>• ស្វែងរកក្រុមហ៊ុនឬសិប្បកម្មថ្មីៗ ដើម្បីធ្វើជាគំរូសម្រាប់វិស័យនេះ និងមានតាំងបង្ហាញផលិតផលស្វាយចន្ទី គ្រឿងចក្រកសិកម្មសម្រាប់ផលិតកម្មស្វាយចន្ទី |
| សហការរៀបចំសន្និសីទស្វាយចន្ទីពិភពលោក នៅខេត្តសៀមរាប | បានរៀបចំកិច្ចប្រជុំត្រៀមចំនួន ៣លើក ដើម្បីបែងចែកការងារ ត្រៀមថវិកា និងអញ្ជើញភាគីពាក់ព័ន្ធដើម្បីចូលរួម និងធ្វើបទបង្ហាញ |

### គ. ការអនុវត្តគោលនយោបាយជាតិ ជំរុញចលនាភូមិ១ផលិតផល១

- ផលិតផលចំនួន ៤០៦មុខ ត្រូវបានពិនិត្យវាយតម្លៃ និងស្នើសុំទទួលស្គាល់ជាផលិតផលភូមិ១ផលិតផល១ សម្រាប់ឆ្នាំ២០២៣
- រៀបចំរបាយការណ៍វឌ្ឍនភាពចលនាជំរុញភូមិ១ផលិតផល១ ប្រចាំឆ្នាំ របស់ក្រសួងពាណិជ្ជកម្ម
- កំពុងរៀបចំចុះបញ្ជីម៉ាកសមូហភាព ដើម្បីជំរុញអភិវឌ្ឍន៍ផលិតផលក្នុងស្រុកមួយចំនួន៖ ១). ស្ករដីនៅខេត្តកំពង់ឆ្នាំង ២). ចម្លាក់ប្រាក់-ស្ពាន់នៅខេត្តកណ្តាល និង៣). ចម្លាក់ថ្មនៅខេត្តពោធិ៍សាត់ តាមរយៈការរៀបចំសិក្ខាសាលាបណ្តុះបណ្តាល និងការចងក្រងក្រុមផលិត។

### ឃ. ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ២០១៥-២០២៥

- សម្របសម្រួលប្រមូលទិន្នន័យ បូកសរុបរបាយការណ៍វិស័យពាណិជ្ជកម្ម និងរៀបចំលិខិតឆ្លើយតបទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ (IDP) សម្រាប់ឆ្នាំ២០២៣
- កែសម្រួលប្រកាស ស្តីពីសមាសភាពក្រុមការងារបច្ចេកទេសលេខាធិការដ្ឋាន សម្រាប់តាមដានការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥។

## ខ. ការងារចងក្រងឯកសារ និងចូលរួមកិច្ចប្រជុំ ការបណ្តុះបណ្តាល បេសកកម្ម

- សហការជាមួយអង្គការ CAPRED ក្នុងការចងក្រង និងបោះពុម្ព ១)ឯកសារស្រាវជ្រាវស្តីពី "Market Study on Cambodia's Agriculture Crops with Prospect for EU and RCEP Markets" ២)ឯកសារស្រាវជ្រាវ ស្តីពី "កម្ពុជានិងការបើកទីផ្សារពិភពលោកតាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្ម" និង៣)គោលនយោបាយជាតិស្តីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧
- រៀបចំចងក្រង និងបោះពុម្ពឯកសារស្រាវជ្រាវ ស្តីពី "បរិយាកាសធុរកិច្ចខេត្តកំពត"
- កំពុងបន្តតាមដានព័ត៌មានទាក់ទងនឹងនិន្នាការសេដ្ឋកិច្ចពាណិជ្ជកម្មក្នុងតំបន់ និងសកល
- កំពុងបន្តស្រាវជ្រាវគោលនយោបាយ និងយុទ្ធសាស្ត្រជំរុញពាណិជ្ជកម្មពាក់ព័ន្ធរបស់ប្រទេសក្នុងតំបន់អាស៊ាន
- ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ កម្រិតបច្ចេកទេស និងកិច្ចប្រជុំកម្រិតអគ្គនាយកនៃវេទិកាជំរុញពាណិជ្ជកម្មអាស៊ី (ATPF) លើកទី៣៦( 36th Asian Trade Promotion Forum CEO Meeting) ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន។

## ៦. កិច្ចការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ

### ៦.១. កិច្ចការពារអ្នកប្រើប្រាស់

| **បរិយាយការងារ** | **លទ្ធផល** |
|---|---|
| ការងារឃ្លាំពិនិត្យទីផ្សារ | ឃ្លាំពិនិត្យទីផ្សារចំនួន **៦០២លើក** និងដកហូតទំនិញមិនមានអនុលោមភាព ចំនួន **២៦តោន ៦២៦គីឡូក្រាម** មកកម្ទេចចោល |
| ការងារត្រួតពិនិត្យស្ថានីយ/ដេប៉ូលក់រាយប្រេងឥន្ធនៈ | ចុះត្រួតពិនិត្យគុណភាព និងបរិមាណរង្វាស់រង្វាល់ប្រេងឥន្ធនៈ នៅតាមបណ្តាស្ថានីយ/ដេប៉ូលក់ប្រេងឥន្ធនៈ សរុបបានចំនួន **១ ៦៩៥ស្ថានីយ/ដេប៉ូ** ដោយរកឃើញស្ថានីយ/ដេប៉ូចំនួន **២៤៩** បានប្រកបអាជីវកម្មមិនសុចរិតផ្នែកបរិមាណនិងគុណភាព |
| ការឃ្លាំពិនិត្យគុណភាពសុវត្ថិភាពទំនិញ | - សហការជាមួយស្ថាប័នមានសមត្ថកិច្ច ធ្វើការចុះត្រួតពិនិត្យតាមទីតាំងស្តុកចែកចាយ និងមធ្យោបាយដឹកជញ្ជូនទំនិញនាំចូលនូវផលិតផលសាច់បង្កកចម្រុះគ្រឿងសមុទ្រគ្រប់ប្រភេទ និងស៊ុតមាន់ ដែលមានសារធាតុគីមី និងចម្លងមេរោគ ដោយបានធ្វើការដកហូត និងយកមកកម្ទេចចោល ចំនួន **២ ០៦៧តោន និង៧៧៩គីឡូក្រាម**<br>-ចុះត្រួតពិនិត្យទីតាំងលក់ ផលិត កែច្នៃ និងស្តុកផលិតផលចំនួន ២០៣ទីតាំង រកឃើញនូវផលិតផលក្លែងក្លាយ រំលោភបំពានបទប្បញ្ញត្តិកម្មសិទ្ធិបញ្ញា ចំនួន **១,២១៥តោន និង៥១២គីឡូក្រាម** ដោយអនុវត្តតាមនីតិវិធីជាធរមាន<br>- ដកហូតសារធាតុគីមីជាម្សៅស Sodium Hydrosulfite ចំនួន **៨៥គក្រ** និងសាជូរ **ចំនួន ២៨បារ ស្មើនឹង ៨៣០គក្រ** ដែលអាជីវករយកមកប្រើប្រាស់ធ្វើឱ្យបន្លែស្រស់ |
| ការត្រួតពិនិត្យការផ្សាយពាណិជ្ជកម្ម និងផ្តល់អនុលោមភាព | - ត្រួតពិនិត្យខ្លឹមសារអត្ថបទ និងរូបភាពស្ពតផ្សាយពាណិជ្ជកម្មតាមបណ្តាប្រព័ន្ធផ្សព្វផ្សាយនានាចំនួន **៤៩** ដោយរកឃើញស្ពតផ្សាយពាណិជ្ជកម្មចំនួន**៣៤** មានលក្ខណៈភូតកុហក់ពង្វាងការពិត និងបានចាត់វិធានការស្របតាមនីតិវិធីច្បាប់<br>- ផ្តល់លិខិតបញ្ជាក់អនុលោមភាពផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញ និងសេវាបានចំនួន **៤០លិខិត** |
| ការទទួល និងដោះស្រាយបណ្តឹងរបស់អ្នកប្រើប្រាស់ | បានទទួលពាក្យបណ្តឹងពីអ្នកប្រើប្រាស់ ចំនួន **៣២បណ្តឹង** ដែលក្នុងនោះ៖<br>- ដោះស្រាយបញ្ចប់ក្រៅប្រព័ន្ធតុលាការចំនួន **១១បណ្តឹង**<br>- បញ្ជូនទៅតុលាការចំនួន **៥បណ្តឹង**<br>- កំពុងបន្តអនុវត្តនីតិវិធីស៊ើបអង្កេត ចំនួន **៨បណ្តឹង** |

| | |
|---|---|
| | - បានបិទបញ្ចប់បណ្តឹង ចំនួន **២បណ្តឹង**<br>- តម្កល់ទុកមិនចាត់ការ ចំនួន **៦បណ្តឹង** |
| ការអនុវត្តកិច្ចការពារអ្នកប្រើប្រាស់អាស៊ាន | - ទទួលធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំលើកទី២៧ នៃគណៈកម្មការការពារអ្នកប្រើប្រាស់អាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធ (27th ACCP)<br>- បានចូលរួមសន្និសីទ កិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលក្នុងក្របខណ្ឌអាស៊ាន បានចំនួន **១៥លើក**<br>- បានចូលរួមសន្និសីទ កិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងការផ្លាស់ប្តូរបទពិសោធន៍ការងារក្នុងក្របខណ្ឌ ACCC បានចំនួន **១៣លើក** |

## ៦.២. កិច្ចការប្រកួតប្រជែង

| **បរិយាយការងារ** | **លទ្ធផល** |
|---|---|
| ការងាររៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត | ការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលទាក់ទងការងារប្រកួតប្រជែងត្រូវបានរាយការណ៍នៅក្នុងចំណុច ស្តីពីការកសាងលិខិតបទដ្ឋានគតិយុត្ត |
| ការងារដកពិសោធន៍ និងបង្កើនសមត្ថភាព | ការងារដកពិសោធន៍ និងបង្កើនសមត្ថភាពត្រូវបានរាយការណ៍នៅក្នុងចំណុច ស្តីពីការបង្កើនប្រសិទ្ធភាពការងារមន្ត្រី |
| ការអនុវត្តច្បាប់កិច្ចការប្រកួតប្រជែង | - ទទួលផ្តល់ការប្រឹក្សាយោបល់ដល់ការិយាល័យមេធាវីចំនួន ៧ ពាក់ព័ន្ធការរួមបញ្ចូលគ្នានៃធុរកិច្ច (Merger) |
| ការអនុវត្តកិច្ចប្រកួតប្រជែងអាស៊ាន | - ចូលរួមជាមួយក្រុមអ្នកជំនាញច្បាប់ស្តីពីការប្រកួតប្រជែងអាស៊ាន(ASEAN Expert Group on Competition-AEGC)<br>- ចូលរួមជាមួយក្រុមការងារប្រជុំចរចាលើការតាក់តែង កិច្ចព្រមព្រៀងក្របខណ្ឌអាស៊ានលើកិច្ចការប្រកួតប្រជែង ASEAN Framework on Competition-AFAC)<br>- ចូលរួមជាមួយក្រុមការងារប្រជុំចរចាក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាស៊ាន-ចិន (ACFTA) និង អាស៊ាន-កាណាដា (ACAFTA) លើជំពូក ពាក់ព័ន្ធនឹង "កិច្ចការប្រកួតប្រជែង"<br>- ធ្វើជាម្ចាស់ផ្ទះ ក្នុងការរៀបចំកិច្ចប្រជុំប្រមូលជាតុចូលលើប្រព័ន្ធព័ត៌មានលើករណីការរួមបញ្ចូលគ្នានៃធុរកិច្ចអាស៊ាន (Merger Information Sharing Portal-MISP) នៅខែធ្នូ ឆ្នាំ២០២៣ |

## ៦.៣. កិច្ចការគ្រប់គ្រងផលិតផលហាឡាល

| **បរិយាយការងារ** | **លទ្ធផល** |
|---|---|
| ការងារផ្តល់វិញ្ញាបនបត្រហាឡាល | បានផ្តល់វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ចំនួន៦៥ច្បាប់ ជូនផលិតករ និងធុរជន/ក្រុមហ៊ុនជាតិ និងអន្តរជាតិ |
| ការអប់រំណែនាំលើការប្រើប្រាស់ស្លាកសញ្ញាហាឡាល | បានចុះធ្វើការអប់រំណែនាំ លើការប្រើប្រាស់ស្លាកសញ្ញាហាឡាលមិនប្រក្រតី ចំនួន ១៦ ករណី នៅរាជធានីភ្នំពេញ និងបណ្តាខេត្ត |
| ការចុះត្រួតពិនិត្យបច្ចេកទេស ស្តង់ដារហាឡាល | បានសហការជាមួយក្រុមឯកទេសផលិតផលហាឡាល ចុះត្រួតពិនិត្យនិងវាយតម្លៃលក្ខណៈបច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ចំនួន **២៥លើក** នៅតាមក្រុមហ៊ុន សិប្បកម្ម សហគ្រាសចំនួន **៤៩ទីតាំង** នៅរាជធានីភ្នំពេញ និងបណ្តាខេត្ត |

## ៦.៤. ការងារមន្ទីរពិសោធន៍

| បរិយាយការងារ | លទ្ធផល |
| --- | --- |
| ការវិភាគគុណភាពទំនិញនៅមន្ទីរពិសោធន៍នៃអគ្គនាយកដ្ឋាន ក.ប.ប. | បានវិភាគគុណភាពទំនិញចំនួន **២ ១០៣ សំណាកគំរូ** ដែលក្នុងនោះមាន៖ ផលិតផលម្ហូបអាហារចំនួន **១ ៦៦០គំរូ** ផលិតផលប្រេងឥន្ធនៈចំនួន **២៧៤គំរូ** ផលិតផលមិនមែនម្ហូបអាហារចំនួន **៤៩គំរូ** ផលិតផលកសិផលចំនួន **១២០គំរូ** ដោយរកឃើញផលិតផលចំនួន **១៥៧គំរូ** មិនអនុលោមទៅនឹងប្បញ្ញត្តិបច្ចេកទេស ក្នុងនោះផលិតផលមិនមែនម្ហូបអាហារចំនួន ៥គំរូ |
| ការវិភាគគុណភាពទំនិញតាមរថយន្តមន្ទីរពិសោធន៍ចល័ត | បានធ្វើការវិភាគគុណភាពទំនិញតាមមន្ទីរពិសោធន៍ចល័តចំនួន **៤៦៩គំរូ** ដោយរកឃើញទំនិញគ្មានអនុលោមភាពចំនួន **៤០៨គំរូ** ជាប្រភេទម្ហូបអាហារ និងចំនួន **៦១គំរូ** ជាប្រភេទប្រេងឥន្ធនៈ ដោយរកឃើញទំនិញគ្មានអនុលោមភាពចំនួន **១១គំរូ** ជាម្ហូបអាហារ និងចំនួន ១គំរូជាប្រេងឥន្ធនៈយកទៅកំទេចចោល |
| ការវិភាគគុណភាពទំនិញតាមមន្ទីរពិសោធន៍ខ្នាតតូច តាមបណ្តាខេត្ត | បានធ្វើការវិភាគគុណភាពទំនិញតាមមន្ទីរពិសោធន៍ខ្នាតតូចចំនួន **៣០៣គំរូ** ដោយរកឃើញទំនិញគ្មានអនុលោមភាពចំនួន **២៥គំរូ** យកទៅកំទេចចោល |
| ការផ្តល់វិញ្ញាបនបត្រវិភាគគុណភាពទំនិញ | បានផ្តល់វិញ្ញាបនបត្រវិភាគគុណភាពទំនិញជូនអតិថិជនបានចំនួន **៥៥២វិញ្ញាបនបត្រ** |
| រៀបចំប្រព័ន្ធគ្រប់ទិន្នន័យមន្ទីរពិសោធន៍ | បានកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ទីរពិសោធន៍តាមប្រព័ន្ធអនឡាញរួមមាន ការចុះបញ្ជីសំណាកគំរូ ការបញ្ជូនលទ្ធផលវិភាគ និងការចេញវិញ្ញាបនបត្រដោយស្វ័យប្រវត្តិ |
| ការពង្រឹងផ្ទៀងផ្ទាត់សមត្ថភាពជាមួយដៃគូមន្ទីរពិសោធន៍ក្នុងតំបន់ | ចូលរួមកម្មវិធីធ្វើតេស្តសាកល្បងសមត្ថភាពវិភាគជាមួយបណ្តាមន្ទីរពិសោធន៍អាស៊ាន **ចំនួន ៦លើក** |
| ការរៀបចំនីតិវិធីប្រតិបត្តិដើម្បីធានាការអនុវត្តល្អក្នុងមន្ទីរពិសោធន៍ | ចងក្រងនីតិវិធីប្រតិបត្តិស្តង់ដា (SOP) សរុបចំនួន **១៥នីតិវិធី។** នីតិវិធីប្រតិបត្តិស្តង់ដាទាំងចំនួន ១៥ ត្រូវបានផ្តល់សុពលភាព និង**២៩នីតិវិធី** កំពុងរៀបចំជាសេចក្តីព្រាង |

## ៦.៥. ការងារស្រាវជ្រាវសេចក្តីជូនដំណឹង អំពីអនាម័យ និងភូតគាមអនាម័យ

| បរិយាយការងារ | លទ្ធផល |
| --- | --- |
| សិក្សាស្រាវជ្រាវ ប្រមូលផ្តុំ និងជ្រើសរើសសេចក្តីជូនដំណឹងស្តីអំពីវិធានអនាម័យ និងភូតគាមអនាម័យ | - បានធ្វើការសិក្សាចំនួន ៣៩៣ករណីទាក់ទងនឹងផ្នែកសុវត្ថិភាពផលិតផល<br>- បានសិក្សាផលិតផលម្ហូបអាហារដែលដាក់លក់លើទីផ្សារអាមេរិក និងទីផ្សារអឺរ៉ុបចំនួន **៥១មុខ** ដែលផលិតផលទាំងនេះអាចនាំចូលមកទីផ្សារកម្ពុជា |

## ៦.៦. ការងារលើកកម្ពស់ការយល់ដឹងសាធារណៈ

| បរិយាយការងារ | លទ្ធផល |
| --- | --- |
| ការចុះផ្សព្វផ្សាយផ្ទាល់តាមគោលដៅអាទិភាព | - ផ្សព្វផ្សាយការយល់ដឹងអំពីច្បាប់សុវត្ថិភាពម្ហូបអាហារនៅតាមបណ្តាគ្រឹះស្ថានសិក្សានានា នៅរាជធានី-ខេត្ត បានចំនួន **១០១លើក** មានអ្នកចូលរួមចំនួន **៤៩ ៤៧៥នាក់**<br>- បានសហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់(GIZ) រៀបចំផ្សព្វផ្សាយការយល់ដឹងអំពីច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់និងច្បាប់ស្តីពីការប្រកួតប្រជែងចំនួន ៧លើក នៅតាមបណ្តាខេត្តជាចង្កោម ដោយមានអ្នកចូលរួមចំនួន **១ ៣០០នាក់** |

| | |
|---|---|
| ការផ្សព្វផ្សាយតាមរយៈរូបភាព និងខិត្តបណ្ណ | - បិទផ្ទាំងរូបភាពផ្សព្វផ្សាយ (Posters) អំពីរបៀបពិនិត្យស្លាកសញ្ញាផលិតផលម្ហូបអាហារ ដែលមានសុវត្ថិភាពនៅតាមទីផ្សារ និងទីសាធារណៈ បានចំនួន **៦ ៨០៩ផ្ទាំង**<br>- បិទខិត្តបណ្ណផ្សព្វផ្សាយ (Flyer) អំពីអំពើមិនសុចរិតក្នុងធុរកិច្ចពាក់ព័ន្ធនឹងវិស័យប្រេងឥន្ធនៈនៅតាមស្ថានីយ/ដេប៉ូលក់ប្រេងឥន្ធនៈនៅទូទាំងប្រទេស បានចំនួន **១ ៤៧៨ផ្ទាំង**<br>- បិទខិត្តបណ្ណផ្សព្វផ្សាយ អំពីការរើកាគរកេសារជាតុអាសបេស្តុស បានចំនួន **១ ៥០០ផ្ទាំង** |

## ៦.៧. ការបង្កើនប្រសិទ្ធភាពការងារមន្ត្រី

| **បរិយាយការងារ** | **លទ្ធផល** |
|---|---|
| ការបង្កើនប្រសិទ្ធភាពដោយផ្ទាល់នៅនឹងកន្លែង | រៀបចំកម្មវិធីបង្កើនសមត្ថភាពមន្ត្រីរាជការតាមរយៈការបើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា វេទិកាតុមូល ពាក់ព័ន្ធនឹងច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ច្បាប់ស្តីពីការប្រកួតប្រជែង ច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា ការប្រយុទ្ធប្រឆាំងនឹងការធ្វើពាណិជ្ជកម្មគ្រឿងស្រវឹងក្លែងក្លាយនៅកម្ពុជា ការកំណត់អត្តសញ្ញាណផលិតផល និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ បានចំនួន **១៩លើក** ដោយមានមន្ត្រីចូលរួមចំនួន **២ ៤៥៩ នាក់** |
| ការបង្កើនសមត្ថភាពតាមរយៈប្រព័ន្ធអនឡាញ | ចូលរួមកម្មវិធីបង្កើនសមត្ថភាពក្នុង និងក្រៅប្រទេសតាមរយៈប្រព័ន្ធអនឡាញបានចំនួន **២៨លើក** មានមន្ត្រីចូលរួម **៩០នាក់** |

## ៦.៨. កិច្ចសហប្រតិបត្តិការជាតិ តំបន់ និងអន្តរជាតិ

| **បរិយាយការងារ** | **លទ្ធផល** |
|---|---|
| ការបង្កើនសមត្ថភាព និងផ្លាស់ប្តូរបទពិសោធន៍ការងារ | - ចូលរួមជាវាគ្មិនដើម្បីដែកពិភាក្សាលើលទ្ធផលនៃការរៀបចំផែនការកម្មវិធីសហប្រតិបត្តិការលើកកម្ពស់និងពង្រឹងសុវត្ថិភាពម្ហូបអាហារក្នុងតំបន់ នៅប្រទេសថៃ<br>- ចូលរួមក្នុងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ីប៉ូពាំលើកទី១៨ ស្តីពីគោលនយោបាយប្រកួតប្រជែង និងសន្និសីទអាស៊ីប៉ូពាំលើកទី១៥ ស្តីពីច្បាប់និងគោលនយោបាយប្រកួតប្រជែង នៅប្រទេសថៃ<br>- ចូលរួមកម្មវិធីសិក្សាដកស្រង់បទពិសោធន៍ ស្តីពីកិច្ចការពារអ្នកប្រើប្រាស់នៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលសេឡង់(AANZFTA CAP 2023) នៅប្រទេសអូស្ត្រាលី ចំនួន ១លើក<br>- បានទទួលមន្ត្រីជំនាញរបស់គណៈកម្មការការពារអ្នកប្រើប្រាស់ប្រទេសអូស្ត្រាលី ចំនួន៣នាក់ មកផ្លាស់ប្តូរបទពិសោធន៍ និងបំពេញការងារ នៅអគ្គនាយកដ្ឋាន ក.ប.ប.<br>- ចូលរួមកម្មវិធី ស្តីពីការរៀបចំគោលនយោបាយប្រកួតប្រជែងសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច ក្នុងទ្វីបអាស៊ីនៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន<br>- ចូលរួមប្រជុំក្រុមជំនាញការប្រកួតប្រជែងអាស៊ានលើកទី៣១ និងកិច្ចប្រជុំពាក់ព័ន្ធ នៅ ទីក្រុង Cebu ប្រទេសហ្វីលីពីន<br>- ចូលរួមវគ្គបង្កើនសមត្ថភាពស្តីពី«ការព្រមព្រៀងខ្សែដេកនិងការឃុបឃិតដេញថ្លៃក្រោមច្បាប់ស្តីពីការប្រកួតប្រជែង» នៅប្រទេសម៉ាឡេស៊ី |

| | |
|---|---|
| | - ចូលរួមក្នុងកិច្ចប្រជុំលើកទី៤៦ នៃគណៈកម្មាធិការកូដិច (The 46th Session of Codex Alimentarius Commission នៅប្រទេសអ៊ីតាលី<br>- ចូលរួមក្នុងកម្មវិធីទស្សនកិច្ចសិក្សាស្តីពីសុវត្ថិភាពម្ហូបអាហារ ដែលរៀបចំឡើងដោយសម្ព័ន្ធនាំចេញផលិតផលម្ហូបអាហារនិងកសិកម្ម នៅទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាម៉េរិក<br>- ចូលរួមក្នុងទស្សនកិច្ចសិក្សាកម្រិតបច្ចេកទេសស្តីពីការបង្កើត និងដំណើរការបណ្តាញឧស្សាហកម្មកែច្នៃអាហារ កសិឧស្សាហកម្ម និងជះផលអវិជ្ជមាន ខាងផ្នែកសេដ្ឋកិច្ច នៅសាធារណរដ្ឋកូរ៉េ<br>- ចូលរួមសិក្ខាសាលាថ្នាក់តំបន់ស្តីពីការធ្វើសវនកម្ម និងអធិការកិច្ចពីចម្ងាយទាក់ទងនឹងសុវត្ថិភាពម្ហូបអាហារ (Remote Audit and Inspection related to Food Safty) នៅប្រទេសវៀតណាម |

## ៧.ការងារគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ[5]

### ៧.១.ការគ្រប់គ្រងរដ្ឋបាលទូទៅ

| **បរិយាយការងារ** | **លទ្ធផល** |
|---|---|
| ការគ្រប់គ្រង រៀបចំ និងចរាចរលិខិតរដ្ឋបាលគ្រប់ប្រភេទ | • លិខិតចូលចំនួន **៣ ៩២៧លិខិត**<br>• លិខិតចេញចំនួន **៧ ៩៩៨លិខិត**<br>• លិខិតអញ្ជើញបានចំនួន **៥១៧លិខិត**<br>• ចុះលេខលិខិតបេសកកម្មបានចំនួន **១ ៤៤៨លិខិត**<br>• ចុះលេខប្រកាសបានចំនួន **៣៤០លិខិត**<br>• ចុះលេខដីកាអមបានចំនួន **៧៤លិខិត**<br>• លិខិតចុះបញ្ជីពាណិជ្ជកម្មចំនួន **១ ៦៩៥លិខិត**<br>• លិខិតចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកចំនួន **១ ០០៥លិខិត** |
| រៀបចំ និងចងក្រងរបាយការណ៍ពាណិជ្ជកម្ម | • រៀបចំរបាយការណ៍បូកសរុបការងារពាណិជ្ជកម្មប្រចាំខែមករា ដល់ខែធ្នូ<br>• រៀបចំរបាយការណ៍ប្រជុំប្រចាំសប្តាហ៍ និងប្រចាំខែ<br>• រៀបចំរបាយការណ៍បូកសរុបការងារពាណិជ្ជកម្មត្រីមាស<br>• រៀបចំរបាយការណ៍បូកសរុបការងារពាណិជ្ជកម្មឆមាសទី១<br>• រៀបចំរបាយការណ៍បូកសរុបការងារពាណិជ្ជកម្មរយៈពេល ៩ខែ<br>• រៀបចំរបាយការណ៍បូកសរុបការងារពាណិជ្ជកម្មឆ្នាំ២០២៣ និងលើកទិសដៅបន្តឆ្នាំ២០២៤ |
| ពិធីការ និងបដិសណ្ឋាកិច្ច | • រៀបចំសាលប្រជុំ និងសម្របសម្រួលការងារពិធីការ សម្រាប់កិច្ចប្រជុំនានា និងពិធីចុះហត្ថលេខាសរុប **៣៩៤លើក** និងអ្នកចូលរួមសរុប **៩ ៦៦៥នាក់** |
| ចូលរួមសម្របសម្រួលព្រឹត្តិការណ៍ថ្នាក់ជាតិ និងពិធីផ្សេងៗ | • កម្មវិធីរៀបចំដោយគណៈកម្មាធិការជាតិ សរុប ៩លើក<br>• រៀបចំចាត់ចែងកម្មវិធីសន្និបាតបូកសរុបការងារពាណិជ្ជកម្មឆ្នាំ២០២៣ និងលើកទិសដៅឆ្នាំ២០២៤<br>• កម្មវិធីគោរពវិញ្ញាណក្ខន្ធព្រះមហាវីរក្សត្រ ព្រះបរមរតនកោដ្ឋ<br>• ពិធីគោរពវិញ្ញាណក្ខន្ធសពទាំងក្នុង និងក្រៅស្ថាប័នចំនួន ៤លើក |

[5] ប្រភព៖ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

| | |
|---|---|
| ការអនុវត្តសណ្តាប់ធ្នាប់ និងវិន័យ | • ពង្រឹងការអនុវត្តបទបញ្ជាផ្ទៃក្នុងក្រសួងឱ្យបានល្អប្រសើរ<br>• ថែទាំសួនច្បារ អំពូលភ្លើង ប្រព័ន្ធទឹក ប្រព័ន្ធអគ្គិសនី ប្រព័ន្ធម៉ាស៊ីនត្រជាក់<br>• រក្សាសន្តិសុខសណ្តាប់ធ្នាប់ក្នុងក្រសួង និងចំណតយានយន្តសម្រាប់មន្ត្រីរាជការ និងភ្ញៀវជាតិ-អន្តរជាតិ |

## ៧.២.ការងារហិរញ្ញវត្ថុ

| **បរិយាយការងារ** | **លទ្ធផល** |
|---|---|
| **ការងារប្រមូលចំណូល៖**<br>ចំណូលដែលប្រមូលបានពីការផ្តល់សេវាសាធារណៈ ការផាកពិន័យជាសាច់ប្រាក់ និងចំណូលថ្លៃឈ្នួលអចលនទ្រព្យ | **សរុបចំណូលប្រមូលបានក្នុងរយៈពេល១១ខែដើមឆ្នាំ២០២៣** នេះមានចំនួន៖ **៥៣ ៥៧៨,១លានរៀល** ( **ស្មើនឹង ១០២,០៩%** នៃច្បាប់ថវិកាឆ្នាំនេះដែលមានចំនួនសរុប **៥២ ៤៨២,០លានរៀល** ) ក្នុងនោះចំណូលបានពី៖<br>- ការផ្តល់វិញ្ញាបនបត្រប្រភពដើមទំនិញ៖ ២៦ ៥១៣ ៨២៧ ៧៦២ រៀល<br>- ការចុះបញ្ជីពាណិជ្ជកម្ម និងសេវាពាក់ព័ន្ធផ្សេងៗ៖ ១៥ ៣៨១ ០៧០ ០០០ រៀល<br>- ការចុះបញ្ជីម៉ាក និងសេវាពាក់ព័ន្ធផ្សេងៗ៖ ៨ ៤៣៩ ២៨១ ៣២២រៀល<br>- សេវាទាក់ទងនឹងកិច្ចការពិព័រណ៍៖ ១០៨ ៩០០ ០០០រៀល<br>- តម្កល់លិខិតជូនដំណឹងប្រតិបត្តិការដែលមានការធានា៖ ៣៣១ ៦៨០ ០០០រៀល<br>- ការផាកពិន័យ និងសេវាផ្សេងៗរបស់អគ្គនាយកដ្ឋានក.ប.ប.៖១ ៦៩១ ៣៦០ ០០០រៀល<br>- បានពីថ្លៃឈ្នួលអចលនទ្រព្យ៖ ១ ១១២ ០២៨ ៩៥៩រៀល |
| **ការងារគ្រប់គ្រងចំណាយ៖** | **សរុបចំណាយក្នុងរយៈពេល១១ខែ ឆ្នាំ២០២៣**នេះមានចំនួន៖ **៩០ ៤៦៩,៨លានរៀល** ( **ស្មើនឹង ៨៧,៧២%** នៃឥណទានថវិកាដែលបានផ្តល់ចំនួន **១០៣ ១៤០,០លានរៀល** )។ ការអនុវត្តឥណទានថវិកាស្របតាមកម្មវិធីកំណែទម្រង់ ដោយធ្វើការកត់ត្រាជាប្រចាំទៅក្នុងប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ(NRMIS) និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS) |
| **ការងារលទ្ធកម្ម៖**<br>បានរៀបចំដេញថ្លៃ ប្រេងឥន្ធនៈ គេសជ្ជៈ ទទួលភ្ញៀវជាតិ និងអន្តរជាតិ សម្ភារៈការិយាល័យ បោះពុម្ពវិញ្ញាបនបត្រប្រភពដើមទំនិញ គ្រឿងសង្ហារឹម ជួសជុលរថយន្ត និងការជួសជុលសាងសង់នានា ដោយមានការចូលរួមពីអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអង្គភាពប្រឆាំងអំពើពុករលួយ | បានដេញថ្លៃចំនួន ១៨គម្រោង សរុបរួមមានទឹកប្រាក់ចំនួន ១៣ ០៦៨ ៩០០ ០០០រៀល ក្នុងនោះរួមមាន៖<br>- លទ្ធកម្មទំនិញ ១១គម្រោង ស្មើនឹង ៩ ៨៣៥ ៣៥០ ០០០រៀល<br>- លទ្ធកម្មសំណង់ ៤គម្រោង ស្មើនឹង ១ ៩៣០ ៥១០ ០០០រៀល និង<br>- លទ្ធកម្មសេវាកម្ម ៣គម្រោង ស្មើនឹង ១ ៣០៣ ០៨០ ០០០រៀល ។ |

| | |
|---|---|
| ការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ៖ | - បានរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋកើនឡើង-ថយចុះឆ្នាំ២០២២ ដោយបានបញ្ចូលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (SARMIS) តាមគោលការណ៍ណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។<br>- បានរៀបចំស្នើសុំប័ណ្ណកម្មសិទ្ធិសម្រាប់អចលនទ្រព្យចំនួន ១៤ទីតាំង ដែលក្នុងនោះបានទទួលប័ណ្ណកម្មសិទ្ធិចំនួន ១១ទីតាំងរួចរាល់ និង៣ទីតាំងផ្សេងៗទៀតកំពុងស្នើសុំ<br>- បានដោះស្រាយវិវាទដីធ្លីទាក់ទង និងទ្រព្យសម្បត្តិរបស់ក្រសួង ដោយកាត់ចេញចំនួន ១ទីតាំង នៅខេត្តសៀមរាប<br>- ស្នើសុំជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋដែលខូចខាត និងបាត់បង់នៅរដ្ឋបាលកណ្ដាល បានចំនួន ៣ ៩៥៩ គ្រឿង ស្មើនឹង ៩ ០៣៩ ២៩៥ ៤៥០ រៀល។<br>- ស្នើសុំជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋដែលខូចខាត និងបាត់បង់នៅមន្ទីរាជធានី-ខេត្ត បានចំនួន ១ ៧៩១ គ្រឿង ស្មើនឹង ២ ២៥៦ ៥១៣ ៨៥០រៀល។ |

## ៧.៣.ការងារបុគ្គលិក

| បរិយាយការងារ | លទ្ធផល |
|---|---|
| ការគ្រប់គ្រងសិត្ថិ និងធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យាក្នុងក្របខ័ណ្ឌ និងក្រៅក្របខ័ណ្ឌ | មន្ត្រីរាជការសរុបរបស់ក្រសួងពាណិជ្ជកម្ម មានចំនួន **១ ៩៣២នាក់** ស្រីចំនួន **៥៧១នាក់** ក្នុងនោះរួមមាន៖<br>• ក្របខ័ណ្ឌប្រភេទ "ក" ចំនួន **១ ៥៩៩នាក់**<br>• ក្របខ័ណ្ឌប្រភេទ "ខ" ចំនួន **១២០នាក់**<br>• ក្របខ័ណ្ឌប្រភេទ "គ" ចំនួន **៩៩នាក់**<br>• មន្ត្រីមិនមែនក្របខ័ណ្ឌមុខងារសាធារណៈ ចំនួន **១១៤នាក់**<br>ក្នុងនោះមន្ត្រីនៅ**អង្គភាពថ្នាក់កណ្ដាល**មានចំនួន **១ ៥១៣នាក់** និង**អង្គភាពថ្នាក់រាជធានី-ខេត្ត** មានចំនួន **៤១៩នាក់** |
| ការងារចាត់តាំងមន្ត្រីរាជការ | បានតែងតាំង ប្រគល់ភារកិច្ច សម្រួលភារកិច្ច ផ្ទេរក្របខ័ណ្ឌ មន្ត្រីរាជការចំនួន ២៨៣នាក់ ក្នុងនោះរួមមាន៖<br>• អង្គភាពថ្នាក់កណ្ដាលចំនួន **២៨៣នាក់**៖ តែងតាំង **២១៦នាក់**, ប្រគល់ភារកិច្ច **១៣នាក់**, ការសម្រួលភារកិច្ច **២១នាក់**, ទទួលយកមន្ត្រីក្របខ័ណ្ឌចូលបម្រើការងារ **១៦នាក់**, និងផ្ទេរក្របខ័ណ្ឌចេញ **១៧នាក់**<br>• អង្គភាពថ្នាក់ក្រោមជាតិចំនួន **៩នាក់**៖ តែងតាំង **៦នាក់**, ការប្រគល់ភារកិច្ច **២នាក់** និងសម្រួលភារកិច្ចចំនួន **១នាក់** |
| ការគ្រប់គ្រងរដ្ឋបាលមន្ត្រីរាជការ | • ចេញវិញ្ញាបនបត្ររដ្ឋបាល ចំនួន ៩៨នាក់ និងលិខិតអនុញ្ញាតច្បាប់ ចំនួន ១៩៣នាក់<br>• ចេញប័ណ្ណសម្គាល់ខ្លួនមន្ត្រីរាជការ ចំនួន ១៧នាក់<br>• ចេញលិខិតបញ្ជាក់ ប័ណ្ណ បសស ចំនួន ១១នាក់<br>• ធ្វើសំណើសុំផ្ដល់លិខិតឆ្លងដែនការទូត និងផ្លូវការ ចំនួន ២១០នាក់<br>• ធ្វើសំណើសុំចេញកំណត់ទូតស្នើសុំទិដ្ឋាការ ចំនួន ៧នាក់<br>• ធ្វើលិខិតស្ដីពីការចេញដំណើរទៅបំពេញបេសកកម្ម ជូនអនុព័ន្ធពាណិជ្ជកម្ម ចំនួន ៧នាក់<br>• ធ្វើសំណើសុំផ្ទេរប្រាក់បៀវត្សទៅក្រៅប្រទេសជូនអនុព័ន្ធពាណិជ្ជកម្ម ចំនួន ៨នាក់<br>• ធ្វើសំណើសុំឋវិកាសមាគមមន្ត្រីរាជការស៊ីវិលក្រសួងពាណិជ្ជកម្មជូនគ្រួសារសព ចំនួន ៨គ្រួសារ |

| | |
|---|---|
| | • ធ្វើសំណើសុំការអនុញ្ញាតផ្តល់ប្រាក់ឧបត្ថម្ភសោហ៊ុយប្រចាំខែ ជូនបុគ្គលិកជាប់កិច្ចសន្យាក្រៅក្របខ័ណ្ឌ ចំនួន ៤៣នាក់<br>• បានធ្វើសំណើសុំអាហារូបករណ៍ថ្នាក់ចំណេះដឹងទូទៅភាសាអង់គ្លេស ជូនមន្ត្រីរាជការក្រសួងពាណិជ្ជកម្ម ចំនួន ៣រូប<br>• បានធ្វើសំណើសុំគ្រឿងឥស្សរិយយសប្រភេទជាតូបការ ព្រះរាជាណាចក្រកម្ពុជា សុវត្ថារា និងប្រភេទការងារផ្តល់ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងពាណិជ្ជកម្ម ចំនួន ១៦៨នាក់<br>• បានធ្វើប្រកាសស្តីពីការចាត់បញ្ជូនមន្ត្រីរាជការឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាល ចំនួន១២នាក់<br>• បានធ្វើប្រកាសស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការចូលបម្រើការងារវិញ ចំនួន ១៣នាក់<br>• បានធ្វើប្រកាសស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ចំនួន ០១នាក់<br>• បានធ្វើប្រកាសស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការចូលបម្រើការងារវិញក្រោយបានបញ្ចប់ពីភាពទំនេរគ្មានបៀវត្ស ចំនួន ០២រូប<br>• បានធ្វើលិខិតជូនដំណឹង ស្តីពីការស្នើវាយតម្លៃផ្តល់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការមានស្នាដៃប្រចាំឆ្នាំ២០២៣<br>• បានធ្វើសេចក្តីសម្រេចស្តីពីការចាត់តាំងគណៈកម្មការ អនុគណៈកម្មការ និងក្រុមការងារជាជំនួយការរៀបចំដំណើរការសន្និបាតបូកសរុបការងារពាណិជ្ជកម្មឆ្នាំ២០២៣ និងទិសដៅការងារពាណិជ្ជកម្មឆ្នាំ២០២៤ |
| <u>ការគ្រប់គ្រងមន្ត្រីរាជការ</u> | • បានធ្វើលិខិតបង្គាប់ការចាត់បញ្ជូនមន្ត្រីកម្មសិក្សាចំនួន ៥នាក់ ឱ្យទៅបំពេញកម្មសិក្សានៅតាមការិយាល័យចំណុះនាយកដ្ឋានបុគ្គលិក<br>• ធ្វើសេចក្តីសម្រេចស្តីពីការតែងតាំងជំនួយការរដ្ឋលេខាធិការ ចំនួន ១០នាក់<br>• សេចក្តីសម្រេចស្តីពីការបញ្ចប់មុខតំណែងមន្ត្រីខុទ្ទកាល័យរដ្ឋមន្ត្រី និងជំនួយការរដ្ឋលេខាធិការនៃក្រសួងពាណិជ្ជកម្ម ចំនួន ៥នាក់<br>• បានធ្វើលិខិតបង្គាប់ការ ប្រគល់ភារកិច្ចមន្ត្រីរាជការ ឱ្យទៅជួយការងារ ប្រធានតំណាងក្រសួងពាណិជ្ជកម្មប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ និងតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែ ក្រុងព្រះសីហនុ បន្ថែមលើមុខងារ<br>• បានធ្វើប្រកាសស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការស៊ីវិលស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចំនួន ៧នាក់<br>• បានធ្វើប្រកាសស្តីពីការចាត់បញ្ជូនមន្ត្រីកម្មសិក្សាឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងពាណិជ្ជកម្ម សម្រាប់ឆ្នាំ២០២៣ ចំនួន ៦៨នាក់<br>• បានធ្វើប្រកាសស្តីពីការផ្លាស់ប្តូរមន្ត្រីជាប់កិច្ចសន្យា ចំនួន ០៤នាក់<br>• បានធ្វើប្រកាសស្តីពីការលុបឈ្មោះមន្ត្រីរាជការ ចំនួន ០៩នាក់<br>• បានធ្វើប្រកាសស្តីពីការតែងតាំងបុគ្គលិកសោហ៊ុយជាអ្នកបើកបរ និងអ្នកដាំស្ល ឱ្យទៅបំពេញភារកិច្ចនៅស្ថានបេសកកម្ម អចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជាប្រចាំអង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ចំនួន ០២នាក់ |
| <u>ការចាត់តាំងចូលរួមក្នុងយន្តការផ្សេងៗ ចំនួន១៦យន្តការ</u> | • ចូលរួមប្រចាំការប្តូរវេនក្នុងក្រុមប្រចាំការអចិន្ត្រៃយ៍របស់លេខាធិការដ្ឋាន គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត (គ.ស.ក) ចំនួន ៣នាក់<br>• ចូលរួមប្រចាំការប្តូរវេនក្នុងក្រុមប្រចាំការអចិន្ត្រៃយ៍របស់លេខាធិការដ្ឋាន គ.ស.អ ចំនួន ៣រូប<br>• ចូលរួមជាសមាជិកក្រុមប្រឹក្សាគណៈស្ថាបត្យករកម្ពុជា ចំនួន១រូប<br>• ចូលរួមជាសមាជិកគណៈកម្មការអន្តរស្ថាប័ន និងក្រុមការងារបច្ចេកទេសប្រសិទ្ធភាពថាមពល ចំនួន ២រូប |

| | |
|---|---|
| | • ចូលរួមជាសមាសភាពគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ (គ.ជ.ស.ស.) ចំនួន ២រូប<br>• ចូលរួមជាសមាជិកក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ចំនួន ១រូប<br>• ចូលរួមជាសមាជិកគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ចំនួន ១រូប<br>• ចូលជាសមាជិកគណៈកម្មាធិការបច្ចេកទេសអន្តរក្រសួង ដើម្បីតាក់តែងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រង និងអភិវឌ្ឍយានយន្តអគ្គីសនី (គ.ល.គ.យ.អ.) ចំនួន ១រូប<br>• ចូលជាសមាជិកក្រុមប្រឹក្សាភិបាល នៃមជ្ឈមណ្ឌលបណ្តុះបណ្តាលធុរកិច្ចថ្មី «តេជោ» ១រូប<br>• ចូលរួមជាសមាជិកក្រុមការងារបច្ចេកទេសជំរុញ និងគាំទ្រសេដ្ឋកិច្ចឌីជីថល និងរៀបចំកិច្ចព្រមព្រាងសេដ្ឋកិច្ចឌីជីថល ចំនួន ១១រូប<br>• ចូលរួមជាសមាជិកក្រុមការងារបច្ចេកទេសគណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា ចំនួន ២រូប<br>• ចូលរួមជាអនុប្រធានក្រុមការងារតម្រង់ទិសអាជីវកម្មបរិយាប័ន្ន ចំនួន ១រូប<br>• ចូលរួមជាសមាជិកគណកម្មាការវាយតម្លៃទទួលស្គាល់អាជីវកម្មបរិយាប័ន្ន ចំនួន ១រូប<br>• ចូលរួមជាសមាសភាពគណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គម (គ.ម.ប.ស) ចំនួន ១រូប<br>• ចូលជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ចំនួន ១រូប<br>• ចូលជាសមាជិកគណៈកម្មាធិការអន្តរក្រសួងរៀបចំពិធីបុណ្យសមុទ្រលើកទី១០ ជុំទី៣ ឆ្នាំ ២០២៣ នៅខេត្តកែប ចំនួន ៦រូប<br>• ចាត់បញ្ជូនសមាសភាព រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងថ្នាក់ប្រហាក់ប្រហែលតាមការចាំបាច់ សារជាថ្មី ដើម្បីរៀបចំកែសម្រួលបញ្ចូលក្នុងក្រុមការងារ ផ្នែកកម្មន្តសាល សហគ្រាសធុនតូច និងមធ្យម និងសេវា (ក្រុម "គ") សម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជន ចំនួន ៣រូប<br>• ចូលរួមក្នុងសមាសភាពគណៈកម្មាធិការឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ ១រូប<br>• ចូលរួមជាសមាជិកគណៈកម្មាធិការអន្តរក្រសួង ស្តីពីសុខភាពសិក្សា(គ.អ.ស.ស) ១រូប<br>• ចូលជាសមាជិកគណៈកម្មាធិការដឹកនាំអនុវត្តផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ចំនួន ១រូប<br>• ចូលរួមជាអនុប្រធាន ឬសមាជិកនៃក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់នៃកម្ពុជា (ក.ជ.វ.ទ.ក) ចំនួន ១រូប<br>• ចូលសមាជិកក្រុមការងារបច្ចេកទេសចម្រុះលើវិស័យសន្តិសុខស្បៀងអាហារូបត្ថម្ភ ចំនួន ២រូប<br>• ចូលរួមជាគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធបញ្ញាចូលរួមជាសមាជិគណៈកម្មាធិការមេរោគមនុស្សរស់ ចំនួន ១រូប<br>• ចូលរួមជាអនុប្រធានគណៈកម្មាធិការជាតិសម្រាប់ការចាកចេញរបស់កម្ពុជាពីចំណាត់ថ្នាក់ក្រុមប្រទេសអភិវឌ្ឍន៍តិចតួច (គ.ច.ក.អ.ត) ចំនួន ១រូប<br>• ចូលរួមជាសមាជិកគណៈកម្មាធិការអន្តរក្រសួងសម្រាប់រៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ៣ មីនា ចំនួន ១រូប<br>• ចូលរួមជាសមាជិកនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល ចំនួន ១រូប<br>• ចូលរួមជាសមាជិកគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ (គ.ជ.ព) ចំនួន ១រូប<br>• ចូលរួមជាសមាសភាពលេខាធិការដ្ឋាន នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (គ.ស.អ) ចំនួន ១រូប<br>• ចូលរួមជាសមាជិកអាជ្ញាធរជាតិអាវុធគីមី ចំនួន ១រូប |

| | |
|---|---|
| | • ចូលរួមជាក្រុមការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត របៀបវារៈស្រាវជ្រាវជាតិ និងចាត់បញ្ជូនមន្ត្រីបង្គោលនៃក្រុមការងារ ចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ ចំនួន ២រូប<br>• ចូលរួមជាសមាជិកគណៈកម្មការសម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ ១រូប<br>• ចូលរួមជាសមាជិកក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ចំនួន ១រូប<br>• ចូលរួមក្នុងសន្និសីទបណ្តាភាគី នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុលើកទី២៨ ចំនួន ១រូប<br>• ចូលរួមជាសមាសភាពក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តវិស័យទី៨ (Module 8) ស្តីពីការវាយតម្លៃហិរញ្ញប្បទានភេរវកម្ម (Terrorist Financing)<br>• ចូលរួមដើម្បីរៀបចំបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងកសាងផែនការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ ចំនួន ១រូប<br>• ចូលរួមក្នុងសមាភាពគណៈកម្មការអន្តរក្រសួង ដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារអន្តរជាតិទូទាំងប្រទេស "គ.អ.ច.ទ" ចំនួន ១រូប<br>• ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី«ភាពជាអ្នកដឹកនាំបរិវត្តកម្មឌីជីថល» ចំនួន ១រូប<br>• ចូលរួមជាសមាជិកក្រុមប្រឹក្សាគោលនយោបាយសហគមន៍កសិកម្ម (ក.គ.ស.ក) ចំនួន ១រូប<br>• ចូលរួមដើម្បីតែងតាំងជាសមាជិកក្រុមប្រឹក្សាសកម្មភាពជនពិការ ចំនួន១រូប<br>• ចូលរួមជាសមាជិកគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល ចំនួន ១រូប<br>• ចូលរួមជាសមាជិក នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (គ.ក.ស.) ចំនួន ១រូប<br>• ចូលរួមជាសមាជិកនៃអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (អ.ជ.ក.) ចំនួន ១រូប<br>• ចូលរួមសម័យប្រជុំលើកទី៦៣ របស់ក្រុមការងារទី៥ នៃគណៈកម្មការ United Nations Commission on International Trade Law |

## ៧.៤. ការងារបណ្តុះបណ្តាល ស្រាវជ្រាវ និងភាពជាដៃគូ

| **បរិយាយការងារ** | **លទ្ធផល** |
|---|---|
| **១) ការងារបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្ស** | |
| <u>បានចាត់បញ្ជូនមន្ត្រីរាជការចំនួន ៧៩ នាក់ ចូលរួមវគ្គបណ្តុះបណ្តាល ចំនួន ១៣វគ្គនៅក្នុងប្រទេស</u> | • វគ្គក្រឹត្យការមន្ត្រីមធ្យមនៃវគ្គបណ្តុះបណ្តាលបន្ត ឆ្នាំ២០២៣ ចំនួន ១នាក់<br>• វគ្គសិក្សាសរសេរសំណើគម្រោង នៅមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការកម្ពុជា-សិង្ហបុរី ចំនួន ២នាក់<br>• វគ្គសិក្សាជំនាញភាសាអង់គ្លេសសម្រាប់ទំនាក់ទំនងនៅមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការកម្ពុជា-សិង្ហបុរី ចំនួន ២នាក់<br>• ពង្រឹងសមត្ថភាពបកប្រែផ្ទាល់មាត់ និងបកប្រែឯកសារភាសាខ្មែរ-អង់គ្លេស-ខ្មែរ នៅវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ ចំនួន ២នាក់<br>• E-commerce: An opportunity to reinvent the economy នៅមជ្ឈមណ្ឌល CSCC ចំនួន ៤នាក់<br>• កម្មវិធីអាហារូបករណ៍ ១០០ភាគរយ ថ្នាក់បរិញ្ញាបត្រ សម្រាប់ឆ្នាំសិក្សា ២០២៣-២០២៤ នៅវិទ្យាស្ថានអាហ្វា ចំនួន ១នាក់<br>• Intermediate English Language and Communication Skills របស់មជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការកម្ពុជា-សិង្ហបុរី ចំនួន ២នាក់ |

| | |
|---|---|
| | • Advanced English Language and Communication Skills របស់មជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការកម្ពុជា-សិង្ហបុរី ចំនួន ២នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "ភាសាបារាំង" នៅវិទ្យាស្ថានភាសាបារាំងនៃកម្ពុជា ចំនួន ៥នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "English for Effective Negotiation" នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-សិង្ហបុរី ចំនួន ២នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "សមភាពយេនឌ័ររវាងបុរស និងស្ត្រី ឆ្ពោះទៅសង្គមសិង្ហបុរីប្រកបដោយបរិយាបន្នកាន់តែច្រើន" តាមប្រព័ន្ធអនឡាញ ចំនួន ១នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "នវានុវត្តន៍ក្នុងអភិបាលកិច្ច" តាមប្រព័ន្ធអនឡាញ ចំនួន ១នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "English Language Interpretation and Translation Skill" នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-សិង្ហបុរី ចំនួន ២នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "ការកត់ត្រា និងការសរសេររបាយការណ៍" នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-សិង្ហបុរី ចំនួន ២នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "ការត្រៀមខ្លួនសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល" នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-សិង្ហបុរី ចំនួន ៥នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "វគ្គរំក្រើកការនៃវគ្គបណ្តុះ  បណ្តាលបន្ត ឆ្នាំ២០២៣" នៅសាលាភូមិន្ទរដ្ឋបាល ១នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "វគ្គបណ្តុះបណ្តាលតម្រង់ទិសដំបូងមន្ត្រីឆ្នាំ២០២១ នៅសាលាភូមិន្ទរដ្ឋបាលក្នុងឆ្នាំ២០២៣ វគ្គទី១ និងទី២" តាមប្រព័ន្ធអនឡាញ ចំនួន ៣៦នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "ភាពជាអ្នកដឹកនាំ និងនវានុវត្តន៍" នៅសាលាភូមិន្ទរដ្ឋបាល និងតាមប្រព័ន្ធអនឡាញ ចំនួន ៤នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "ថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់គ្រងនៃក្រសួង-ស្ថាប័ន" តាមប្រព័ន្ធអនឡាញ ចំនួន ៥នាក់។ |
| <u>បានចាត់បញ្ជូនមន្ត្រីរាជការចំនួន ១១៧ នាក់ ទៅចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និង អាហារូបករណ៍ នៅប្រទេស ចិន ជប៉ុន ឥណ្ឌា សិង្ហបុរី ស្វីស ម៉ាឡេស៊ី និងនូវែលសេឡង់</u> | • វគ្គបណ្តុះបណ្តាលស្តីពី "The Specialized Training Programmed on Select WTO Issue Agriculture, Service, Trips and RTAS" នៅប្រទេសឥណ្ឌា និងតាមប្រព័ន្ធអនឡាញ ចំនួន ៣នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "WTO Regional Workshop on IT Agreement and Digital Transformation" នៅប្រទេសស្វីស ចំនួន ២នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "Capacity Building Workshop on The Notification of Quantitative Restriction" នៅប្រទេសស្វីស ចំនួន ២នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "Training Couse on Trade and Gender" នៅប្រទេសស្វីស ចំនួន ១នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "Advanced Global E-Workshop on the Agreement on Government Procurement of 2012 (GPA 2012)" តាមប្រព័ន្ធអនឡាញ ៤នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "2023 Advanced Course on the SPS Agreement" នៅប្រទេសស្វីស ចំនួន ០១នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "Advanced Course on the Economic Analysis of Trade Policy" នៅប្រទេសស្វីស ចំនួន ៣នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "Trade and Business Development" នៅប្រទេសសិង្ហបុរី ចំនួន ១៥នាក់<br>• ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "The Future of Maritime Economics: Solutions to the Global Conflicts via UN SDG 8 Integration" នៅប្រទេសម៉ាឡេស៊ី ២នាក់ |

| | |
|---|---|
| | • វគ្គបណ្តុះបណ្តាលស្តីពី "WTO Advance Trade Policy Course (ATPC)" នៅប្រទេសស្វីស ចំនួន ១នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "Investment Promotion and Business Environment Reform (A)" នៅប្រទេសជប៉ុន ចំនួន ១នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "Introductory Course On Trade Policy for LDCs ជាភាសាបារាំង" នៅប្រទេសស្វីស ចំនួន ២នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "២០២៤ WTO Funded Internship Programmes (NTP/FIMIP)" នៅប្រទេសស្វីស ចំនួន ២នាក់<br>• ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "Banyan Tree, China-ASEAN Youth Language Exchange Program" នៅប្រទេសចិន និងតាមប្រព័ន្ធអនឡាញ ចំនួន ១នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "Promotion of Food Value Chain for Community-Based Agri-Business (B)" នៅប្រទេសជប៉ុន និងតាមប្រព័ន្ធអនឡាញ ចំនួន ១នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "វគ្គបណ្តុះបណ្តាលរយៈពេលខ្លីៗ" នៅប្រទេសនូវែលសេឡង់ និងតាមប្រព័ន្ធអនឡាញ ចំនួន ០៣នាក់<br>• វគ្គបណ្តុះបណ្តាលស្តីពី "Supply Chain Management" នៅប្រទេសសិង្ហបុរី ១៣នាក់<br>• វគ្គបណ្តុះបណ្តាលរយៈពេលខ្លីៗ (កម្រិតមធ្យម និងជាន់ខ្ពស់) នៅប្រទេសនូវែលសេឡង់ ចំនួន ១នាក់<br>• សិក្ខាសាលាស្តីពី "E-Commerce and Digital Economy for Cambodia" នៅប្រទេសចិន ចំនួន ២៥នាក់<br>• សិក្ខាសាលាស្តីពី "Development of Small and Medium-Sized Enterprises for RCEP Countries" នៅប្រទេសចិន ចំនួន ៤នាក់<br>• សិក្ខាសាលាស្តីពី "Digital Economy under Global Development Initiative" នៅប្រទេសចិន ចំនួន ៤នាក់<br>• សិក្ខាសាលាស្តីពី "Article 67 of the TRIPS Agreement Technical Cooperation" នៅប្រទេសស្វីស ចំនួន ៥នាក់<br>• សិក្ខាសាលាស្តីពី "Promoting Cooperation on Cross-border Supply Chain for Industry and Commerce Chambers of RCEP Countries" នៅប្រទេសចិន ចំនួន ៤នាក់<br>• សិក្ខាសាលាស្តីពី "Training International Business and trade Legal Professionals for Developing Countries" នៅប្រទេសចិន ចំនួន ៤នាក់<br>• សិក្ខាសាលាស្តីពី "People-to-People Friendship for Cambodia and Laos" តាមប្រព័ន្ធអនឡាញ ចំនួន ២នាក់<br>• សិក្ខាសាលាស្តីពី "Digital Marketing for Cross-border E-commerce: Workshop on Global Branding and Marketing Strategies 2023" តាមប្រព័ន្ធអនឡាញ ចំនួន ២នាក់<br>• សិក្ខាសាលាស្តីពី "Advanced Seminar on Digital Economy for Laos and Cambodia" នៅប្រទេសចិន ចំនួន ០៨នាក់<br>• ចូលរួមកម្មវិធីអាហារូបករណ៍ 2023-2024 Training Program of IDE-JETRO នៅប្រទេសជប៉ុន ចំនួន១នាក់ ។ |

| | |
|---|---|
| បាត់បញ្ជូននិស្សិត និងសិស្សមន្ត្រី នៃសាលាភូមិន្ទរដ្ឋបាល ឱ្យចុះកម្មសិក្សាតាមអង្គភាពនានាចំណុះក្រសួង | • សិស្សមន្ត្រីជំនាន់ទី១០ និងទី១២ សាលាភូមិន្ទរដ្ឋបាល ចំនួន ៤នាក់ ចុះកម្មសិក្សានៅទីស្តីការក្រសួង<br>• និស្សិត សាកលវិទ្យាល័យអាស៊ីអឺរ៉ុប ចំនួន ៥នាក់ ចុះកម្មសិក្សានៅ នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម<br>• និស្សិត សាកលវិទ្យាល័យជាតិគ្រប់គ្រង ចំនួន ៣នាក់ ចុះកម្មសិក្សានៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា<br>• និស្សិត សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ចំនួន ២នាក់ ចុះកម្មសិក្សានៅ នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម<br>• និស្សិត សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ចំនួន ១នាក់ ចុះកម្មសិក្សានៅ អគ្គនាយកដ្ឋានក.ប.ប.។ |
| **២) ការងាររៀបចំសិក្ខាសាលាពង្រឹងសមត្ថភាពមន្ត្រី** | |
| បានពង្រឹងសមត្ថភាពមន្ត្រីតាមរយៈការរៀបចំសិក្ខាសាលានៅ អង្គភាពថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិ បានចំនួន ១៨វគ្គ | • ការស្រាវជ្រាវនិងការប្រើប្រាស់ឧបករណ៍វិភាគទីផ្សារអន្តរជាតិ<br>• កម្រិត១៖ សេចក្តីផ្តើមនៃអង្គការពាណិជ្ជកម្មពិភពលោក<br>• កម្រិត២៖ ឧបាស្រ័យពាណិជ្ជកម្មក្រោមយន្តការអង្គការ WTO<br>• ការបង្កើត និងគ្រប់គ្រងគម្រោង<br>• វិធីសាស្ត្រនៃការស្រាវជ្រាវ ការប្រមូល និងការវិភាគទិន្នន័យពាណិជ្ជកម្ម<br>• មជ្ឈត្តការពាណិជ្ជកម្មនៅកម្ពុជា<br>• ស៊េរីលើកទី១ស្តីពីមូលដ្ឋានគ្រឹះនៃភស្តុភារកម្ម<br>• ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក<br>• ការរៀបចំ និងការអភិវឌ្ឍបណ្ណាល័យ<br>• របាយការណ៍ហិរញ្ញវត្ថុសាធារណៈ និងមូលដ្ឋានគ្រឹះពន្ធដារនៅកម្ពុជា<br>• ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងយុគសម័យឌីជីថល<br>• ស៊េរីលើកទី២ ស្តីពីលក្ខខណ្ឌពាណិជ្ជកម្មអន្តរជាតិ២០២០<br>• ស៊េរីលើកទី៣ស្តីពី ឯកសារបញ្ជូនទំនិញអន្តរជាតិ និងលិខិតឥណទាន (LC)<br>• ស៊េរីលើកទី៤ស្តីពីការដឹកជញ្ជូនរួមបញ្ចូលគ្នានិងអន្តរម៉ូដ<br>• សិក្ខាសាលាពិគ្រោះយោបល់ស្តីពី ផែនការយុទ្ធសាស្ត្រអាជីវកម្ម ២០០៤-២០២៨<br>• ការយល់ដឹងអំពីជែនដើមកំណើតទំនិញអាស៊ាន<br>• ការទាញយកប្រយោជន៍ជាអតិបរមានៃការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី<br>• ការសិក្សាស្រាវជ្រាវពីតម្រូវការវគ្គបណ្តុះបណ្តាល |
| ការងារផ្សព្វផ្សាយចំនេះដឹងដល់វិស័យឯកជនដោយសហការជាមួយស្ថាប័ន ជំនាញ | • បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងចែករំលែកចំណេះដឹងស្តីពី "ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តកម្ម បុគ្គលិក ស្ថិតិ និងសន្ទស្សន៍ថ្លៃទំនិញ១១៩មុខ លទ្ធផលស្ទង់មតិ ការផលិត ផ្សព្វផ្សាយ និងប្រើប្រាស់ស្ថិតិនិងព័ត៌មានពាណិជ្ជកម្ម និងការកសាង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម" នៅខេត្តព្រះសីហនុ និងខេត្តស្ទឹងត្រែង<br>• រៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពី "ប្រតិបត្តិការដែលមានកិច្ចធានា នីតិវិធីតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា និងចែករំលែកចំណេះដឹងស្តីពីការរៀបចំផែនការចងក្រង ស្ថិតិព័ត៌មានពាណិជ្ជកម្ម និងការប្រើប្រាស់បច្ចេកទេសព័ត៌មាន |

| | |
|---|---|
| | វិទ្យា" នៅតាមបណ្ដាខេត្តរួមមាន ខេត្តព្រះសីហនុ បន្ទាយមានជ័យ សៀមរាប កំពង់ធំ និងខេត្តកំពង់ចាម សិក្ខាសាលានេះធ្វើឡើងក្នុងគោលបំណងបញ្ជ្រាប ការយល់ដឹងអំពីច្បាប់ ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា និងអត្ថប្រយោជន៍សម្រាប់បរិបទសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន |
| **៣) ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍** | |
| រៀបចំព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្មជាទម្រង់អេឡិចត្រូនិក (iTradeBulletin) | បានចេញផ្សាយព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម បានចំនួន ១១លើក ហើយបានផ្សាយក្នុងគេហទំព័រផ្លូវការរបស់ក្រសួង និងតាមប្រព័ន្ធផ្សព្វផ្សាយមួយចំនួនទៀត |
| ការអភិវឌ្ឍភាពជាដៃគូ | • បានចុះអនុស្សរណៈនៃការយោគយល់គ្នា(MOU) វាំងវិទ្យាស្ថាន(TTRI) និង សមាគមកសិករកម្មកម្ពុជា (CLA)<br>• បានបង្កើតមជ្ឈមណ្ឌលប្រឹក្សាយោបល់សហគ្រាសធុនតូច និងមធ្យម (SMEs Service Centre) |

## ៨. ការងារអាជីវកម្មស្រូវ-អង្ករ និងសន្និធិស្បៀងបម្រុងរដ្ឋ (ក្រុមហ៊ុនគ្រីនត្រេដ)[6]

ក្រុមហ៊ុនគ្រីនត្រេដស្ថិតក្រោមអាណាព្យាបាលក្រសួងពាណិជ្ជកម្មផ្នែកបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្នែកហិរញ្ញវត្ថុ ។ តួនាទី និងភារកិច្ចចម្បងរបស់ក្រុមហ៊ុនគ្រីនត្រេដគឺ ៖(១) គ្រប់គ្រងថែរក្សាស្តុកសន្និធិស្បៀងត្រៀមបម្រុងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល (២) ទិញ លក់ផលិតផលស្បៀង និងម្ហូបអាហារក្នុងគោលដៅរក្សាស្ថេរភាពតម្លៃទីផ្សារដើម្បីទ្រទ្រង់ថ្លៃស្បៀងជូនប្រជាពលរដ្ឋ និង(៣)ធ្វើសកម្មភាពអាជីវកម្មដូចមានចែងក្នុងលក្ខន្តិកៈក្រុមហ៊ុន ។

### ក.ការងារអាជីវកម្ម និងវិនិយោគ

❖ លទ្ធផលប្រមូលទិញ

○ លើមុខទំនិញអង្ករ៖

- ទិញចូលរយៈពេល ១១ខែ ឆ្នាំ២០២៣ = ១២ ២២១ តោន
- ប៉ាន់ស្មានទិញចូល ១ខែ ចុងឆ្នាំ២០២៣ = ៩ ០០០ តោន

សរុបអនុវត្តក្នុងឆ្នាំ ២០២៣ = ២១ ២២១ តោន

❖ លទ្ធផលលក់ចេញ

○ លើមុខទំនិញអង្ករ

- លក់ចេញរយៈពេល ១២ខែ ឆ្នាំ២០២៣ = ២១ ២២១តោន
- លក់ស្តុកចាស់ = ៩៨ ត ៦២៥

សរុបលក់ក្នុងឆ្នាំ ២០២៣ = ២១ ៣១៩ ត ៦២៥

**ក្នុងនោះ ៖**

- នាំចេញទៅប្រទេសចិន = ២ ២០០ តោន
- នាំចេញទៅប្រទេសឥណ្ឌូនេស៊ី = ១០ ០០០ តោន
- លក់ក្នុងស្រុក(សល់ស្តុកចាស់៩៨ត៦២៥)= ១១៩ ត ៦២៥

[6] ប្រភព៖ ក្រុមហ៊ុន គ្រីនត្រេដ

- កំពុងនាំចេញទៅប្រទេសឥណ្ឌូនេស៊ី = ៥ ០០០ តោន
- កំពុងនាំចេញទៅប្រទេសទីម័រលេស្តេ = ៤ ០០០ តោន

## ខ.ការងារគ្រប់គ្រងស្តុកសន្និធិស្បៀងត្រៀមបម្រុងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល

(យោងអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១)

❖ ស្តុកត្រៀមបម្រុងជាអង្គរក្នុង ឆ្នាំ២០២៣ = ៣ ០០០ តោន

- ០ បញ្ចេញប្រើប្រាស់ ១២ខែ ក្នុងឆ្នាំ២០២៣ = ៤២២ ត ៤៥០
- ០ ស្តុកសល់ចុងគ្រាគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣ = ២ ៥៧៧ ត ៥៥០

❖ ស្តុកសន្និធិស្បៀងត្រៀមបម្រុងយុទ្ធសាស្ត្រជារូបវន្តក្នុងឆ្នាំ ២០២៣

- ○ ស្តុកត្រៀមបម្រុង «មី»
  - ○ ស្តុកដើមគ្រា = ២០ ០០០កេស
  - ○ បញ្ចេញប្រើប្រាស់ក្នុងគ្រា ឆ្នាំ២០២៣ = ១៦ ៨៩៨កេស
  - ○ ស្តុកសល់ចុងគ្រាគិតត្រឹមខែ ឆ្នាំ២០២៣ (ទិញបង្វិលបញ្ចូលស្តុកគ្រប់ចំនួន) = ២០ ០០០កេស
- ○ ស្តុកត្រៀមបម្រុង «ទឹកសុទ្ធ»
  - ○ ស្តុកដើមគ្រា = ១០០ ០០០កេស
  - ○ បញ្ចេញប្រើប្រាស់ក្នុងគ្រា ឆ្នាំ២០២៣ = ១៦ ៨៩៨កេស
  - ○ ស្តុកសល់ចុងគ្រាគិតត្រឹមខែធ្នូ ឆ្នាំ២០២៣ (ទិញបង្វិលបញ្ចូលស្តុកគ្រប់ចំនួន) = ១០០ ០០០កេស
- ○ ស្តុកត្រៀមបម្រុង « ទឹកត្រី»
  - ○ ស្តុកដើមគ្រា = ២៥ ០០០យួរ
  - ○ បញ្ចេញប្រើប្រាស់ក្នុងគ្រា ឆ្នាំ២០២៣ = ១៦ ៨៩៨យួរ
  - ○ ស្តុកសល់ចុងគ្រាគិតត្រឹមខែធ្នូ ឆ្នាំ២០២៣ (ទិញបង្វិលបញ្ចូលស្តុកគ្រប់ចំនួន) = ២៥ ០០០យួរ
- ○ ស្តុកត្រៀមបម្រុង «ទឹកស៊ីអ៊ីវ»
  - ○ ស្តុកដើមគ្រា ឆ្នាំ២០២៣ = ២៥ ០០០យួរ
  - ○ បញ្ចេញប្រើប្រាស់ក្នុងគ្រាក្នុង ឆ្នាំ២០២៣ = ១៦ ៨៩៨យួរ
  - ○ ស្តុកសល់ចុងគ្រាគិតត្រឹមខែធ្នូ ឆ្នាំ២០២៣ (ទិញបង្វិលបញ្ចូលស្តុកគ្រប់ចំនួន) = ២៥ ០០០យួរ
- ○ ស្តុកត្រៀមបម្រុង «ត្រីខ»
  - ○ ស្តុកដើមគ្រា = ៧១ ៣០៧យួរ
  - ○ បញ្ចេញប្រើប្រាស់ក្នុងគ្រាក្នុង ឆ្នាំ២០២៣ = ១៦ ៨៩៨យួរ
  - ○ ស្តុកសល់ចុងគ្រាគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣ = ៥៤ ៤០៩យួរ

## គ.ការងារហិរញ្ញកិច្ច

❖ លទ្ធផលសម្រេចបាន ១១ខែ ក្នុងឆ្នាំ២០២៣

- សរុបចំណូល =៣៨ ១២៤ ៣៨៩ ១៩៣៛
- សរុបចំណាយ =៣៦ ០៦៤ ៥១៤ ២០៥៛
- សរុបចំណេញពិត = ២ ០៥៩ ៨៧៤ ៩៨៨៛

**ឃ.ការងារផ្សេងៗ**

- បានទទួលក្រុមប្រតិភូអធិការកិច្ចក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រង ការអនុវត្តន៍ចំណូល-ចំណាយថវិកាជាតិ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកាតព្វកិច្ចត្រូវបង់ចូលថវិការដ្ឋ ក្នុងការិយបរិច្ឆេទឆ្នាំ២០២១ និងឆ្នាំពាក់ព័ន្ធ
- បានទទួលក្រុមប្រតិភូក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា និងព្រឹទ្ធសភា និងអធិការកិច្ចចុះធ្វើអធិការកិច្ចលើការអនុវត្តន៍តួនាទីការគ្រប់គ្រងការផ្តល់សេវាសាធារណៈ និងការអនុវត្តន៍កិច្ចលទ្ធកម្មសាធារណៈក្នុងការិយបរិច្ឆេទឆ្នាំ២០២២ និងបណ្តាឆ្នាំពាក់ព័ន្ធ
- បានទទួលប្រតិភូសវនកម្ម អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចុះធ្វើសវនកម្មពេញលេញលើការប្រកាសសារពើពន្ធ ដែលទាក់ទិនពន្ធអាករគ្រប់ប្រភេទក្នុងការិយបរិច្ឆេទថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២
- រៀបចំសំណុំឯកសារស្នើសុំចុះបញ្ជីក្បាលដី និងធ្វើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនទ្រព្យឡើងវិញ នៅទីតាំងដីចំនួន ០២កន្លែងស្ថិតនៅខេត្តព្រះសីហនុក្រោយពីបានធ្វើការដោះស្រាយវិវាទរួចរាល់ជាមួយប្រជាពលរដ្ឋ
- បានសហការជាមួយក្រុមការងារអន្តរក្រសួង អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ចុះត្រួតពិនិត្យ និងពិភាក្សាដោះស្រាយករណីដី-ឃ្លាំងព្រះនេត្រព្រះរបស់ក្រុមហ៊ុនហ្គ្រីនត្រេដដែលមានវិវាទជាមួយប្រជាពលរដ្ឋចូលមកតាំងទីលំនៅ និងរស់នៅលើដី-ឃ្លាំងជាបន្តបន្ទាប់ ស្ថិតនៅភូមិភ្នំជញ្ជាំង ឃុំជប់វារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
- ធ្វើការសិក្សា និងរៀបចំគម្រោងជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករឡើងវិញ (គម្រោងសាងសង់ឃ្លាំង និងឡសម្ងួត) ដែលការងារនេះដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានធ្វើការនាំចេញអង្ករលើកដំបូងទៅកាន់ប្រទេសឥណ្ឌូនេស៊ីចំនួន ១៥ ០០០តោន តាមរយៈក្រុមហ៊ុន BULOG ប្រទេសឥណ្ឌូនេស៊ី និងទៅកាន់ប្រទេសចិនចំនួន ២ ២០០តោន តាមរយៈក្រុមហ៊ុន COFCO នៃសាធារណរដ្ឋប្រជាមានិតចិន និងទៅប្រទេសទីម័រលេស្តេចំនួន ៤០០០តោន
- បានបញ្ចេញប្រើប្រាស់ស្តុកសន្និធិស្បៀងត្រៀមបម្រុងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលចំនួនសរុប១៦ ៨៩៨គ្រួសារ ដែលបានទទួលរងគ្រោះដោយសារទឹកជំនន់ក្នុងនោះ៖ នៅខេត្តកំពង់ធំចំនួន ៤ ០១៨ គ្រួសារ ខេត្តពោធិ៍សាត់ចំនួន ៤ ៣៩១ ខេត្តបាត់ដំបង ៦ ៤៥៤គ្រួសារ ខេត្តកំពង់ឆ្នាំង ១០០គ្រួសារ បន្ទាយមានជ័យ ៣៣០គ្រួសារ ឧត្តរមានជ័យ ៤៥៩គ្រួសារ និងខេត្តសៀមរាប ១ ១៤៦គ្រួសារ
- បានធ្វើបច្ចុប្បន្នភាពវាយតម្លៃលើស្ថានភាពហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ដើម្បីជាមូលដ្ឋានកំណត់ទុនរបស់ក្រុមហ៊ុនឡើងវិញ
- បានជំរុញការលក់រាយ/ដុំអង្ករក្នុងស្រុកនៅអាគាររបស់ក្រុមហ៊ុន
- ធានាស្ថេរភាពតម្លៃអង្ករទីផ្សារក្នុងស្រុក រក្សាផលប្រយោជន៍ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ

- ចូលរួមពង្រឹងបន្ថែមការងារផ្សព្វផ្សាយ ចែករំលែកព័ត៌មានដែលពាក់ព័ន្ធក្នុងការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករកម្ពុជា ដល់សមាជិកអ្នកផលិត សមាគមម៉ាស៊ីនកិនស្រូវ ព្រមទាំងសហព័ន្ធស្រូវ-អង្ករកម្ពុជា
- បានខិតខំបន្តស្វែងរកទីផ្សារ និងជួយជំរុញការនាំចេញអង្ករកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិឲ្យមានកំណើនបន្ថែមជាពិសេស អង្ករក្រអូប អង្ករផ្កាម្លិះ អង្ករផ្ការំដួល និងអង្ករសគ្រាប់វែង
- ខិតខំពង្រីកអាជីវកម្មរបស់ក្រុមហ៊ុនបន្ថែមដើម្បីបង្កើនទុនក្រុមហ៊ុនក្នុងការជួយលើកកម្ពស់ជីវភាពដល់បុគ្គលិកនិយោជិតក្រុមហ៊ុន
- បានធ្វើការសហការជាមួយកម្មវិធីស្បៀងអាហារពិភពលោក(WFP)ក្នុងការលាយបញ្ចូលវីតាមីនទៅក្នុងអង្ករបានចំនួន ២០០តោន
- បានធ្វើបច្ចុប្បន្នភាពជាប្រចាំក្នុងការពិនិត្យតាមដានការប្រែប្រួលស្ថានភាពតម្លៃស្រូវ-អង្ករក្នុងប្រទេស និងទីផ្សារអន្តរជាតិ
- បានធ្វើការពិភាក្សាក្នុងការជំរុញបើកច្រកទីផ្សារអង្ករជាមួយបណ្តាប្រទេសផ្សេងៗ ដូចជា៖ បានចុះ MOU ស្តីពីការធ្វើពាណិជ្ជកម្មអង្ករជាមួយប្រទេសទីម័រលេស្តេ និងជំរុញការនាំចេញទៅប្រទេសចិន ឥណ្ឌូនេស៊ី ហ្វីលីពីន សិង្ហបុរី សហគមន៍អឺរ៉ុប និងបណ្តាប្រទេសផ្សេងៗទៀតនៅទ្វីបអាហ្វ្រិក។

## ៩. ការងារយេនឌ័រ[7]

### ក. ការអប់រំ ផ្សព្វផ្សាយ បណ្តុះបណ្តាលទាក់ទងនឹងយេនឌ័រ និងអនុសញ្ញា CEDAW

- ចាត់បញ្ជូនសមាជិកា១រូប ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី ចំណេះដឹង និង ជំនាញវិភាគក្នុងការសរសេរ"របាយការណ៍វឌ្ឍនភាពឆ្លើយតបទៅនឹងគោលនយោបាយ អនុសញ្ញា CEDAW" ថ្ងៃទី៧ ខែកក្កដា ឆ្នាំ ២០២៣
- ចូលរួមធ្វើជាគណអធិបតី និងថ្លែងសន្ទរកថាបិទ ក្នុងសិក្ខាសាលាឆ្លុះបញ្ចាំងស្តីពី "ការផ្តល់លិខិតអនុញ្ញាតប្រកបអាជីវកម្ម និងទីតាំងលក់សម្រាប់អ្នកលក់ដូរតាមដងផ្លូវ ដែលរៀបចំឡើងដោយអង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)"កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣
- ប្រធានក្រុមលេខាធិការដ្ឋាន នៃក្រុមការងារយេនឌ័រវិស័យពាណិជ្ជកម្ម បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីអបអរសាទរទិវាវប្បធម៌ជាតិ ៣មីនា លើកទី២៥ កាលពីថ្ងៃទី២ ខែមីនា ឆ្នាំ២០២៣។

### ខ. លទ្ធផលការងារនៃការអភិវឌ្ឍន៍សមត្ថភាពស្ត្រី

ក្រសួងពាណិជ្ជកម្ម បានរៀបចំ និងសហការរៀបចំសិក្ខាសាលា កិច្ចប្រជុំ វេទិកាពិភាក្សានានា ក្រោមកិច្ចសហការជាមួយអង្គការដៃគូ ព្រមទាំងសមាគមសហគ្រិនស្ត្រីកម្ពុជា ចំនួន៥លើក ដែលមានសមាសភាពចូលរួមសរុបចំនួន ៧២០នាក់ ក្នុងនោះស្ត្រីចំនួន ៥៩៨នាក់ ដូចខាងក្រោម៖

| បរិយាយកម្មវិធី | សមាជិកចូលរួម | |
|---|---|---|
| បទបង្ហាញស្តីពី៖ ការរៀបចំផែនការហិរញ្ញវត្ថុលើអចលនទ្រព្យ និងចំណុចគន្លឹះក្នុងការគណនាការប្រាក់ឥណទាន ដោយសហការជាមួយក្រុមហ៊ុន OCIC កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ | សរុបចំនួន ៨៦នាក់ | ស្រីចំនួន ៥៦នាក់ |
| សម្ពោធការតាំងពិព័រណ៍ផលិតផលសហគ្រិនស្ត្រី ដោយសហការជាមួយសមាគមសហគ្រិនស្ត្រីកម្ពុជា កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ | សរុបចំនួន ៤០០នាក់ | ស្រីចំនួន ៣០០នាក់ |

[7] ប្រភព៖ ក្រុមការងារយេនឌ័រក្រសួងពាណិជ្ជកម្ម

| | | |
|---|---|---|
| កិច្ចប្រជុំពិគ្រោះយោបល់ក្រោមប្រធានបទស្តីពី "ការពង្រឹងស្ថានភាពសេដ្ឋកិច្ចស្ត្រី និងកិច្ចការសហប្រតិបត្តិការប្រកបដោយប្រសិទ្ធិភាពនៅកន្លែងការងារ"ដោយសហការជាមួយ GIZ កាលពីថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០២៣ | សរុបចំនួន ១០០នាក់ | ស្រីចំនួន៧១នាក់ |
| កិច្ចប្រជុំប្រចាំត្រីមាសរបស់ក្រុមការងារយេនឌ័រក្រសួងពាណិជ្ជកម្មជាមួយ ២៥មន្ទីររាជធានី-ខេត្ត កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ | សរុបចំនួន ១០០នាក់ | ស្រីចំនួន៧១នាក់ |
| ពិធីអបអរសាទរខួបលើកទី១១២ទិវាអន្តរជាតិឆ្នាំ២០២៣ កាលពីថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣ | សរុបចំនួន ១២០នាក់ | ស្រីចំនួន១០០នាក់ |

ក្រៅពីសកម្មភាពដែលបានរៀបចំដោយក្រសួងពាណិជ្ជកម្ម ក្រសួងក៏បានចាត់បញ្ជូនមន្ត្រីរាជការជាស្ត្រីចូលរួមកិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗទៀត ដើម្បីពង្រីកនូវចំណេះដឹង និងទទួលបានបទពិសោធន៍បន្ថែម ដូចខាងក្រោម៖

| **បរិយាយកម្មវិធី** | **សមាជិកាចូលរួម** |
|---|---|
| វេទិកាសេដ្ឋកិច្ចឌីជីថលនៅកម្ពុជា៖ "ស្ថានភាពកិច្ចព្រមព្រៀងក្រមខ័ណ្ឌសេដ្ឋកិច្ចឌីជីថល និងបច្ចុប្បន្នភាពគោលនយោបាយឌីជីថល" "Digital Economy Forum Cambodia: Digital Policy Updates and DEFA Status" កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ | ២នាក់ |
| ជំនួបពិភាក្សាការងារជាមួយអង្គការ GIZ Compete II project កាលពីថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣ | ៤នាក់ |
| ជំនួបពិភាក្សាការងារជាមួយអង្គការ Swiss Contactកាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣ | ៣នាក់ |
| ចូលរួមប្រជុំជាមួយទីប្រឹក្សាសម្រាប់គម្រោង ITC ដើម្បីចូលរួមឆ្លើយក្នុងគម្រោងការវាយតម្លៃអំពីយេនឌ័រ កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ | ២នាក់ |
| សិក្ខាសាលា ចែករំលែកព័ត៌មាន បទពិសោធន៍ និងវិធីសាស្ត្រគន្លឹះៗក្នុងការទទួលបានអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតទៅសិក្សានៅប្រទេសអូស្ត្រាលី កាលពីថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៣ | ៣នាក់ |
| ចូលរួមជាវាគ្មិន ក្នុងកិច្ចពិភាក្សាស្តីពី "សហគ្រិនស្ត្រី និងទិសដៅអភិវឌ្ឍ" នៅអង្គការមណ្ឌលព័ត៌មានស្ត្រី កម្ពុជា (វិទ្យុស្ត្រី) កាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ | ១នាក់ |
| កិច្ចប្រជុំក្រុមការងារបច្ចេកទេសយេនឌ័រក្រសួង ស្ថាប័ន នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងរបាយការណ៍បូកសរុបលទ្ធផល ការងារ ឆ្នាំ២០២២ និងលើកផែនការសកម្មភាពការងារឆ្នាំ២០២៣ របស់ក្រុមការងារប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី កាលពីថ្ងៃទី៤ ខែមករា ឆ្នាំ២០២៣ | ១នាក់ |

### គ. ការបញ្ជ្រាបយេនឌ័រក្នុងច្បាប់ គោលនយោបាយ ផែនការ កម្មវិធីលើកកម្ពស់ស្ត្រី

- អនុវត្តផែនការបញ្ជ្រាបយេនឌ័ក្នុងវិស័យពាណិជ្ជកម្មឆ្នាំ២០២១២០២៥- ដោយរៀបចំផែនការសកម្មភាពឱ្យស្របទៅតាមអនុសញ្ញា CEDAW ច្បាប់ គោលនយោបាយ ផែនការ កម្មវិធី និងផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់ក្រសួងពាណិជ្ជកម្ម
- ស្ត្រីជាថ្នាក់ដឹកនាំតែងតែត្រូវបានជ្រើសរើសឱ្យចូលរួមក្នុងគណៈកម្មការ និងក្រុមការងារតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ និងសកម្មភាពការងារផ្សេងៗទៀតដែលទាក់ទងទៅនឹងការងាររបស់ក្រសួងពាណិជ្ជកម្ម
- ចូលរួមក្នុងការជំរុញវិស័យពាណិជ្ជកម្មឱ្យកាន់តែរីកចម្រើន តាមរយៈការជំរុញការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលមានស្រាប់ និងកិច្ចព្រមព្រៀងពាណិជ្ជកម្ម ដែលទើបចុះហត្ថលេខាថ្មីៗ ការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ច្បាប់កិច្ចការពារអ្នកប្រើប្រាស់ ការជំរុញកិច្ចការពិព័ណ៌ ការលើកកម្ពស់ផលិតផលខ្មែរ និងការជំរុញសហគ្រិនភាពស្ត្រី
- ក្នុងឆ្នាំ២០២៣នេះ ក្រសួងពាណិជ្ជកម្មមានថ្នាក់ដឹកនាំស្ត្រីមួយរូបជារដ្ឋមន្ត្រី និងថ្នាក់ដឹកនាំមានតួនាទីជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការសរុបចំនួន ១៣ រូប អគ្គាធិការ ១រូប និងអគ្គនាយករង/អគ្គាធិការរង ៨រូប។

## ១០. ការងារអគ្គាធិការដ្ឋាន[8]

| **បរិយាយការងារ** | **លទ្ធផល** |
|---|---|
| ១) <u>ការធ្វើអធិការកិច្ច</u> | |
| ការចុះធ្វើអធិការកិច្ចនៅតាមអង្គភាពក្រោមឱវាទក្រសួងពាណិជ្ជកម្មបានចំនួន **៤៨អង្គភាព** | រកឃើញចំណុចខ្វះខាតចំនួន **១៤៣ករណី** ដែលក្នុងនោះរួមមាន៖<br>ការងារគណនេយ្យនិងហិរញ្ញវត្ថុ ចំនួន ៣៤ករណី<br>ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ចំនួន ១៣ករណី<br>ការផ្តល់សេវាសាធារណៈ ចំនួន ១២ករណី<br>ការគ្រប់គ្រងរដ្ឋបាល-បុគ្គលិក ចំនួន ៧៩ករណី<br>ការអនុវត្តតួនាទីភារកិច្ច ចំនួន ៤ករណី<br>ការអនុវត្តអនុលោមភាពនៃច្បាប់ ចំនួន ១ករណី |
| ការចុះធ្វើអធិការកិច្ចដោយមិនជូនដំណឹងមុន (Spot Check) ចំនួន **៥អង្គភាព**គឺ៖<br>មន្ទីរពាណិជ្ជកម្មខេត្តបន្ទាយមានជ័យ<br>មន្ទីរពាណិជ្ជកម្មខេត្តខេត្តក្រចេះ<br>មន្ទីរពាណិជ្ជកម្មខេត្តខេត្តខេត្តស្ទឹងត្រែង<br>មន្ទីរពាណិជ្ជកម្មខេត្តខេត្តខេត្តកំពង់ធំ<br>មន្ទីរពាណិជ្ជកម្មខេត្តខេត្តខេត្តព្រះសីហនុ | រកឃើញចំណុចខ្វះខាតមួយចំនួនទាក់ទងនឹងការអនុវត្តការងារ ហើយបានណែនាំឱ្យធ្វើការកែលម្អឡើងវិញ |
| តាមដានលើការអនុវត្តកែលម្អតាមអនុសាសន៍គ្រាមុនរបស់បណ្តាប្រតិភូអធិការកិច្ច/សវនកម្មផ្ទៃក្នុងក្រសួងពាណិជ្ជកម្ម បានចំនួន **៤៨អង្គភាព** | រកឃើញចំណុចខ្វះខាត ចំនួន **២៦៤ករណី** ដោយអង្គភាពរងអធិការកិច្ច និងរងសវនកម្មទាំងនោះ បានធ្វើការកែលម្អ ចំនួន **២១៩ករណី** និងពុំទាន់បានកែលម្អ ចំនួន **៤៥ករណី** |
| ២) <u>ការបង្កើនប្រសិទ្ធភាពការងារមន្ត្រី</u> | |

[8] ប្រភព៖ អគ្គាធិការដ្ឋាន

| | |
|---|---|
| ការបង្កើនប្រសិទ្ធភាពដោយផ្ទាល់នៅនឹងកន្លែង | រៀបចំកម្មវិធីបង្កើនសមត្ថភាពបានចំនួន ៧លើកស្តីពី ការងារអធិការកិច្ច និង វិធីសាស្ត្រអនុវត្តលិខិតបទដ្ឋានគតិយុត្តឱ្យមានប្រសិទ្ធភាព |
| ***៣)ការងារទទួល និងដោះស្រាយបណ្តឹងតវ៉ា បណ្តឹងបរិហារ និងវិវាទ*** | |
| ទទួលបានពាក្យបណ្តឹងតវ៉ា ១ករណី | បានដោះស្រាយបញ្ចប់រួចរាល់ដោយសម្របសម្រួលបញ្ចប់វិវាទ |
| បានដាក់ដំណើរការគេហទំព័រ ប្រអប់សំបុត្រអេឡិកត្រូនិក និងប្រអប់សំបុត្រ | ដើម្បីសម្រួលដល់ សាធារណជនមានភាពងាយស្រួលក្នុងការសម្តែងមតិ ឬធ្វើការប្តឹងតវ៉ាផ្សេងៗ។ |

## ១១. ការងារសវនកម្មផ្ទៃក្នុង[9]

| បរិយាយការងារ | លទ្ធផល |
|---|---|
| ***១) ការធ្វើសវនកម្ម*** | |
| ចុះធ្វើសវនកម្មផ្ទៃក្នុងតាមអង្គភាពក្រោមឱវាទក្រសួងពាណិជ្ជកម្មបានចំនួន ២១អង្គភាព រួមមាន ៖ អង្គភាពថ្នាក់កណ្តាល ១សវនដ្ឋាន និងអង្គភាពមូលដ្ឋាន ២០សវនដ្ឋាន | រកឃើញចំណុចខ្វះចន្លោះ និងផ្តល់ជាអនុសាសន៍កែលម្អបានចំនួន ៥៧ ចំណុច ក្នុងនោះរួមមាន៖ ចំណុចខ្វះចន្លោះគ្រប់គ្រងរដ្ឋបាល ចំនួន ១៦ ចំណុច ចំណុចខ្វះចន្លោះផ្នែកគណនេយ្យ និងហិរញ្ញវត្ថុចំនួន ២៨ចំណុច ចំណុចខ្វះចន្លោះផ្នែកគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋចំនួន ០៨ចំណុច និងចំណុចខ្វះចន្លោះលើផ្នែក  បច្ចេកវិទ្យាព័ត៌មានចំនួន០៥ចំណុច |
| តាមដានការអនុវត្តអនុសាសន៍សវនកម្មគ្រាមុន បានចំនួន ១៦សវនដ្ឋាន | ក្នុងចំណោម ១៦សវនដ្ឋាន មានអនុសាសន៍គ្រាមុន សរុបចំនួន ៥៦ចំណុច ក្នុងនោះអនុវត្តបានពេញលេញ ៤១ចំណុច ស្មើនឹង៧៤%  និងអនុវត្តពុំទាន់បានពេញលេញ ៨ចំណុច ស្មើនឹង១៤% និងពុំទាន់អនុវត្តបាន ៧ ចំណុច ស្មើនឹង១៣% |
| ២)***ការបង្កើនប្រសិទ្ធភាពការងារមន្ត្រី*** | |
| ការបង្កើនប្រសិទ្ធភាពដោយផ្ទាល់នៅនឹងកន្លែង | រៀបចំកម្មវិធីបង្កើនសមត្ថភាពបានចំនួន ២វគ្គ ស្តីពីវគ្គការស្វែងយល់អំពីសវនកម្មលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងនីតិវិធីចុះធ្វើសវនកម្ម ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។ |

## ១២. សកម្មភាពការងារមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត

| បរិយាយការងារ | លទ្ធផល |
|---|---|
| ***ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ*** | សម្ពោធដាក់ឱ្យប្រើប្រាស់អគាររដ្ឋបាលរបស់មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ចំនួន ២ទីតាំង នៅខេត្តក្រចេះ និងខេត្តតាកែវ ព្រមទាំងជួសជុលអគាររដ្ឋបាល, អគារដាក់ឯកសារ, រោងដាក់ម៉ូតូ, បន្ទប់ទឹក, របង, បណ្ណាល័យ, សួនច្បារ, និងផ្លូវ |
| ***សកម្មភាពចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាពង្រឹងសមត្ថភាព*** | ថ្នាក់ដឹកនាំ និងមន្ត្រីតាមបណ្តាមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត បានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាពង្រឹងសម្ថភាព សរុបចំនួន **៦៥៣លើក** |
| ***ការចុះបញ្ជីពាណិជ្ជកម្ម ការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្មពាណិជ្ជកម្ម លោហធាតុត្បូងថ្ម វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ឌី(Form D) និងការចេញលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងឆ្នាំ*** | បានចុះបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន សហគ្រាស សរុបចំនួន**៥ ៤៥៤** ក្នុងនោះ៖ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតចំនួន**២ ០១២** សាខាក្រុមហ៊ុនចំនួន**៣២៩** និងសហគ្រាសឯកបុគ្គលចំនួន**៣ ១១៣** |
| | បានទទួលរបាយការណ៍ស្តីពីស្ថិតិអាជីវកម្ម សេវាកម្ម ដែលមិនជាប់ពន្ធលើរបបស្វ័យប្រកាសនៅក្នុងខេត្តដែលរដ្ឋបាលក្រុង/ស្រុកបានចេញលិខិតអនុញ្ញាតិមានចំនួន **៣៥ ២៧៣**ទីតាំង |

[9] ប្រភព៖ នាយកដ្ឋានសវនកម្មផ្ទៃក្នុង

| | |
|---|---|
| ***២០២៣ ព្រមទាំងស្ថិតិអាជីវកម្ម សេវាកម្ម ដែលមិនជាប់ពន្ធលើរបបស្វ័យប្រកាស*** | *លិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ចំនួន **១៦ ៦៥៧**ទីតាំង* |
| | *ចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម លោហធាតុត្បូងថ្ម មានតម្លៃជាគ្រឿងអលង្ការមានចំនួន **៦៣០**ទីតាំង* |
| | *វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ឌី (Form D) ចំនួន **៨៩៧**ច្បាប់* |
| | *ទទួលពាក្យស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិកចំនួន **២ ៧៧២**ច្បាប់* |
| ***ការសហការត្រួតពិនិត្យ សម្របសម្រួល ការស្រង់ស្ថិតិព័ត៌មានសន្ទស្សន៍ថ្លៃទំនិញចាំបាច់ និងចុះផ្សព្វផ្សាយពីការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្ម ចុះបញ្ជីពាណិជ្ជកម្ម និងការចុះបញ្ជីម៉ាក់*** | *ចុះត្រួតពិនិត្យ ផ្សព្វផ្សាយ និងចែកតម្លៃប្រេងឥន្ធនៈលក់រាយតាមស្ថានីយ/ដេប៉ូប្រេងឥន្ធនៈតាមបណ្ដារាជធានី-ខេត្តបានចំនួន**១ ០៣៤**លើក លើ **២ ៩២១** ទីតាំង ស្មើនឹង**៣ ៧២០**ស្ថានីយ៍ប្រេង* |
| | *សហការជាមួយសាខា ក.ប.ប តាមបណ្ដាខេត្ត ចុះត្រួតពិនិត្យផលិតផលទំនិញលើទីផ្សារ និងផ្សព្វផ្សាយច្បាប់ស្ដីពីកិច្ចការពារអ្នកប្រើប្រាស់ ព្រមទាំងផលប៉ះពាល់សុវត្ថិភាពចំណីអាហារតាមសាលារៀនចំនួន **៤០៧**លើក ចំនួន **១៩៧**ទីតាំង* |
| | *ចូលរួមពិនិត្យទីតាំងរោងចក្រដាក់ស្លែងដែលបានស្នើសុំចុះបញ្ជីក្នុងបណ្ដារាជធានី-ខេត្ត សរុបចំនួន **១៨**ទីតាំង* |
| | *ស្រង់ និងបញ្ចូលទិន្នន័យព័ត៌មាន ទីផ្សារពងមាន់ ពងទា និងសាច់មាន់ សាច់ទា ចំនួន **២១២**លើក* |
| | *បានបញ្ជូនទិន្នន័យផ្គត់ផ្គង់តម្រូវការផលិតផលក្នុងស្រុកចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃចំនួន**១ ៦៩៤**លើក និងបានចុះស្រង់ថ្លៃទំនិញជាប្រចាំ* |
| | *ចុះត្រួតពិនិត្យនាមករណ៍ និងសាខាក្រុមហ៊ុនក្នុងរាជធានី-ខេត្ត ចំនួន **៥៧៧**ទីតាំង* |
| | *ការចុះត្រួតពិនិត្យទំនិញ នាំចេញ-នាំចូល តាមច្រកទ្វារព្រំដែន រៀងរាល់សប្ដាហ៍របស់មន្ទីរពាណិជ្ជកម្មខេត្តជាប់ព្រំដែនកម្ពុជា* |
| | *ចុះបិទស្លាកថ្លៃលើមុខទំនិញជារៀងរាល់ចុងសប្ដាហ៍ សរុបបានចំនួន **៨៤**លើក* |
| | *បានចាត់មន្ត្រីជំនាញចុះត្រួតពិនិត្យ និងជំរុញការងារបិតស្លាកថ្លៃលើគ្រឿងសមុទ្រនៅចុងសប្ដាហ៍ នៅតាមទីផ្សារ ដើម្បីផ្ដល់ភាពងាយស្រួលដល់ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិជ្រើសរើសមុខទំនិញសមស្របទៅតាមតម្លៃដែលខ្លួនពេញចិត្ត* |
| | *ផ្ដល់ព័ត៌មានពីការចុះបញ្ជីពាណិជ្ជកម្ម និងចុះបញ្ជីម៉ាកតាមប្រព័ន្ធស្វ័យប្រវត្តិកម្មជូនដល់ប្រជាពលរដ្ឋតាមរយៈច្រកចេញចូលតែមួយរបស់មន្ទីររាជធានីភ្នំពេញបានចំនួន **១២៤**នាក់* |
| | *សហការជាមួយរដ្ឋបាលខេត្ត ចុះផ្សព្វផ្សាយ និងស្រង់ស្ថិតិអាជីវកម្មក្នុងមូលដ្ឋានដែលមានច្បាប់អនុញ្ញាត និងគ្មានច្បាប់អនុញ្ញាត* |
| | *បានតាមដាន និងរាយការណ៍បរិមាណស្តុកស្រូវអង្ករចំនួនរៀងរាល់សប្ដាហ៍* |
| | *បានធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ជូនក្រុមការងារសម្របសម្រួលសន្តិសុខស្បៀង និងអាហារូបត្ថម្ភខេត្ត បានទៀងទាត់* |

| | |
|---|---|
| ***សហការសម្របសម្រួលជាមួយវិស័យឯកជន*** | បានធ្វើការដាក់ដេញថ្លៃភាស៊ីផ្សាររដ្ឋ ផ្សារឯកជន ផ្សារសហគមន៍ កន្លែងប្រមូលផ្តុំបន្លែ មាន់ស្រែ និងស្រូវ និងសមាគមន៍អាជីវកម្ម នៅតាមបណ្តារាជធានី-ខេត្ត |
| | បានរៀបចំការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំងសភាពាណិជ្ជខេត្ត និងបោះឆ្នោតជ្រើសរើសប្រធានសភាពាណិជ្ជកម្មតាមបណ្តារាជធានី-ខេត្ត |
| | រៀបចំបង្កើតសមាសភាពដឹកនាំក្រុមការងារផ្លូវការភាពជាដៃគូរវាងរដ្ឋបាលខេត្ត និងសភាពាណិជ្ជកម្មខេត្ត។ |
| ***ផលិតផលសក្តានុពលកម្ពុជាតាមបណ្តា រាជធានី-ខេត្ត និងការជំរុញផលិតផលតាមរយៈ រៀបចំ និងចូលរួមព្រឹត្តិការណ៍នានាក្នុងរាជធានី-ខេត្ត*** | ផលិតផលសក្តានុពលកម្ពុជាមានដូចជា ៖ គុយទាវ មីសសៃ សាច់កែថ្នៃ ប្រេងដូង កៅស៊ូ ដំឡូងមី ដូងខ្ទិះ ស្វាយចន្ទី ស្រូវ បន្លែ ស្វាយកែវរមៀត ស្ករត្នោត អំពៅ ពោតក្រហម ចេក អំបុក សណ្តែកដី សណ្តែកបាយ សណ្តែកសៀង ល្ង អំបុកសាន់គរ ពងទាកូន បង្កង ក្តាមថ្ម គ្រឿងសមុទ្រស្រស់/គ្រៀម ត្រីងៀត ត្រីឆ្អើរ ត្រីប្រា ធុរេន ប្រេងចន្ទន៍គ្រឹស្នា ទឹកឃ្មុំ ទឹកត្រី អំបិល ផ្លែផាសិន មៀនប៉ៃលិន ក្រូចពោធិ៍សាត់ ផ្កាចន្ទរ ត្បូងធម្មជាតិ ខ្សាច់សំណង់ គ្រួសសំណង់ ថ្មម៉ាប ចំលាក់ប្រាក់ស្ពាន់ និងដើមម៉ៃសាក់ កុលកាជន៍ ផលិតផលពីឫស្សី ផ្តៅ ចង្ក្រានឡូវ កន្ទេលកក់ សំពត់សឹង្គ ក្រមា ក្រពើ និងម្នាស់។ល។ |
| | បានរៀបចំ និងចូលរួមពិព័រណ៍ផលិតផលក្នុងស្រុក ភូមិ១ ផលិតផល១ ចំនួន **១៩លើក** ពិព័រណ៍ជាតិ និងអន្តរជាតិចំនួន **១៨លើក** ថ្នាក់ខេត្តចំនួន **៥៨លើក** ពិព័រណ៍វិស័យឯកជន **៨លើក** និងក្រៅខេត្តបានចំនួន **៦២លើក** |
| | ចូលរួមគណៈកម្មាធិកាជាតិជំរុញភូមិ១ ផលិតផល១ បានទទួលស្គាល់ផលិតផលរបស់ខ្លួន និងបានចូលរួមផ្គូរផ្គងផលិតផលក្នុងស្រុកជាមួយគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១ |
| | បានផ្សព្វផ្សាយដល់អាជីវករឲ្យចូលរួមនាំយកផលិតដែលផលិតផល ទៅចូលរួមដាក់តាំងបង្ហាញក្នុងព្រឹត្តិការបុណ្យសមុទ្រលើកទី១០ ជុំទី៣ ដែលប្រព្រឹត្តទៅនៅខេត្តកែប និងពិព័រណ៍ផលិតផលខ្មែរ និងទំនិញនាំចេញ-នាំចូលលើកទី១៦ឆ្នាំ២០២៣" នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្ររាជធានីភ្នំពេញ |
| | បាននាំយកផលិតផលក្នុងស្រុកទៅពិព័រណ៍ទំនិញព្រំដែនកម្ពុជា-ថៃក្រោមគម្រោងគាំទ្រអភិវឌ្ឍន៍សក្តានុពលពាណិជ្ជកម្ម ការវិនិយោគ ការបម្រើសេវាកម្ម និងការផ្សារភ្ជាប់សេដ្ឋកិច្ចជាយដែនឆ្នាំ២០២៣ |
| | បានអញ្ជើញអាជីវករឲ្យចូលរួមដាក់តាំងបង្ហាញផលិតផលខ្មែរ ក្នុងស្ថានីយ៍ប្រេងឥន្ធនៈ PTT ចំនួន **២៨៣**លើក ដែលក្នុងនោះរួមមានប្រភេទផលិតផលដូចជា៖ គ្រឿង សមុទ្រក្រៀម ទំពាំងក្រៀម ទឹកត្រី បន្លែត្រីសាច់ បំពង់បីតផលិតអំពីឫស្សី គ្រឿងសង្ហារឹមផលិតអំពីផ្តៅ និង ផ្លែដូងក្រអូប។ល។ |
| | សម្របសម្រួល ផ្សព្វផ្សាយ និងជ្រើសរើសទីតាំងសាងសង់ **កន្លែងប្រមូលផ្តុំមាន់ស្រែ ចំនួន ១កន្លែង និងអណ្តូងបូមទឹក solar ចំនួន  ១កន្លែង** |

| | |
|---|---|
| ***ការងារអនុវត្តគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច(AIMS) តាមបណ្តាខេត្តដែលទទួលបានគម្រោងអនុវត្ត*** | ចុះសិក្សាវាយតម្លៃប្រសិទ្ធភាព និងផលប៉ះពាល់នៃវគ្គបណ្តុះបណ្តាលចំណេះដឹងអាជីវកម្មដែលអនុវត្តន៍ដោយអង្គការដៃគូ(អង្គការមុស្លីមអេដកម្ពុជា) |
| | ចុះសិក្សាពីផលប៉ះពាល់របស់កសិករ ដែលទទួលបានការគាំទ្រហិរញ្ញប្បទានឥតសំណង(VCIF) ចំនួន **១៥គ្រួសារ** លើផលិតផលមាន់ស្រែ |
| | ចុះផ្ទៀងផ្ទាត់មូលដ្ឋានលើកសិករ ដែលស្នើកញ្ចប់បច្ចេកទេស របស់ក្រុមហ៊ុនហ្គ្រីនអិនណូវេតខេម(GIC) ក្នុងឆ្នាំ២០២៣ ចំនួន **៧០គ្រួសារ** លើផលិតផលមាន់ស្រែ |
| | ចុះផ្ទៀងផ្ទាត់តាមដានវឌ្ឍនភាពកសិករ ដែលទទួលមូលនិធិនវានុវត្តន៍ខ្សែច្រវាក់តម្លៃ (VCIF) ២០២២-២០២៣ ចំនួន **១៣៤គ្រួសារ** លើផលិតផលមាន់ស្រែ |
| | ធ្វើបច្ចុប្បន្នភាពកត់ត្រាទិន្នន័យកសិករពីចំណាយ-ចំណូលប្រចាំថ្ងៃក្នុងប្រព័ន្ធMIS ចំនួន **៩៣៦**គ្រួសារ |
| | រៀបចំកិច្ចប្រជុំអាជីវកម្ម រៀបចំជំនួបរវាងឈ្មួញ និងឈ្មួញក្នុងតំបន់ឬសហគមន៍ភ្ជាប់ឈ្មួញ និងសហគមន៍កសិកម្ម និងមានអ្នកទំនាក់ទំនងចូលរួមដោះស្រាយបញ្ហាប្រឈមរបស់សហគមន៍កសិករ គោលបំណងចង់ឲ្យមានការសហការអាជីវកម្ម និងមានកិច្ចសន្យាទិញ-លក់ |
| | បានសាងសង់ទ្រុងមាន់ ផ្តល់សម្ភារៈ និងកូនមាន់ ដល់កសិករដែលបានអនុម័តកញ្ចប់ថវិកាក្នុងឆ្នាំ២០២២ ចំនួន**កសិករ ១១គ្រួសារ ស្មើនឹង១១លើក** |

## ១៣. លទ្ធផលការងាររបស់គណៈកម្មាធិការជាតិពាក់ព័ន្ធវិស័យពាណិជ្ជកម្ម

| **បរិយាយការងារ** | **លទ្ធផល** |
|---|---|
| **១) <u>គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់</u>** | |
| ការរៀបចំ និងចូលរួមកិច្ចប្រជុំថ្នាក់ជាតិនិងអន្តរជាតិ | បានរៀបចំកិច្ចប្រជុំដើម្បីពិនិត្យនិងសម្រេច លើបណ្តឹងតវ៉ារបស់ក្រុមហ៊ុនចំនួន២ ដែលស្នើឱ្យ គ.ជ.ក.ប. ពិនិត្យកែតម្រូវ និងដកចេញសេចក្តីសម្រេចរបស់ខ្លួនវិញ |
| | ធ្វើជាម្ចាស់ផ្ទះ រៀបចំកិច្ចប្រជុំលើកទី ២៧ របស់គណៈកម្មាធិការកិច្ចការពារអ្នកប្រើប្រាស់អាស៊ាន (27th ACCP) នៅខេត្តសៀមរាប។ |
| | សហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) រៀបចំសន្និសីទអ្នកប្រើប្រាស់ថ្នាក់ជាតិឆ្នាំ២០២៣ ក្រោមប្រធានបទ «ពង្រឹងសិទ្ធិអំណាចអ្នកប្រើប្រាស់ដើម្បីជំរុញការអនុវត្តដោយសុចរិតលើទីផ្សារ» |
| | ធ្វើទស្សនកិច្ចសិក្សាទៅប្រទេសអូស្ត្រាលី ដើម្បីស្វែងយល់ពីបទពិសោធន៍ និងរបៀបរបបការងារ របស់គណៈកម្មាធិការប្រកួតប្រជែង និងការពារអ្នកប្រើប្រាស់អូស្ត្រាលី (ACCC) |
| | ចូលរួមកិច្ចប្រជុំ និងសិក្ខាសាលា ដែលរៀបចំដោយគណៈកម្មាធិការការពារអ្នកប្រើប្រាស់អាស៊ាន និងគណៈកម្មាធិការការពារអ្នកប្រើប្រាស់នៃបណ្តាប្រទេសជាសមាជិក ចំនួន២១ លើក។ |
| ការកសាងលិខិតបទដ្ឋានគតិយុត្ត | បានជំរុញណែនាំដោយផ្តល់ជាគោលនយោបាយ និងខ្លឹមសារគន្លឹះដើម្បីកសាងលិខិតបទដ្ឋានគតិយុត្តចាំបាច់ទាក់ទងនិងកិច្ចការពារអ្នកប្រើប្រាស់ សំដៅពង្រឹងប្រសិទ្ធ |

| | |
|---|---|
| | *ភាពនៃការអនុវត្តច្បាប់ (ដូចបានរាយការណ៍នៅក្នុងចំណុច ស្តីពីការកសាងលិខិតបទដ្ឋានគតិយុត្ត)* |
| ***២) គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា*** | |
| *ការរៀបចំ និងចូលរួមកិច្ចប្រជុំថ្នាក់ជាតិនិងអន្តរជាតិ* | *រៀបចំកិច្ចប្រជុំគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា «គ.ប.ក.» ចំនួន ៣លើក ដើម្បីពិនិត្យនិង ពិភាក្សាលើ (១).សេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងស្តីពីរបៀបរបបការងាររបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា **(២).**សេចក្តីព្រាងផែនការសកម្មភាពរបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា ឆ្នាំ២០២២-២០២៧ **(៣).**សេចក្តីព្រាងប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការត្រួតពិនិត្យ និងការស៊ើបអង្កេត ក្រោមច្បាប់ស្តីពីការប្រកួតប្រជែង **(៤).**សេចក្តីព្រាងប្រកាសស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការដោះស្រាយតាមការចរចាចំពោះបទល្មើសក្រោមច្បាប់ស្តីពីការប្រកួតប្រជែង **(៥).**សេចក្តីព្រាងសេចក្តីសម្រេចស្តីពីកម្រិតកំណត់នៃការជូនដំណឹងជាមុនអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច **(៦).**សេចក្តីព្រាងសេចក្តីសម្រេចស្តីពីបែបបទនិងនីតិវិធីនៃការគណនាប្រាក់ផាកពិន័យក្រោមច្បាប់ស្តីពីការប្រកួតប្រជែង និង **(៧).**សេចក្តីព្រាងប្រកាសស្តីពីបែបបទនិងនីតិវិធីនៃការចេញវិធានការផ្អាកជាបណ្តោះអាសន្ន និង/ឬសេចក្តីសម្រេចរបស់ គ.ប.ក* |
| | *ធ្វើទស្សនកិច្ចសិក្សាទៅហ្វីលីពីនដើម្បីស្វែងយល់អំពីបទពិសោធន៍ និងរបៀបរបបការងារ របស់គណៈកម្មាធិការប្រកួតប្រជែងហ្វីលីពីន(PCC)* |
| | *ចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ីបូព៌ាលើកទី១៨ ស្តីពីគោលនយោបាយប្រកួតប្រជែង (EATOP) (គឺជាកិច្ចប្រជុំប្រចាំឆ្នាំ)* |
| | *ចូលរួមសន្និសីទអាស៊ីបូព៌ាលើកទី១៥ ស្តីពីច្បាប់និងគោលនយោបាយប្រកួតប្រជែង (EAC) នៅប្រទេសថៃឡង់ (គឺជាកិច្ចប្រជុំប្រចាំឆ្នាំ)។* |
| ***ការកសាងលិខិតបទដ្ឋានគតិយុត្ត*** | *បានជំរុញណែនាំដោយផ្តល់ជាគោលនយោបាយ និងខ្លឹមសារគន្លឹះដើម្បីកសាងលិខិតបទដ្ឋានគតិយុត្តចាំបាច់ទាក់ទងនិងកិច្ចការប្រកួតប្រជែង សំដៅពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ (ដូចបានរាយការណ៍នៅក្នុងចំណុច ស្តីពីការកសាងលិខិតបទដ្ឋានគតិយុត្ត)* |
| ***៣. គណៈកម្មាធិការហាឡាលកម្ពុជា*** | |
| *ការរៀបចំ និងចូលរួមកិច្ចប្រជុំជាតិនិងអន្តរជាតិ* | *ចូលរួមកិច្ចប្រជុំនៅក្នុងប្រទេសចំនួន៣លើក ក្រោមប្រធានបទ៖ ការអនុវត្តប្រកាសស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្មលើការគ្រប់គ្រងផលិតផលហាឡាល, វគ្គបណ្តុះបណ្តាលស្តីពីកិច្ចការហាឡាល ដែលរៀបចំដោយស្ថាប័ន JAKIM នៃប្រទេសម៉ាឡេស៊ី និងវគ្គបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍប្រព័ន្ធហាឡាល (Halal Eco System) ដែលរៀបចំដោយមជ្ឈមណ្ឌលអភិវឌ្ឍវិស័យហាឡាល (HDC)។* |
| | *ចូលរួមកិច្ចប្រជុំនិងវគ្គបណ្តុះបណ្តាលនៅក្រៅប្រទេសចំនួន ៤លើក រួមមាន៖ កិច្ចប្រជុំលើកទី១៩ ក្រុមការងារម្ហូបអាហារអាស៊ាន (19th ASEAN Working Group on Halal Food) ,វគ្គបណ្តុះបណ្តាលស្តីពី Halal Slaughtering and Certification and halal Executive and management, សន្និសីទអន្តរជាតិស្តីពីការទទួលស្គាល់វិញ្ញាបនបត្រហាឡាល, សិក្ខាសាលាកម្រិតខ្ពស់ស្តីពីសេដ្ឋកិច្ចឌីជីថលសម្រាប់ប្រទេសឡាវ និងកម្ពុជា។* |

| | |
|---|---|
| ***ការកសាងលិខិតបទដ្ឋានគតិយុត្ត*** | *បានជំរុញណែនាំដោយផ្តល់ជាគោលនយោបាយ និងខ្លឹមសារគន្លឹះដើម្បីកសាងលិខិតបទដ្ឋានគតិយុត្តចាំបាច់ទាក់ទងនិងការគ្រប់គ្រងផលិតផលហាឡាល សំដៅពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ (ដូចបានរាយការណ៍នៅក្នុងចំណុច ស្តីពីការកសាងលិខិតបទដ្ឋានគតិយុត្ត)* |
| ***៤. គណៈកម្មាធិការកូដិចជាតិ*** | |
| *ការចូលរួមកិច្ចប្រជុំជាតិនិងអន្តរជាតិ* | *កិច្ចប្រជុំលើកទី៤៣ នៃគណៈកម្មាធិការកូដិច ស្តីពីអាហាររូបត្ថម្ភនិងម្ហូបអាហារប្រើសម្រាប់ជារបបអាហារពិសេសដែលបានរៀបចំធ្វើឡើងនៅទីក្រុងឌុសេលដូវនៃប្រទេសអាល្លឺម៉ង់* |
| | *កិច្ចប្រចំលើកទី២៦ នៃគណៈកម្មាធិការកូដិច ស្តីអំពីប្រព័ន្ធអធិការកិច្ចនិងការធ្វើវិញ្ញាបនប័ត្រម្ហូបអាហារនាំចេញ នាំចូល ដែលបានរៀបចំធ្វើឡើងនៅទីក្រុងហូបាតនៃប្រទេសអូស្ត្រាលី* |
| | *កិច្ចប្រជុំលើកទី៤៧នៃគណៈកម្មាធិការកូដិចស្តីអំពីការធ្វើស្លាកសញ្ញាម្ហូបអាហារដែលបានរៀបចំធ្វើឡើងនៅទីក្រុងអូតាវ៉ានៃប្រទេសកាណាដា* |
| | *កិច្ចប្រជុំលើកទី៤៦នៃគណៈកម្មាធិការកូដិច (Codex Commission) ដែលរៀបចំដោយអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងអង្គការសុខភាពពិភពលោក នៅទីក្រុងរ៉ូមនៃប្រទេសអ៊ីតាលី* |
| | *កិច្ចប្រជុំលើកទី២២ របស់ក្រុមការងារកូដិចអាស៊ានដែលបានរៀបចំធ្វើឡើងដោយប្រទេស សឹង្ហបុរីតាមរយៈVideo Conference។* |
| *ការផ្សព្វផ្សាយការងារកូដិចថ្នាក់ជាតិ* | *ចូលរួមជាវាគ្មិន ក្នុងវេទិកាជាតិស្តីពីទិវាសុវត្ថិភាពម្ហូបអាហារពិភពលោក ដែលបានរៀបចំឡើងដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ លើប្រធានបទ "ស្តង់ដាម្ហូបអាហារសង្គ្រោះជីវិត"* |
| | *ចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាស្តីពី "ក្រមអនុវត្តន៍និងគោលការណ៍កូដិចពាក់ព័ន្ធទៅនឹងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ" រៀបចំឡើងដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ* |
| | *សហការជាមួយអង្គការហេឡិនខាល័អន្តរជាតិ រៀបចំពិធីអបអរសាទរខួបលើកទី៦០ នៃកូដិចពិភពលោក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣* |
| | *រៀបចំកម្មវិធីបង្កើនសមត្ថភាពការយល់ដឹងអំពីស្តង់ដាកូដិច ដល់មន្ត្រីអគ្គនាយកដ្ឋាន ក.ប.ប. សរុបចំនួន ៥០នាក់។* |
| ***៥. គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា (គ.ក.ប.)*** | |
| *ការធ្វើទំនើបកម្មប្រព័ន្ធកម្មសិទ្ធបញ្ញា* | *កំពុងបន្តធ្វើទំនើបកម្មប្រព័ន្ធស្វ័យប្រវត្តិកម្ម កម្មសិទ្ធិឧស្សាហកម្មជំនាន់ទី៤ (IPAS 4) តាមស្មារតីអង្គប្រជុំរបស់គណៈកម្មាធិការ* |
| *ការចូលជាសមាជិកនៃកិច្ចព្រមព្រៀង អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិ* | *លេខាធិការដ្ឋានគណៈកម្មាធិការកំពុងសិក្សាគុណសម្បត្តិ និងគុណវិបត្តិនៃការចូលជាសមាជិកនេះ៖*<br>*-សន្ធិសញ្ញាទីក្រុងម៉ារ៉ាកេស ស្តីពីការសម្រួលឱ្យទទួលបានស្នាដៃបោះពុម្ពសម្រាប់ជនពិការភ្នែក, ជនបាត់បង់សមត្ថភាពចក្ខុវិញ្ញាណ ឬការបោះពុម្ពសម្រាប់ពិការភាពដទៃទៀត*<br>*-សន្ធិសញ្ញាស្តីពីសិទ្ធិអ្នកនិពន្ធរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក(WCT)*<br>*-សន្ធិសញ្ញាស្តីពីការសម្តែងនិង ហ្វូណូក្រាមរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WPTT)* |

| | |
|---|---|
| | -សន្ធិសញ្ញាសិង្ហបុរីស្តីពីច្បាប់ម៉ាក (STLT) |
| ការងារកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត | បានជំរុញណែនាំដោយផ្តល់ជាគោលនយោបាយ និងខ្លឹមសារគន្លឹះដើម្បីកសាងលិខិតបទដ្ឋានគតិយុត្តចាំបាច់ទាក់ទងនឹងការងារកម្មសិទ្ធិបញ្ញា សំដៅពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ (ដូចបានរាយការណ៍នៅក្នុងចំណុច ស្តីពីការកសាងលិខិតបទដ្ឋានគតិយុត្ត) |
| ការងារសហប្រតិបត្តិការ | -បានចុះអនុស្សរណៈកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាជាមួយនឹងអង្គការកម្មសិទ្ធិបញ្ញាហ្វីលីពីន នៅប្រទេសហ្វីលីពីន ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣<br>- បានចុះអនុស្សរណៈយោគយល់គ្នា ស្តីពីគម្រោងសិក្សាស្រាវជ្រាវការកសាងកេរ្តិ៍ឈ្មោះម៉ាក រវាងក្រសួងពាណិជ្ជកម្ម អង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន និងវិទ្យាស្ថានស្រាវជ្រាវ សេដ្ឋកិច្ចអាស៊ាន និងអាស៊ីបូព៌ា នៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២៣<br>- បន្តសហការរៀបចំគម្រោងស្តីពី Empowering Women Entrepreneurs Through Intellectual Property Protections and Utilizations |
| ការផ្សព្វផ្សាយនិងជំរុញការយល់ដឹងពីកម្មសិទ្ធិបញ្ញា | បានរៀបចំទិវាកម្មសិទ្ធិបញ្ញាពិភពលោកឆ្នាំ២០២៣ ក្រោមប្រធានបទ ស្ត្រី និងកម្មសិទ្ធិបញ្ញា៖ ពន្លឿនការបង្កើតថ្មី និងភាពច្នៃប្រតិដ្ឋ" រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ |
| ការកែទម្រង់រចនាសម្ព័ន្ធ និងកិច្ចប្រជុំគណៈកម្មាធិការកម្មសិទ្ធិបញ្ញា | - បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា លើកទី១២ នៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣<br>-រៀបចំរបាយការណ៍លទ្ធផលការងារឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣ របស់គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា គោរពជូន **សម្តេចតេជោអតីតនាយករដ្ឋមន្ត្រី**<br>-កំពុងទទួលនិងត្រៀមរៀបចំសេចក្តីសម្រេចថ្មី ស្តីពីការតែងតាំងសមាសភាពគ.ក.ប. និងសេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាព និងតួនាទី ភារកិច្ច លេខាធិការដ្ឋាន គ.ក.ប.<br>-រៀបចំរបាយការណ៍លទ្ធផល ដើម្បីវាយតម្លៃ និងជំរុញការអនុវត្តផែនការការងារកម្មសិទ្ធិបញ្ញារយៈពេល៣ឆ្នាំ(២០២១-២០២៣)របស់ គ.ក.ប. |

# ជំពូកទី ២

# ទិសដៅការងារពាណិជ្ជកម្ម

# ឆ្នាំ២០២៤

## ១. ទិសដៅការងារសេវាពាណិជ្ជកម្ម [10]

### ១.១. ទិសដៅការងារចុះបញ្ជីពាណិជ្ជកម្ម

| ផែនការសកម្មភាព | ពេលវេលាអនុវត្ត |
|---|---|
| **១) រៀបចំវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយការចុះបញ្ជីពាណិជ្ជកម្ម តាមរយៈ ប្រព័ន្ធស្វ័យប្រវត្តកម្ម និងអាជ្ញាបណ្ណប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក** | |
| រៀបចំសិក្ខាសាលាតាមបណ្តារាជធានី-ខេត្ត ៦ដង | ត្រីមាសទី១-៤ |
| **២) សហការជាមួយ ក្រុមហ៊ុន Foster Moore ធ្វើការផ្ទេរប្រព័ន្ធចុះបញ្ជី ពី Cloud មក MoC data center** | |
| បញ្ចូលការចុះបញ្ជីកែប្រែ ក្នុងថ្នាលបច្ចេកវិទ្យាព័ត៌មាន CamDX | ត្រីមាសទី១-៤ |
| រៀបចំធ្វើបច្ចុប្បន្នភាពកម្មវត្ថុអាជីវកម្មឱ្យបានស្របទៅនឹងចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចកម្ពុជា (ប.ស.ស.ក) | ត្រីមាសទី២-៤ |
| **៣) ពង្រីក និងពង្រឹងប្រព័ន្ធស្វ័យប្រវត្តកម្ម (Enhancement of Business Registration System)** | |
| បន្តតភ្ជាប់ប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្ម ជាមួយប្រព័ន្ធចុះបញ្ជីតាមថ្នាលបច្ចេកវិទ្យាព័ត៌មាវិទ្យា(CamDX) | ត្រីមាសទី១-៤ |
| បង្កើតមុខងារចុះបញ្ជីកែប្រែក្នុងប្រព័ន្ធចុះបញ្ជីតាមថ្នាលបច្ចេកវិទ្យាព័ត៌មានវិទ្យា(CamDX) | ត្រីមាសទី១-៤ |
| បង្កើតមុខងារសេវាថ្មីក្នុងប្រព័ន្ធចុះបញ្ជីស្វ័យប្រវត្តកម្ម (CamDX) តាមការចាំបាច់ | ត្រីមាសទី១-៤ |
| **៤) ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស និងការចូលរួមសិក្ខាសាលា និងកិច្ចប្រជុំអន្តរជាតិនានា** | |
| ចូលរួមប្រជុំ Pacific Forum on Strategic Goods Control | ត្រីមាសទី២ |
| ចូលរួមប្រជុំផ្ទាល់ជាមួយក្រុមការងារត្រួតពិនិត្យរួមគ្នានៃប្រទេសអាស៊ីប៉ាស៊ីហ្វិក លើការអនុវត្តផែនការសកម្មភាពស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម | ត្រីមាសទី១ |
| ចូលរួមប្រជុំប្រចាំឆ្នាំ ASEAN Task Force on Starting a Business | ត្រីមាសទី៣ |
| ចូលរួមប្រជុំ Corporate Register Forum ប្រចាំឆ្នាំ | ត្រីមាសទី៤ |
| **៥) គ្រប់គ្រងការធ្វើអាជីវកម្មតាម ប្រព័ន្ធអេឡិចត្រូនិក** | |
| ធ្វើការអភិវឌ្ឍន៍ប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ការផ្តល់លិខិតអនុញ្ញាត្ត និងអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក | ត្រីមាសទី១-៤ |
| រៀបចំប្រកាសរួមជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ស្តីពីក្រមសីលធម៌វិជ្ជាជីវៈ និងបទប្បញ្ញត្តិសម្រាប់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក | ត្រីមាសទី១-២ |
| **៦) រៀបចំប្រកាសពាក់ព័ន្ធ និងការងារចុះបញ្ជីដែលបានកំណត់នៅក្នុងច្បាប់ស្តីពី វិសោធនកម្មច្បាប់សហគ្រាសពាណិជ្ជកម្មច្បាប់** | |
| ជំរុញការអនុម័ត អនុក្រឹត្យ ស្តីពី អ្នកតំណាងម្ចាស់ហ៊ុន | ត្រីមាសទី១-២ |
| រៀបចំប្រកាសស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបង្កើត និងគ្រប់គ្រងលេខាធិការរបស់ក្រុមហ៊ុន | ត្រីមាសទី១-២ |

### ១.២. ទិសដៅការងារកម្មសិទ្ធិបញ្ញា

| ផែនការសកម្មភាព | ពេលវេលាអនុវត្ត |
|---|---|
| **១) ការងារធំនើបកម្មប្រព័ន្ធកម្មសិទ្ធបញ្ញា** | |
| ធ្វើបច្ចុប្បន្នភាពប្រព័ន្ធស្វ័យប្រវត្តិកម្មកម្មសិទ្ធិបញ្ញា ដោយសហការជាមួយជំនាញការអង្គការកម្មសិទ្ធិបញ្ញាពិភពលោក | ត្រីមាសទី១-៤ |
| រៀបចំប្រព័ន្ធ Cloud សម្រាប់គ្រងគ្រងទិន្នន័យ និងឯកសារនៃការចុះបញ្ជីម៉ាក | ត្រីមាសទី៣-៤ |
| បន្តកែលម្អកម្មវិធីគេហទំព័រ (Web Application) សម្រាប់កិច្ចការទាក់ទងនឹងព័ត៌មានការចុះបញ្ជីម៉ាក | ត្រីមាសទី១-២ |

[10] ប្រភព ៖ អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម

| | |
|---|---|
| ដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីម៉ាក ជំនាន់ទី៤ ( IPAS 4 ) | ត្រីមាសទី៣-៤ |
| រៀបចំកែសម្រួល និងធ្វើបច្ចុប្បន្នភាពគេហទំព័រនាយកដ្ឋាន និងបញ្ចូល ឱ្យមានការសិក្សាពីចម្ងាយ ( Distance E-learning ) | ត្រីមាសទី១-២ |
| រៀបចំប្រព័ន្ធជូនដំណឹងជាស្វ័យប្រវត្តិអំពីដំណើរការ និងស្ថានភាពនៃការចុះបញ្ជីម៉ាកទៅអ្នកដាក់ពាក្យស្នើសុំ និងភ្នាក់ងារតំណាង | ត្រីមាសទី៣-៤ |
| **២) ការពង្រឹងសមត្ថភាព ការកសាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយ** | |
| កែសម្រួលនីតិវិធីនៃការចុះបញ្ជីកម្មសិទ្ធិបញ្ញា ដើម្បីផ្តល់លក្ខណៈងាយស្រួលក្នុងការចុះបញ្ជីកម្មសិទ្ធិបញ្ញា ដើម្បីស្របតាមផែនការសកម្មភាពកម្មសិទ្ធិបញ្ញាអាស៊ាន ឆ្នាំ២០១៦-២០២៥ | ត្រីមាសទី១-៤ |
| រៀបចំសេចក្តីព្រាងច្បាប់ស្តីពីការសម្ងាត់ពាណិជ្ជកម្ម និងព័ត៌មានមិនបង្ហាញចេញ ( Law on Trade Secret and Undisclosed Information ) | ត្រីមាសទី១-៤ |
| រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពី វិធានរដ្ឋបាលនៃការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា | ត្រីមាសទី១-៤ |
| រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ | ត្រីមាសទី២-៣ |
| រៀបចំសេចក្តីព្រាងប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំ អំពីការចុះបញ្ជីម៉ាក | ត្រីមាសទី២-៣ |
| សហការរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួង ស្តីពី ការគ្រប់គ្រង និងការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណេត | ត្រីមាសទី១-៤ |
| រៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើតក្រុមប្រឹក្សាបណ្តឹងតវ៉ា និងនីតិវិធីដោះស្រាយទំនាស់ | ត្រីមាសទី៣-៤ |
| **៣) ការផ្សព្វផ្សាយ និងបង្កើនសមត្ថភាពជូនអ្នកប្រើប្រាស់ អំពីវិស័យកម្មសិទ្ធិបញ្ញា** | |
| រៀបចំវគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីតាមមន្ទីរពាណិជ្ជកម្ម ពីការប្រើប្រាស់ប្រព័ន្ធចុះបញ្ជីម៉ាកអនឡាញ | ត្រីមាសទី៣ |
| បណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ( ចៅក្រម ព្រះរាជអាជ្ញា មេធាវី និងភាគីពាក់ព័ន្ធ ) | ត្រីមាសទី២ |
| រៀបចំសិក្ខាសិលាផ្សព្វផ្សាយស្តីពី ទស្សនទាន និងអត្ថប្រយោជន៍នៃការចុះបញ្ជីម៉ាក ម៉ាក សម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម | ត្រីមាសទី៣ |
| រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីនីតិវិធី នៃការចុះបញ្ជីម៉ាកអន្តរជាតិ និងផលប្រយោជន៍ នៃការចុះបញ្ជីម៉ាកអន្តរជាតិ តាមប្រព័ន្ធម៉ាឌ្រីដ ដល់ស្ថាប័នពាក់ព័ន្ធ ពាណិជ្ជករ អាជីវករ និងMSME | ត្រីមាសទី៣ |
| រៀបចំបណ្ឌិតសភាកម្មសិទ្ធិបញ្ញា ( IP Academy ) | ត្រីមាសទី៣ |
| រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីកម្មសិទ្ធិបញ្ញាដល់ដល់មន្ត្រីបង្គោលរបស់សមាជិលេខាដ្ឋានគណៈកម្មការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា | ត្រីមាសទី២ |
| រៀបចំវគ្គសិក្ខាសាលាស្តីពីវិស័យកម្មសិទ្ធិបញ្ញា តាមសាកលវិទ្យាល័យ | ត្រីមាសទី១-២ |
| ធ្វើការបណ្តុះបណ្តាល និងផ្សព្វផ្សាយកម្មសិទ្ធិបញ្ញាដល់សាធារណជន និងអាជីវករ-ពាណិជ្ជករ | ត្រីមាសទី១-២ |
| ចូលរួមបណ្តុះបណ្តាលសិស្ស-និស្សិត តាមសាកលវិទ្យាល័យ និងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ | ត្រីមាសទី១-៤ |
| កសាងសមត្ថភាពស្តីពី ការអនុវត្តគម្រោងការបណ្តុះបណ្តាលជាលក្ខណៈបុគ្គល និងប្រព័ន្ធគ្រប់គ្រងការសិក្សាសម្រាប់មន្ត្រីត្រួតពិនិត្យម៉ាក ដើម្បីលើកកម្ពស់គុណភាពគ្រប់គ្រងរបស់អង្គភាពកម្មសិទ្ធិបញ្ញា | ត្រីមាសទី៤ |
| ធ្វើការបណ្តុះបណ្តាលភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក និងមេធាវីជំនាន់ទី៧ | ត្រីមាសទី១-២ |
| **៤) ការរៀបចំកម្មវិធី និងកិច្ចប្រជុំជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា** | |
| ប្រារព្ធទិវាកម្មសិទ្ធិបញ្ញាពិភពលោក | ត្រីមាសទី២ |
| រៀបចំកិច្ចប្រជុំលេខាធិការដ្ឋាននៃ គ.ក.ប. | ត្រីមាសទី១-២ |
| រៀបចំកិច្ចប្រជុំប្រចាំឆ្នាំលើកទី១៣ របស់គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា | ត្រីមាសទី១-២ |
| **៥) កិច្ចសហប្រតិបត្តិការ ជំរុញការចុះម៉ាកសមូហភាព និងទំនិញសម្គាល់ភូមិសាស្ត្រ** | |
| បន្តបេសកកម្ម ត្រួតពិនិត្យ តាមដាន និងទប់ស្កាត់ការក្លែងបន្លំ និងជំរុញការលើកកម្ពស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ "ស្ករត្នោតកំពង់ស្ពឺ" "ម្រេចកំពត" "ក្រូចថ្លុងកោះទ្រង់" "ទឹកឃ្មុំព្រៃមណ្ឌលគិរី" "អំបិលកំពតកែប" "ទឹក | ត្រីមាសទី១-២ |

| | |
|---|---|
| ត្រីកំពតកែប" និង "បង្កងតាកែវ" និងម៉ាកសមូហភាព "ក្រូចថ្លុងកោះពីរ" "អំបុកកំពង់ធំ" "អង្ករព្រះវិហារ" "ដូងខ្ទិះបាត់ដំបង" "នំបញ្ចុកសៀមរាប" និង "គុយទាវភ្នំពេញ" និងម៉ាកវិញ្ញាតកម្ម "Malys Angkor" | |
| បន្តរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការពិនិត្យ និងផ្តល់ជាតុចូលលើសៀវភៅបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ "ប្រហុកសៀមរាប" និង "ក្តាមថ្មកោះកុង" និងសៀវភៅបទបញ្ញាររួមគ្រប់គ្រងការប្រើប្រាស់ម៉ាកសមូហភាព "ក្រូចពោធិ៍សាត់" "ចម្លាក់ប្រាក់ស្ពាន់ខេត្តកណ្តាល" និង "សំបុកត្រចៀកកាំកម្ពុជា" ដើម្បីចុះបញ្ជីការពារនៅក្រសួងពាណិជ្ជកម្ម | ត្រីមាសទី១-២ |
| រៀបចំវគ្គបណ្តុះបណ្តាលដល់សមាជិកគណៈកម្មការប្រតិបត្តិរបស់សមាគម និងក្រុមអ្នកផលិតស្តីពី ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង យុទ្ធសាស្ត្រទីផ្សារ និងការទប់ស្កាត់ការក្លែងបន្លំគុណភាពនៃទំនិញសម្គាល់ភូមិសាស្ត្រ និងម៉ាកសមូហភាព | ត្រីមាសទី១-២ |
| បន្តស្វែងរកដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ដើម្បីបន្តកិច្ចគាំទ្រដល់ការចុះបញ្ជីម៉ាកសមូហភាព ឬម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ លើផលិតផលសក្តានុពល ដែលក្រសួងពាណិជ្ជកម្មបានកំណត់ ដូចជា៖ "បង្គាក្រៀមកំពង់សោម" "បង្គាក្រៀមកោះកុង" "ទឹកត្រីកោះកុង" "អង្ករបាត់ដំបង" "ស្វាយចន្ទីកំពង់ធំ" "សូត្រភ្នំស្រុក" និង "ទុរេនកំពត" | ត្រីមាសទី២ |
| បន្តកិច្ចសហប្រត្តិបត្តិការក្រុមការងារសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ាន (AWGIPC) និងអនុវត្តផែនការសកម្មភាពអាស៊ាន ២០១៦-២០២៥ | ត្រីមាសទី១-៤ |
| អនុវត្តផែនការសកម្មភាព និងកិច្ចសហប្រតិបត្តិការក្រោមអនុស្សរណៈនៃការយោគយល់គ្នាក្នុងវិស័យកម្មសិទ្ធិបញ្ញា រវាងកម្ពុជា និង WIPO ចិន អាម៉េរិក សហភាពអឺរ៉ុប ជប៉ុន កូរ៉េ ថៃ និងឡាវ។ | ត្រីមាសទី១-៤ |

## ១.៣. ទិសដៅការងារនាំចេញ-នាំចូល

| ផែនការសកម្មភាព | ពេលវេលាអនុវត្ត |
|---|---|
| **១) ការធ្វើប្រតិភូកម្ម ការចេញ និងបន្តសុពលភាពលិខិតអនុញ្ញាត វិញ្ញាបនបត្រប្រភពដើមទំនិញ អាជ្ញាប័ណ្ណនាំចេញ-នាំចូល និងចុះបញ្ជីសុំសិទ្ធនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម** | |
| ធ្វើប្រតិភូកម្មក្នុងការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ឌី(D) សម្រាប់ទំនិញកសិផលដល់គ្រប់មន្ទីរពាណិជ្ជកម្ម និងនៅតាមតំបន់សេដ្ឋកិច្ចពិសេស | ត្រីមាសទី១-៤ |
| ផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម | ត្រីមាសទី១-៤ |
| ផ្តល់អាជ្ញាបណ្ណនាំចេញ និងផ្តល់ការពន្យាពន្យាសុពលភាពអាជ្ញាបណ្ណនាំចេញ | ត្រីមាសទី១-៤ |
| ផ្តល់លិខិតជូនដំណឹងដឹកជញ្ជូនទំនិញឆ្លងកាត់ | ត្រីមាសទី១-៤ |
| ផ្តល់អាជ្ញាបណ្ណនាំចូល និងផ្តល់ការពន្យាសុពលភាពអាជ្ញាបណ្ណនាំចូល | ត្រីមាសទី១-៤ |
| ផ្តល់វិញ្ញាបនបត្រគីមប៉លើ (KPC) សម្រាប់ការនាំចេញត្បូងពេជ្រមិនទាន់កែច្នៃ និងសល់ពីការកែច្នៃ | ត្រីមាសទី១-៤ |
| ផ្តល់វិញ្ញាបនបត្រគីមប៉លើ (KPC) សម្រាប់ការនាំចូលត្បូងពេជ្រមិនទាន់កែច្នៃ | ត្រីមាសទី១-៤ |
| ចុះបញ្ជីសុំសិទ្ធនាំចេញតាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងពាណិជ្ជកម្មសេរី | ត្រីមាសទី១-៤ |
| ចុះបញ្ជីស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញតាមប្រព័ន្ធអេឡិចត្រូនិក | ត្រីមាសទី១-៤ |
| ចុះត្រួតពិនិត្យវាយតម្លៃ នីតិសម្បទាសម្រាប់ចុះឈ្មោះក្នុងប្រព័ន្ធចុះបញ្ជីអ្នកនាំចេញ (Registered Exporter system) | ត្រីមាសទី១-៤ |
| **២) ផ្សព្វផ្សាយ និងស្រាវជ្រាវ អំពីវិស័យនាំចេញ-នាំចូល ជូនអ្នកផ្តល់សេវា អ្នកប្រើសេវា និងអន្តរការី** | |
| សហការរៀបចំកម្មវិធី និងវគ្គបណ្តុះបណ្តាលអ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំឯកសារនាំចេញ-នាំចូល ចំនួន ២លើក | ត្រីមាសទី២ និងត្រីមាសទី៤ |

| | |
|---|---|
| វគ្គបណ្តុះបណ្តាលស្តីពី «នីតិវិធីនាំចេញទំនិញ វិធានដើមកំណើតទំនិញ វិធានការមិនមែនពន្ធនានារបស់ប្រទេសនាំចូល ចំនួន ៥លើក | ត្រីមាសទី១-៤ |
| សិក្ខាសាលាស្តីពី «ការនាំចេញវិញ្ញាបនបត្រគីមប៉លី និងនីតិវិធី នៃការផ្តល់វិញ្ញាបនបត្រតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ជូនមន្ត្រីតាមមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត» | ត្រីមាសទី១-៤ |
| វគ្គបណ្តុះបណ្តាលដល់មន្ត្រី និងតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តកម្មវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញគ្រប់ទម្រង់នៅតាមរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស | ត្រីមាសទី១-៤ |
| ធ្វើបច្ចុប្បន្នភាពការចុះបញ្ជីអ្នកនាំចេញ និងបញ្ញត្តិរបស់សហភាពអឺរ៉ុប | ត្រីមាសទី១-៤ |
| ***៣) កិច្ចសហការជាមួយដៃគូជាតិ និងអន្តរជាតិក្នុងការពង្រឹងសមត្ថភាពវិស័យនាំចេញ-នាំចូល*** | |
| ចូលរួមកិច្ចប្រជុំពាក់ព័ន្ធនឹងវិធានដើមកំណើតទំនិញអាស៊ាន ដៃគូអាស៊ាន និងបណ្តាប្រទេសផ្សេងៗទៀត | ត្រីមាសទី១-៤ |
| សហការជាមួយស្ថាប័នពាក់ព័ន្ធរៀបចំតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តកម្មវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញគ្រប់ទម្រង់ ការចេញអាជ្ញាបណ្ណនាំចេញ-នាំចូល និងវិញ្ញាបនបត្រគីមប៉លីប្រូសេស ទៅក្នុងបញ្ជរតែមួយជាតិ និងឈានទៅតភ្ជាប់បញ្ជរតែមួយអាស៊ាន | ត្រីមាសទី១-៤ |
| ចូលរួមកិច្ចប្រជុំក្នុងប្រទេស និងក្រៅប្រទេសលក្ខណៈទ្វេភាគី អនុតំបន់ និងពិភពលោក | ត្រីមាសទី១-៤ |
| ចូលរួមប្រជុំប្រចាំឆ្នាំរបស់អង្គការគីមប៉លីប្រូសេស (Kimmberly Process Certification) | ត្រីមាសទី១ និងត្រីមាសទី៤ |
| បន្តអនុវត្តកិច្ចសម្របសម្រួលពាណិជ្ជកម្មទ្វេភាគីរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម | ត្រីមាសទី១-៤ |
| រៀបចំបែបបទពាក់ព័ន្ធទៅនឹងការស្នើសុំឆ្លងកាត់ទំនិញដែលស្ថិតក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល និងកិច្ចព្រមព្រៀងនានាជាលក្ខណៈទ្វេភាគី និងពហុភាគី | ត្រីមាសទី១-៤ |
| រៀបចំទទួលក្រុមការងាររបស់អង្គការគីមប៉លីប្រូសេស ក្នុងការចុះទស្សនកិច្ចត្រួតពិនិត្យការអនុវត្តនិងនីតិវិធីនៃការចេញវិញ្ញាបនបត្រគីមប៉លីប្រូសេសនៅកម្ពុជា | ត្រីមាសទី១-៤ |
| បន្តសហការ និងចូលរួមកិច្ចប្រជុំ ជាមួយក្រុមការងារក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមការងារនៃគម្រោងរោងចក្រកាន់តែប្រសើរ (ILO/BFC) និងក្រុមការងារសមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា (TAFTAC) | ត្រីមាសទី១-៤ |
| ***៤) ការងារតាមដាន វាយតម្លៃ និងកសាងបទប្បញ្ញត្តិ*** | |
| ចុះត្រួតពិនិត្យវាយតម្លៃនីតិសម្បទា សម្រាប់ចុះឈ្មោះក្នុងប្រព័ន្ធចុះបញ្ជីអ្នកនាំចេញរបស់ក្រុមហ៊ុន/រោងចក្រ ដែលមកសុំចុះឈ្មោះចូលរួមអនុវត្តការប្រកាសប្រភពដើម (Statement on Origin) | ត្រីមាសទី១-៤ |
| ចុះធ្វើសវនកម្មតាមការដោយផ្ទាល់លើទីតាំងរោងចក្រ សហគ្រាស និងក្រុមហ៊ុន | ត្រីមាសទី២ និងត្រីមាសទី៤ |
| ចុះពិនិត្យទីតាំង និងមូលដ្ឋានផលិតកម្មរបស់រោងចក្រ-សហគ្រាស និង ក្រុមហ៊ុន ដែលស្នើសុំចុះបញ្ជីសុំសិទ្ធិនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងពាណិជ្ជកម្មសេរី | ត្រីមាសទី១-៤ |
| បន្តចុះពិនិត្យទីតាំង និងមូលដ្ឋានផលិតកម្មរបស់រោងចក្រ សហគ្រាស និងក្រុមហ៊ុនចុះកិច្ចសន្យាដួលផលិតបន្ត | ត្រីមាសទី១-៤ |
| ចុះពិនិត្យឯកសារបញ្ជាក់ភាពត្រឹមត្រូវនៃវិធានដើមកំណើតទំនិញ តាមការស្នើសុំរបស់អាជ្ញាធរគយនៃប្រទេសនាំចូលនៅតាមរោងចក្រ សហគ្រាស និងក្រុមហ៊ុនតាមបណ្តាខេត្ត និងតំបន់សេដ្ឋកិច្ចពិសេស | ត្រីមាសទី១-៤ |
| រៀបចំទទួល និងសហការជាមួយអាជ្ញាធរគយ នៃប្រទេសនាំចូល ក្នុងបេសកម្មផ្ទៀងផ្ទាត់វិធានដើមកំណើតទំនិញនៅកម្ពុជា | ត្រីមាសទី១-៤ |
| ចុះពិនិត្យមូលដ្ឋានផលិតកម្ម ខ្សែប្រវាក់ផលិតកម្ម និងលទ្ធភាពនាំចេញរបស់រោងចក្រ សហគ្រាស និងក្រុមហ៊ុន ដែលស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ | ត្រីមាសទី១-៤ |
| រៀបចំការតាក់តែងច្បាប់ អនុក្រឹត្យ និងប្រកាសរួមស្តីពីវិធានដើមកំណើតទំនិញ | ត្រីមាសទី១-៤ |

| ៥) កិច្ចការប្រព័ន្ធស្វ័យប្រវត្តកម្មនៃវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ | |
|---|---|
| ថែទាំ កែលម្អប្រព័ន្ធស្វ័យប្រវត្តកម្មវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ | ត្រីមាសទី១ |
| រៀបចំបន្ថែម វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ផ្សេងៗទៀត ស្របតាមវិធានប្រភពដើមទំនិញនៃប្រទេសនាំចូលក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម | ត្រីមាសទី១-៤ |

## ១.៤. ទិសដៅការងារតំណាងពាណិជ្ជកម្មប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស

| ផែនការសកម្មភាព | ពេលវេលាអនុវត្ត |
|---|---|
| ចុះត្រួតពិនិត្យនិងវាយតម្លៃអនុលោមភាព និងធ្វើការអង្កេតលើដើមកំណើតទំនិញ ដើម្បីទទួលបានភាពអនុគ្រោះពាណិជ្ជកម្មនិងណែនាំអំពីនីតិវិធី និងឯកសារពាក់ព័ន្ធក្នុងការស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញតាមប្រព័ន្ធស្វ័យប្រវត្តកម្ម | ត្រីមាសទី១-៤ |
| បន្តផ្សព្វផ្សាយនិងណែនាំដល់បណ្តារោងចក្រដែលនាំចេញទំនិញទៅកាន់សហគមន៍អឺរ៉ុប អំពីនីតិវិធីនៃការស្នើសុំចុះបញ្ជីក្នុងប្រព័ន្ធអ្នកនាំចេញ | ត្រីមាសទី១-៤ |
| បន្តផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការនាំចេញទំនិញ | ត្រីមាសទី១-៤ |
| ចុះពិនិត្យ និងផ្ទៀងផ្ទាត់សន្និធិវត្ថុធាតុដើម និងផលិតភាពផលិតកម្មតាមបណ្តារោងចក្រក្នុងតំបន់សេដ្ឋកិច្ចពិសេស | ត្រីមាសទី១-៤ |
| បន្តសហការជាមួយនឹងរោងចក្រ និងនាយកដ្ឋាននាំចេញ-នាំចូល ដើម្បីផ្តល់ឯកសារសេចក្តីកម្មនៅពេលដែលមានការស្នើសុំផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃវិធានដើមទំនិញពីប្រទេសនាំចូល | ត្រីមាសទី១-៤ |

# ២.ទិសដៅការងារពាណិជ្ជកម្មក្នុងប្រទេស [11]

## ២.១. ទិសដៅការងារនីតិកម្ម

| ផែនការសកម្មភាព | ពេលវេលាអនុវត្ត |
|---|---|
| **១) ការកសាងលិខិតបទដ្ឋានគតិយុត្ត** | |
| • រៀបចំសេចក្តីព្រាងនិងជំរុញការអនុម័តច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម | ត្រីមាសទី១-៤ |
| • រៀបចំសេចក្តីព្រាងនិងជំរុញការអនុម័តច្បាប់ស្តីពីភ្នាក់ងារពាណិជ្ជកម្ម | ត្រីមាសទី២-៤ |
| • រៀបចំសេចក្តីព្រាងនិងជំរុញការអនុម័តច្បាប់ស្តីពីសន្ទានកម្មពាណិជ្ជកម្ម | ត្រីមាសទី៤ |
| • រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា | ត្រីមាសទី២-៣ |
| • រៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់ពាណិជ្ជកម្ម និងបទប្បញ្ញត្តិពាណិជ្ជកម្ម តាមបណ្តាខេត្ត-រាជធានី | ត្រីមាសទី១-៤ |
| • រៀបចំនីតិវិធីក្នុងការផ្តល់វិញ្ញាបនបត្រសម្គាល់ទំនុកចិត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក | ត្រីមាសទី៣-៤ |
| **២) ការងារតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា** | |
| • ធ្វើទំនើបកម្មប្រព័ន្ធតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា (www.setfo.gov.kh) និងតភ្ជាប់ជាមួយប្រព័ន្ធទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក (E-payment) | ត្រីមាសទី២-៤ |
| • ផ្សព្វផ្សាយច្បាប់ប្រតិបត្តិការដែលមានកិច្ចធានា និងនីតិវិធីតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានាតាមរយៈប្រព័ន្ធ www.setfo.gov.kh | ត្រីមាសទី១-៤ |
| **៣) ការងារសម្រុះសម្រួលដោះស្រាយវិវាទពាណិជ្ជកម្ម** | |
| • រៀបចំដាក់ឱ្យដំណើរការបណ្ណាល័យច្បាប់ (E-Library on Laws and Regulations) | ត្រីមាសទី៣-៤ |
| • សហការជាមួយក្រសួងយុត្តិធម៌ដើម្បីជំរុញការបង្កើតតុលាការផ្នែកពាណិជ្ជកម្ម | ត្រីមាសទី៣-៤ |
| **៤) ការវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (RIA)** | |

[11] ប្រភព៖ អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស

| | |
|---|---|
| • ពិនិត្យឡើងវិញ វាយតម្លៃ និងផ្តល់យោបល់លើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួងពាណិជ្ជកម្ម និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗទៀត | ត្រីមាសទី១-៤ |
| • បញ្ជ្រាបការយល់ដឹងអំពីការវាយតម្លៃ និងការផ្តល់យោបល់លើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត និងការផ្សព្វផ្សាយលទ្ធផល | ត្រីមាសទី១-៤ |
| • រៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាក់ទងវិស័យពាណិជ្ជកម្មដើម្បីដាក់ឱ្យប្រើប្រាស់តាមប្រព័ន្ធអេឡិចត្រូនិក | ត្រីមាសទី៣-៤ |
| **៥) កិច្ចការផ្សេងៗ** | |
| • បោះពុម្ព ចងក្រង តម្កល់ច្បាប់ លិខិតបទដ្ឋានគតិយុត្តវិស័យពាណិជ្ជកម្ម និងលិខិតបទដ្ឋានពាក់ព័ន្ធទុកជាឯកសារ | ត្រីមាសទី១-៤ |
| • ចូលរួមអនុវត្តផែនការសកម្មភាពសម្រាប់ការអនុវត្តកិច្ចព្រមព្រៀងអាស៊ាន ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (ASEAN Agreement of Electronic Commerce) និងជំពូកស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្រោមកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) (ជំពូកស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក) និងជំពូកស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្រោមក្របខ័ណ្ឌតំបន់ពាណិជ្ជកម្មសេរី អាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ (AANZFTA)។ | ត្រីមាសទី១-៤ |

## ២.២. ទិសដៅការងារអភិវឌ្ឍន៍វិស័យឯកជន

| ផែនការសកម្មភាព | ពេលវេលាអនុវត្ត |
|---|---|
| **១) ការងារពិនិត្យឃ្លាំមើលសកម្មភាពពាណិជ្ជកម្ម** | |
| • ត្រួតពិនិត្យការអនុវត្ត ការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មពាណិជ្ជកម្ម និងសេវាកម្មតាមបណ្តារាជធានី-ខេត្ត | ត្រីមាសទី១-៤ |
| • ពិនិត្យតាមដាន ការចេញលិខិតអាជីវកម្មត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ តាមបណ្តារាជធានី-ខេត្ត | ត្រីមាសទី១-៤ |
| • ត្រួតពិនិត្យតាមដានការអនុវត្តន៍ការងារច្រកចេញចូលតែមួយរបស់មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត | ត្រីមាសទី១-៤ |
| • តាមដាន និងផ្ទៀងផ្ទាត់សន្និធិប្រេងឥន្ធនៈ និងហ្គាស នៃបណ្តាក្រុមហ៊ុននាំចូលទាំងអស់ | ត្រីមាសទី១-៤ |
| **២) ការងារអភិវឌ្ឍន៍ស្ថាប័នពាណិជ្ជកម្ម** | |
| • រៀបចំការបោះឆ្នោតបង្កើតតំណាងសភាពាណិជ្ជកម្មកម្ពុជានៅក្រៅប្រទេស អាណត្តិថ្មី | ត្រីមាសទី១-៤ |
| • ផ្សព្វផ្សាយ អំពីភារៈកិច្ច បទបញ្ជាផ្ទៃក្នុង និងការគ្រប់គ្រងរដ្ឋបាលដល់ការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជានៅក្រៅប្រទេស | ត្រីមាសទី១-៤ |
| • រៀបចំបោះឆ្នោតសភាពាណិជ្ជកម្មខេត្ត | ត្រីមាសទី១-៤ |
| • រៀបចំសិក្ខាសាលាផ្សព្វផ្សាយ អំពីភារៈកិច្ច បទបញ្ជាផ្ទៃក្នុង និងការគ្រប់គ្រងរដ្ឋបាលដល់សភាពាណិជ្ជកម្មរាជធានី-ខេត្ត | ត្រីមាសទី២-៣ |
| • រៀបចំបោះពុម្ពវត្តមានភាពសៀវភៅបញ្ជីសមាជិកសភាពាណិជ្ជកម្មរាជធានី-ខេត្ត ការិយាល័យតំណាងសភាពាណិជ្ជកម្មនៅក្រៅប្រទេស និងបណ្តុំអាជីវកម្ម | ត្រីមាសទី២ និងទី៤ |
| • ផ្សព្វផ្សាយពីសារប្រយោជន៍ នៃការរៀបចំសមាគម និងប្រកាសឬច្បាប់ទាំងឡាយ ទាក់ទងដល់ការបង្កើតសមាគម | ត្រីមាសទី៣-៤ |
| • ចុះសម្របសម្រួលរៀបចំបង្កើតសមាគមអាជីវកម្មពាណិជ្ជកម្ម នៅតាមរាជធានី-ខេត្ត | ត្រីមាសទី៣-៤ |
| • ចុះពង្រឹងសមត្ថភាព និងការងារដល់សមាគមអាជីវកម្មរាជធានី-ខេត្ត ទាក់ទងនឹងការពង្រឹងតួនាទីភារៈកិច្ចរបស់សមាគមអាជីវកម្ម | ត្រីមាសទី៣-៤ |
| **៣) ការងារអភិវឌ្ឍន៍ផលិតផល** | |

| | |
|---|---|
| • រៀបចំយុទ្ធនាការជំរុញនិងប្រើប្រាស់ផលិតផលធ្វើអំពីសូត្រ | ត្រីមាសទី១ |
| • ចុះរៀបចំស្រាវជ្រាវ និងធ្វើបច្ចុប្បន្នភាពទិន្នន័យអំពីផលិតផលសូត្រតាមបណ្ដាខេត្ត | ត្រីមាសទី១-៤ |
| • រៀបចំវេទិកាពិភាក្សា និងពិគ្រោះយោបល់រវាងផលិតករ អាជីវករ និងភាគីអ្នកពាក់ព័ន្ធក្នុងវិស័យសូត្រនៅរាជធានី-ខេត្ត | ត្រីមាសទី១-៣ |
| • ចុះស្រាវជ្រាវកំណត់ទីតាំងភូមិសាស្ត្រផលិតផលដែលមានសក្ដានុពលទៅលើការអភិវឌ្ឍខ្សែច្រវាក់តម្លៃ និងផលិតផល ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា (CTIS) និងបោះពុម្ពសៀវភៅស្ដីពីផលិតផលសក្ដានុពលនៅតាមខេត្តគោលដៅ | ត្រីមាសទី១-៤ |
| • រៀបចំសិក្ខាសាលាស្ដីពី ផលិតភាព និងពាណិជ្ជកម្ម តាមរយៈការបង្កើតតំណភ្ជាប់ឆ្ពោះទៅកាន់ប្រភពផលិតកម្ម និងអ្នកប្រើប្រាស់ | ត្រីមាសទី១-៣ |
| • រៀបចំសិក្ខាសាលាស្ដីពីការលើកកម្ពស់ការកែច្នៃកសិផលរបស់ផលិតករខ្នាតតូចនិងមធ្យមសម្រាប់ពង្រីកវិសាលភាពនៃការជ្រៀតចូលទីផ្សារឱ្យបានកាន់តែទូលំទូលាយ | ត្រីមាសទី២-៣ |
| • បោះពុម្ពសៀវភៅស្ដីពីស្ថានភាពនៃទំនិញចាំបាច់នៅតាមខេត្តគោលដៅចំនួន១០ | ត្រីមាសទី៤ |
| • ចុះសិក្សា ចងក្រងនិងបោះពុម្ពសៀវភៅស្ដីពីថ្លៃដើមនៃផលិតផលសក្ដានុពល | ត្រីមាសទី៤ |
| • ចុះសិក្សាស្រាវជ្រាវអំពីស្ថានភាពនៃខ្សែច្រវាក់តម្លៃផលិតផលដំឡូងមី និងស្វាយចន្ទី ដើម្បីធ្វើបច្ចុប្បន្នកម្មពីវិស័យដំឡូងមី និងស្វាយចន្ទី ដែលឆ្លើយតបនឹងសូចនាករនៃផែនការសកម្មភាពរបស់គោលនយោបាយជាតិស្ដីពីស្វាយចន្ទី និងគោលនយោបាយជាតិស្ដីពីដំឡូងមី | ត្រីមាសទី១-៤ |
| • រៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ អំពីការធ្វើបច្ចុប្បន្នកម្មលើវិស័យស្វាយចន្ទី និងដំឡូងមី និងការធ្វើពាណិជ្ជូបនីយកម្ម និងការពិពិធកម្មផលិតផល | ត្រីមាសទី១-៤ |

## ២.៣. ទិសដៅការងារផែនការ ស្ថិតិ និងព័ត៌មានវិទ្យា

| ផែនការសកម្មភាព | ពេលវេលាអនុវត្ត |
|---|---|
| **១) ការងារផែនការ** | |
| • តាមដានការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យពាណិជ្ជកម្ម៖<br>- ផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម ឆ្នាំ២០២៤-២០២៨ (ផ.យ.អ.ព.) ដល់មន្ទីរពាណិជ្ជកម្ម និងអាជ្ញាធរថ្នាក់ខេត្ត<br>- តាមដាន និងរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្ត ផ.យ.អ.ព. ២០២៤-២០២៨<br>- សិក្ខាសាលាផ្សព្វផ្សាយ អំពីរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម | - ត្រីមាសទី១<br>- ត្រីមាសទី១-៤<br>- ត្រីមាសទី៣ |
| • ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ និងផែនការរួមនៃវិស័យពាណិជ្ជកម្ម៖<br>- តាមដានរាល់គោលនយោបាយយុទ្ធសាស្ត្រជាតិ និងផ្នែកពាណិជ្ជកម្ម ដែលបានចេញផ្សាយ<br>- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្ត គោលនយោបាយយុទ្ធសាស្ត្រជាតិ និងលើផ្នែកពាណិជ្ជកម្ម ទាំងកម្រិតថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន<br>- ប្រមូល វិភាគ សន្និដ្ឋាន និងចងក្រង នូវផែនការរួម របស់វិស័យពាណិជ្ជកម្ម | ត្រីមាសទី១-៤ |
| **២) ការងារស្ថិតិពាណិជ្ជកម្ម** | |
| • ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងស្វ័យប្រវត្តកម្មស្ថិតិពាណិជ្ជកម្ម (SAS) និងតាមដានសន្ទស្សន៍ថ្លៃទំនិញ និងស្ថិតិពាណិជ្ជកម្មទៅតាមតម្រូវការជាក់ស្ដែង | ត្រីមាសទី១-៤ |

| | |
|---|---|
| • សិក្សាស្រាវជ្រាវថ្លៃទំនិញជាតិ និងអន្តរជាតិ ប្រមូល ចងក្រង វិភាគ និងផ្សព្វផ្សាយព័ត៌មានថ្លៃទំនិញនៅលើទីផ្សារជាតិ និងអន្តរជាតិ | ត្រីមាសទី១-៤ |
| • ចងក្រងសៀវភៅស្ថិតិពាណិជ្ជកម្ម៖<br>- វិភាគ និងចងក្រងព័ត៌មានពាណិជ្ជកម្ម<br>- ចងក្រងសៀវភៅស្ថិតិព័ត៌មានពាណិជ្ជកម្មប្រចាំឆ្នាំ | <br>- ត្រីមាសទី១-៤<br>- ត្រីមាសទី៤ |
| • ចងក្រងឯកសារលំហូរទំនិញសក្តានុពលរបស់កម្ពុជា៖<br>- សិក្សាស្រាវជ្រាវពីលំហូរទំនិញសក្តានុពលរបស់កម្ពុជា<br>- វិភាគ និងចងក្រងឯកសារទំនិញសក្តានុពលរបស់កម្ពុជាប្រចាំឆ្នាំ | <br>- ត្រីមាសទី១-៤<br>- ត្រីមាសទី៤ |
| ***៣) ការងារព័ត៌មានវិទ្យា*** | |
| • កសាងគោលនយោបាយប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួង៖<br>- រៀបចំគោលនយោបាយប្រើប្រាស់សេវាអ៊ីនធឺណិតរបស់ក្រសួង<br>- រៀបចំបញ្ជីស្តង់ដា Hardware និង Software សម្រាប់ប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យានៅក្នុងក្រសួង<br>- រៀបចំនីតិវិធីក្នុងការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួង | ត្រីមាសទី១-៤ |
| • គ្រប់គ្រង ស្រាវជ្រាវ និងអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានវិទ្យា៖<br>- អាជ្ញាបណ្ណសម្រាប់ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា<br>- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធស្វ័យប្រវត្តកម្មគ្រប់គ្រងរដ្ឋបាល ទូទៅ (AAS) របស់ក្រសួង<br>- ធ្វើបច្ចុប្បន្នភាពថ្នាលជំរុញផលិតផលកសិកម្ម(ដំណាក់កាលទី២)<br>- បង្កើតប្រព័ន្ធគ្រប់គ្រងប្រតិទិនសម្រាប់កិច្ចប្រជុំ របស់ក្រសួង<br>- គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់ក្រសួង<br>- គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធចុះឈ្មោះតាមប្រព័ន្ធអនឡាញរបស់ក្រសួង | ត្រីមាសទី១-៤ |
| • គ្រប់គ្រងមជ្ឈមណ្ឌលទិន្នន័យ និងឧបករណ៍បច្ចេកវិទ្យាព័ត៌មាន៖<br>- ប្រើប្រាស់សេវាអ៊ីនធឺណិត របស់ក្រសួង<br>- សេវាថែទាំមជ្ឈមណ្ឌលទិន្នន័យ និងប្រព័ន្ធសុវត្ថិភាពព័ត៌មានវិទ្យារបស់ក្រសួង<br>- សេវាថែទាំម៉ាស៊ីនភ្លើងសម្រាប់មជ្ឈមណ្ឌលទិន្នន័យ<br>- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធវីដេអូសន្និសីទរបស់ក្រសួង<br>- បង្កើតមជ្ឈមណ្ឌលទំនាក់ទំនងរបស់ក្រសួង (MoC Call Center)<br>- ធ្វើបច្ចុប្បន្នភាព ហេដ្ឋារចនាសម្ព័ន្ធបណ្តាញប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួង<br>- ថែទាំ ជួសជុលឧបករណ៍ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌ មានរបស់ក្រសួង (IT Support and services desk) | <br>- ត្រីមាសទី១-៤<br>- ត្រីមាសទី១-៤<br>- ត្រីមាសទី១-៤<br>- ត្រីមាសទី១-៤<br>- ត្រីមាសទី១-៤<br>- ត្រីមាសទី១-៤<br>- ត្រីមាសទី១-៤ |
| • ជំនួយបច្ចេកទេសលើការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួង៖<br>- ប្រឹក្សាយោបល់លើការរៀបចំគោលនយោបាយប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួង<br>- ប្រឹក្សាយោបល់ទៅលើប្រព័ន្ធសន្តិសុខបច្ចេកវិទ្យាព័ត៌មាន (Cyber Security) របស់ក្រសួង និងបច្ចេកវិទ្យាព័ត៌មានថ្មីៗ | ត្រីមាសទី១-៤ |
| ***៤) ការងារបោះពុម្ពផ្សាយព្រឹត្តិបត្រពាណិជ្ជកម្ម*** | |
| • គ្រប់គ្រង អភិវឌ្ឍ និងបោះពុម្ពព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្មរបស់ក្រសួង៖<br>- ប្រមូល និងចងក្រងព័ត៌មានពាណិជ្ជកម្មក្នុងប្រទេស និងអន្តរជាតិ<br>- បោះពុម្ពសៀវភៅព្រឹត្តបត្រព័ត៌មានពាណិជ្ជកម្ម | ត្រីមាសទី១-៤ |

| | |
|---|---|
| • ប្រមូល ចងក្រង សហការផលិត និងផ្សព្វផ្សាយព័ត៌មានពាណិជ្ជកម្ម៖<br>- ប្រមូល ចងក្រង សហការផលិតព័ត៌មានពាណិជ្ជកម្ម<br>- ផលិតវីដេអូសម្រាប់ផ្សព្វផ្សាយព័ត៌មានពាណិជ្ជកម្ម និងសមិទ្ធផលរបស់ក្រសួង<br>- បោះពុម្ព និងផ្សព្វផ្សាយព័ត៌មានពាណិជ្ជកម្ម ករណីសិក្សា ខិតប័ណ្ណ កូនសៀវភៅសក្តានុពលអភិវឌ្ឍន៍ពាណិជ្ជកម្ម (២ដង/ឆ្នាំ) | <br>- ត្រីមាសទី១-៤<br>- ត្រីមាសទី១-៤<br>- ត្រីមាសទី២ |
| • ស្ទង់មតិ ត្រួតពិនិត្យ និងវាយតម្លៃលើគុណភាព និងប្រសិទ្ធភាពនៃព័ត៌មានពាណិជ្ជកម្ម៖<br>- រៀបចំកម្រងសំណួរសម្រាប់អ្នកប្រើប្រាស់ ដើម្បីវាយតម្លៃលើព័ត៌មានពាណិជ្ជកម្ម<br>- បង្កើតប្រព័ន្ធស្ទង់មតិលើការប្រើប្រាស់ព័ត៌មានពាណិជ្ជកម្ម (១២ដង/ឆ្នាំ) | <br>- ត្រីមាសទី៣<br>- ត្រីមាសទី១-៤ |

### ២.៤. ទិសដៅការងារអនុវត្តគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច

| សកម្មភាពការងារ | ពេលវេលាអនុវត្ត |
|---|---|
| បន្តសម្របសម្រួលជាមួយវិស័យឯកជន ដើម្បីពង្រីកទីផ្សារក្នុងស្រុក តាមរយៈការពង្រឹង និងពង្រីកកិច្ចសន្យាទិញ-លក់ និងការនាំចេញទៅក្រៅប្រទេស ដោយរៀបចំឱ្យមានការចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) ក្នុងនោះគម្រោងមាន ផែនការចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយបណ្តាក្រុមហ៊ុន រួមមានរោងម៉ាស៊ីនកិនស្រូវ ក្រុមហ៊ុនទិញបន្លែ និងក្រុមហ៊ុនផ្គត់ផ្គង់ធាតុចូលកសិកម្ម | ត្រីមាសទី១-៤ |
| បន្តគាំទ្រខ្សែច្រវាក់តម្លៃលើផ្នែកផលិតកម្ម ដោយប្រើប្រាស់មូលនិធិអភិវឌ្ឍតាមវិស័យ (SDF) ដែលនឹងផ្តល់ជូនក្រុមផលិតឱ្យទទួលបាននូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត | ត្រីមាសទី១-៤ |
| បន្តគាំទ្រ និងជួយសម្របសម្រួលកសិករខ្នាតតូច រៀបចំផែនការវិនិយោគ និងសំណើគម្រោងវិនិយោគសម្រាប់មូលនិធិនវានុវត្តន៍ខ្សែច្រវាក់តម្លៃជុំទី១ (VCIF-Win-1) សម្រាប់កសិករខ្នាតតូច ដែលគម្រោងបានកៀរគរ និងចងក្រងជាក្រុមផលិត និងចាប់ផ្តើមរៀបចំសម្របសម្រួលសហគ្រាសធុនតូច និងមធ្យមក្នុងការរៀបចំផែនការវិយោគ និងសំណើគម្រោងវិនិយោគ VCIF-Win-2 ក្នុងទំហំថវិកាប្រចាំឆ្នាំផងដែរ | ត្រីមាសទី១-៤ |
| ជួយគ្រួសារកសិករខ្នាតតូច និងតួអង្គខ្សែច្រវាក់តម្លៃផ្សេងទៀតក្នុងការពង្រីកអាជីវកម្មកសិ-ពាណិជ្ជកម្មតាមរយៈការផ្តល់ឥណទានក្នុងទំហំថវិកាប្រចាំឆ្នាំប្រមាណមួយលានដុល្លារសហរដ្ឋអាម៉េរិក | ត្រីមាសទី១-៤ |

## ៣.ទិសដៅការងារពាណិជ្ជកម្មអន្តរជាតិ [12]

### ៣.១.ទិសដៅសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មទ្វេភាគី អនុតំបន់ និងសមាហរណកម្មសេដ្ឋកិច្ច

| សកម្មភាពការងារ | ពេលវេលាអនុវត្ត |
|---|---|
| **១) កិច្ចការអាស៊ាន** | |
| • កិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន នៅប្រទេសឡាវ | ត្រីមាសទី១-៣ |
| • កិច្ចប្រជុំចង្អៀតថ្នាក់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៣០ នៅប្រទេសឡាវ | ត្រីមាសទី១ |
| • កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៥៦ ឆ្នាំ២០២៤ នៅប្រទេសឡាវ | ត្រីមាសទី៣ |
| • ក្រុមការងារជាន់ខ្ពស់ស្តីពីសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន នៅប្រទេសឡាវ | ត្រីមាសទី១-៣ |
| • កិច្ចប្រជុំក្រុមការងារជាន់ខ្ពស់ស្តីពីទស្សនវិស័យអាស៊ានក្រោយឆ្នាំ២០២៥ (HLTV-ACV Post 2025) នៅប្រទេសឡាវ | ត្រីមាសទី១-៤ |
| • កិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ាន នៅប្រទេសឡាវ | ត្រីមាសទី៤ |

[12] ប្រភព៖ អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម

| | |
|---|---|
| • កិច្ចប្រជុំកំពូលអាស៊ានលើកទី៤៤ និង៤៥ នៅប្រទេសឡាវ | ត្រីមាសទី៤ |
| • កិច្ចប្រជុំគណៈកម្មាធិការចរចាដំឡើងកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន | ត្រីមាសទី១ |
| • កិច្ចប្រជុំក្រុមការងារវិធានដើមកំណើតទំនិញ នៃការចរចាដំឡើងកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន | ត្រីមាសទី១ |
| • កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលអាស៊ានស្តីពីពាណិជ្ជកម្មសេវាកម្ម ចំនួន ៣លើក | ត្រីមាសទី១-៤ |
| • កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលលើការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន (CCA) និងអនុគណៈកម្មាធិការស្តីពីច្បាប់ដើមកំណើតកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន | ត្រីមាសទី១-៣ |
| • កិច្ចប្រជុំគណៈកម្មាធិការក្រុមប្រឹក្សាយោបល់ចម្រុះស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម | ត្រីមាសទី១-៣ |
| • កិច្ចប្រជុំចរចាកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថលអាស៊ាន នៅប្រទេសសមាជិកអាស៊ាន | ត្រីមាសទី១-៤ |
| • រៀបចំឯកសារពាក់ព័ន្ធ និងធាតុចូល ជូនថ្នាក់ដឹកនាំសម្រាប់កិច្ចប្រជុំនានា និងការងារពាក់ព័ន្ធក្រោមសហគមន៍សេដ្ឋកិច្ចអាស៊ាន | ត្រីមាសទី១-៤ |
| ***២) កិច្ចការដៃគូអាស៊ាន*** | |
| • កិច្ចប្រជុំគណៈកម្មាធិការចរចាពាណិជ្ជកម្មសម្រាប់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កាណាដា និងកិច្ចប្រជុំពាក់ព័ន្ធ ចំនួន ៦លើក | ត្រីមាសទី១-៤ |
| • កិច្ចប្រជុំចរចាដំឡើងកម្រិតកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ជំនាន់៣.០ | ត្រីមាសទី១-៣ |
| • កិច្ចប្រជុំចរចាដំឡើងកម្រិតកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន-ឥណ្ឌា (AITIGA) | ត្រីមាសទី១-៤ |
| • កិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ានជាមួយប្រទេសដៃគូអាស៊ាន ប្រព្រឹត្តទៅស្របនឹងកិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី២ (SEOM 2/55) នៅប្រទេសឡាវ | ត្រីមាសទី២ |
| • កិច្ចប្រជុំគណៈកម្មាធិការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ លើកទី២០ (20th AKFTA-IC) នៅសាធារណរដ្ឋកូរ៉េ | ត្រីមាសទី១ |
| • កិច្ចប្រជុំផ្សេងៗទៀត រួមមាន៖ ក្រុមការងាររួមអាស៊ាន-សហភាពអឺរ៉ុប (ASEAN-EU JWG) ជាដើម | ត្រីមាសទី១-៤ |
| • ការបន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធក្រោមសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ព្រមទាំងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការប្រមូល និងផ្តល់មតិយោបល់/ធាតុចូលលើឯកសារសំខាន់ៗ ដើម្បីផ្ញើជូនលេខាធិការដ្ឋានអាស៊ាន និងផ្តល់មតិយោបល់/ធាតុចូល/ចំណុចពិភាក្សា/ជំនួយស្មារតី។ | ត្រីមាសទី១-៤ |
| ***៣) កិច្ចការទ្វេភាគី*** | |
| • ត្រៀមរៀបចំផ្តល់ធាតុចូល និងរបាយការណ៍វឌ្ឍនភាព ស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មទ្វេភាគី៖ (១) កម្ពុជា-ព្រុយណេ (២) កម្ពុជា-ឥណ្ឌូនេស៊ី (៣) កម្ពុជា-ឡាវ (៤) កម្ពុជា-ម៉ាឡេស៊ី (៥) កម្ពុជា-មីយ៉ាន់ម៉ា (៦) កម្ពុជា-ហ្វីលីពីន (៧) កម្ពុជា-សិង្ហបុរី (៨) កម្ពុជា-ថៃ (៩) កម្ពុជា-ទីម័រខាងកើត (១០) កម្ពុជា-វៀតណាម (១១) កម្ពុជា-ចិន (១២) កម្ពុជា-ជប៉ុន (១៣) កម្ពុជា-កូរ៉េ (១៤) កម្ពុជា-ឥណ្ឌា (១៥) កម្ពុជា-អូស្ត្រាលី (១៦) កម្ពុជា-នូវែលសេឡង់ (១៧) កម្ពុជា-បង់ក្លាដែស (១៨) កម្ពុជា-ប៉ាគីស្ថាន (១៩) កម្ពុជា-ម៉ាល់ឌីវ (២០) កម្ពុជា-នេប៉ាល់ (២១) កម្ពុជា-ស្រីលង្កា (២២) កម្ពុជា-ម៉ុងហ្គោលី (២៣) កម្ពុជា-ហុងកុង ជាដើម។ | ត្រីមាសទី១-៤ |
| • ត្រៀមរៀបចំកិច្ចប្រជុំលើកទី២ នៃក្រុមការងារចម្រុះកម្ពុជា-ឥណ្ឌា ស្តីពីពាណិជ្ជកម្ម និងវិនិយោគ (2nd Meeting of Cambodia-India Joint Working Group on Trade and Investment) | ត្រីមាសទី១-២ |
| • ត្រៀមរៀបចំកិច្ចប្រជុំលើកទី៧ នៃគណៈកម្មការចម្រុះពាណិជ្ជកម្មកម្ពុជា-ថៃ (7th Cambodia-Thailand Joint Trade Commission) | ត្រីមាសទី២ |
| • ត្រៀមរៀបចំកិច្ចប្រជុំអន្តរក្រសួង-ស្ថាប័នត្រៀមចូលរួមកិច្ចប្រជុំលើកទី២ នៃគណៈកម្មការរួមនៃកិច្ចព្រមព្រៀង CCFTA នៅប្រទេសកម្ពុជា | ត្រីមាសទី១ |

| | |
|---|---|
| • ត្រៀមរៀបចំសហការផ្ទៃក្នុងជាមួយអន្តរក្រសួង-ស្ថាប័ន ក្នុងការប្រមូលទិន្នន័យ ធាតុចូល យោបល់ និងចូលរួមដោះស្រាយបញ្ហាផ្សេងៗ ជាពិសេសពាណិជ្ជកម្មតាមព្រំដែនដូចជា៖ ថៃ និងវៀតណាមជាដើម | ត្រីមាសទី១-៤ |
| • ត្រៀមរៀបចំឯកសារចំណុចពិភាក្សា ជំនួយស្មារតី និងឯកសារពាក់ព័ន្ធជូន លោកជំទាវរដ្ឋមន្ត្រី និងថ្នាក់ដឹកនាំ សម្រាប់ជំនួបសម្តែងការគួរសម និងកិច្ចប្រជុំនានា នៅក្នុងក្របខណ្ឌទ្វេភាគី។ | ត្រីមាសទី១-៤ |
| ***៤) កិច្ចការអនុតំបន់*** | |
| • ត្រៀមចូលរួមកិច្ចប្រជុំមហាអនុតំបន់មេគង្គ GMS | ត្រីមាសទី១-៤ |
| • ត្រៀមឯកសារពាក់ព័ន្ធផ្សេងៗជូន **លោកជំទាវរដ្ឋមន្ត្រី** និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម លើកទី១៣ (13th CLV-DTA-JCC) នៅខេត្តអត្តពើ ប្រទេសឡាវ។ | ត្រីមាសទី១-២ |
| • ត្រៀមធ្វើជាម្ចាស់រៀបចំកិច្ចប្រជុំកំពូល CLV លើកទី១២ | ត្រីមាសទី២-៤ |
| • ត្រៀមឯកសារពាក់ព័ន្ធជូន **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** ប្រធានដឹកនាំកិច្ចប្រជុំ (CLV Summit Chair) និងរៀបចំកិច្ចប្រជុំត្រៀមដើម្បីប្រមូលរបាយការណ៍វឌ្ឍនភាពក្រោមកិច្ចសហប្រតិបត្តិការ CLV ពីអន្តរក្រសួង/ស្ថាប័នពាក់ព័ន្ធ និងពិនិត្យវឌ្ឍនភាពការងារក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាមលើកទី១២ នៅព្រះរាជាណាចក្រកម្ពុជា | ត្រីមាសទី២-៤ |
| • ត្រៀមលើកសំណើគម្រោងក្រោមក្របខណ្ឌអនុតំបន់។ | ត្រីមាសទី១-៤ |

## ៣.២. ទិសដៅសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មជាមួយអឺរ៉ុប មជ្ឈិមបូព៌ា និងអាហ្វ្រិក

| សកម្មភាពការងារ | ពេលវេលាអនុវត្ត |
|---|---|
| • តាមដាននីតិវិធីអនុវត្តវិធានបូកបន្ថែម (Extended Cumulation) ពីសហភាពអឺរ៉ុប និងចក្រភពអង់គ្លេស សម្រាប់ឧស្សាហកម្មគ្រឿងបង្គុំទោចក្រ យាននៅកម្ពុជា សម្រាប់មុខទំនិញដែលនាំចូលពីវៀតណាមមកកម្ពុជាដើម្បីផលិត ផ្គុំ និងតម្លើងទៅជាផលិតផលសម្រេច ដើម្បីនាំចេញទៅសហភាពអឺរ៉ុបនិងចក្រភពអង់គ្លេស ដែលទទួលបានការអនុគ្រោះពន្ធ | ត្រីមាសទី១-៤ |
| • ត្រៀមចូលរួមកិច្ចប្រជុំអនុក្រុមស្តីពីពាណិជ្ជកម្ម និងវិនិយោគ (SGTI) នៃគណៈកម្មាធិការចម្រុះកម្ពុជា-សហភាពអឺរ៉ុបលើកទី១២ (JC12) នៅប៊ែលហ្ស៊ិក | ត្រីមាសទី១-៤ |
| • សិក្សាអំពីសមិទ្ធិលទ្ធភាព (Feasibility Study) នៃការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងកម្ពុជា-ស្វ៊ីស | ត្រីមាសទី១-៤ |
| • ចូលរួមកិច្ចប្រជុំលើកទី២ ក្រុមការងារចម្រុះស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ច រវាងកម្ពុជា និងហុងគ្រី និងជំនួបធុរកិច្ចលើកទី២ រវាងកម្ពុជា-ហុងគ្រី នៅហុងគ្រី | ត្រីមាសទី១ |
| • រៀបចំវេទិកាពាណិជ្ជកម្ម និងវិនិយោគរួមគ្នារវាងកម្ពុជា-ចក្រភពអង់គ្លេសលើកទី២ នៅកម្ពុជា | ត្រីមាសទី១-៤ |
| • ពន្លឿនបញ្ចប់សេចក្តីព្រាងលក្ខខណ្ឌយោង (ToR) ស្តីពីការបង្កើតក្រុមការងាររួម គណៈកម្មាធិការចម្រុះនៃកិច្ចសហប្រតិបត្តិការវិស័យសេដ្ឋកិច្ចរវាងកម្ពុជា និងប៊ុលហ្គារី | ត្រីមាសទី១-៤ |
| • រៀបចំសេចក្តីព្រាងអនុស្សរណៈស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម និងបង្កើតគណៈកម្មការចម្រុះរវាងកម្ពុជា និងរ៉ូម៉ានី (Joint Committee) | ត្រីមាសទី១-៤ |
| • រៀបចំកិច្ចប្រជុំលើកទី៤ គណៈកម្មាធិការចម្រុះស្តីពីពាណិជ្ជកម្មនិងសេដ្ឋកិច្ច រវាងកម្ពុជា-បេឡារុស នៅកម្ពុជា | ត្រីមាសទី១-៤ |
| • សហការរៀបចំ និងចូលរួមកិច្ចប្រជុំលើកទី៣ របស់ក្រុមការងារជាន់ខ្ពស់កម្ពុជា-រុស្ស៊ី ដើម្បីជំរុញគម្រោងវិនិយោគអាទិភាពរួម | ត្រីមាសទី១ |

| | |
|---|---|
| • សហការរៀបចំ និងចូលរួមកិច្ចប្រជុំលើកទី៤ នៃក្រុមការងាររួមស្តីពី កិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងគណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី (គ.ស.អ.អ) នៅសហព័ន្ធរុស្ស៊ី | ត្រីមាសទី១ |
| • បន្តទំនាក់ទំនងល្អជាមួយភាគីរុស្ស៊ី ដើម្បីស្វែងរកលទ្ធភាពក្នុងការចាប់ផ្តើមការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយសហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី (EAEU) ជាគោលដៅដែលរាជរដ្ឋាភិបាលចង់សម្រេចឱ្យបានកិច្ចព្រមព្រៀងនេះនាពេលអនាគត | ត្រីមាសទី១-៤ |
| • ពន្លឿនបញ្ចប់សេចក្តីព្រាងអនុស្សរណៈស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មរវាងកម្ពុជានិងកាហ្សាក់ស្ថាន តាមរយៈក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ (ស្នើរៀបចំប្រជុំកម្រិតបច្ចេកទេសតាមប្រព័ន្ធវីដេអូ ពិភាក្សាលើសេចក្តីព្រាងអនុស្សរណៈ) | ត្រីមាសទី១-៤ |
| • ពន្លឿនបញ្ចប់សេចក្តីព្រាង និងចុះហត្ថលេខាលើអនុស្សរណៈស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មរវាងកម្ពុជា និងអាស៊ែបៃហ្សង់ នៅអាស៊ែបៃហ្សង់ | ត្រីមាសទី១-៤ |
| • រៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីអត្ថប្រយោជន៍ការបង្កើតកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម ជូនដល់វិស័យឯកជន ក្រុមធុរជន វិនិយោគិន អ្នកនាំចេញ-នាំចូល និងភាគីពាក់ព័ន្ធនៅភ្នំពេញនិងខេត្តដែលមានសក្តានុពល | ត្រីមាសទី១-៤ |
| • សហការជាមួយស្ថានទូតនៃរដ្ឋកូវ៉ែតប្រចាំនៅកម្ពុជា ដើម្បីកំណត់កាលបរិច្ឆេទនិង ចូលរួមកិច្ចប្រជុំលើកទី២ នៃគណៈកម្មាធិការពាណិជ្ជកម្មចម្រុះរវាងកម្ពុជា និងកូវ៉ែត នៅរដ្ឋកូវ៉ែត | ត្រីមាសទី១-៤ |
| • សហការជាមួយភាគីកាតា កំណត់កាលបរិច្ឆេទ និងចូលរួមពិធីចុះហត្ថលេខាកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងបច្ចេកទេសរវាងកម្ពុជា និងកាតា នៅរដ្ឋកាតា | ត្រីមាសទី១-៤ |
